# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៨០

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# អភិធម្មបិដក

## និង

# បរមត្ថទីបនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# បដ្ឋាន

# នវម-ទសម-ឯកាទសមភាគ

# ៨០

# បាលីប្រែ ១០២-១០៣-១០៤



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៨០

# អភិធម្មបិដក

# បដ្ឋាន នវមភាគ

# អនុលោមទុកបដ្ឋាន ខាងចុង

*សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## សារម្មណទុកៈ

## បដិច្ចវារៈ

[ ១ ] *សារម្មណធម៌ ( ធម៌ប្រកបដោយអារម្មណ៍ ) អាស្រ័យនូវសារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាសារម្មណៈ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ អនារម្មណធម៌ ( ធម៌មិនមានអារម្មណ៍ ) អាស្រ័យនូវសារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវសារម្មណក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។បេ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី អាស្រ័យនូវសារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាសារម្មណៈ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ អនារម្មណធម៌ អាស្រ័យនូវអនារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមហាភូត ១ ។បេ។ ចិត្តសមុដ្ឋានរូប កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សារម្មណធម៌ អាស្រ័យនូវអនារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួក*

សារម្មណក្ខន្ធ អាស្រ័យនូវវត្ថុ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី អាស្រ័យនូវអនារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកសារម្មណក្ខន្ធអាស្រ័យនូវវត្ថុ កដត្តារូបអាស្រ័យនូវពួកមហាភូត ។ សារម្មណធម៌អាស្រ័យនូវសារម្មណធម៌ផង នូវអនារម្មណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាសារម្មណៈផង នូវវត្ថុផង នូវខន្ធ ២ ... ។ អនារម្មណធម៌អាស្រ័យនូវសារម្មណធម៌ផង នូវអនារម្មណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យនូវសារម្មណក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ។បេ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី អាស្រ័យនូវសារម្មណធម៌ផង នូវអនារម្មណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាសារម្មណៈផង នូវវត្ថុផង នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវសារម្មណក្ខន្ធផង នូវពួកមហាភូតផង ។

[ ២ ] សារម្មណធម៌អាស្រ័យនូវសារម្មណធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាសារម្មណៈ នូវខន្ធ ២ ... ជាបដិសន្ធិ ។ សារម្មណធម៌ អាស្រ័យនូវអនារម្មណធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកសារម្មណក្ខន្ធអាស្រ័យនូវវត្ថុ ។ សារម្មណធម៌ អាស្រ័យនូវសារម្មណធម៌ផង នូវអនារម្មណធម៌ផង ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ

ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាសារម្មណៈផង នូវវត្ថុផង នូវខន្ធ ២ ... សេចក្តីបំប្រួញ ។

[ ៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤ ] សារម្មណធម៌ អាស្រ័យនូវសារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាសារម្មណៈ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ អនារម្មណធម៌អាស្រ័យនូវសារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាអហេតុកប្បដិសន្ធិ អាស្រ័យនូវពួក

អហេតុកក្ខន្ធជាសារម្មណៈ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី អាស្រ័យនូវសារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាសារម្មណៈ នូវខន្ធ ២ ... ជាអហេតុកបដិសន្ធិ ។ អនារម្មណធម៌ អាស្រ័យនូវអនារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមហាភូត ១ ... មហាភូត ១ របស់ពួកអសញ្ញសត្វ... ។ សារម្មណធម៌ អាស្រ័យនូវអនារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងខណៈនៃអហេតុកបដិសន្ធិ ពួកសារម្មណក្ខន្ធអាស្រ័យនូវវត្ថុ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី អាស្រ័យនូវអនារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងខណៈនៃអហេតុកបដិសន្ធិ ពួកសារម្មណក្ខន្ធ អាស្រ័យនូវវត្ថុ កដត្តារូប អាស្រ័យនូវពួកមហាភូត ។ សារម្មណធម៌អាស្រ័យនូវសារម្មណធម៌ផង នូវអនារម្មណធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងខណៈនៃអហេតុកបដិសន្ធិខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាសារម្មណៈផង នូវវត្ថុផង នូវខន្ធ ២ ... ។ អនារម្មណធម៌ អាស្រ័យនូវសារម្មណធម៌ផង នូវអនារម្មណធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាអហេតុកបដិសន្ធិអាស្រ័យនូវពួកអហេតុកក្ខន្ធ ជាសារម្មណៈផង នូវពួកមហាភូតផង ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី អាស្រ័យនូវសារម្មណធម៌ផង នូវអនារម្មណធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងខណៈនៃអហេតុកបដិសន្ធិ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាសារម្មណៈផង នូវវត្ថុផង នូវខន្ធ

២ ... កដត្តារូប អាស្រ័យនូវពួកសារម្មណក្ខន្ធផង នូវពួកមហាភូតផង ។

[ ៥ ] អនារម្មណធម៌អាស្រ័យនូវសារម្មណធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសារម្មណក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។បេ។ អនារម្មណធម៌ អាស្រ័យនូវអនារម្មណធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ រហូតដល់ពួកអសញ្ញសត្វ ។ អនារម្មណធម៌ អាស្រ័យនូវសារម្មណធម៌ផង នូវអនារម្មណធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូបជាបដិសន្ធិ អាស្រ័យនូវពួកសារម្មណក្ខន្ធផង នូវពួកមហាភូតផង ។ សេចក្តីបំប្រួញ ។

[ ៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុង

នអធិបតិប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។

[ ៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ... ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។ ... ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ឯសហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៩ ] សារម្មណធម៌ពឹងផ្អែកនឹងសារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចបដិច្ចវារៈដែរ ។ អនារម្មណធម៌ ពឹងផ្អែកនឹងអនារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមហាភូត ១ ។បេ។ ចិត្តសមុដ្ឋានរូប កដត្តារូបនិងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ។ សារម្មណធម៌ ពឹងផ្អែកនឹងអនារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសារម្មណក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ពួកសារម្មណក្ខន្ធពឹងផ្អែកនឹងវត្ថុ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី ពឹងផ្អែកនឹងអនារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសារម្មណក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូបជាបដិសន្ធិ ពឹងផ្អែកនឹងពួកមហាភូត ។ សារម្មណធម៌ ពឹងផ្អែកនឹងសារម្មណធម៌ផង នឹងអនារម្មណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាសារម្មណៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។ អនារម្មណធម៌ ពឹងផ្អែកនឹងសារម្មណធម៌ផង

នឹងអនារម្មណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាបដិសន្ធិ ពីងផ្អែកនឹងពួកសារម្មណក្ខន្ធផង នឹងពួកមហាភូតផង ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី ពឹងផ្អែកនឹងសារម្មណធម៌ផង នឹងអនារម្មណធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាសារម្មណៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ជាបដិសន្ធិ ពឹងផ្អែកនឹងពួកសារម្មណក្ខន្ធផង នឹងពួកមហាភូតផង ។

[ ១០ ] សារម្មណធម៌ពឹងផ្អែកនឹងសារម្មណធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាសារម្មណៈ នឹងខន្ធ ២ ... ជាបដិសន្ធិ ។ សារម្មណធម៌ ពឹងផ្អែកនឹងអនារម្មណធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកសារម្មណក្ខន្ធ ជាបដិសន្ធិ ពឹងផ្អែកនឹងវត្ថុ ។ សារម្មណធម៌ពឹងផ្អែកនឹងសារម្មណធម៌ផង នឹងអនារម្មណធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ប្រឡំដោយកាយវិញ្ញាណ ។បេ។ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាសារម្មណៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១២ ] សារម្មណធម៌ពឹងផ្អែកនឹងសារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចបដិច្ចវារៈដែរ ។ អនារម្មណធម៌ ពឹងផ្អែកនឹងអនារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមហាភូត ១ ... មហាភូត ១ របស់ពួកអសញ្ញសត្វ... ។ សារម្មណធម៌ ពឹងផ្អែកនឹងអនារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកអហេតុកក្ខន្ធ ជាសារម្មណៈ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី ពឹងផ្អែកនឹងអនារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសារម្មណក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ជាបដិសន្ធិ ពឹងផ្អែកនឹងពួកមហាភូត ។ សារម្មណធម៌ ពឹងផ្អែកនឹងសារម្មណធម៌ផង នឹងអនា-

រម្មណធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ដែលប្រកបដោយកាយវិញ្ញាណ ។បេ។ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាសារម្មណៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។ អនារម្មណធម៌ ពឹងផ្អែកនឹងសារម្មណធម៌ផង នឹងអនារម្មណធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបជាបដិសន្ធិ ពឹងផ្អែកនឹងពួកសារម្មណក្ខន្ធផង នឹងពួកមហាភូតផង ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី ពឹងផ្អែកនឹងសារម្មណធម៌ផង នឹងអនារម្មណធម៌ផង ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាសារម្មណៈផង នឹងវត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធ ២ ផង នឹងសារម្មណក្ខន្ធផង នឹងពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ពឹងផ្អែកនឹងពួកខន្ធផង នឹងខន្ធ ១ ជាសារម្មណៈផង នឹងវត្ថុផង នឹងខន្ធ ២ ... កដត្តារូប ពឹងផ្អែកនឹងពួកសារម្មណក្ខន្ធផង នឹងពួកមហាភូតផង ។ សេចក្តីបំប្រួញ ។

[ ១៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហា-

របច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យមានវារៈ ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។

[ ១៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។ ... ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

និស្សយវារៈ ដូចបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ១៦ ] សារម្មណធម៌ ច្រឡំនឹងសារម្មណធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ច្រឡំនឹងខន្ធ ១ ជាសារម្មណៈ ។បេ។ ខន្ធ ២ ច្រឡំនឹងខន្ធ ២ ។

[ ១៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៨ ] សារម្មណធម៌ ប្រឡំនឹងសារម្មណធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំនឹងអហេតុកក្ខន្ធ ១ ជាសារម្មណៈ នឹងខន្ធ ២ ... មោហៈប្រឡំនឹងពួកខន្ធដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ សេចក្តីបំប្រួញ ។

[ ១៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។ ការរាប់ទាំងពីរយ៉ាងក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើចុះ ។

## បញ្ហាវារៈ

[ ២០ ] សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជាសារម្មណៈជាបច្ច័យ គឺជាបដិសន្ធិនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ សារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ជាសារម្មណៈជាបច្ច័យ គឺជាបដិសន្ធិនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ផង នៃអនារម្មណធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុ ជាសារម្មណៈជាបច្ច័យ គឺជាបដិសន្ធិនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង

ដោយហេតុប្បច្ច័យ ។

[ ២១ ] សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន... នូវសីល... នូវឧបោសថកម្ម... ពិចារណានូវកុសលនោះ ត្រេកអរ រីករាយ ព្រោះប្រារព្ធនូវកុសលនោះ ។បេ។ ទោមនស្សកើតឡើង នូវពួកកុសលដែលធ្លាប់សន្សំហើយក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈ ពិចារណានូវគោត្រភូនិងវោទានៈ ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវពួកកិលេសដែលលះបង់ហើយ ពិចារណានូវពួកកិលេស ដែលសង្កត់សង្កិនហើយ ដឹងនូវពួកកិលេសដែលធ្លាប់សន្សំហើយ ក្នុងកាលមុន នូវពួកសារម្មណក្ខន្ធ ជាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយសារម្មណចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ ពួកសារម្មណក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ អនារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គនិងផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ... នូវវត្ថុ ជាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយ

ទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ពួកអនារម្មណក្ខន្ធ ជាបច្ច័យនៃការពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ២២ ] សារម្មណធម៌ជាបច្ច័យនៃសារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន... នូវសីល... នូវឧបោសថកម្ម... បុគ្គលធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។បេ។ នូវពួកកុសល ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន... ចេញអំពីឈាន នូវឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ... នូវមគ្គ ឲ្យជាទីគោរព... នូវផលឲ្យជាទីគោរព... ធ្វើនូវពួកសារម្មណក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើនូវពួកខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។បេ។ ឯសហជាតាធិបតិ គឺសារម្មណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ សារម្មណធម៌ជាបច្ច័យនៃអនារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺសារម្មណាធិបតិជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ផង នៃអនារម្មណធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺសារម្មណាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប

ផង ដោយអធិបតិប្បច្ច័យ ។ អនារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទាន: មគ្គនិងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... ធ្វើនូវវត្ថុ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើនូវវត្ថុនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។បេ។

[ ២៣ ] សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសារម្មណៈមុនៗ ។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ ជាបច្ច័យ ដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺបច្ច័យទាំង ៧ ដូចសហជាតប្បច្ច័យក្នុងបដិច្ចវារៈដែរ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺបច្ច័យទាំង ៦ ដូចអញ្ញមញ្ញប្បច្ច័យ ក្នុងបដិច្ចវារៈដែរ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺបច្ច័យទាំង ៧ ដូចនិស្សយប្បច្ច័យក្នុងបច្ចយវារៈដែរ ។

[ ២៤ ] សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល... នូវបញ្ញា សេចក្តីប្រាថ្នា និងកាយិកសុខ... អាស្រ័យនូវកាយិកទុក្ខ ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សម្លាប់សត្វ ។បេ។ បំបែកសង្ឃ សទ្ធា... បញ្ញា

រាគៈ ។បេ។ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ ( ជាបច្ច័យ ) នៃសទ្ធា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អនារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺ ( បុគ្គល ) នូវរដូវ... នូវភោជន... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ញុំាងសមាបត្តិ ឲ្យកើតឡើង សម្លាប់សត្វ បំបែកសង្ឃ រដូវ... ភោជន... សេនាសនៈ ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ នៃសេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៥ ] អនារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកសារម្មណក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

[ ២៦ ] សារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺមានវារៈ ១ ។

[ ២៧ ] សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយអាសេវនប្បច្ច័យ គឺមានវារៈ ១ ។

[ ២៨ ] សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺសារម្មណចេតនាជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺសារម្មណចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដោយកម្មប្បច្ច័យ ។ សារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺសារម្មណចេតនា ជាបច្ច័យនៃចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺសារម្មណចេតនា ជាបច្ច័យនៃពួកកដត្តារូប ដោយកម្មប្បច្ច័យ ។ សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ផង នៃអនារម្មណធម៌ផង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺសារម្មណចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺសារម្មណចេតនាជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ២៩ ] សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ ៣ ។

[ ៣០ ] សារម្មណធម៌ជាបច្ច័យនៃសារម្មណធម៌ ដោយអាហារប្បច្ច័យ គឺមានវារៈ ៣ ។ អនារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយអាហា-

វប្បច្ច័យ គឺកពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ ។

[ ៣១ ] សារម្មណធម៌ជាបច្ច័យនៃសារម្មណធម៌ ដោយឥន្រ្ទិយប្បច្ច័យ គឺមានវារៈ ៣ ។ អនារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺរូបជីវិតិន្ទ្រិយជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ។ អនារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយិន្ទ្រិយជាបច្ច័យនៃកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី ជាបច្ច័យនៃសារម្មណធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយក្តី ចក្ខុវិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ កាយិន្ទ្រិយក្តី កាយវិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រឡំដោយកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣២ ] សារម្មណធម៌ជាបច្ច័យនៃអនារម្មណធម៌ ដោយឈានប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយមគ្គប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ ១ ។

[ ៣៣ ] សារម្មណធម៌ជាបច្ច័យនៃអនារម្មណធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ អនារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកសារម្មណក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ )

នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៤ ] សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ជាសារម្មណៈ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... បដិសន្ធិ ។ សារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្ដីបំប្រួញ ។ សារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ផង នៃអនារម្មណធម៌ផង ដោយអត្ថិប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈដែរ ។ អនារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយអត្ថិប្បច្ច័យ គឺមហាភូត ១ រហូតដល់ពួកអសញ្ញសត្វ ។ អនារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកសារម្មណក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកសារម្មណក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ សារម្មណធម៌ក្ដី អនារម្មណធម៌ក្ដី ជាបច្ច័យនៃសារម្មណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណក្ដី ចក្ខាយតនៈក្ដី ជាបច្ច័យនៃ

ខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ដែលប្រទូ្បំដោយកាយ-វិញ្ញាណក្តី កាយាយតនៈក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ជាសារម្មណៈក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... បដិសន្ធិ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី ជាបច្ច័យនៃអនារម្មណធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺពួកសារម្មណក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យ គឺជាបដិសន្ធិនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកសារម្មណក្ខន្ធក្តី កពឡិង្ការាហារក្តីជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកសារម្មណក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៣៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៦ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុង

វិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៣៦ ] សារម្មណធម៌ជាបច្ច័យនៃសារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ សារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ សារម្មណធម៌ជាបច្ច័យនៃសារម្មណធម៌ផង នៃអនារម្មណធម៌ផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ អនារម្មណធម៌ ជាបច្ច័យនៃអនារម្មណធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អនារម្មណធម៌ ជាបច្ច័យនៃសារម្មណធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី ជាបច្ច័យនៃសារម្មណធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ សារម្មណធម៌ក្តី អនារម្មណធម៌ក្តី ជាបច្ច័យនៃអនារម្មណធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៣៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៧ ។បេ។ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ។បេ។ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៣៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ ។បេ។ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៣៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

## ចប់ សារម្មណទុកៈ ។

## ចិត្តទុកៈ

## បដិច្ចវារៈ

[ ៤០ ] នោចិត្តធម៌ ( ធម៌មិនមែនជាចិត្ត ) អាស្រ័យនូវចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្ត ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបក្តី អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ។ នោចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាចិត្ត ខន្ធ ១ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ អាស្រ័យនូវមហាភូត ១ ។បេ។ ចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តអាស្រ័យនូវពួកខន្ធ មិនមែនជាចិត្ត ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវពួកខន្ធមិនមែនជាចិត្ត ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវវត្ថុ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាចិត្ត នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាចិត្ត ខន្ធ ១ ក្តី ចិត្តក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ផង នូវនោចិត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អា-

ស្រ័យនូវខន្ធ ១ មិនមែនជាចិត្តផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាចិត្តផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកនោចិត្តក្ខន្ធ អាស្រ័យនូវចិត្តផង នូវវត្ថុផង ។

[ ៤១ ] នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធអាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ។បេ។ នោចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវខន្ធ ១ មិនមែនជាចិត្ត នូវខន្ធ ២ ... ពួកខន្ធអាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្តអាស្រ័យនូវពួកនោចិត្តក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវពួកនោចិត្តក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវវត្ថុ ។ ចិត្តក្តី នោចិត្តធម៌ក្តី អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាចិត្ត អាស្រ័យនូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវខន្ធ ១ មិនមែនជាចិត្ត នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ផង នូវនោចិត្តធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវខន្ធ ១ មិនមែនជាចិត្តផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកនោចិត្តក្ខន្ធ អាស្រ័យនូវចិត្តផង នូវវត្ថុផង ។ សេចក្តី

បំប្រួញ ។

[ ៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអាហារប្បច្ច័យ មានវារៈ ៥ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៥ ក្នុងឈានប្បច្ច័យ មានវារៈ ៥ ក្នុងមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៤៣ ] នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវចិត្តដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ នោចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ មិនមែនជាចិត្ត នូវខន្ធ ២ ... មានអហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ មោហៈដែលប្រកប

ដោយវិចិកិច្ឆា ប្រទូំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រទូំដោយ វិចិកិច្ឆា ប្រទូំដោយឧទ្ធច្ចៈ ។ ចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តអាស្រ័យនូវអហេតុកក្ខន្ធ មិនមែនជាចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តអាស្រ័យនូវពួកខន្ធ មិនមែនជាចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តអាស្រ័យនូវវត្ថុ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ដែលមិនមែនជាចិត្ត នូវខន្ធ ២ ។បេ។ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ផង នូវនោចិត្តធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ដែលមិនមែនជាចិត្តផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាចិត្តផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកនោចិត្តក្ខន្ធ អាស្រ័យនូវចិត្តផង នូវវត្ថុផង មោហៈ ដែលប្រទូំដោយវិចិកិច្ឆា ប្រទូំដោយឧទ្ធច្ចៈ អាស្រ័យនូវចិត្ត ដែលប្រទូំដោយវិចិកិច្ឆា ប្រទូំដោយឧទ្ធច្ចៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។

[ ៤៤ ] នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាបដិសន្ធិអាស្រ័យនូវចិត្ត ។ នោចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្ត-

សមុដ្ឋានរូបជាបដិសន្ធិ រហូតដល់អសញ្ញសត្វ អាស្រ័យនូវពួកនោចិត្តក្ខន្ធ ។ នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ផង នូវនោចិត្តធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្តផង នូវពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្តផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យនូវចិត្តផង នូវពួកសម្បយុត្តកក្ខន្ធផង កដត្តារូប អាស្រ័យនូវចិត្តផង នូវពួកមហាភូតផង ។

[ ៤៥ ] នោចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺមានវារៈ ៥ ។ ព្រោះនអនន្តរប្បច្ច័យ ។បេ។ ព្រោះនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។

[ ៤៦ ] នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវចិត្ត ក្នុងអរូប ចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបក្តី អាស្រ័យនូវចិត្ត ។ នោចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាចិត្ត ក្នុងអរូប នូវខន្ធ ២ ។បេ។ ចិត្តសមុដ្ឋានរូបជាបដិសន្ធិ រហូតដល់អសញ្ញសត្វ អាស្រ័យនូវពួកនោចិត្តក្ខន្ធ ។ ចិត្តធម៌អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ចិត្តអាស្រ័យនូវពួកនោចិត្តក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវវត្ថុ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ

គឺក្នុងអរូប ខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាចិត្ត ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ផង នូវនោចិត្តធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ខន្ធ ២ អាស្រ័យនូវខន្ធ ១ ដែលមិនមែនជាចិត្តផង នូវចិត្តផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនោចិត្តក្ខន្ធផង នូវចិត្តផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្តផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ពួកនោចិត្តក្ខន្ធ អាស្រ័យនូវចិត្តផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូបអាស្រ័យនូវចិត្តផង នូវពួកសម្បយុត្តកក្ខន្ធផង កដត្តារូប អាស្រ័យនូវចិត្តផង នូវពួកមហាភូតផង ។ ព្រោះនបច្ឆាជាតប្បច្ច័យ ព្រោះនអាសេវនប្បច្ច័យ ។

[ ៤៧ ] នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវចិត្ត ។ នោចិត្តធម៌ អាស្រ័យនូវនោចិត្តធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកនោចិត្តក្ខន្ធ ពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ។ នោចិត្តធម៌ អាស្រ័យនូវចិត្តធម៌ផង នូវនោចិត្តធម៌ផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកនោចិត្តក្ខន្ធផង នូវចិត្តផង ។ សេចក្តីបំប្រួញ ។

[ ៤៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣

ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៥ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៤៩ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ។ សេចក្តីបំប្រួញ ។

[ ៥០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។ សហជាតវារៈ ដូចបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៥១ ] នោចិត្តធម៌ពឹងផ្អែកនឹងចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូប ជាបដិសន្ធិក្តី ពឹងផ្អែកនឹងចិត្ត ។ នោចិត្តធម៌ ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមែនជាចិត្ត នឹង

ខន្ធ ២ ។បេ។ ជាបដិសន្ធិ រហូតដល់ពួកមហាភូត ពួកនោចិត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ ចិត្តធម៌ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្ត ពឹងផ្អែកនឹងពួកនោចិត្តក្ខន្ធ ចិត្តពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ចិត្ត ពឹងផ្អែកនឹងពួកនោចិត្តក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ចិត្តពឹងផ្អែកនឹងវត្ថុ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមែនជាចិត្ត នឹងខន្ធ ២ ... ចិត្តក្តី ពួកសម្បយុត្តក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី កដត្តារូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមែនជាចិត្ត នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ។ នោចិត្តធម៌ ពឹងផ្អែកនឹងចិត្តធម៌ផង នឹងនោចិត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមែនជាចិត្តផង នឹងចិត្តផង នឹងខន្ធ ២ ... ពួកនោចិត្តក្ខន្ធ ពឹងផ្អែកនឹងចិត្តផង នឹងវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមែនជាចិត្តផង នឹងចិត្តផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកនោចិត្តក្ខន្ធ ពឹងផ្អែកនឹងចិត្តផង នឹងវត្ថុផង ។

[ ៥២ ] នោចិត្តធម៌ ពឹងផ្អែកនឹងចិត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ ១ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នោចិត្តធម៌ ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ពឹង

ផ្អែកនឹងខន្ធ ១ ដែលមិនមែនជាចិត្ត នឹងខន្ធ ២ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ពួកនោចិត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ពួកខន្ធដែលប្រទ្បំដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ពួកខន្ធ ដែលប្រទ្បំដោយកាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកនោចិត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ ចិត្តធម៌ ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្ត ពឹងផ្អែកនឹងពួកនោចិត្តក្ខន្ធចិត្ត ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ចិត្តពឹងផ្អែកនឹងពួកនោចិត្តក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ចិត្តពឹងផ្អែកនឹងវត្ថុ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ។ ចិត្តធម៌ក្តី នោ-ចិត្តធម៌ក្តី ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមែនជាចិត្ត នឹងខន្ធ ២ ... ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ចក្ខុវិញ្ញាណក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងកាយាយតនៈ ។ នោចិត្តធម៌ ពឹងផ្អែកនឹងចិត្តធម៌ផង នឹងនោចិត្តធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមែនជាចិត្តផង នឹងចិត្តផង នឹងខន្ធ ២ ... ពួកនោចិត្តក្ខន្ធ ពឹងផ្អែកនឹងចិត្តផង នឹងវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ពួកនោចិត្តក្ខន្ធពឹងផ្អែកនឹងចិត្តផង នឹងវត្ថុផង ពួកខន្ធដែលប្រទ្បំដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈផង នឹងចក្ខុវិញ្ញាណផង នឹងកាយាយតនៈផង... សេចក្តីបំប្រួញ ។

[ ៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៥៤ ] នោចិត្តធម៌ ពឹងផ្អែកនឹងចិត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកចិត្តក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងចិត្ត ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ នោចិត្តធម៌ ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ដែលមិនមែនជាចិត្ត នឹងខន្ធ ២ ... មានអហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ ពួកខន្ធ ដែលប្រកបដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ពួកខន្ធ ដែលប្រកបដោយកាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកនោចិត្តក្ខន្ធ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផងនឹងវត្ថុផង ។ ចិត្តធម៌ ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តពឹងផ្អែកនឹងពួកអហេតុកក្ខន្ធ ដែលមិនមែនជាចិត្ត ចិត្តជាអហេតុកប្បដិសន្ធិ ពឹងផ្អែកនឹងវត្ថុ ។បេ។ ក្នុងខណៈនៃអហេតុកប្បដិសន្ធិចិត្តពឹងផ្អែកនឹងវត្ថុ ចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ ពឹងផ្អែកនឹងកាយាយតនៈ ។បេ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ពឹងផ្អែកនឹងនោចិត្តធម៌ ទើបកើត

ឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ដែលមិនមែនជាចិត្ត នឹងខន្ធ ២ ។បេ។ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាអហេតុកប្បដិសន្ធិ ពឹងផ្អែកនឹងវត្ថុ ។បេ។ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ពឹងផ្អែកនឹងចក្ខាយតនៈ ។បេ។ កាយាយតនៈ ។បេ។ នោចិត្តធម៌ ពឹងផ្អែកនឹងចិត្តធម៌ផង នឹងនោចិត្តធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ដែលមិនមែនជាចិត្តផង នឹងចិត្តផង នឹងខន្ធ ២ ។បេ។ ពួកនោចិត្តក្ខន្ធ ពឹងផ្អែកនឹងចិត្តផង នឹងវត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកនោចិត្តក្ខន្ធ ពឹងផ្អែកនឹងចិត្តផង នឹងវត្ថុផង ពួកខន្ធដែលប្រកបដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈផង នឹងចក្ខុវិញ្ញាណផង នឹងកាយាយតនៈផង ។បេ។ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងចិត្តផង ។ សេចក្តីបំប្រួញ ។

[ ៥៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហា-

វប្បច្ច័យ មានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងឈានប្បច្ច័យ មានវារៈ ៥ ក្នុងមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៥៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ។ សេចក្តីបំប្រួញ ។

[ ៥៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

និស្សយវារៈ ដូចបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ៥៨ ] នោចិត្តធម៌ប្រឡំនឹងចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ ប្រឡំនឹងចិត្ត ក្នុងខណៈនៃបដិសន្ធិ ។បេ។ នោចិត្តធម៌ប្រឡំនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡំនឹងខន្ធ ១ ដែលមិនមែនជាចិត្ត ខន្ធ ១ ជាបដិសន្ធិ ប្រឡំនឹងខន្ធ ២ ។ ចិត្តធម៌ប្រឡំនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តជាបដិសន្ធិ ប្រឡំនឹងពួកខន្ធដែលមិនមែនជាចិត្ត ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ប្រឡំនឹងនោចិត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តធម៌ក្តី

ប្រទ្បូំនឹងខន្ធ ១ ដែលមិនមែនជាចិត្ត នឹងខន្ធ ២ ។បេ។ ជាបដិសន្ធិ ។ នោចិត្តធម៌ ប្រទ្បូំនឹងចិត្តធម៌ផង នឹងនោចិត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រទ្បូំនឹងខន្ធ ១ ដែលមិនមែនជាចិត្តផង នឹងចិត្តផង នឹងខន្ធ ២ ។បេ។ ជាបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ៥៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។ សេចក្តីបំប្រួញ ។

[ ៦០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនឈានប្បច្ច័យ មានវារៈ ៥ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ។

ការរាប់ ២ យ៉ាងក្រៅពីនេះក្តី សម្បយុត្តវារៈក្តី ទាំងអស់នេះ
បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ៦១ ] នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលមិនមែនជាចិត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ នោ-

ចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលមិនមែនជាចិត្ត ជាបច្ច័យ គឺជាបដិសន្ធិនៃចិត្ត ដោយហេតុប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុដែលមិនមែនជាចិត្ត ជាបច្ច័យ គឺជាបដិសន្ធិនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ៦២ ] ចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយអារម្មណប្បច្ច័យ គឺចិត្តកើតឡើង ព្រោះប្រារព្ធនូវចិត្ត ។ មូលបណ្ណិតគប្បីធ្វើចុះ ។ ពួកនោចិត្តក្ខន្ធកើតឡើង ព្រោះប្រារព្ធនូវចិត្ត ។ មូល បណ្ណិតគប្បីធ្វើចុះ ។ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវចិត្ត ។ នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន រក្សានូវសីល ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះប្រារព្ធនូវកុសលនោះ ។បេ។ ទោមនស្សកើតឡើង នូវពួកកុសល ដែលខ្លួនធ្លាប់សន្សំហើយ ក្នុងកាលមុន... ចេញអំពីឈាន នូវឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន និព្វានជាបច្ច័យនៃការពិចារណានៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេសមិនមែនជាចិត្តដែលលះបង់ហើយ ពិចារណានូវពួកកិលេសដែលខ្លួនសង្កត់សង្កិនហើយ ដឹងនូវពួកកិលេស ដែលខ្លួនធ្លាប់សន្សំហើយ ក្នុងកាលមុន នូវចក្ខុ... នូវត្រចៈ... នូវពួកនោចិត្តក្ខន្ធថាមិនទៀង ។បេ។ ទោមនស្ស

កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោត-ធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយធម៌ មិនមែនជាចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ។បេ។ អាកិញ្ចញ្ញាយតនៈ ។បេ។ រូបាយតនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ ផោដ្ឋព្វា-យតនៈ ។បេ។ ពួកនោចិត្តក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និង អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្ត-ធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន... ដូចជាដំណើរទី ១ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ នេះជាសេចក្តីផ្សេងគ្នា គឺរូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ នោចិត្តក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ។បេ។ ដោយអា-រម្មណប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយអារម្មណប្បច្ច័យ គឺបុគ្គល ឲ្យនូវទាន... ដូចជាដំណើរទី ១ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ នេះជាសេចក្តីផ្សេងគ្នា គឺរូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ។ នោចិត្តក្ខន្ធ ( ជាបច្ច័យ ) នៃការពិចារណានូវឥទ្ធិវិធញ្ញាណ ។បេ។ ដោយអារម្មណប្បច្ច័យ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ជាបច្ច័យនៃចិត្តធម៌ ដោយអារម្មណប្បច្ច័យ គឺចិត្តប្រារព្ធនូវចិត្តផង នូវពួកសម្បយុត្តកក្ខន្ធផង មានវារៈ ៣ ។

[ ៦៣ ] ចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺចិត្តកើតឡើង ព្រោះធ្វើនូវចិត្ត ឲ្យជាទីគោរព ។ ចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិង សហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកនោចិត្តក្ខន្ធ កើតឡើង ព្រោះធ្វើ នូវចិត្តឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺចិត្តាធិបតិធម៌ជាបច្ច័យនៃពួក សម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ចិត្តធម៌ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយអធិបតិប្បច្ច័យ បាន ដល់ អារម្មណាធិបតិ គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះធ្វើនូវ ចិត្តឲ្យជាទីគោព ។ នោចិត្តធម៌ជាបច្ច័យនៃនោចិត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវ ទាន... នូវសីល... នូវឧបោសថកម្ម... បុគ្គលធ្វើនូវកុសលនោះ ហើយ ពិចារណានូវកុសលនោះ ឲ្យជាទីគោរព ត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវកុសលនោះឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។បេ។ ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណានូវមគ្គ នូវផល... ព្រោះធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព... ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោ- ទានៈ មគ្គនិងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... ត្រេកអរ រីករាយ ព្រោះធ្វើនូវនោចិត្តក្ខន្ធ ឲ្យជាទីគោរព រាគៈកើតឡើង ព្រោះធ្វើនូវ ពួកខន្ធនោះ ឲ្យធ្ងន់ ទិដ្ឋិកើតឡើង ។បេ។ ឯសហជាតាធិបតិ គឺនោចិត្តា- ធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយ

អធិបតិប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយអធិបតិប្បច្ច័យ គឺ ដំណើរទាំង ២ យ៉ាង ដូចជាដំណើរទី ១ ដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ឯអារម្មណាធិបតិនិងសហជាតាធិបតិ បណ្ឌិតគប្បីធ្វើចុះ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ជាបច្ច័យនៃចិត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺមានវារៈ ៣ មានការធ្វើឲ្យធ្ងន់ជាអារម្មណ៍ បណ្ឌិតគប្បីធ្វើចុះ គឺអារម្មណាធិបតិហ្នឹងដដែល ។

[ ៦៤ ] ចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយអនន្តរប្បច្ច័យ គឺចិត្តមុនៗ ជាបច្ច័យនៃចិត្តក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយអនន្តរប្បច្ច័យ គឺចិត្តមុនៗ ជាបច្ច័យនៃនោចិត្តកន្លងក្រោយៗ ដោយអនន្តរប្បច្ច័យ ចិត្តជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ ចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយអនន្តរប្បច្ច័យ គឺចិត្តមុនៗ ជាបច្ច័យនៃចិត្តក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោចិត្តកន្ធមុនៗ ។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ វារៈទាំង ២ យ៉ាងនេះ បណ្ឌិតអ្នកមានប្រាថ្នានឹងបំពេញ គប្បីធ្វើឲ្យដូចដំណើរមុនចុះ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ជាបច្ច័យនៃចិត្តធម៌ ដោយអនន្តរប្បច្ច័យ គឺចិត្តមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃចិត្តក្រោយៗ ដោយអនន្តរប្បច្ច័យ ។ បណ្ឌិតគប្បីសួរមូលចុះ ចិត្តមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកនោចិត្តកន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជា

បច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ បណ្ឌិតគប្បីសួរមូលចុះ ចិត្តមុនៗក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃចិត្តក្រោយៗផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ ជាបច្ច័យដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៥ ដូចបដិច្ចវារៈដែរ ជាបច្ច័យដោយអញ្ញ-មញ្ញប្បច្ច័យ គឺមានវារៈ ៥ ដូចបដិច្ចវារៈដែរ ជាបច្ច័យដោយនិស្ស-យប្បច្ច័យ គឺមានវារៈ ៥ ដូចបច្ចយវារៈដែរ ។

[ ៦៥ ] ចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺចិត្តជាបច្ច័យនៃចិត្ត ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យទាន ។បេ។ ដំឡើងមានះ ប្រកាន់ទិដ្ឋិ សីល ។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ ហើយឲ្យទាន។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេនាសនៈជាបច្ច័យនៃសទ្ធា ។បេ។ នៃមគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយឧបនិស្សយប្បច្ច័យ គឺវារៈទាំង ២ យ៉ាងនេះ បណ្ឌិតអ្នកប្រាថ្នានឹងបំពេញ គប្បីធ្វើក្នុងបច្ច័យទាំងអស់ឲ្យដូចជាដំណើរទី ១ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តីជាបច្ច័យនៃចិត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និង

បកតូបនិស្ស័យ ។បេ។ ឯកបតូបនិស្ស័យ គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃចិត្ត ដោយឧបនិស្សយបច្ច័យ មានវារៈ ៣ ។

[ ៦៦ ] នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយបុរេជាតបច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃពួកខន្ធដែលប្រឡំដោយកាយវិញ្ញាណ ដោយបុរេជាតបច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខ្វាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកនោចិត្តក្ខន្ធ ដោយបុរេជាតបច្ច័យ ។ នោចិត្តធម៌ជាបច្ច័យនៃចិត្តធម៌ ដោយបុរេជាតបច្ច័យ បានដល់អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខ្វាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃចិត្ត ដោយបុរេជាតបច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយបុរេជាតបច្ច័យ បានដល់អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង ។បេ។

ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ផោដ្ឋព្វាយតនៈ ។បេ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង វត្ថុជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។

[ ៦៧ ] ចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ នោចិត្តធម៌ជាបច្ច័យនៃនោចិត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ជាបច្ច័យនៃនោចិត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។

[ ៦៨ ] ចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយអាសេវនប្បច្ច័យ គឺមានវារៈ ៩ ។

[ ៦៩ ] នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនា ដែលមិនមែនជាចិត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលមិនមែនជាចិត្ត ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនាដែលមិនមែនជាចិត្តជាបច្ច័យនៃចិត្ត ដោយកម្មប្បច្ច័យ ។

ឯនានាខណិកៈ គឺចេតនាដែលមិនមែនជាចិត្ត ជាបច្ច័យនៃវិបាកចិត្ត ដោយកម្មប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនាដែលមិនមែនជាចិត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលមិនមែនជាចិត្ត ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃចិត្តផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៧០ ] ចិត្តធម៌ជាបច្ច័យនៃនោចិត្តធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ ៥ ជាបច្ច័យដោយអាហារប្បច្ច័យ គឺមានវារៈ ៥ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ ៥ ។

[ ៧១ ] នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយឈានប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយមគ្គប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ ៥ ។

[ ៧២ ] ចិត្តធម៌ជាបច្ច័យនៃនោចិត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺពួកនោចិត្តក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកនោចិត្តក្ខន្ធជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត

គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធដែលប្រឡំដោយកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃពួកនោចិត្តក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួក នោចិត្តក្ខន្ធ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិវត្ថុជាបច្ច័យនៃចិត្ត ដោយ វិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុ-វិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃ ចិត្ត ដោយវិប្បយុត្តប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃ នោចិត្តធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្ត-កក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យ នៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ កា-យាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ... វត្ថុ ជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ជាបច្ច័យនៃនោចិត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និង បច្ឆាជាត ។ សេចក្តីបំប្រួញ ។

[ ៧៣ ] ចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ នោចិត្តធម៌ ជាបច្ច័យនៃនោ-

ចិត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺពួកនោចិត្តក្ខន្ធ ( ជាបច្ច័យ ) នៃចិត្ត ក្នុងខណៈនៃបដិសន្ធិ ពួកនោចិត្ត ។បេ។ ក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃចិត្ត ដោយអត្ថិប្បច្ច័យ ។ បុរេជាត គឺនូវចក្ខុ... នូវវត្ថុ ជាមិនទៀង... ដូចជាបុរេជាតប្បច្ច័យដែរ ។ សេចក្តីបំប្រួញ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺនោចិត្តក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ២ ផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ នោចិត្តក្ខន្ធ ១ ។បេ។ ក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ។ បុរេជាត គឺនូវចក្ខុ ... នូវវត្ថុ... ដូចជាបុរេជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ជាបច្ច័យនៃនោចិត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺនោចិត្តក្ខន្ធ ១ ក្តី ចិត្តក្តី ជាបច្ច័យនៃខន្ធ ២ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហជាត គឺចិត្តក្តី វត្ថុក្តី ជាបច្ច័យនៃពួកនោចិត្តក្ខន្ធ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានវារៈ ២ ។ សហជាត គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ សហជាត គឺចិត្តក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយ

អត្ថិប្បច្ច័យ ។ បច្ឆាជាត គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៧៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអាហារប្បច្ច័យ មានវារៈ ៥ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៥ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៧៥ ] ចិត្តធម៌ជាបច្ច័យនៃចិត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ចិត្តធម៌ជាបច្ច័យនៃនោចិត្តធម៌ ដោយអារម្ម-

ណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្ស-យប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្ស-យប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃនោចិត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិ-យប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ នោចិត្តធម៌ ជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេ-ជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ជាបច្ច័យនៃចិត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តី ជាបច្ច័យនៃនោចិត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ចិត្តធម៌ក្តី នោចិត្តធម៌ក្តីជាបច្ច័យនៃចិត្តធម៌ផង នៃនោចិត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៧៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន

 វារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៧ ] ក្នុងនអារម្មណប្បច្ច័យមានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។បេ។ ... ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិ-គតប្បច្ច័យ មានវារៈ ៣ ។

[ ៧៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។

អនុលោមប្បដិលោមមាតិកា បណ្ឌិតគប្បីធ្វើចុះ ។

**ចប់ ចិត្តទុកៈ ។**

# ចេតសិកទុកៈ

## បដិច្ចវារៈ

[ ៧៩ ] ចេតសិកធម៌ អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចេតសិកខន្ធ ១ ខន្ធ ១ អាស្រ័យនូវខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ។បេ។ អចេតសិកធម៌ អាស្រ័យនូវចេត-

សិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកចេតសិកក្ខន្ធ ចិត្តក្តី កដត្តារូបក្តី អាស្រ័យនូវពួកចេតសិកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ អចេតសិកធម៌ អាស្រ័យនូវអចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យនូវចិត្ត វត្ថុអាស្រ័យនូវចិត្ត ចិត្តអាស្រ័យនូវវត្ថុ មហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ចេតសិកធម៌ អាស្រ័យនូវអចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិចិត្ត ។បេ។ ក្នុងខណៈនៃបដិសន្ធិ ពួកចេតសិកក្ខន្ធ អាស្រ័យនូវវត្ថុ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវអចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិចិត្ត ។បេ។ ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ ចេតសិកធម៌អាស្រ័យនូវចេតសិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈ នៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធផង នូវចិត្តផង នូវខន្ធ ២ ...

ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវចិត្តផង នូវវត្ថុផង នូវខន្ធ ២ ... ។ អចេតសិកធម៌ អាស្រ័យនូវចេតសិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវចិត្តផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវចិត្តផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិចិត្ត អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវវត្ថុផង ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវចេតសិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវវត្ថុផង ខន្ធ ១ ក្តី ចិត្តក្តី អាស្រ័យនូវខន្ធ ២ ផង នូវវត្ថុផង ។

[ ៨០ ] ចេតសិកធម៌អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ នូវខន្ធ ២ ... បដិសន្ធិ ។ អចេតសិកធម៌អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្តជាបដិសន្ធិ អាស្រ័យនូវពួកចេតសិកក្ខន្ធ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើងព្រោះ

អារម្មណប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ នូវខន្ធ ២ ... បដិសន្ធិ ។ អចេតសិកធម៌ អាស្រ័យនូវអចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវវត្ថុ ។ ចេតសិកធម៌អាស្រ័យនូវអចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធអាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិចិត្ត ។បេ។ ក្នុងខណៈនៃបដិសន្ធិ ពួកចេតសិកក្ខន្ធ អាស្រ័យនូវវត្ថុ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវអចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ចេតសិកធម៌ អាស្រ័យនូវចេតសិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវចិត្តផង នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវចិត្តផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ អចេតសិកធម៌ អាស្រ័យនូវចេតសិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្តអាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវចេតសិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ... ។

[ ៨១ ] ចេតសិកធម៌ អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ ។ សេចក្តីបំប្រួញ ។

[ ៨២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៣ ] ចេតសិកធម៌អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ អចេតសិកធម៌ អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី ជាអហេតុកប្បដិសន្ធិ អាស្រ័យនូវពួកចេតសិកក្ខន្ធ ជាអហេតុកៈ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ជាអហេតុកប្បដិសន្ធិ ។ អចេតសិកធម៌ អាស្រ័យនូវអចេតសិកធម៌

ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យនូវអហេតុក-ចិត្ត កដត្តារូបអាស្រ័យនូវចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ វត្ថុអាស្រ័យនូវចិត្ត ចិត្តអាស្រ័យនូវវត្ថុ មហាភូត ១ ... មហាភូត ១ របស់ពួកអសញ្ញសត្វ... ៗ ចេតសិកធម៌ អាស្រ័យនូវអចេតសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវអហេតុកចិត្ត ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកចេត-សិកក្ខន្ធ អាស្រ័យនូវវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវចិត្តដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ៗ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវអ-ចេតសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកចិត្ត ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបក្តី អាស្រ័យនូវចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តក្តី ពួកសម្បយុត្ត-កក្ខន្ធក្តី អាស្រ័យនូវវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ៗ ចេតសិកធម៌ អាស្រ័យនូវចេតសិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ជាអហេតុកៈផង នូវចិត្តផង នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវចិត្តផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... មោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួក

ខន្ធដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នូវចិត្តផង ។ អចេត-សិកធម៌ អាស្រ័យនូវចេតសិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចេតសិកក្ខន្ធ ជាអហេតុកៈផង នូវចិត្តផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចេតសិកក្ខន្ធជាអហេតុកៈផង នូវពួកមហាភូតផង កដត្តារូប អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវចិត្តផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តអាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវវត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី អាស្រ័យនូវចេតសិកធម៌ផង នូវអចេត-សិកធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តស-មុដ្ឋានរូបក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ ជាអហេតុកៈផង នូវចិត្តផង ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវចិត្តផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវចេតសិកក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... ។

[ ៨៤ ] អចេតសិកធម៌ អាស្រ័យនូវចេតសិកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចេតសិកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។បេ។ អចេតសិកធម៌ អាស្រ័យនូវអចេតសិកធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្ត ជាបដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ ។ អចេតសិកធម៌ អាស្រ័យនូវចេត-

សិកធម៌ផង នូវអចេតសិកធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវវិញ្ញាណផង នូវចិត្តផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចេតសិកក្ខន្ធផង នូវពួកមហាភូតផង វារៈទាំង ២ យ៉ាង បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ៨៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៦ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៨៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។

[ ៨៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យ

ទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ ឯសហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៨៨ ] ចេតសិកធម៌ពឹងផ្អែកនឹងចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ អចេតសិកធម៌ ពឹងផ្អែកនឹងអចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងចិត្ត ចិត្តពឹងផ្អែកនឹងវត្ថុ កដត្តារូបពឹងផ្អែកនឹងចិត្ត ក្នុងខណៈនៃបដិសន្ធិ វត្ថុពឹងផ្អែកនឹងចិត្ត ចិត្តពឹងផ្អែកនឹងវត្ថុ មហាភូត ១ ... ។ ចេតសិកធម៌ ពឹងផ្អែកនឹងអចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងចិត្ត ពួកចេតសិកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ វារៈទាំង ២ យ៉ាង បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ពឹងផ្អែកនឹងអចេតសិកធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងចិត្ត ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ វារៈ ២ យ៉ាង បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ ចេតសិកធម៌ ពឹងផ្អែកនឹងចេតសិកធម៌ផង នឹងអចេតសិកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងចេតសិកក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ខន្ធ ២ ពឹងផ្អែកនឹងចេតសិកក្ខន្ធ ១ ផង នឹងចិត្តផង នឹងវត្ថុផង នឹងខន្ធ ២ ... វារៈ ២ យ៉ាង បណ្ឌិតគប្បីធ្វើ

ក្នុងខណៈនៃបដិសន្ធិចុះ ។ អចេតសិកធម៌ ពឹងផ្អែកនឹងចេតសិកធម៌ផង នឹងអចេតសិកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកចេតសិកក្ខន្ធផង នឹងចិត្តផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកចេតសិកក្ខន្ធផង នឹងពួកមហាភូតផង ចិត្តពឹងផ្អែកនឹងពួកចេតសិកក្ខន្ធផង នឹងវត្ថុផង វារៈ ៣ យ៉ាងបណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ពឹងផ្អែកនឹងចេតសិកធម៌ផង នឹងអចេតសិកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងចេតសិកក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ខន្ធ ២ ក្តី ចិត្តក្តី ពឹងផ្អែកនឹងចេតសិកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... វារៈ ២ យ៉ាង បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។

[ ៨៩ ] ចេតសិកធម៌ពឹងផ្អែកនឹងចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ អចេតសិកធម៌ពឹងផ្អែកនឹងអចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ចិត្តជាបដិសន្ធិ ពឹងផ្អែកនឹងវត្ថុ ។ ចេតសិកធម៌ ពឹងផ្អែកនឹងអចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ពឹងផ្អែកនឹងកាយាយតនៈ... ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងចិត្ត ពួកចេតសិកក្ខន្ធពឹងផ្អែកនឹងវត្ថុ វារៈ ២ យ៉ាង បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ពឹងផ្អែកនឹង

អចេតសិកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងចក្ខាយតនៈ ពឹងផ្អែកនឹងកាយាយតនៈ... ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ វារៈ ១ ក្នុងខណៈនៃបដិសន្ធិ ។ ចេតសិកធម៌ ពឹងផ្អែកនឹងចេតសិកធម៌ផង នឹងអចេតសិកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង នឹងចក្ខុវិញ្ញាណផង នឹងខន្ធ ២ ... ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ដែលប្រកបដោយកាយវិញ្ញាណ... ខន្ធ ២ ពឹងផ្អែកនឹងចេតសិកក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ខន្ធ ២ ពឹងផ្អែកនឹងចេតសិកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... វារៈ ២ ក្នុងខណៈនៃបដិសន្ធិ ។ អចេតសិកធម៌ ពឹងផ្អែកនឹងចេតសិកធម៌ផង នឹងអចេតសិកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយចក្ខុ-វិញ្ញាណផង នឹងចក្ខាយតនៈផង ដែលប្រកបដោយកាយវិញ្ញាណ... ចិត្តពឹងផ្អែកនឹងពួកចេតសិកក្ខន្ធផង នឹងវត្ថុផង ឯបដិសន្ធិ មានវារៈ ១ ។ ចេត-សិកធម៌ក្តី អចេតសិកធម៌ក្តី ពឹងផ្អែកនឹងចេតសិកធម៌ផង នឹងអចេតសិកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ក្តី ចក្ខុវិញ្ញាណក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង ពឹងផ្អែកនឹងខន្ធ ២ ... ខន្ធ ២ ក្តី ចិត្តក្តី ពឹងផ្អែកនឹងចេតសិកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... បដិសន្ធិ មានវារៈ ១ ។ សេចក្តីបំប្រួញ ។

[ ៩០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩១ ] ចេតសិកធម៌ពឹងផ្អែកនឹងចេតសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអហេតុកចេតសិក... ។ សេចក្ដីបំប្រួញ ។ ប្រស្នា ៩ ក្ដីបញ្ចវិញ្ញាណក្ដី បណ្ឌិតគប្បីធ្វើដូចអារម្មណប្បច្ច័យដែរ មោហៈក្នុងវារៈទាំង ៣ និងប្រស្នាទាំងអស់ បណ្ឌិតកាលមិនវង្វេង គប្បីធ្វើក្នុងបវត្តិប្បដិសន្ធិចុះ ។

[ ៩២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៩៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុង

នអធិបតិប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។

[ ៩៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

## សំសដ្ឋវារៈ

[ ៩៥ ] ចេតសិកធម៌ ប្រឡូកនឹងចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡូកនឹងចេតសិកក្ខន្ធ ១ នឹងខន្ធ ២ ... ជាបដិសន្ធិ ។ អចេតសិកធម៌ ប្រឡូកនឹងចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តជាបដិសន្ធិ ប្រឡូកនឹងពួកចេតសិកក្ខន្ធ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ប្រឡូកនឹងចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ប្រឡូកនឹងចេតសិកក្ខន្ធ ១ នឹងខន្ធ ២ ... ជាបដិសន្ធិ ។ ចេតសិកធម៌ ប្រឡូកនឹងអចេតសិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ ជាបដិសន្ធិ ប្រឡូកនឹងចិត្ត ។ ចេតសិកធម៌ ប្រឡូកនឹងចេតសិកធម៌ផង នឹងអចេតសិកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡូកនឹងចេតសិកក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ៩៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមាន

វារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៩៧ ] ចេតសិកធម៌ ប្រឡូំនឹងចេតសិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺប្រស្នា ៥ យ៉ាង បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ក្នុងវារៈទាំង ៣ មានមោហៈដែរ ។ សេចក្តីបំប្រួញ ។

[ ៩៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនឈានប្បច្ច័យ មានវារៈ ៥ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ។

ការរាប់ ២ យ៉ាង ក្រៅពីនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ៩៩ ] ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយហេតុប្បច្ច័យ គឺពួកចេតសិកហេតុ ជាបច្ច័យ គឺជាបដិសន្ធិនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ ចេតសិកធម៌ជាបច្ច័យនៃអចេតសិកធម៌ ដោយហេតុប្បច្ច័យ គឺពួកចេតសិកហេតុជាបច្ច័យ គឺជាបដិសន្ធិនៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយហេតុប្បច្ច័យ គឺពួកចេតសិកហេតុ ជាបច្ច័យ គឺ

ជាបដិសន្ធិនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ១០០ ] ចេតសិកធម៌ជាបច្ច័យនៃចេតសិកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកចេតសិកក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកចេតសិកក្ខន្ធ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ ចិត្តកើតឡើងព្រោះប្រារព្ធនូវចេតសិកក្ខន្ធ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ ពួកចេតសិកក្ខន្ធក្តី ចិត្តក្តី កើតឡើង ព្រោះប្រារព្ធនូវពួកចេតសិកក្ខន្ធ ។ អចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈពិចារណានូវផល ពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទាន: មគ្គនិងផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... បុគ្គលឃើញច្បាស់នូវពួកអចេតសិកក្ខន្ធជាមិនទៀង ត្រេកអរ រីករាយ ចិត្តកើតឡើង ព្រោះប្រារព្ធនូវចេតសិកក្ខន្ធនោះ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយអចេតសិកចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ។បេ។ អាកិញ្ចញ្ញាយតនៈ ។បេ។ ពួកអចេតសិកក្ខន្ធជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ពិចារណានូវព្រះនិព្វាន ដូចដំណើរទី ១ ដែរ ។ នូវចក្ខុ... នូវវត្ថុ... នូវពួកអចេតសិកក្ខន្ធ ជាមិនទៀង ។បេ។

ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវពួកអចេតសិកក្ខន្ធ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ... អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ពួកអចេតសិកក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈពិចារណានូវព្រះនិព្វាន ដូចដំណើរទី ១ ដែរ ។ នូវចក្ខុ... នូវវត្ថុ... បុគ្គលឃើញច្បាស់នូវពួកអចេតសិកក្ខន្ធ ថាមិនទៀង ត្រេកអរ រីករាយ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវអចេតសិកក្ខន្ធនោះ ទិព្វ... សេចក្តីបំប្រួញ ។ រូបាយតនៈជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអារម្មណប្បច្ច័យ ផោដ្ឋព្វាយតនៈ... ពួកអចេតសិកក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃចេតសិកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកចេតសិកក្ខន្ធកើតឡើង ព្រោះប្រារព្ធនូវពួកចេតសិកក្ខន្ធផង នូវចិត្តផង ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ ចិត្តកើតឡើង ព្រោះប្រារព្ធនូវពួកចេតសិកក្ខន្ធផង នូវចិត្តផង ។ បណ្ឌិតគប្បី

សួរនូវមូលផងចុះ ពួកចេតសិកក្ខន្ធក្តី ចិត្តក្តី កើតឡើង ព្រោះប្រារព្ធនូវពួកចេតសិកក្ខន្ធផង នូវចិត្តផង ។

[ ១០១ ] ចេតសិកធម៌ជាបច្ច័យនៃចេតសិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកចេតសិកក្ខន្ធ កើតឡើងព្រោះធ្វើនូវចេតសិកក្ខន្ធ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺចេតសិកាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ អារម្មណាធិបតិ គឺចិត្តកើតឡើង ព្រោះធ្វើនូវចេតសិកក្ខន្ធ ឲ្យជាទីគោរព ឯសហជាតាធិបតិ គឺចេតសិកាធិបតិ ជាបច្ច័យនៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ អារម្មណាធិបតិ គឺពួកចេតសិកក្ខន្ធក្តី ចិត្តក្តី កើតឡើងព្រោះធ្វើនូវពួកចេតសិកក្ខន្ធ ឲ្យជាទីគោរព ឯសហជាតាធិបតិ គឺចេតសិកាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ អចេតសិកធម៌ជាបច្ច័យនៃអចេតសិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈធ្វើនូវព្រះនិព្វានឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គនិងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... បុគ្គលធ្វើនូវពួកអចេតសិកក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ចិត្តកើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ។ សហជាតាធិបតិ គឺអចេតសិកាធិបតិ ជា

បច្ច័យនៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ អ-
ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់
អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈធ្វើ
នូវព្រះនិព្វាន ឲ្យជាទីគោរព ... ដូចជំណើរទី ១ ដែរ ។ នូវចក្ខុ... នូវវត្ថុ...
បុគ្គលធ្វើនូវពួកអចេតសិកក្ខន្ធឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ
កើតឡើង ព្រោះធ្វើនូវអចេតសិកក្ខន្ធនោះឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។បេ។
ឯសហជាតាធិបតិ គឺអចេតសិកាធិបតិជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយ
អធិបតិប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេត-
សិកធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជា-
តាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ព្រះនិព្វាន... ដូចជំណើរទី ១
ដែរ ។ បុគ្គលធ្វើនូវពួកអចេតសិកក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីក
រាយ ពួកអចេតសិកក្ខន្ធក្តី ចិត្តក្តី កើតឡើងព្រោះធ្វើនូវអចេតសិកក្ខន្ធនោះ
ឲ្យជាទីគោរព ។ សហជាតាធិបតិ គឺអចេតសិកាធិបតិ ជាបច្ច័យនៃពួក
សម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។
ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃចេតសិកធម៌ ដោយអធិ-
បតិប្បច្ច័យ បានដល់ អារម្មណាធិបតិ ។ មានវារៈ ៣ ។ ជាអារម្មណា-
ធិបតិដដែល ។

[ ១០២ ] ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយអនន្តរប្បច្ច័យ
គឺពួកចេតសិកក្ខន្ធមុនៗ ជាបច្ច័យនៃពួកចេតសិកក្ខន្ធក្រោយៗ ដោយអនន្ត-

រប្បច្ច័យ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ ពួកចេតសិកក្ខន្ធមុនៗ ជាបច្ច័យនៃចិត្តក្រោយៗ ដោយអនន្តរប្បច្ច័យ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ ពួកចេតសិកក្ខន្ធមុនៗជាបច្ច័យនៃពួកចេតសិកក្ខន្ធក្រោយៗផង នៃចិត្តផង ដោយអនន្តរប្បច្ច័យ ។ អចេតសិកធម៌ជាបច្ច័យនៃអចេតសិកធម៌ ដោយអនន្តរប្បច្ច័យ គឺចិត្តមុនៗ ជាបច្ច័យនៃចិត្តក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោមជាបច្ច័យនៃគោត្រភូផង នៃផលសមាបត្តិផង ដោយអនន្តរប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយអនន្តរប្បច្ច័យ គឺមានវារៈ ៣ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ បណ្ឌិតគប្បីធ្វើឲ្យពេញដូចជំណើរទី ១ ចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃចេតសិកធម៌ ដោយអនន្តរប្បច្ច័យ គឺមានវារៈ ៣ អាវជ្ជនៈក្តី វុដ្ឋានក្តី មិនមានទេ ។ ជាបច្ច័យដោយសមនន្តរប្បច្ច័យ គឺមានវារៈ ៩ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបច្ចយវារៈដែរ ។

[ ១០៣ ] ចេតសិកធម៌ជាបច្ច័យនៃចេតសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកចេតសិកក្ខន្ធ ជាបច្ច័យនៃពួកចេតសិកក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ មានវារៈ ៣ ពួកចេតសិកក្ខន្ធ ជាឧបនិស្ស័យ ជាបច្ច័យនៃចិត្ត ដោយឧបនិស្សយប្បច្ច័យ ។

បណ្ឌិតគប្បីសួរនូវមូលផងចុះ មានវារៈ ៣ ពួកចេតសិកក្ខន្ធជាឧបនិស្ស័យ ជាបច្ច័យនៃពួកចេតសិកក្ខន្ធផង នៃចិត្តផង ដោយឧបនិស្សយប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បាន ដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯ បកតូបនិស្ស័យ គឺនូវវជ្ជៈ... នូវភោជន... នូវសេនាសនៈ... បុគ្គលអាស្រ័យនូវចិត្ត ហើយឲ្យនូវទាន ។បេ។ បំបែកនូវសង្ឃ វជ្ជៈ... ភោជន... សេនាសនៈ... ចិត្តជាបច្ច័យនៃសទ្ធា ។បេ។ នៃបញ្ញានិងរាគៈ ។បេ។ នៃ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និង បកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺនូវវជ្ជៈ... នូវភោជន... នូវ សេនាសនៈ... បុគ្គលអាស្រ័យនូវចិត្ត ហើយឲ្យនូវទាន មានវារៈ ៣ ដូច ដំណើរទី ១ ដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃចេតសិកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺមានវារៈ ៣ ។

[ ១០៤ ] អចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញនូវចក្ខុ... នូវវត្ថុ... ជាមិនទៀង ត្រេកអរ រីករាយ ចិត្តកើតឡើងព្រោះប្រារព្ធនូវវត្ថុនោះ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង

ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃចិត្ត ដោយបុរេជាតបច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយបុរេជាតបច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធដែលប្រឡំដោយកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធដែលប្រឡំដោយចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកចេតសិកក្ខន្ធ ដោយបុរេជាតបច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយបុរេជាតបច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញនូវចក្ខុ... នូវវត្ថុថាមិនទៀង ត្រេកអរ រីករាយ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ផោដ្ឋព្វាយតនៈ... ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង កាយាយតនៈ... វត្ថុ ជាបច្ច័យ

នៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។

[ ១០៥ ] ចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ អចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃអចេតសិកធម៌ ដោយបច្ឆាជាតប្បច្ច័យ ។

[ ១០៦ ] ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយអាសេវនប្បច្ច័យ ។

[ ១០៧ ] ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតសិកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតសិកចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និង នានាខណិកៈ ។ សហជាត គឺចេតសិកចេតនា ជាបច្ច័យនៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតសិកចេតនា ជាបច្ច័យនៃវិបាក ចិត្តផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ចេតសិកធម៌ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតសិកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតសិកចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធ

ផង នៃចិត្តផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ១០៨ ] ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយវិបាកប្បច្ច័យ គឺមានវារៈ ៩ ជាបច្ច័យដោយអាហារប្បច្ច័យ គឺមានវារៈ ៩ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ ៩ ជាបច្ច័យដោយឈានប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយមគ្គប្បច្ច័យ គឺមានវារៈ ៣ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ គឺមានវារៈ ៥ ។

[ ១០៩ ] ចេតសិកធម៌ជាបច្ច័យនៃអចេតសិកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ អចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺចិត្តជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ចិត្តជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ចិត្តជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃចិត្ត ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃចិត្ត ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺចិត្តជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកចេតសិកក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ( ជា

បច្ច័យ ) នៃពួកខន្ធ ដែលប្រទាំដោយចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកចេតសិកក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកចេតសិកក្ខន្ធផង នៃចិត្តផង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេ-ជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្ត-កក្ខន្ធផង កាយាយតនៈ... វត្ថុជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃអចេតសិកធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។

[ ១១០ ] ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយអត្ថិប្បច្ច័យ គឺមានវារៈ ១ ដូចបដិច្ចវារៈដែរ ។ ចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយអត្ថិប្បច្ច័យ គឺមានវារៈ ១ ដូចបដិច្ចវារៈដែរ ។ អចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ អចេតសិកធម៌ ជាបច្ច័យនៃចេត-សិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺចិត្ត ជាបច្ច័យនៃពួកចេតសិកក្ខន្ធ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ

ចិត្ត ។បេ។ ក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកចេតសិកក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ជាមិនទៀង... ដូចបុរេជាតប្បច្ច័យដែរ មិនមានផ្សេងៗគ្នាទេ ។ អចេតសិកធម៌ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺចិត្តជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ចិត្ត ។បេ។ ក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកចេតសិកក្ខន្ធផង នៃចិត្តផង ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ជាមិនទៀង... ដូចបុរេជាតប្បច្ច័យដែរ មិនមានផ្សេងៗគ្នាទេ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃចេតសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃខន្ធ ២ ដែលប្រកបដោយកាយវិញ្ញាណ... ចេតសិកក្ខន្ធ ១ ក្តី វត្ថុក្តី ចិត្តក្តី ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ នូវខន្ធ ២ ... ។ សហជាត គឺចេតសិកក្ខន្ធ ១ ក្តី វត្ថុក្តី ចិត្តក្តី ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ នូវខន្ធ ២ ... ឯវារៈទាំង ២ យ៉ាង បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃអចេតសិកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺពួកខន្ធដែលប្រកបដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ដែលប្រកបដោយកាយវិញ្ញាណ... ពួកចេតសិកក្ខន្ធក្តី ចិត្តក្តី ជា

បច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកចេតសិកក្ខន្ធក្តី ចិត្តក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ សហ-ជាត គឺពួកចេតសិកក្ខន្ធក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃចិត្ត ដោយអត្ថិប្បច្ច័យ សហជាត គឺពួកចេតសិកក្ខន្ធក្តី វត្ថុក្តី ជាបច្ច័យនៃចិត្ត ដោយអត្ថិប្បច្ច័យ វារៈ ៣ បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិផងចុះ ។ បច្ឆាជាត គឺពួកចេត-សិកក្ខន្ធក្តី ចិត្តក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាតគឺ ពួកចេតសិកក្ខន្ធក្តី ចិត្តក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកចេតសិកក្ខន្ធក្តី ចិត្តក្តី រូបជីវិ-តិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃខន្ធ ២ ផង នៃចក្ខុ-វិញ្ញាណផង ដោយអត្ថិប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយកាយវិញ្ញាណក្តី កាយាយតនៈក្តី ជាបច្ច័យនៃខន្ធ ២ ផង នៃកាយវិញ្ញាណផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហជាត គឺចេតសិកក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ផង នៃចិត្តផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... មានវារៈ ២ បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។

[ ១១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩

ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១២ ] ចេតសិកធម៌ជាបច្ច័យនៃចេតសិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ចេតសិកធម៌ជាបច្ច័យនៃអចេតសិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃអចេតសិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ

ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយ ឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ អចេតសិកធម៌ ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តីជាបច្ច័យនៃចេតសិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃអចេតសិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ចេតសិកធម៌ក្តី អចេតសិកធម៌ក្តី ជាបច្ច័យនៃចេតសិកធម៌ផង នៃអចេតសិកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១១៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ...

ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១១៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យមានវារៈ ៩ ។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

**ចប់ ចេតសិកទុកៈ ។**

# ចិត្តសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ១១៦ ] ចិត្តសម្បយុត្តធម៌ ( ធម៌ដែលប្រកបដោយចិត្ត ) អាស្រ័យនូវចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចិត្តសម្បយុត្តកខន្ធ ១ ខន្ធ ១ អាស្រ័យនូវខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ចិត្តវិប្បយុត្តធម៌ ( ធម៌ដែលប្រាសចាកចិត្ត ) អាស្រ័យនូវចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប

អាស្រ័យនូវពួកចិត្តសម្បយុត្តក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ចិត្តសម្បយុត្តធម៌ក្តី ចិត្តវិប្បយុត្តធម៌ក្តី អាស្រ័យនូវចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្តសម្បយុត្តក្ខន្ធ ១ នូវខន្ធ ២ ... ជាបដិសន្ធិ ។ ចិត្តវិប្បយុត្តធម៌ អាស្រ័យនូវចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមហាភូត ១ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកមហាភូត ក្នុងខណៈនៃបដិសន្ធិ មហាភូត ១ ... កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ចិត្តសម្បយុត្តធម៌ អាស្រ័យនូវចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកចិត្តសម្បយុត្តកក្ខន្ធ អាស្រ័យនូវវត្ថុ ។ ចិត្តសម្បយុត្តធម៌ក្តី ចិត្តវិប្បយុត្តធម៌ក្តី អាស្រ័យនូវចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកចិត្តសម្បយុត្តកក្ខន្ធ អាស្រ័យនូវវត្ថុ កដត្តារូប អាស្រ័យនូវពួកមហាភូត ។ ចិត្តសម្បយុត្តធម៌ អាស្រ័យនូវចិត្តសម្បយុត្តធម៌ផង នូវចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវចិត្តសម្បយុត្តក្ខន្ធ ១ ផង នូវវត្ថុផង នូវខន្ធ ២ ... ។ ចិត្តវិប្បយុត្តធម៌ អាស្រ័យនូវចិត្តសម្បយុត្តធម៌ផង នូវចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចិត្តសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យនូវពួកចិត្តសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង ។ ចិត្តសម្បយុត្តធម៌ក្តី ចិត្តវិប្បយុត្តធម៌ក្តី អាស្រ័យនូវ

ចិត្តសម្បយុត្តធម៌ផង នូវចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវចិត្តសម្បយុត្តកខន្ធ ១ ផង នូវវត្ថុផង នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវពួកចិត្តសម្បយុត្តកខន្ធផង នូវពួកមហាភូតផង ។

[ ១១៧ ] ចិត្តសម្បយុត្តធម៌ អាស្រ័យនូវចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចិត្តសម្បយុត្តកខន្ធ ១ នូវខន្ធ ២ ... ជាបដិសន្ធិ ។ ចិត្តសម្បយុត្តធម៌ អាស្រ័យនូវចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកចិត្តសម្បយុត្តកខន្ធ អាស្រ័យនូវវត្ថុ ។ ចិត្តសម្បយុត្តធម៌ អាស្រ័យនូវចិត្តសម្បយុត្តធម៌ផង នូវចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវចិត្តសម្បយុត្តកខន្ធ ១ ផង នូវវត្ថុផង នូវខន្ធ ២ ... សេចក្តីបំប្រួញ ។

[ ១១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ

ឈានប្បច្ច័យនិងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៩ ] ចិត្តសម្បយុត្តធម៌ អាស្រ័យនូវចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាចិត្តសម្បយុត្តនូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ឯប្រស្នាទាំង ៩ អ្នកប្រាជ្ញ គប្បីធ្វើយ៉ាងនេះចុះ បទថា អហេតុកៈ ដូច្នេះ បណ្ឌិតគប្បីកំណត់ ក្នុងបច្ច័យទាំងពួងមោហៈមូលមានតែ ១ គត់ បណ្ឌិតគប្បីបំពេញចុះ ។

[ ១២០ ] ចិត្តវិប្បយុត្តធម៌ អាស្រ័យនូវចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាបដិសន្ធិ អាស្រ័យនូវពួកចិត្តសម្បយុត្តក្ខន្ធ ។ ចិត្តវិប្បយុត្តធម៌ អាស្រ័យនូវចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺមហាភូត ១ រហូតដល់ពួកអសញ្ញសត្វ ។ ចិត្តវិប្បយុត្តធម៌ អាស្រ័យនូវចិត្តសម្បយុត្តធម៌ផង នូវចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចិត្តសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង មានវារៈ ១ ក្នុងខណៈនៃបដិសន្ធិ សេចក្តីបំប្រួញ ។

[ ១២១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១២២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១២៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ

មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈ ដូចបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ១២៨ ] ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចបដិច្ចវារៈដែរ ។ ចិត្តវិប្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ១ ... ដូចបដិច្ចវារៈដែរ ។ ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកចិត្តសម្បយុត្តកក្ខន្ធជាបដិសន្ធិ ពឹងផ្អែកនឹងវត្ថុ ។ ចិត្តសម្បយុត្តធម៌ក្តី ចិត្តវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូបជាបដិសន្ធិ ពឹងផ្អែកនឹងពួកមហាភូត ។ ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តសម្បយុត្តធម៌ផង នឹងចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងចិត្តសម្បយុត្តកក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។ ចិត្តវិប្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តសម្បយុត្តធម៌ផង នឹងចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបជាបដិសន្ធិ ពឹងផ្អែកនឹងពួកចិត្តសម្បយុត្តកក្ខន្ធផង នឹងពួកមហាភូតផង ។ ចិត្តសម្បយុត្តធម៌ក្តី ចិត្តវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងចិត្តសម្បយុត្តធម៌ផង នឹងចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងចិត្តសម្បយុត្តក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូបជាបដិសន្ធិ ពឹងផ្អែកនឹងពួកចិត្តសម្បយុត្តក្ខន្ធ ផង នឹងពួកមហាភូតផង ។

[ ១២៥ ] ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ ១ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រឡំដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ... ពួកចិត្តសម្បយុត្តកក្ខន្ធ ជាបដិសន្ធិ ពឹងផ្អែកនឹងវត្ថុ ។ ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តសម្បយុត្តធម៌ផង នឹងចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ដែលប្រឡំដោយកាយវិញ្ញាណ... ខន្ធ ២ ពឹងផ្អែកនឹងចិត្តសម្បយុត្តក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ សេចក្តីបំប្រួញ ។

[ ១២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុង

អវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១២៧ ] ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ចិត្ត-វិប្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តវិប្បយុត្តធម៌ ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺមហាភូត ១ រហូតដល់ពួកអសញ្ញសត្វ ។ ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកខន្ធដែលប្រឡំដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ... ពួកអហេតុកក្ខន្ធ ជាចិត្តសម្បយុត្ត ជាបដិសន្ធិ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ ចិត្តសម្បយុត្តធម៌ក្តី ចិត្តវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងចិត្តវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកអហេតុកក្ខន្ធ ជាចិត្តសម្បយុត្ត ពឹងផ្អែកនឹងវត្ថុ ចិត្ត-សមុដ្ឋានរូបជាបដិសន្ធិ ពឹងផ្អែកនឹងពួកមហាភូត ។ ចិត្តសម្បយុត្តធម៌ ពឹងផ្អែកនឹងចិត្តសម្បយុត្តធម៌ផង នឹងចិត្តវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ពឹងផ្អែកនឹងខន្ធ ១ ដែលប្រឡំដោយកាយវិញ្ញាណផង នឹងកាយាយតនៈផង ... ខន្ធ ២ ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ជាចិត្តសម្បយុត្តផង នឹងវត្ថុផង នឹងខន្ធ ២ ... ក្នុងខណៈនៃអហេតុកបដិសន្ធិ មោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នឹងវត្ថុ

ផង ។ ប្រស្នា ២ យ៉ាង និងបវត្តិប្បដិសន្ធិ អ្នកប្រាជ្ញគប្បីធ្វើយ៉ាងនេះចុះ ។ សេចក្តីបំប្រួញ ។

[ ១២៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១២៩ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៣០ ] ក្នុងអារម្មណប្បច្ច័យមានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។បេ។ ... ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ។បេ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

និស្សយវារៈ ដូចគ្នានឹងបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ១៣១ ] ចិត្តសម្បយុត្តធម៌ ប្រឡូំនឹងចិត្តសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡូំនឹងចិត្តសម្បយុត្តកខន្ធ ១ នឹងខន្ធ ២ ... ជាបដិសន្ធិ ។

[ ១៣២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៣៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។

ការរាប់ទាំង ២ យ៉ាងក្រៅពីនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ១៣៤ ] ចិត្តសម្បយុត្តធម៌ ជាបច្ច័យនៃចិត្តសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកចិត្តសម្បយុត្តហេតុជាបច្ច័យ គឺជាបដិសន្ធិនៃពួកសម្បយុត្តកខន្ធ ដោយហេតុប្បច្ច័យ ។ ចិត្តសម្បយុត្តធម៌ ជាបច្ច័យនៃចិត្តវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកចិត្តសម្បយុត្តហេតុ ជាបច្ច័យ គឺជា

បដិសន្ធិនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ ចិត្តសម្បយុត្តធម៌ ជាបច្ច័យនៃចិត្តសម្បយុត្តធម៌ផង នៃចិត្តវិប្បយុត្តធម៌ផង ដោយហេតុប្បច្ច័យ គឺពួកចិត្តសម្បយុត្តហេតុ ជាបច្ច័យ គឺជាបដិសន្ធិ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ១៣៥ ] ចិត្តសម្បយុត្តធម៌ ជាបច្ច័យនៃចិត្តសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន... នូវសីល... បុគ្គលធ្វើនូវឧបោសថកម្ម ពិចារណានូវឧបោសថកម្មនោះ ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះប្រារព្ធនូវពួកកុសលនោះ ទោមនស្សកើតឡើង នូវពួកកុសល ដែលសន្សំហើយ ក្នុងកាលមុន... ចេញអំពីឈាន នូវឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណានូវមគ្គ ពិចារណានូវផល នូវពួកកិលេសដែលលះបង់ហើយ... ពិចារណានូវពួកកិលេស ដែលសង្កត់សង្កិនហើយ ដឹងនូវពួកកិលេសដែលធ្លាប់សន្សំហើយក្នុងកាលមុន នូវពួកចិត្តសម្បយុត្តក្ខន្ធ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយចិត្តសម្បយុត្តធម៌ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ ពួកចិត្តសម្បយុត្តក្ខន្ធជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ចិត្តវិប្បយុត្តធម៌ ជាបច្ច័យនៃចិត្តសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះ

អរិយៈ ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គនិងផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... នូវចិត្តវិប្បយុត្តក្ខន្ធ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធដែលប្រចាំដោយចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ពួកចិត្តវិប្បយុត្តក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ១៣៦ ] ចិត្តសម្បយុត្តធម៌ ជាបច្ច័យនៃចិត្តសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន... នូវសីល... នូវឧបោសថកម្ម... ធ្វើនូវកុសលនោះឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវកុសលនោះឲ្យជាទីគោរព ទិដ្ឋិកើតឡើង ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គ ឲ្យជាទីគោរព... ធ្វើនូវផល ឲ្យជាទីគោរព ហើយពិចារណា បុគ្គលធ្វើនូវពួកចិត្តសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺចិត្តសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ចិត្តសម្បយុត្តធម៌ ជាបច្ច័យនៃចិត្តវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺចិត្ត-

សម្បយុត្តាធិបតិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ ចិត្តសម្បយុត្តធម៌ ជាបច្ច័យនៃចិត្តសម្បយុត្តធម៌ផង នៃចិត្តវិប្បយុត្តធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺចិត្តសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ចិត្តវិប្បយុត្តធម៌ ជាបច្ច័យនៃចិត្តសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកព្រះអរិយៈ ធ្វើនូវព្រះនិព្វានឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... បុគ្គលធ្វើនូវពួកចិត្តវិប្បយុត្តក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។

[ ១៣៧ ] ចិត្តសម្បយុត្តធម៌ ជាបច្ច័យនៃចិត្តសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកចិត្តសម្បយុត្តក្ខន្ធមុនៗ ។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ ជាបច្ច័យដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺប្រស្នា ៧ ដូចគ្នានឹងបដិច្ចវារៈដែរ តំណាមិនមានទេ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានប្រស្នា ៦ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានប្រស្នា ៧ ដូចគ្នានឹងបច្ចយវារៈដែរ តំណាមិនមានទេ ។

[ ១៩១ ] ចិត្តសហភុធម៌ អាស្រ័យនូវចិត្តសហភុធម៌ ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបជាចិត្តសហភុក្តី អាស្រ័យនូវចិត្តសហភុក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ បញ្ហាទាំង ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ គប្បីកំណត់ថាជាអហេតុកៈដែលធ្លាប់មានក្នុងអនុលោម

យ៉ាងណា ត្រូវធ្វើយ៉ាងនោះចុះ វារៈ ៣ និងមោហៈ បណ្ឌិតគប្បីធ្វើឲ្យដូច ក្នុងចិត្តសមុដ្ឋានទុកៈដែរ ។

[ ១៩២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន វារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ។

[ ១៩៣ ] ចិត្តសហភុធម៌ អាស្រ័យនូវចិត្តសហភុធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចិត្តសហភុចេតនា អាស្រ័យនូវពួកចិត្តសហភុក្ខន្ធ ។ នោចិត្តសហភុធម៌ អាស្រ័យនូវនោចិត្តសហភុធម៌ ទើបកើតឡើង ព្រោះ នកម្មប្បច្ច័យ គឺពាហិរៈ... អាហារ... រដូវ... ។ ចិត្តសហភុធម៌ អាស្រ័យ នូវនោចិត្តសហភុធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តក- ចេតនា អាស្រ័យនូវចិត្ត ។ ចិត្តសហភុធម៌ អាស្រ័យនូវចិត្តសហភុធម៌ផង នូវនោចិត្តសហភុធម៌ផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តក- ចេតនា អាស្រ័យនូវពួកចិត្តសហភុក្ខន្ធផង នូវចិត្តផង ។

[ ១៩៤ ] ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ។

[ ១៩៥ ] ចិត្តសហភុធម៌ អាស្រ័យនូវចិត្តសហភុធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺដែលប្រកបដោយបញ្ចវិញ្ញាណ ។បេ។

[ ១៩៦ ] ក្នុងឈានប្បច្ច័យ មានវារៈ ៦ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ការរាប់ ២ យ៉ាងក្រៅពីនេះ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

សហជាតវារៈ ដូចបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ១៩៧ ] ចិត្តសហភូធម៌ ពឹងផ្អែកនឹងចិត្តសហភូធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចបដិច្ចវារៈដែរ ។ នោចិត្តសហភូធម៌ ពឹងផ្អែកនឹងនោចិត្តសហភូធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ជានោចិត្តសហភូនិងបដិសន្ធិ ពឹងផ្អែកនឹងចិត្ត ពួកមហាភូតទាំងអស់ ដូចបដិច្ចវារៈដែរ ។ ចិត្តសហភូធម៌ ពឹងផ្អែកនឹងនោចិត្តសហភូធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូប ជាចិត្តសហភូក្តី ពឹងផ្អែកនឹងចិត្ត ពួកចិត្តសហភូក្ខន្ធនិងបដិសន្ធិ ពឹងផ្អែកនឹងវត្ថុ ពួកមហាភូតទាំងអស់ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ចិត្តសហភូធម៌ក្តី នោចិត្តសហភូធម៌ក្តី ពឹងផ្អែកនឹងនោចិត្តសហភូធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធនិងចិត្តសមុដ្ឋានរូប ជាចិត្តសហភូនិងជានោចិត្តសហភូ ពឹងផ្អែកនឹងចិត្ត ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធ

ក្តី ពឹងផ្អែកនឹងវត្ថុ បដិសន្ធិ ពួកមហាភូតទាំងអស់ ដូចបដិច្ចវារៈដែរ ។ ចិត្តសហភុធម៌ពឹងផ្អែកនឹងចិត្តសហភុធម៌ផង នឹងនោចិត្តសហភុធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូប ជាចិត្តសហភុក្តី ពឹងផ្អែកនឹងចិត្តសហភុក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ខន្ធ ២ ពឹងផ្អែកនឹងចិត្តសហភុក្ខន្ធ ១ ផង នឹងវត្ថុផង ខន្ធ ២ ... បដិសន្ធិ ពួកមហាភូតទាំងអស់ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នោចិត្តសហភុធម៌ ពឹងផ្អែកនឹងចិត្តសហភុធម៌ផង នឹងនោចិត្តសហភុធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺជាចិត្តសមុដ្ឋានរូប ជានោចិត្តសហភុ ពឹងផ្អែកនឹងពួកចិត្ត-សហភុក្ខន្ធផង នឹងចិត្តផង ចិត្តពឹងផ្អែកនឹងពួកចិត្តសហភុក្ខន្ធផង នឹងវត្ថុផង ចិត្តសមុដ្ឋានរូបជានោចិត្តសហភុ ពឹងផ្អែកនឹងពួកចិត្តសហភុក្ខន្ធផង នឹងពួកមហាភូតផង បដិសន្ធិ ពួកមហាភូតទាំងអស់ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ចិត្តសហភុធម៌ក្តី នោចិត្តសហភុធម៌ក្តី ពឹងផ្អែកនឹងចិត្តសហភុធម៌ផង នឹងនោចិត្តសហភុធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្ត-សមុដ្ឋានរូបជាចិត្តសហភុនិងជានោចិត្តសហភុក្តី ពឹងផ្អែកនឹងចិត្ត សហភុក្ខន្ធ ១ ផង នឹងចិត្តផង ខន្ធ ២ ក្តី ចិត្តក្តី ពឹងផ្អែកនឹងចិត្តសហភុក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... បដិសន្ធិ ពួកមហាភូតទាំងអស់ ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ១៩៨ ] ចិត្តសហភុធម៌ ពឹងផ្អែកនឹងចិត្តសហភុធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ ៣ ដូចបដិច្ចវារៈដែរ ។ នោចិត្តសហ-

កុសលធម៌ ពឹងផ្អែកនឹងនោចិត្តសហភុធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយាយតនៈ... ។ បទនេះ ដូចគ្នានឹងអារម្មណប្បច្ច័យ ក្នុងបច្ចយវារៈ ត្រង់ចិត្តសមុដ្ឋានទុកៈដែរ ឯពួកបញ្ចវិញ្ញាណមូលបណ្ឌិតគប្បីធ្វើដោយអំណាចនៃវារៈទាំង ៦ នេះចុះ ។ សេចក្តីបំប្រួញ ។

[ ១៩៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ គ្រប់បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២០០ ] ចិត្តសហភុធម៌ពឹងផ្អែកនឹងចិត្តសហភុធម៌ ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺចិត្តសហភុក្ខន្ធ ១ ជាអហេតុកៈ... ។ សេចក្តីបំប្រួញ ។ បញ្ចវិញ្ញាណនៃបច្ចយវារៈទាំងអស់ បណ្ឌិតគប្បីធ្វើចុះ មូលនៃវារៈទាំង ៦ មហាភូតទាំងអស់ មានវារៈ ៣ និងមោហៈ បណ្ឌិតគប្បីធ្វើចុះ ។ សេចក្តីបំប្រួញ ។

[ ២០១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យមានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហា-

វប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២០២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ... ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២០៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ គ្រប់បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

និស្សយវារៈដូចបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ២០៤ ] ចិត្តសហភុធម៌ ប្រឡូកនឹងចិត្តសហភុធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡូកនឹងចិត្តសហភុក្ខន្ធ ១ នឹងខន្ធ ២ ... ជាបដិសន្ធិ ។ នោចិត្តសហភុធម៌ប្រឡូកនឹងចិត្តសហភុធម៌ ទើបកើតឡើង ព្រោះគឺចិត្តជាបដិសន្ធិ ប្រឡូកនឹងពួកចិត្តសហភុក្ខន្ធ ។ ចិត្តសហភុធម៌ក្តី នោចិត្ត-

សហកុជម៌ក្តី ប្រទ្បំនឹងចិត្តសហកុជម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ប្រទ្បំនឹងចិត្តសហកុក្ខន្ធ ១ នឹងខន្ធ ២ ... ជាបដិសន្ធិ ។ ចិត្តសហកុជម៌ប្រទ្បំនឹងនោចិត្តសហកុជម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ ជាបដិសន្ធិ ប្រទ្បំនឹងចិត្ត ។ ចិត្តសហកុជម៌ ប្រទ្បំនឹងចិត្តសហកុជម៌ផង នឹងនោចិត្តសហកុជម៌ផង ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ គឺខន្ធ ២ ប្រទ្បំនឹងចិត្តសហកុក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ២០៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ២០៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក៏មាន មានវារៈ ៣ ក៏មាន ហើយមានមោហៈដែរ ។ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបា-កប្បច្ច័យ មានវារៈ ៥ ក្នុងនឈានប្បច្ច័យ មានវារៈ ៥ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ។ ក្រៅនេះ ការរាប់ទាំង ២ យ៉ាងក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើទាំងអស់ចុះ ។

# បញ្ហាវារៈ

[ ២០៧ ] ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ ដោយហេតុប្បច្ច័យ គឺពួកចិត្តសហភុហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាចិត្តសហភុផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ចិត្តសហភុធម៌ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយហេតុប្បច្ច័យ គឺពួកចិត្តសហភុហេតុ ជាបច្ច័យនៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបជានោចិត្តសហភុផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តសហភុហេតុ ជាបច្ច័យនៃចិត្តផង នៃពួកកដត្តារូបផង ដោយហេតុប្បច្ច័យ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ផង នៃនោចិត្តសហភុធម៌ផង ដោយហេតុប្បច្ច័យ គឺពួកចិត្តសហភុហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបជាចិត្តសហភុនិងជានោចិត្តសហភុផង ដោយហេតុប្បច្ច័យ ។

[ ២០៨ ] ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ ដោយអារម្មណប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងចិត្តសមុដ្ឋានទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

[ ២០៩ ] ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ ដោយអធិបតិប្បច្ច័យ គឺមានវារៈ ៣ ឯអារម្មណាធិបតិក្តី សហជាតាធិបតិក្តី បណ្ឌិតគប្បីធ្វើចុះ ។ នោចិត្តសហភុធម៌ ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយអធិបតិប្បច្ច័យ គឺមានវារៈ ៣ អារម្មណាធិបតិក្តី សហជាតាធិបតិក្តី ប្រស្នាទាំង ៩ ក្តី ដូចចិត្តសមុដ្ឋានរូបដែរ បណ្ឌិតគប្បីធ្វើ ( ដោយអំណាច ) នៃវារៈទាំង ៣ ចុះ ក្នុងទីបំផុតមានវារៈ ៣ ហើយជាអារម្មណាធិបតិដដែល ។

[ ២១០ ] ចិត្តសហភូធម៌ ជាបច្ច័យនៃចិត្តសហភូធម៌ ដោយអនន្តរប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងចិត្តសមុដ្ឋានទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ ជាបច្ច័យដោយសមនន្តរប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបច្ចយវារៈដែរ ។ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងចិត្តសមុដ្ឋានទុកៈដែរ ។

[ ២១១ ] នោចិត្តសហភូធម៌ ជាបច្ច័យនៃនោចិត្តសហភូធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ហើយមានវារៈ ៣ ។ នោចិត្តសហភូមូល បណ្ឌិតតែងបានពិតប្រាកដ មានវារៈ ៣ ដូចគ្នានឹងចិត្តសមុដ្ឋានទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

[ ២១២ ] ចិត្តសហភូធម៌ ជាបច្ច័យនៃនោចិត្តសហភូធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកចិត្តសហភូក្ខន្ធ ជាបច្ច័យនៃនោចិត្តសហភូកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ នោចិត្តសហភូធម៌ ជាបច្ច័យនៃនោចិត្តសហភូធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ ចិត្តសហភូធម៌ក្តី នោចិត្តសហភូធម៌ក្តីជាបច្ច័យនៃនោចិត្តសហភូធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ ជាបច្ច័យដោយអាសេវនប្បច្ច័យ គឺមានវារៈ ៩ ។

[ ២១៣ ] ចិត្តសហភូធម៌ ជាបច្ច័យនៃចិត្តសហភូធម៌ ដោយកម្មប្បច្ច័យ

បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចិត្តសហភុចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ជាចិត្តសហភុផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចិត្តសហភុចេតនា ជាបច្ច័យនៃពួកចិត្តសហភុក្ខន្ធ ជាវិបាក ដោយកម្មប្បច្ច័យ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាតនិងនានាខណិកៈ ។ ឯសហជាត គឺចិត្តសហភុចេតនា ជាបច្ច័យនៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូប ជានោចិត្តសហភុផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចិត្តសហភុ-ចេតនា ជាបច្ច័យនៃវិបាកចិត្តផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ផង នៃនោចិត្តសហភុធម៌ផង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចិត្តសហភុចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូប ជាចិត្តសហភុនិងជានោចិត្តសហភុផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចិត្តសហភុចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃចិត្តផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ២១៤ ] ចិត្តសហភុធម៌ជាបច្ច័យនៃចិត្តសហភុធម៌ ដោយវិបាកប្បច្ច័យ គឺដូចគ្នានឹងចិត្តសមុដ្ឋានទុកៈដែរ ។ ជាបច្ច័យដោយអាហារប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងចិត្តសមុដ្ឋានទុកៈដែរ ឯចិត្តសមុដ្ឋានទុកៈ ១ នេះ ដូចគ្នានឹងកពឡិង្ការាហារដែរ ។

[ ២១៥ ] ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ ដោយឥន្ទ្រិ-

យប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងចិត្តសមុដ្ឋានទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៣ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៣ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៥ ។

[ ២១៦ ] ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត គឺពួកចិត្តសហភុក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូបជាចិត្តសហភុ ដោយវិប្បយុត្តប្បច្ច័យ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺពួកចិត្តសហភុក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូបជានោចិត្តសហភុ ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។ ឯបច្ឆាជាត គឺពួកចិត្តសហភុក្ខន្ធ ជាបច្ច័យនៃនោចិត្តសហភុកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ផង នៃនោចិត្តសហភុធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត គឺពួកចិត្តសហភុក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាចិត្តសហភុ និងជានោចិត្តសហភុ ដោយវិប្បយុត្តប្បច្ច័យ ។ នោចិត្តសហភុធម៌ ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺចិត្តជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជានោចិត្តសហភុ ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ចិត្តជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ចិត្តជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃចិត្ត ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ជា

បច្ច័យនៃចក្ខុវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈ... វត្ថុជាបច្ច័យនៃចិត្ត ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺចិត្តជាបច្ច័យនៃនោចិត្ត-សហភូកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ នោចិត្តសហភូធម៌ជាបច្ច័យនៃចិត្តសហភូធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺចិត្តជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាចិត្តសហភូ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃពួកខន្ធដែលប្រឡំដោយចក្ខុវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកចិត្តសហភូក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ នោចិត្តសហភូធម៌ជាបច្ច័យនៃចិត្តសហភូធម៌ផង នៃនោចិត្តសហភូធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាតិ ។ សហជាតិ គឺចិត្តជាបច្ច័យនៃពួកចិត្ត-សមុដ្ឋានរូប ជាចិត្តសហភូនិងជានោចិត្តសហភូ ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈ... វត្ថុជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ចិត្តសហភូធម៌ក្តី នោចិត្តសហភូធម៌ក្តី ជាបច្ច័យនៃចិត្តសហភូធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត គឺពួកចិត្តសហភូក្ខន្ធក្តី ចិត្តក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាចិត្តសហភូ ដោយវិប្បយុត្តប្បច្ច័យ ។ ចិត្ត-សហភូធម៌ក្តី នោចិត្តសហភូធម៌ក្តី ជាបច្ច័យនៃនោចិត្តសហភូធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួក

ចិត្តសហភុក្ខន្ធក្តី ពួកនោចិត្តសហភុក្ខន្ធក្តី ចិត្តក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូបជានោចិត្តសហភុ ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។ ឯបច្ឆាជាត គឺពួកចិត្តសហភុក្ខន្ធក្តី ពួកនោចិត្តសហភុក្ខន្ធក្តី ជាបច្ច័យនៃនោចិត្តសហភុកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ចិត្តសហភុធម៌ក្តី នោចិត្តសហភុធម៌ក្តី ជាបច្ច័យនៃចិត្តសហភុធម៌ផង នោចិត្តសហភុធម៌ផង ដោយវិប្បយុត្តប្បច្ច័យ គឺពួកចិត្តសហភុក្ខន្ធក្តី ពួកនោចិត្តសហភុក្ខន្ធក្តី ចិត្តក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាចិត្តសហភុនិងជានោចិត្តសហភុ ដោយវិប្បយុត្តប្បច្ច័យ ។

[ ២១៧ ] ចិត្តសហភុធម៌ជាបច្ច័យនៃចិត្តសហភុធម៌ ដោយអត្ថិប្បច្ច័យ គឺចិត្តសហភុក្ខន្ធ ១ ... ដូចបដិច្ចវារៈដែរ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ផង នៃនោចិត្តសហភូធម៌ផង ដោយអត្ថិប្បច្ច័យ គឺចិត្តសហភុក្ខន្ធ ១ ... ដូចបដិច្ចវារៈដែរ ។ នោចិត្តសហភុធម៌ ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ នោចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ នោចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ផង នៃនោចិត្តសហភុធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សេចក្តីបំប្រួញ ។ ចិត្តសហភុធម៌ក្តី នោចិត្តស-

ហាកុធម៌ក្តី ជាបច្ច័យនៃចិត្តសហាកុធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហ-ជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ចក្ខុវិញ្ញាណក្តី ( ជាបច្ច័យ ) នៃខន្ធ ២ ... បទទាំងអស់ ជាសហជាតនិងបុរេជាត បណ្ឌិតគប្បីធ្វើក្នុងបដិសន្ធិចុះ ។ ចិត្តសហាកុធម៌ក្តី នោចិត្តសហាកុធម៌ក្តី ជាបច្ច័យនៃនោចិត្តសហាកុធម៌ ដោយអត្ថិប្បច្ច័យ បាន ដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺ ពួកខន្ធដែលប្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអត្ថិប្បច្ច័យ ដែលប្រឡំដោយកាយវិញ្ញាណ... ពួកចិត្តសហាភុក្ខន្ធក្តី ចិត្តក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូបជានោចិត្តសហាកុ ដោយអត្ថិប្បច្ច័យ ។ សហជាត គឺពួកចិត្តសហាកុធម៌ក្តី វត្ថុក្តី ជាបច្ច័យនៃចិត្ត ដោយអត្ថិប្បច្ច័យ ។ សហជាត គឺពួកចិត្តសហាភុក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្ត-សមុដ្ឋានរូប ជានោចិត្តសហាកុ ដោយអត្ថិប្បច្ច័យ វារៈ ៣ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ បច្ឆាជាត គឺពួកចិត្តសហាភុក្ខន្ធ ពួកនោចិត្ត-សហាភុក្ខន្ធក្តី ជាបច្ច័យនៃនោចិត្តសហាកុកាយនេះ ដែលកើតមុន ដោយ អត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកចិត្តសហាភុក្ខន្ធក្តី ពួកនោចិត្តសហាភុក្ខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃនោចិត្តសហាកុកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកចិត្តសហាភុក្ខន្ធក្តី ពួកនោចិត្តសហាភុក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ចិត្តសហាកុធម៌ក្តី នោចិត្ត-សហាកុធម៌ក្តី ជាបច្ច័យនៃចិត្តសហាកុធម៌ផង នៃនោចិត្តសហាកុធម៌ផង ដោយ

អត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណក្ដី ចក្ខាយតនៈក្ដី... ដូចគ្នានឹងបច្ចយវារៈដែរ ។

[ ២១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២១៩ ] ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជា

បច្ច័យដោយកម្មប្បច្ច័យ ។ ចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ផង នៃនោចិត្តសហភុធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ នោចិត្តសហភុធម៌ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នោចិត្តសហភុធម៌ជាបច្ច័យនៃចិត្តសហភុធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នោចិត្តសហភុធម៌ ជាបច្ច័យនៃចិត្តសហភុធម៌ផងនិងនោចិត្តសហភុធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ចិត្តសហភុធម៌ក្តី នោចិត្តសហភុធម៌ក្តី ជាបច្ច័យនៃចិត្តសហភុធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ចិត្តសហភុធម៌ក្តី នោចិត្តសហភុធម៌ក្តី ជាបច្ច័យនៃនោចិត្តសហភុធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ចិត្តសហភុធម៌ក្តី នោចិត្តសហភុធម៌ក្តី ជាបច្ច័យនៃចិត្តសហភុធម៌ផង នៃនោចិត្តសហភុធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយ

ឧបនិស្សយប្បច្ច័យ ។

[ ២២០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២២១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យមានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២២២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។

អនុលោមមាតិកា បណ្ឌិតគប្បីធ្វើចុះ ។

**ចប់ ចិត្តសហភុទុកៈ ។**

# ចិត្តានុបរិវត្តិទុកៈ

## បដិច្ចវារៈ

[ ២២៣ ] ចិត្តានុបរិវត្តិធម៌ ( ធម៌ប្រព្រឹត្តទៅតាមចិត្ត ) អាស្រ័យនូវ

ចិត្តានុបរិវត្តិធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូប ជាចិត្តានុបរិវត្តិក្តី អាស្រ័យនូវចិត្តានុបរិវត្តិក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ចិត្តសហភូទុកៈយ៉ាងណា ចិត្តានុបរិវត្តិទុកៈនេះ បណ្ឌិតគប្បីធ្វើយ៉ាងនោះដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

# ចិត្តសំសដ្ឋសមុដ្ឋានទុកៈ

## បដិច្ចវារៈ

[ ២២៤ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ( ធម៌ច្រឡំដោយចិត្តនិងតាំងឡើងដោយចិត្ត ) អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ខន្ធ ១ អាស្រ័យនូវខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ។បេ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ( ធម៌មិនមែនច្រឡំដោយចិត្ត និងមិនមែនតាំងឡើងព្រោះចិត្ត ) អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី កដត្តារូបក្តី អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ នូវខន្ធ ២ ... ជាបដិសន្ធិ ។

នោចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ កដត្តារូបអាស្រ័យនូវចិត្ត វត្ថុអាស្រ័យនូវចិត្ត ចិត្តអាស្រ័យនូវវត្ថុ មហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ អាស្រ័យនូវវត្ថុ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី អាស្រ័យនូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបក្តី អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នូវវត្ថុផង នូវខន្ធ ២ ... ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវចិត្តសំសដ្ឋស-

មុដ្ឋានធម៌ផង នូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវចិត្តផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យនូវពួកចិត្តសំ-សដ្ឋសមុដ្ឋានក្ខន្ធផង នូវចិត្តផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូបអាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវវត្ថុផង ។ ចិត្តសំសដ្ឋ-សមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី អាស្រ័យនូវចិត្តសំសដ្ឋស-មុដ្ឋានធម៌ផង នូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្តសំសដ្ឋ-សមុដ្ឋានក្ខន្ធផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវចិត្តសំសដ្ឋសមុ-ដ្ឋានក្ខន្ធ ១ ផង នូវវត្ថុផង នូវខន្ធ ២ ... ។ សេចក្តីបំប្រួញ ។

[ ២២៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុង

អាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ គ្រប់បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២២៦ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី ជាអហេតុកប្បដិសន្ធិ អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ជាអហេតុកៈ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ជាអហេតុកប្បដិសន្ធិ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវអហេតុកចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូបអាស្រ័យនូវចិត្ត វត្ថុ អាស្រ័យនូវចិត្ត ចិត្តអាស្រ័យនូវវត្ថុ មហាភូត ១ រហូតដល់ពួកអសញ្ញសត្វ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង

ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវអហេតុកចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ អាស្រ័យនូវវត្ថុ មោហៈដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវចិត្ត ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី អាស្រ័យនូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបក្តី អាស្រ័យនូវចិត្ត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នូវនោចិត្ត សំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវអហេតុកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នូវចិត្តផង... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នូវវត្ថុផង នូវខន្ធ ២ ... មោហៈដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈផង នូវចិត្តផង ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប

អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ជាអហេតុកៈផង នូវចិត្តផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវអហេតុកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវចិត្តផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តអាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវវត្ថុផង ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ជាអហេតុកៈផង នូវចិត្តផង នូវខន្ធ ២ ... វារៈ ២ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃអហេតុកប្បដិសន្ធិចុះ ។

[ ២២៧ ] នោចិត្តសំសដ្ឋសមុដ្ឋានធម៌អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាបដិសន្ធិ អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ កដត្តារូបអាស្រ័យនូវចិត្ត វត្ថុអាស្រ័យនូវចិត្ត មហាភូត ១ រហូតដល់ពួកអសញ្ញសត្វ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នូវនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ

ចិត្តសមុដ្ឋានរូបអាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវចិត្តផង ចិត្ត-សមុដ្ឋានរូប អាស្រ័យនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នូវពួកកូតផង វារៈ ២ បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។ សេចក្តីបំប្រួញ ។

[ ២២៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៦ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២២៩ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបំប្រួញ ។

[ ២៣០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។ សហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ ។

# បច្ចយវារៈ

[ ២៣១ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សេចក្តីបំប្រួញ ។ មានវារៈ ៣ ដូចបដិច្ចវារៈដែរ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ពឹងផ្អែកនឹងនោចិត្តសំសដ្ឋ-សមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងចិត្ត ចិត្តពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ មានរហូតដល់ពួកមហា-ភូត ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ពឹងផ្អែកនឹងនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងចិត្ត ពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ពឹងផ្អែកនឹងវត្ថុ វារៈ ២ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នឹងនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង និងចិត្តផង នឹងខន្ធ ២ ... ខន្ធ ២ ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... វារៈ ២ បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។ នោចិត្តសំសដ្ឋសមុដ្ឋាន-ធម៌ ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នឹងនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺនោចិត្តសំសដ្ឋសមុដ្ឋានរូប ពឹងផ្អែកនឹងពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នឹងចិត្តផង នោចិត្តសំសដ្ឋសមុដ្ឋាន-រូប ពឹងផ្អែកនឹងពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នឹងពួកមហាភូតផង ចិត្តពឹងផ្អែកនឹងពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នឹងវត្ថុផង វារៈ ៣ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋ-

សម្បដ្ឋានធម៌ក្តី ពឹងផ្អែកនឹងចិត្តសំសដ្ឋសម្បដ្ឋានធម៌ផង នឹងនោចិត្តសំសដ្ឋ-សម្បដ្ឋានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្ត-សំសដ្ឋសម្បដ្ឋានរូបក្តី ពឹងផ្អែកនឹងចិត្តសំសដ្ឋសម្បដ្ឋានក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ខន្ធ ២ ក្តី ចិត្តក្តី ពឹងផ្អែកនឹងចិត្តសំសដ្ឋសម្បដ្ឋានក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... វារៈ ២ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិ ។

[ ២៣២ ] ចិត្តសំសដ្ឋសម្បដ្ឋានធម៌ ពឹងផ្អែកនឹងចិត្តសំសដ្ឋសម្បដ្ឋានធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នោចិត្តសំសដ្ឋសម្បដ្ឋានធម៌ ពឹងផ្អែកនឹងនោចិត្តសំសដ្ឋសម្បដ្ឋានធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ កាយាយតនៈ... ចិត្តពឹងផ្អែកនឹងវត្ថុ មានបដិសន្ធិដែរ ។ ចិត្តសំសដ្ឋស-ម្បដ្ឋានធម៌ ពឹងផ្អែកនឹងនោចិត្តសំសដ្ឋសម្បដ្ឋានធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ... ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងចិត្ត ពួកចិត្តសំសដ្ឋសម្បដ្ឋានក្ខន្ធ ពឹងផ្អែកនឹងវត្ថុ វារៈ ២ បណ្ឌិត គប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។ ចិត្តសំសដ្ឋសម្បដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសម្បដ្ឋានធម៌ក្តី ពឹងផ្អែកនឹងនោចិត្តសំសដ្ឋសម្បដ្ឋានធម៌ ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយា-យតនៈ... ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ វារៈ ១ ក្នុងខណៈ

នៃបដិសន្ធិ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ ពីងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នឹងនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងចក្ខុវិញ្ញាណផង នឹងខន្ធ ២ ... ដែលប្រកបដោយកាយវិញ្ញាណ... ខន្ធ ២ ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ខន្ធ ២ ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... វារៈ ២ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នឹងនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង ដែលប្រកបដោយកាយវិញ្ញាណ... ចិត្តពឹងផ្អែកនឹងពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធផង នឹងវត្ថុផង វារៈ ១ ក្នុងខណៈនៃបដិសន្ធិ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នឹងនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... វារៈ ១ ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ២៣៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ

៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៣៤ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ពឹងផ្អែកនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺបញ្ហាទាំង ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ឯបញ្ចវិញ្ញាណ បណ្ឌិតគប្បីធ្វើក្នុងបច្ចយវារៈចុះ មានវារៈ ៣ មានមោហៈ ។

[ ២៣៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំង ២ យ៉ាងក្រៅពីនេះក្តី និស្សយវារៈក្តី
បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

[ ២៣៦ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ប្រឡូកនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌

ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡាំនឹងចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ នឹងខន្ធ ២ ... ជាបដិសន្ធិ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ប្រឡាំនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តជាបដិសន្ធិប្រឡាំនឹងពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ប្រឡាំនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ប្រឡាំនឹងចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ នឹងខន្ធ ២ ... ជាបដិសន្ធិ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ ប្រឡាំនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធជាបដិសន្ធិប្រឡាំនឹងចិត្ត ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ ប្រឡាំនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នឹងនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡាំនឹងចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ផង នឹងចិត្តផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ២៣៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ២៣៨ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ប្រឡាំនឹងចិត្តសំសដ្ឋសមុដ្ឋានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ សេចក្តីបំប្រួញ មានវារៈ ៣ និងមានមោហៈ ។

[ ២៣៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ

៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនឈានប្បច្ច័យ មានវារៈ ៥ ក្នុងន-មគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ។

ការរាប់ទាំង ២ យ៉ាង ក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិត
គប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ២៨០ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយហេតុប្បច្ច័យ គឺពួកចិត្តសំសដ្ឋសមុដ្ឋានហេតុ ជាបច្ច័យ គឺជាបដិសន្ធិនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូលបណ្ឌិតគប្បីធ្វើចុះ ពួកចិត្តសំសដ្ឋសមុដ្ឋានហេតុ ជាបច្ច័យ គឺជាបដិសន្ធិនៃចិត្តផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ មូលបណ្ឌិតគប្បីធ្វើចុះ ពួកចិត្ត-សំសដ្ឋសមុដ្ឋានហេតុ ជាបច្ច័យ គឺជាបដិសន្ធិ នៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ២៨១ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអារម្មណប្បច្ច័យ គឺពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធកើតឡើង ព្រោះប្រារព្ធនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ។ មូល បណ្ឌិតគប្បីធ្វើចុះ ចិត្តកើតឡើង ព្រោះប្រារព្ធនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ។ មូល បណ្ឌិតគប្បីធ្វើចុះ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ។

នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ( ជាបច្ច័យ ) នៃគោត្រភូ ។ សេចក្ដីបំប្រួញ ។ អារម្មណប្បច្ច័យ ក្នុងចិត្តសហភុទុកៈយ៉ាងណា អារម្មណប្បច្ច័យ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ឯបញ្ហាមាន ៩ ។

[ ២៨២ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ឯអធិបតិទាំង ២ យ៉ាង បណ្ឌិតគប្បីធ្វើចុះ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតធិបតិ មានវារៈ ៣ ។ អធិបតិទាំង ២ យ៉ាង បណ្ឌិតគប្បីធ្វើចុះ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្ដី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្ដី ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ ។ អធិបតិ ១ បណ្ឌិតគប្បីធ្វើចុះ ឯបញ្ហាមាន ៩ ចិត្តសហភុទុកៈយ៉ាងណា ( អធិបតិប្បច្ច័យ ) បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

[ ២៨៣ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអនន្តរប្បច្ច័យ គឺមានបញ្ហា ៩ ដូចគ្នានឹងចិត្តសហភុទុកៈដែរ ។ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ គឺមានវារៈ ៩ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយ

អញ្ញមញ្ញប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៩ ដូចគ្នានឹងបច្ចយវារៈដែរ ។ ... ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ឯបញ្ហាមាន ៩ ដូចគ្នានឹងចិត្តសហភុទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

[ ២៨៤ ] នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត មានវារៈ ៣ ។ ដូចគ្នានឹងចិត្តសហភុទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

[ ២៨៥ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយបច្ឆាជាតប្បច្ច័យ គឺដូចគ្នានឹងចិត្តសហភុទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ មានវារៈ ៣ បានដល់ បច្ឆាជាត មានឯកមូលពីរជង មានគំណាតែមួយ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ គឺមានវារៈ ៩ ។

[ ២៨៦ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយកម្មប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងចិត្តសហភុទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ មានវារៈ ៣ តែជាសហជាតនិងនានាខណិកៈ ។ ... ជាបច្ច័យដោយវិបាកប្បច្ច័យ គឺមានវារៈ ៩ ជាបច្ច័យដោយអាហារប្បច្ច័យ គឺមានវារៈ ៩ ដូចដំណើរក្នុងចិត្តសហភុដែរ កពឡិង្ការាហារមានតែ ១ ទេ ។ ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៣ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៣ ជាបច្ច័យ ដោយ

សម្បយុត្តប្បច្ច័យ មានវារៈ ៥ ។

[ ២៤៧ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋាន-ធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យនៃពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃពួកខន្ធដែលប្រឡំដោយចក្ខុវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ នោចិត្តសំសដ្ឋស-មុដ្ឋានធម៌ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈ... វត្ថុជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ជាបច្ច័យនៃនោ-ចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិង

បច្ឆាជាត ។ សេចក្តីបំប្រួញ ។

[ ២៤៨ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអត្ថិប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈដែរ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ដោយអត្ថិប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈដែរ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ បុរេជាត ដូចគ្នានឹងបុរេជាតប្បច្ច័យដែរ បណ្ឌិត គប្បីធ្វើផងចុះ ។ សេចក្តីបំប្រួញទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺចិត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ចិត្ត ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យនៃពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ បុរេជាតដូចគ្នានឹងបុរេជាតប្បច្ច័យដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺចិត្តជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប

ផង ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ចិត្តជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ។ បុរេជាតដូចគ្នានឹងបុរេជាតប្បច្ច័យដែរ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខុវិញ្ញាណក្តី ( ជាបច្ច័យ ) នៃខន្ធ ២ ខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ( ជាបច្ច័យ ) នៃខន្ធ ២ ចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ដែលប្រឡំដោយកាយវិញ្ញាណក្តី ចិត្តក្តី ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ មានវារៈ ២ ក្នុងខណៈនៃបដិសន្ធិដែរ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអត្ថិប្បច្ច័យ ដែលប្រឡំដោយកាយវិញ្ញាណ... ពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធក្តី ចិត្តក្តី ជាបច្ច័យនៃពួកចិត្តសំសដ្ឋសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសំសដ្ឋសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធក្តី វត្ថុក្តី ជាបច្ច័យនៃចិត្ត ដោយអត្ថិប្បច្ច័យ ក្នុង

ខណៈនៃបដិសន្ធិ មានវារៈ ៣ ។ បច្ឆាជាត គឺពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធក្តី ចិត្តក្តី ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធក្តី ចិត្តក្តី កពឡីង្ការាហារក្តី ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធក្តី ចិត្តក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រទូំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃខន្ធ ២ ផង នៃចក្ខុវិញ្ញាណផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ដែលប្រទូំដោយកាយវិញ្ញាណ... ។ សហជាត គឺចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ក្តី ចិត្តក្តី ជាបច្ច័យនៃខន្ធ ២ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ចិត្តសំសដ្ឋសមុដ្ឋានក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ផង នៃចិត្តផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... មានវារៈ ២ ក្នុងខណៈនៃបដិសន្ធិ ។

[ ២៤៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុង

ឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៥០ ] ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយ

បុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហា-រប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេ-ជាតប្បច្ច័យ ។ នោចិត្តសំសដ្ឋសមុដ្ឋានធម៌ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋាន-ធម៌ផង នៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យឧបនិស្សយប្បច្ច័យ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ជាបច្ច័យនៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី នោចិត្តសំសដ្ឋសមុដ្ឋានធម៌ក្តី ជាបច្ច័យនៃចិត្តសំសដ្ឋសមុដ្ឋានធម៌ផង នៃនោចិត្តសំសដ្ឋសមុដ្ឋានធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយស-ហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២៥១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ គ្រប់បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៥២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ គ្រប់បទទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៥៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ គ្រប់បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ។

អនុលោមមាតិកា បណ្ឌិតគប្បីធ្វើចុះ ។

**ចប់ ចិត្តសំសដ្ឋសមុដ្ឋានទុកៈ ។**

# ចិត្តសំសដ្ឋសមុដ្ឋានសហភុទុកៈ

## បដិច្ចវារៈ

[ ២៥៤ ] ចិត្តសំសដ្ឋសមុដ្ឋានសហភុធម៌ ( ធម៌ដែលប្រឡូកនឹងចិត្ត តាំងឡើងព្រោះចិត្ត និងកើតជាមួយនឹងចិត្ត ) អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានសហភុធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ខន្ធ ២ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានសហភុក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ ចិត្តសំសដ្ឋសមុដ្ឋានទុកៈយ៉ាងណា ចិត្តសំសដ្ឋសមុដ្ឋានសហភុទុកៈនេះ ក៏

យ៉ាងនោះដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

**ចប់ ចិត្តសំសដ្ឋសមុដ្ឋានសហភូទុកៈ ។**

## ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិទុកៈ

## បដិច្ចវារៈ

[ ២៥៥ ] ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិធម៌ ( ធម៌ដែលប្រកបនឹងចិត្ត តាំងឡើងព្រោះចិត្ត និងប្រព្រឹត្តទៅតាមចិត្ត ) អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ ចិត្តសំសដ្ឋសមុដ្ឋានទុកៈយ៉ាងណា ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិទុកៈនេះ ក៏យ៉ាងនោះដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

**ចប់ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិទុកៈ ។**

## អជ្ឈត្តិកទុកៈ

## បដិច្ចវារៈ

[ ២៥៦ ] ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបខាងក្នុង អាស្រ័យនូវចិត្ត ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបខាងក្រៅក្តី អាស្រ័យនូវចិត្ត ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅក្តី អាស្រ័យនូវចិត្ត ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបខាងក្រៅក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ធម៌ខាងក្នុងអាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តអាស្រ័យនូវពួកខន្ធខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី កដត្តារូបខាងក្នុងក្តី អាស្រ័យនូវពួកខន្ធខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវវត្ថុខាងក្រៅ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ ធម៌ខាងក្នុងអាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបខាងក្នុង អាស្រ័យនូវចិត្តផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្ត-សមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅផង នូវចិត្តផង នូវខន្ធ ២ ... ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្តផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបខាងក្រៅក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅផង នូវចិត្តផង កដត្តារូបខាងក្រៅ អាស្រ័យនូវចិត្តផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធខាងក្រៅ អាស្រ័យនូវចិត្តផង នូវវត្ថុផង ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅផង នូវចិត្តផង នូវខន្ធ ២ ... ។

[ ២៥៧ ] ធម៌ខាងក្រៅអាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធអាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវចិត្ត ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ ។ ធម៌ខាងក្នុងអាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្តអាស្រ័យនូវពួកខន្ធខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវពួក

ខន្ធខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ ចិត្តអាស្រ័យនូវវត្ថុ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ខន្ធ ២ អាស្រ័យនូវខន្ធ ១ ខាងក្រៅផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យនូវខន្ធ ១ ខាងក្រៅផង នូវចិត្តផង នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកចិត្តសម្បយុត្តកក្ខន្ធ អាស្រ័យនូវខន្ធ ១ ខាងក្រៅផង នូវចិត្តផង នូវវត្ថុផង ។ សេចក្តីបំព្រួញ ។

[ ២៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ

៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៥៩ ] ធម៌ខាងក្នុងអាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូបខាងក្នុងអាស្រ័យនូវចិត្ត ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវចិត្តជាអហេតុកៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបខាងក្រៅក្តី អាស្រ័យនូវចិត្ត មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវចិត្តដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅក្តី អាស្រ័យនូវចិត្ត ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ រហូតដល់ពួកអសញ្ញសត្វ ។ ធម៌ខាងក្នុងអាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តអាស្រ័យនូវពួកខន្ធខាងក្រៅ ជាអហេតុកៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តក្តី កដត្តារូបខាងក្នុងក្តី អាស្រ័យនូវពួក

ខន្ធខាងក្រៅ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តអាស្រ័យនូវវត្ថុ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ខាងក្រៅ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ ក្តី ចិត្តក្តី កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ។ ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូបខាងក្នុង អាស្រ័យនូវចិត្តផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ខាងក្រៅផង នូវចិត្តផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្តជាអហេតុកៈផង នូវពួកមហាភូតផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបខាងក្រៅក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅផង នូវចិត្តផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូបខាងក្រៅ អាស្រ័យនូវចិត្តផង នូវពួកមហាភូតផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកខន្ធខាងក្រៅ អាស្រ័យនូវចិត្តផង នូវវត្ថុផង មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវចិត្តផង ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌

ខាងក្រៅផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងខណៈនៃអហេតុ-កប្បដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅក្តី អាស្រ័យនូវខន្ធ ១ ខាងក្រៅផង នូវចិត្តផង នូវខន្ធ ២ ... ។

[ ២៦០ ] ធម៌ខាងក្នុងអាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបខាងក្នុង អាស្រ័យនូវចិត្ត ។ ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនអា-រម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូបខាងក្រៅ អាស្រ័យនូវចិត្ត ក្នុងខណៈនៃបដិសន្ធិ កដត្តារូបខាងក្រៅ អាស្រ័យនូវចិត្ត ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅ អាស្រ័យនូវចិត្ត ។ ធម៌ខាងក្រៅអាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យនូវពួកខន្ធខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ កដត្តា-រូបខាងក្រៅ អាស្រ័យនូវពួកខន្ធខាងក្រៅ វត្ថុអាស្រ័យនូវពួកខន្ធខាងក្រៅ មហាភូត ១ រហូតដល់ពួកអសញ្ញសត្វ ។ ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបខាងក្នុង អាស្រ័យនូវពួកខន្ធខាងក្រៅ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបទាំងខាងក្នុងទាំងខាងក្រៅ អាស្រ័យនូវពួកខន្ធខាងក្រៅ ។ ធម៌ខាងក្នុងអាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង

ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបខាងក្នុង អាស្រ័យនូវចិត្តផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ធម៌ខាងក្រៅអាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធខាងក្រៅផង នូវចិត្តផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវចិត្តផង នូវពួកមហាភូតផង មានវារៈ ២ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅ អាស្រ័យនូវចិត្តផង នូវពួកសម្បយុត្តកក្ខន្ធផង ។ សេចក្តីបំប្រួញ ។

[ ២៦១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ។

[ ២៦២ ] ធម៌ខាងក្រៅអាស្រ័យនូវធម៌ខាងក្នុង ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវចក្ខុវិញ្ញាណ នូវកាយ-វិញ្ញាណ... ។ ធម៌ខាងក្រៅអាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណ នូវខន្ធ ២ ... ដែលប្រកបដោយកាយវិញ្ញាណ... ខាងក្រៅ... អាហារ-

សមុដ្ឋាន... ឧតុសមុដ្ឋាន... របស់ពួកអសញ្ញសត្វ... ។ ធម៌ខាងក្នុង អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺចក្ខុវិញ្ញាណ អាស្រ័យនូវពួកខន្ធដែលប្រឡាំដោយចក្ខុវិញ្ញាណ កាយវិញ្ញាណ អាស្រ័យនូវពួកខន្ធ ដែលប្រឡាំដោយកាយវិញ្ញាណ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី អាស្រ័យនូវធម៌ខាងក្រៅ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺខន្ធ ២ ក្តី ចក្ខុវិញ្ញាណក្តី អាស្រ័យនូវខន្ធ ១ ដែលប្រឡាំដោយចក្ខុវិញ្ញាណ នូវខន្ធ ២ ... នូវខន្ធ ១ ដែលប្រឡាំដោយកាយវិញ្ញាណ... ធម៌ខាងក្រៅ អាស្រ័យនូវធម៌ខាងក្នុងផង នូវធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវខន្ធ ១ ដែលប្រឡាំដោយចក្ខុវិញ្ញាណផង នូវចក្ខុវិញ្ញាណផង នូវខន្ធ ២ ... ដែលប្រឡាំដោយកាយវិញ្ញាណ... ។ ចក្កៈ ។

[ ២៦៣ ] ក្នុងនឈានប្បច្ច័យ មានវារៈ ៥ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៦៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។

[ ២៦៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។

ឯសហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ២៦៦ ] ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ធម៌ខាងក្រៅ ពឹងផ្អែកនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ខាងក្រៅ នឹងខន្ធ ២ ... វារៈ ២ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិ រហូតដល់ពួកមហាភូតខាងក្នុងចុះ ពួកខន្ធខាងក្រៅ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តពឹងផ្អែកនឹងពួកខន្ធខាងក្រៅ ចិត្ត ពឹងផ្អែកនឹងវត្ថុ វារៈ ២ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ពឹងផ្អែកនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ខាងក្រៅ នឹងខន្ធ ២ ... ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ វារៈ ២ បណ្ឌិតគប្បីធ្វើ ក្នុងខណៈនៃបដិសន្ធិចុះ ។ ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្នុងផង នឹងធម៌ខាងក្រៅផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបខាងក្នុង ពឹងផ្អែកនឹងចិត្តផង នឹងពួកសម្បយុត្តកក្ខន្ធផង ។ ធម៌ខាងក្រៅ ពឹងផ្អែកនឹងធម៌ខាងក្នុងផង នឹងធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ខាងក្រៅផង

នឹងចិត្តផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងចិត្តផង នឹងពួកមហាភូតផង ពួកខន្ធខាងក្រៅ ពឹងផ្អែកនឹងចិត្តផង នឹងវត្ថុផង វារៈ ៣ បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ពឹងផ្អែកនឹងធម៌ខាងក្នុងផងនឹងធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិ-សន្ធិ ខន្ធ ២ ក្តី កដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅ ពឹងផ្អែកនឹងខន្ធ ១ ខាងក្រៅផង នឹងចិត្តផង នឹងខន្ធ ២ ... ។

[ ២៦៧ ] ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយា-យតនៈ... ។ ធម៌ខាងក្រៅ ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រឡំដោយចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខា-យតនៈផង នឹងចក្ខុវិញ្ញាណផង នឹងកាយាយតនៈផង... ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងចិត្ត ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងចក្ខាយតនៈ និងកាយាយតនៈ... ។ ធម៌ខាងក្រៅពឹងផ្អែកនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ខាងក្រៅ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធខាងក្រៅ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្ត ពឹងផ្អែកនឹងពួកខន្ធខាងក្រៅ ចិត្តពឹងផ្អែកនឹងវត្ថុ វារៈ ២ បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។ ធម៌

ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ពឹងផ្អែកនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ វារៈ ១ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ខាងក្នុងពឹងផ្អែកនឹងធម៌ខាងក្នុងផង នឹងធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រទ្បំដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង ដែលប្រទ្បំដោយកាយវិញ្ញាណ... ។ ធម៌ខាងក្រៅ ពឹងផ្អែកនឹងធម៌ខាងក្នុងផង នឹងធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រទ្បំដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងចក្ខុវិញ្ញាណផង នឹងខន្ធ ២ ... ដែលប្រទ្បំដោយកាយវិញ្ញាណ... ខន្ធ ២ ពឹងផ្អែកនឹងខន្ធ ១ ខាងក្រៅផង នឹងចិត្តផង នឹងខន្ធ ២ ... ពួកខន្ធខាងក្រៅ ពឹងផ្អែកនឹងចិត្តផង នឹងវត្ថុផង ក្នុងខណៈនៃបដិសន្ធិ វារៈ ២ បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិចុះ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ពឹងផ្អែកនឹងធម៌ខាងក្នុងផង នឹងធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ២ ក្តី ចក្ខុវិញ្ញាណក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រទ្បំដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ។ សេចក្តីបំប្រួញ ។

[ ២៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុង

ឧបនិស្សយបច្ច័យ មានវារៈ ៩ ក្នុងបុរេជាតបច្ច័យ មានវារៈ ៩ ក្នុងអាសេវនបច្ច័យ មានវារៈ ៩ ក្នុងកម្មបច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងអវិគតបច្ច័យ មានវារៈ ៩ ។

[ ២៦៩ ] ធម៌ខាងក្នុង ពឹងផ្អែកនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះនហេតុបច្ច័យ គឺក្នុងខណៈនៃអហេតុកបដិសន្ធិ កដត្តារូបខាងក្នុង ពឹងផ្អែកនឹងចិត្ត ចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ ។ សេចក្តីបំប្រួញ ។ បញ្ហា ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ឯបញ្ចវិញ្ញាណ គប្បីបញ្ចូលថែមទៀតផង មានវារៈ ៣ មានមោហៈដែរ ។

[ ២៧០ ] ក្នុងនហេតុបច្ច័យ មានវារៈ ៩ ក្នុងនអារម្មណបច្ច័យ មានវារៈ ៩ ក្នុងនអធិបតិបច្ច័យ មានវារៈ ៩ ក្នុងនអនន្តរបច្ច័យ មានវារៈ ៩ ក្នុងនសមនន្តរបច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញបច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយបច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតបច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតបច្ច័យ មានវារៈ ៩ ក្នុងនអាសេវនបច្ច័យ មានវារៈ ៩ ក្នុងនកម្មបច្ច័យ មានវារៈ ៣ ក្នុងនវិបាកបច្ច័យ មានវារៈ ៥ ក្នុងនអាហារបច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយបច្ច័យ មានវារៈ ១ ក្នុងនឈានបច្ច័យ មានវារៈ ៩ ក្នុងនមគ្គបច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តបច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តបច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិបច្ច័យ មានវារៈ ៩ ក្នុងនោវិគតបច្ច័យ មានវារៈ ៩ ។

ការរាប់ ២ យ៉ាងក្រៅនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើ

យ៉ាងនេះចុះ ។

## សំសន្ធវារៈ

[ ២៧១ ] ធម៌ខាងក្រៅ ប្រឡុំនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ពួកសម្បយុត្តកក្ខន្ធ ប្រឡុំនឹងចិត្ត ក្នុងខណៈនៃបដិសន្ធិ ពួកសម្បយុត្តកក្ខន្ធ ប្រឡុំនឹងចិត្ត ។ ធម៌ខាងក្រៅ ប្រឡុំនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡុំនឹងខន្ធ ១ ខាងក្រៅ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ខាងក្នុង ប្រឡុំនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្ត ប្រឡុំនឹងពួកខន្ធខាងក្រៅ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ប្រឡុំនឹងធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ចិត្តក្តី ប្រឡុំនឹងខន្ធ ១ ខាងក្រៅ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ខាងក្រៅ ប្រឡុំនឹងធម៌ខាងក្នុងផង នឹងធម៌ខាងក្រៅផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ប្រឡុំនឹងខន្ធ ១ ខាងក្រៅផង នឹងចិត្តផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ សេចក្តីបំប្រួញ ។

[ ២៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ២៧៣ ] ធម៌ខាងក្រៅ ប្រឡុំនឹងធម៌ខាងក្នុង ទើបកើតឡើង ព្រោះ

នហេតុប្បច្ច័យ គឺប្រស្នាទាំង ៥ បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ មានវារៈតែ ៣ ទេ ឯមោហៈក៏មានដែរ ។

[ ២៧៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនឈានប្បច្ច័យ មានវារៈ ៥ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ។

ការរាប់ទាំង ២ យ៉ាងក្រៅពីនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិត គប្បីធ្វើយ៉ាងនេះ ។

## បញ្ហាវារៈ

[ ២៧៥ ] ធម៌ខាងក្រៅជាបច្ច័យនៃធម៌ខាងក្រៅ ដោយហេតុប្បច្ច័យ គឺពួកហេតុខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកហេតុខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបខាងក្រៅផង ដោយហេតុប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយហេតុប្បច្ច័យ គឺពួកហេតុខាងក្រៅ ជាបច្ច័យនៃចិត្ត ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកហេតុខាងក្រៅជាបច្ច័យនៃចិត្តផង នៃពួកកដត្តារូបខាងក្នុងផង ដោយហេតុប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយហេ-

តុប្បច្ច័យ គឺពួកហេតុខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកហេតុខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅផង ដោយហេតុប្បច្ច័យ ។

[ ២៧៦ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ គឺចិត្តកើតឡើងព្រោះប្រារព្ធនូវចិត្ត ។ ដោយអារម្មណប្បច្ច័យ មូល បណ្ឌិតគប្បីសួរផងចុះ ពួកខន្ធខាងក្រៅ កើតឡើង ព្រោះប្រារព្ធនូវចិត្ត ។ មូលបណ្ឌិតគប្បីសួរផងចុះ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវចិត្ត ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ គឺបុគ្គលនូវទាន... នូវសីល... ធ្វើនូវឧបោសថកម្មហើយពិចារណានូវកុសលនោះ ត្រេកអរ រីករាយ រាគៈព្រោះប្រារព្ធនូវកុសលនោះ ។បេ។ ទោមនស្សកើតឡើង បុគ្គលពិចារណានូវពួកកុសល ដែលសន្សំហើយ ក្នុងកាលមុនចេញអំពីឈាន នូវឈាន... ពួកព្រះអរិយៈចេញអំពីមគ្គ នូវមគ្គ... នូវផល... ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គនិងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈពិចារណានូវពួកកិលេសខាងក្រៅ ដែលលះបង់ហើយ នូវពួកកិលេសដែលសង្កត់សង្កិនហើយ... ដឹងនូវពួកកិលេសដែលសន្សំហើយ ក្នុងកាលមុន នូវពួករូប ។បេ។ នូវវត្ថុ... នូវពួកខន្ធខាងក្រៅ ជាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោត-

ធាតុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយចិត្តខាងក្រៅ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ពួកខន្ធខាងក្រៅ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ គឺបុគ្គល ( ឲ្យ ) នូវទាន... នូវសីល... នូវឧបោសថកម្ម... ពិចារណានូវកុសលនោះ ត្រេកអរ រីករាយ ចិត្តកើតឡើង ព្រោះប្រារព្ធនូវកុសលនោះ នូវពួកកុសលដែលសន្សំហើយក្នុងកាលមុន... ចេញអំពីឈាននូវឈាន... ។ សេចក្តីបំប្រួញ បទទាំងអស់បណ្ឌិតគប្បីធ្វើចុះ ។ ដែលធ្លាប់សន្សំហើយ ក្នុងកាលមុននូវពួករូប ។បេ។ ឃើញនូវវត្ថុជាមិនទៀង ។បេ។ ត្រេកអរ រីករាយ ចិត្តកើតឡើងព្រោះប្រារព្ធនូវវត្ថុនោះ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ។ សេចក្តីបំប្រួញ ។ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ពួកខន្ធខាងក្រៅ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន... នូវសីល... នូវឧបោសថកម្ម... ពិចារណានូវកុសលនោះ

ត្រេកអរ រីករាយ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវកុសលនោះ ។ សេចក្តីបំប្រួញ បទទាំងអស់បណ្ឌិតគប្បីធ្វើចុះ ។ បុគ្គលឃើញច្បាស់នូវពួកខន្ធខាងក្រៅ ថាមិនទៀង ។បេ។ ត្រេកអរ រីករាយ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវខន្ធនោះ បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ។ សេចក្តីបំប្រួញ ។ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ផោដ្ឋព្វាយតនៈ... ពួកខន្ធខាងក្រៅ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេ-និវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុងដោយអារម្មណប្បច្ច័យ គឺមានវារៈ ៣ ។

[ ២៧៧ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺចិត្តកើតឡើង ព្រោះធ្វើនូវពួកខន្ធខាងក្នុងនិងចិត្តឲ្យជាទីគោរព ។ ធម៌ខាងក្នុងជាបច្ច័យនៃធម៌ខាងក្រៅ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកខន្ធខាងក្រៅ កើតឡើង ព្រោះធ្វើនូវចិត្ត ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺចិត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ មូលបណ្ឌិតគប្បីសួរផងចុះ អារម្មណាធិបតិ គឺចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវចិត្តខាងក្នុងឲ្យជាទីគោរព ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអធិបតិប្បច្ច័យ បានដល់ អា-

រម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យនូវទាន... មានវារៈ ៣ ។ អធិបតិទាំង ២ បណ្ឌិតគប្បីធ្វើដោយអំណាចនៃបច្ច័យទាំង ៣ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយអធិបតិប្បច្ច័យ គឺមានវារៈ ៣ ។ អធិបតិតែ ១ នៃវារៈទាំង ៣ ។

[ ២៧៨ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអនន្តរប្បច្ច័យ គឺចិត្តមុនៗ ជាបច្ច័យនៃចិត្តក្រោយៗ ដោយអនន្តរប្បច្ច័យ មានវារៈ ៣ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធខាងក្រៅមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ មានវារៈ ៣ ។ ឯវារៈទាំង ៣ មានសេចក្តីដូចគ្នានឹងវារៈ ១ ដែរ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុងដោយអនន្តរប្បច្ច័យ គឺមានវារៈ ៣ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៩ ដូចបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ ៥ ដូចបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៩ ដូចបច្ចយវារៈដែរ ។

[ ២៧៩ ] ធម៌ខាងក្នុងជាបច្ច័យនៃធម៌ខាងក្នុង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺចិត្តជាបច្ច័យនៃចិត្ត ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។

ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈហើយឲ្យនូវទាន ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ពួកបច្ច័យបណ្ឌិតគប្បីធ្វើបំពេញ ឲ្យមានវារៈ ៣ ហើយគប្បីធ្វើថា ជាបច្ច័យនៃចិត្តដូច្នេះផង គប្បីធ្វើថា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធដូច្នេះផងចុះ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយឧបនិស្សយប្បច្ច័យ គឺមានវារៈ ៣ ។

[ ២៨០ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ។បេ។ ពិចារណាឃើញច្បាស់នូវកាយ ថាមិនទៀង ។បេ។ ត្រេកអររីករាយ ចិត្តកើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ។បេ។ បុគ្គលពិចារណាឃើញច្បាស់នូវកាយ ថាមិនទៀង ។បេ។ ត្រេកអរ ។បេ។ ទោមនស្សកើតឡើង ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធដែលច្រឡំដោយចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃពួកខន្ធដែលច្រឡំដោយកាយវិញ្ញាណ ដោយបុរេ-

ជាតប្បច្ច័យ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ ។បេ។ ពិចារណាឃើញច្បាស់នូវកាយ ជាមិនទៀង ។បេ។ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវវត្ថុនោះ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង កាយាយតនៈជាបច្ច័យនៃកាយវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។ ធម៌ខាងក្រៅជាបច្ច័យនៃធម៌ខាងក្រៅ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវពួករូប ។បេ។ នូវពួកផោដ្ឋព្វៈ... បុគ្គលពិចារណាឃើញច្បាស់នូវវត្ថុ ជាមិនទៀង ។បេ។ ទោមនស្សកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកខន្ធខាងក្រៅ ដោយបុរេជាតប្បច្ច័យ ។ ធម៌ខាងក្រៅជាបច្ច័យនៃធម៌ខាងក្នុង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវពួករូប ។បេ។ នូវពួកផោដ្ឋព្វៈ... បុគ្គលពិចារណាឃើញច្បាស់នូវវត្ថុ ជាមិនទៀង ។បេ។ ចិត្តកើតឡើងព្រោះប្រារព្ធនូវវត្ថុនោះ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃចិត្ត ដោយបុរេជាតប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវពួករូប ។បេ។ នូវពួកផោដ្ឋព្វៈ... នូវវត្ថុ ជាមិនទៀង ។បេ។ ចិត្តក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុ

នោះ ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ ចក្ខាយតនៈក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃកាយាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃចិត្ត ដោយបុរេជាតប្បច្ច័យ រូបាយតនៈក្តី ចក្ខាយតនៈក្តី ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈក្តី កាយាយតនៈក្តី ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ ចក្ខាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកខន្ធខាងក្រៅ ដោយបុរេជាតប្បច្ច័យ កាយាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកខន្ធខាងក្រៅ ដោយបុរេជាតប្បច្ច័យ រូបាយតនៈក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃពួកខន្ធដែលប្រទូរំដោយចក្ខុវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ផោដ្ឋព្វាយតនៈក្តី កាយាយតនៈក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រទូរំដោយកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយបុរេ-ជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ ចក្ខាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃចិត្តផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ កាយាយតនៈក្តី វត្ថុក្តី... រូបាយតនៈក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ផោដ្ឋព្វាយតនៈក្តី... ។

[ ២៨១ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយបច្ឆាជាតប្បច្ច័យ

បានដល់ បច្ឆាជាត គឺពួកខន្ធខាងក្នុង ជាបច្ច័យនៃកាយខាងក្នុងនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើផងចុះ បច្ឆាជាត គឺពួកខន្ធខាងក្នុង ជាបច្ច័យនៃកាយខាងក្រៅនេះដែលកើតមុន ដោយបច្ឆា-ជាតប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើផងចុះ បច្ឆាជាត គឺពួកខន្ធខាងក្នុង ជាបច្ច័យនៃកាយទាំងខាងក្នុង ទាំងខាងក្រៅនេះ ដែលកើតមុន ដោយបច្ឆាជា-តប្បច្ច័យ ។ ឯបញ្ហាទាំង ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ បញ្ហាទាំង ៩ បណ្ឌិតគប្បីធ្វើចុះ ។

[ ២៨២ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនាខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាខាងក្រៅ ជាបច្ច័យនៃពួកវិបាកក្ខន្ធខាងក្រៅផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនាខាងក្រៅ ជាបច្ច័យនៃចិត្ត ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាខាងក្រៅជាបច្ច័យនៃវិបាកចិត្តផង នៃពួកកដត្តារូបខាងក្នុងផង ដោយកម្មប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនាខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផងនៃពួកចិត្ត-សមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាខាងក្រៅ ជា

បច្ច័យនៃពួកវិបាកក្ខន្ធផង នៃចិត្តផង នៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅផង ដោយកម្មប្បច្ច័យ ។ ... ជាបច្ច័យដោយវិបាកប្បច្ច័យ គឺមានវារៈ ៩ ។

[ ២៨៣ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអាហារប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកអាហារខាងក្នុង ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយអាហារប្បច្ច័យ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអាហារប្បច្ច័យ គឺពួកអាហារខាងក្នុង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកអាហារខាងក្នុង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបខាងក្រៅផង ដោយអាហារប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើផងចុះ ក្នុងខណៈនៃបដិសន្ធិ ពួកអាហារខាងក្នុង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូប ទាំងខាងក្នុងទាំងខាងក្រៅផង ដោយអាហារប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអាហារប្បច្ច័យ គឺពួកអាហារខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ កពឡិង្ការាហារខាងក្រៅ ជាបច្ច័យនៃកាយខាងក្រៅ ដោយអាហារប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអាហារប្បច្ច័យ គឺពួកអាហារខាងក្រៅជាបច្ច័យនៃចិត្ត ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកអាហារខាងក្រៅ ជាបច្ច័យនៃចិត្តផង នៃពួកកដត្តារូបខាងក្នុងផង ដោយអាហារប្បច្ច័យ កពឡិង្ការាហារខាងក្រៅ ជា

បច្ច័យនៃកាយខាងក្នុង ដោយអាហារប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយអាហារប្បច្ច័យ គឺពួកអាហារខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកអាហារខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅផង ដោយអាហារប្បច្ច័យ កពឡិង្ការាហារខាងក្រៅ ជាបច្ច័យនៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅ ដោយអាហារប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយអាហារប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកអាហារខាងក្នុងក្តី ខាងក្រៅក្តី ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយអាហារប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអាហារប្បច្ច័យ គឺពួកអាហារខាងក្នុងក្តី ខាងក្រៅក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហា-រប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកអាហារខាងក្នុងក្តី ខាងក្រៅក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបខាងក្រៅផង ដោយអាហារប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយអាហារប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកអាហារខាងក្នុងក្តី ខាងក្រៅក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅផង ដោយអាហារប្បច្ច័យ ។

[ ២៨៤ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយឥន្ទ្រិយប្បច្ច័យ

ក្នុងខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយខាងក្នុង ជាបច្ច័យនៃពួកកដត្តារូប ខាងក្នុង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយិន្ទ្រិយ ជាបច្ច័យនៃកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្នុងជាបច្ច័យនៃ ធម៌ខាងក្រៅ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយខាងក្នុង ជាបច្ច័យនៃពួក សម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុង ខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយខាងក្នុង ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃ ពួកកដត្តារូបខាងក្រៅផង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ជាបច្ច័យនៃពួក ខន្ធដែលប្រទូរំដោយចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ កាយិន្ទ្រិយជាបច្ច័យ នៃពួកខន្ធ ដែលប្រទូរំដោយកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាង ក្នុងជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយឥន្ទ្រិ-យប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយខាងក្នុង ជាបច្ច័យនៃពួក សម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូប ទាំងខាងក្នុង ទាំងខាងក្រៅផង ដោយ ឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណផង នៃពួកសម្ប-យុត្តកក្ខន្ធផង កាយិន្ទ្រិយជាបច្ច័យនៃកាយវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធ ផង ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយ ឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយខាងក្រៅជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃ ពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួក ឥន្ទ្រិយខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង នៃ

ពួកកដត្តារូបខាងក្រៅផង ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូបខាងក្រៅ ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយឥន្ទ្រិយប្បច្ចយ គឺពួកឥន្ទ្រិយខាងក្រៅ ជាបច្ច័យនៃចិត្ត ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយខាងក្រៅ ជាបច្ច័យនៃចិត្តផង នៃពួកកដត្តារូបខាងក្នុងផង ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយខាងក្រៅ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តផង នៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅផង ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយជាបច្ច័យនៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅ ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយឥន្ទ្រិយប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយខាងក្នុងក្តី ខាងក្រៅក្តី ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយក្តី ឧបេក្ខិន្ទ្រិយក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ កាយិន្ទ្រិយក្តី សុខិន្ទ្រិយក្តី កាយិន្ទ្រិយក្តី ទុក្ខិន្ទ្រិយក្តី ជាបច្ច័យនៃកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយខាងក្នុងក្តី ពួកឥន្ទ្រិយខាងក្រៅក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង

នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយខាងក្នុងក្តី ពួកឥន្ទ្រិយខាងក្រៅក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបខាងក្រៅផង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយក្តី ឧបេក្ខិន្ទ្រិយក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រទ្បំដោយចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ កាយិន្ទ្រិយក្តី សុខិន្ទ្រិយក្តី កាយិន្ទ្រិយក្តី ទុក្ខិន្ទ្រិយក្តី ជាបច្ច័យនៃពួកខន្ធដែលប្រទ្បំដោយកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយឥន្ទ្រិយប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយខាងក្នុងក្តី ពួកឥន្ទ្រិយខាងក្រៅក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅផង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយក្តី ឧបេក្ខិន្ទ្រិយក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឥន្ទ្រិយប្បច្ច័យ កាយិន្ទ្រិយក្តី... ។

[ ២៨៥ ] ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយឈានប្បច្ច័យ គឺមានវារៈ ៣ ។ ... ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៣ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៥ ។

[ ២៨៦ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ ចិត្ត ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ជា

បច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធខាងក្នុង ជាបច្ច័យនៃកាយខាងក្នុងនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺពួកខន្ធខាងក្នុង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។ បុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រឡំដោយកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធខាងក្នុង ជាបច្ច័យនៃកាយខាងក្រៅនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ ពួកខន្ធខាងក្នុង ជាបច្ច័យនៃពួកកដត្តារូបទាំងខាងក្នុង ទាំងខាងក្រៅ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈជាបច្ច័យនៃកាយវិញ្ញាណផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធខាងក្នុងដែលកើតក្រោយ ជាបច្ច័យនៃកាយខាងក្នុងនិងខាងក្រៅនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺពួកខន្ធខាងក្រៅដែលកើតជាមួយគ្នា ជាបច្ច័យនៃ

ពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធ ជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាតគឺវត្ថុ ជាបច្ច័យនៃពួកខន្ធខាងក្រៅ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធខាងក្រៅ ដែលកើតក្រោយ ជាបច្ច័យនៃកាយខាងក្រៅនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ ពួកខន្ធខាងក្រៅ ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃចិត្ត ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាតគឺវត្ថុ ជាបច្ច័យនៃចិត្ត ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកខន្ធខាងក្រៅ ដែលកើតក្រោយ ជាបច្ច័យនៃកាយខាងក្នុងនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ទាំងខាងក្នុង ទាំងខាងក្រៅ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ ពួកខន្ធខាងក្នុងក្តី ពួកខន្ធខាងក្រៅក្តី ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺដែលកើតក្រោយ សេចក្តីបំប្រួញ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ធម៌ខាងក្នុងក្តី ធម៌ខាង

ក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ ពួកខន្ធខាងក្នុងក្តី ពួកខន្ធខាងក្រៅក្តី សេចក្តីបំប្រួញ ។

[ ២៨៧ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ ចិត្ត ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយអត្ថិប្បច្ច័យ ។ បុរេជាត គឺនូវចក្ខុ ។បេ។ នូវកាយ ថាមិនទៀង ។បេ។ ដូចគ្នានឹងបុរេជាតប្បច្ច័យ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ ឯបច្ឆាជាត គឺបណ្ឌិតគប្បីធ្វើ ឲ្យដូចគ្នានឹងបច្ឆាជាតប្បច្ច័យផងចុះ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺពួកខន្ធខាងក្នុង ដែលកើតជាមួយគ្នា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ក្នុងបច្ច័យនេះ ( សេចក្តីអធិប្បាយ ) មានក្នុងទីទាំងពួង សហជាត ដូចបច្ចយវារៈ បុរេ-ជាត ដូចបុរេជាតប្បច្ច័យដែរ ឯបច្ឆាជាត ក៏ដូចបច្ឆាជាតប្បច្ច័យដែរ បណ្ឌិតគប្បីធ្វើចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ បណ្ឌិតគប្បីធ្វើឲ្យពិស្តារគ្រប់បទទាំងអស់ផងចុះ ។ ធម៌

ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្ដីបំប្រួញ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្ដីបំប្រួញ ។ ធម៌ខាងក្នុងក្ដី ធម៌ខាងក្រៅក្ដី ជាបច្ច័យនៃធម៌ខាងក្នុង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺពួកខន្ធ ដែលប្រឡំដោយចក្ខុវិញ្ញាណក្ដី ចក្ខាយតនៈក្ដី ជាបច្ច័យនៃចក្ខុ-វិញ្ញាណ ដោយអត្ថិប្បច្ច័យ ពួកខន្ធដែលប្រឡំដោយកាយវិញ្ញាណក្ដី... ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធខាងក្នុងក្ដី ពួកខន្ធខាងក្រៅក្ដី ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយអត្ថិប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈក្ដី វត្ថុក្ដី ជាបច្ច័យនៃចិត្ត ដោយអត្ថិប្បច្ច័យ កាយាយតនៈក្ដី វត្ថុក្ដី ជាបច្ច័យនៃចិត្ត ដោយអត្ថិប្បច្ច័យ រូបាយតនៈក្ដី ចក្ខាយតនៈក្ដី ( ជាបច្ច័យ ) នៃចក្ខុ-វិញ្ញាណ ផោដ្ឋព្វាយតនៈក្ដី កាយាយតនៈក្ដី ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធខាងក្នុងក្ដី ពួកខន្ធខាងក្រៅក្ដី ជាបច្ច័យនៃកាយខាងក្នុងនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធខាងក្នុងក្ដី ពួកខន្ធខាងក្រៅក្ដី កពឡិង្ការាហារក្ដី ជាបច្ច័យនៃកាយខាងក្នុងនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធខាងក្នុងក្ដី ពួកខន្ធខាងក្រៅក្ដី រូបជីវិតិន្ទ្រិយក្ដី ជាបច្ច័យនៃពួកកដត្តារូបខាងក្នុង ដោយអត្ថិប្បច្ច័យ ។ ធម៌ខាងក្នុងក្ដី ធម៌ខាងក្រៅក្ដី ជាបច្ច័យនៃធម៌ខាងក្រៅ ដោយ

អត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលប្រទ្បំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ចក្ខុ-វិញ្ញាណក្តី ជាបច្ច័យនៃខន្ធ ២ ដោយអត្ថិប្បច្ច័យ ។ សហជាត ដូចគ្នានឹងបច្ចយវារៈដែរ មិនមានការធ្វើផ្សេងៗគ្នាទេ ដូចដំណើរទី ១ ដែរ ។ បទទាំងអស់ បណ្ឌិតគប្បីចែកតាមន័យនៃតំណទី ១ ចុះ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលប្រទ្បំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃខន្ធ ២ ផង នៃចក្ខុវិញ្ញាណផង ដោយអត្ថិប្បច្ច័យ ។ សេចក្តីបំប្រួញ ។ បទទាំងអស់ បណ្ឌិតគប្បីចែកតាមន័យនៃតំណទី ១ ចុះ ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ២៨៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ

៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៨៩ ] ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ធម៌ខាងក្នុងជាបច្ច័យនៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហ-ជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជា-តប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ធម៌ខាងក្នុង ជាបច្ច័យនៃធម៌ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យ

ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហា-
រប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្រៅ ជាបច្ច័យនៃធម៌
ខាងក្នុងផង នៃធម៌ខាងក្រៅផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយ
សហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេ-
ជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជា
បច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្នុងក្តី
ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាងក្នុង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ
ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយ
បុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហា-
រប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី
ជាបច្ច័យនៃធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជា-
តប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ
ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ
ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ខាងក្នុងក្តី ធម៌ខាងក្រៅក្តី ជាបច្ច័យនៃធម៌ខាង
ក្នុងផង នៃធម៌ខាងក្រៅផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហ-
ជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជា-
តប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ
ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ២៩០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៩១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៩២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិត គប្បីធ្វើអនុលោមមាតិកាផងចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

**ចប់ អជ្ឈត្តិកទុកៈ ។**

# អភិធម្មបិដក

# បដ្ឋាន ទសមភាគ

## ឧបាទាទុកៈ

## បដិច្ចវារៈ

[ ១ ] នោឧបាទាធម៌ ( ធម៌មិនមែនជាឧបាទា ) អាស្រ័យនូវឧបាទាធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកនោឧបាទាខន្ធ អាស្រ័យនូវវត្ថុ ។ នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជានោឧបាទាក្តី អាស្រ័យនូវខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី កដត្តារូបជានោឧបាទាក្តី អាស្រ័យនូវខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... នូវមហាភូត ១ ... មហាភូត ២ អាស្រ័យនូវមហាភូត ២ ។ ឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តស-មុដ្ឋានរូបជាឧបាទា អាស្រ័យនូវពួកខន្ធជានោឧបាទា ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូបជាឧបាទា កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបជាឧបាទា និងជានោឧបាទាក្តី អាស្រ័យនូវខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... ជាបដិសន្ធិ ។ នោ-ឧបាទាធម៌ អាស្រ័យនូវឧបាទាធម៌ផង នូវនោឧបាទាធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជា

នោឧបាទាផង នូវវត្ថុផង នូវខន្ធ ២ ... ។

[ ២ ] នោឧបាទាធម៌ អាស្រ័យនូវឧបាទាធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកនោឧបាទាខន្ធ អាស្រ័យនូវវត្ថុ ។ នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ នោឧបាទាធម៌ អាស្រ័យនូវឧបាទាធម៌ផង នូវនោឧបាទាធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានោឧបាទាផង នូវវត្ថុផង នូវខន្ធ ២ ... ។

[ ៣ ] នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបជានោឧបាទាក្តី អាស្រ័យនូវខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... ។ ឧបាទាធម៌អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូបជាឧបាទា អាស្រ័យនូវពួកនោឧបាទាខន្ធ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យ នូវនោ-ឧបាទាធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្ត-សមុដ្ឋានរូបជាឧបាទានិងជានោឧបាទាក្តី អាស្រ័យនូវខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... ។ ... ព្រោះអនន្តរប្បច្ច័យ មានវារៈ ៣ ព្រោះសមនន្ត-រប្បច្ច័យ មានវារៈ ៣ ព្រោះសហជាតប្បច្ច័យ មានវារៈ ៥ ។

[ ៤ ] នោឧបាទាធម៌ អាស្រ័យនូវឧបាទាធម៌ ទើបកើតឡើង ព្រោះ

អញ្ញមញ្ញប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ពួកនោឧបាទាខន្ធ អាស្រ័យនូវវត្ថុ ។ នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... នូវមហាភូត ១ ។បេ។ មហាភូត ៣ អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ មហាភូត ២ អាស្រ័យនូវមហាភូត ២ ។ នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ វត្ថុអាស្រ័យនូវពួកនោឧបាទាខន្ធ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើងព្រោះអញ្ញមញ្ញប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី វត្ថុក្តី អាស្រ័យនូវខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... ។ នោឧបាទាធម៌ អាស្រ័យនូវឧបាទាធម៌ផង នូវនោឧបាទាធម៌ផង ទើបកើតឡើង ព្រោះអញ្ញមញ្ញប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានោឧបាទាផង នូវវត្ថុផង នូវខន្ធ ២ ... ។ សេចក្តីបំប្រួញ ។

[ ៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបា-

កប្បច្ច័យ មានវារៈ ៥ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៥ ក្នុងសម្ប-យុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៦ ] នោឧបាទាធម៌ អាស្រ័យនូវឧបាទាធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺក្នុងអហេតុកប្បដិសន្ធិក្ខណៈ ពួកនោឧបាទាខន្ធ អាស្រ័យនូវវត្ថុ ។ នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជានោឧបាទាក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ជានោឧបាទា នូវខន្ធ ២ ... ក្នុងអហេតុកប្បដិសន្ធិក្ខណៈ នូវមហាភូត ១ ។បេ។ មហាភូត ៣ អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ មហាភូត ២ អាស្រ័យនូវមហាភូត ២ ។ ឧបាទាធម៌ អា-ស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបជាឧបាទា អាស្រ័យនូវពួកអហេតុកក្ខន្ធ ជានោឧបាទា ក្នុងអហេតុកប្បដិ-សន្ធិក្ខណៈ ចិត្តសមុដ្ឋានរូបជាឧបាទា កដត្តារូបនិងឧបាទារូប រហូតដល់ពួកអសញ្ញសត្វ អាស្រ័យនូវពួកមហាភូត ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបជាឧបាទានិងជានោឧបាទាក្តី ជាអហេតុកប្បដិសន្ធិ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជានោឧបាទាដែរ ។ នោឧបាទាធម៌ អាស្រ័យនូវឧបា-ទាធម៌ផង នូវនោឧបាទាធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ

ក្នុងអហេតុកប្បដិសន្ធិក្ខណៈ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានោឧបាទាផង នូវវត្ថុផង នូវខន្ធ ២ ... ។

[ ៧ ] នោឧបាទាធម៌អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជានោឧបាទា អាស្រ័យនូវពួកនោ-ឧបាទាខន្ធ ក្នុងខណៈនៃបដិសន្ធិ មហាភូត ១ រហូតដល់ពួកអសញ្ញសត្វ មហាភូត ២ អាស្រ័យនូវមហាភូត ២ ។ ឧបាទាធម៌ អាស្រ័យនូវនោឧ-បាទាធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាឧបាទា អាស្រ័យនូវពួកនោឧបាទាខន្ធ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូបជាឧបាទា កដត្តារូបនិងឧបាទារូប រហូតដល់ពួកអសញ្ញសត្វ អាស្រ័យនូវពួកមហាភូត ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ជាឧបាទានិងជានោឧបាទា អាស្រ័យនូវពួកនោឧបាទាខន្ធ មានបដិសន្ធិដែរ ។ ... ព្រោះនអធិបតិប្បច្ច័យ មានវារៈ ៥ ព្រោះនអនន្តរប្បច្ច័យ មានវារៈ ៣ ។ សេចក្តីបំប្រួញ ។ ... ព្រោះនឧបនិស្សយប្បច្ច័យ ព្រោះនបុរេជាតប្បច្ច័យ មានវារៈ ៥ ព្រោះនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ព្រោះនអាសេវនប្បច្ច័យ មានវារៈ ៥ ។

[ ៨ ] នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកនោឧបាទាខន្ធ ពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មហាភូត ២ អាស្រ័យនូវមហាភូត ២ ។

ឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ ពាហិរៈ... អាហារសមុដ្ឋាន... ឧបាទារូប អាស្រ័យនូវពួកមហាភូត មានរដូវជាសមុដ្ឋាន ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ ពាហិរៈ... អាហារសមុដ្ឋាន... មហាភូត ៣ ក្តី ឧបាទារូបក្តី អាស្រ័យនូវមហាភូត ១ មានរដូវជាសមុដ្ឋាន ។

[ ៩ ] នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជានោឧបាទាក្តី អាស្រ័យនូវខន្ធ ១ ជានោឧបាទា មហាភូត ១ រហូតដល់ពួកអសញ្ញសត្វ ក្នុងនោឧបា-ទាមូលកៈ មានវារៈ ៣ យ៉ាងនេះ ។

[ ១០ ] នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនអាហារប្បច្ច័យ ពាហិរៈ... ឧតុសមុដ្ឋាន... មហាភូត ១ របស់ពួកអសញ្ញសត្វ... មហាភូត ២ អាស្រ័យនូវមហាភូត ២ ។ ឧបាទាធម៌ អា-ស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនអាហារប្បច្ច័យ ពាហិរៈ... ឧតុសមុដ្ឋាន... ឧបាទារូប អាស្រ័យនូវពួកមហាភូតរបស់ពួកអសញ្ញសត្វ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនអាហារប្បច្ច័យ ពាហិរៈ... មហាភូត ៣ ក្តី ឧបាទារូបក្តី អាស្រ័យនូវមហាភូត ១ មានរដូវជាសមុដ្ឋាន ។

[ ១១ ] នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនឥន្ទ្រិយប្បច្ច័យ គឺពាហិរៈ... អាហារសមុដ្ឋាន... មហាភូត ១ មាន

វដ្ដជាសមុដ្ឋាន... ។ ឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនឥន្ទ្រិយប្បច្ច័យ គឺពួកមហាភូតខាងក្រៅ... មានអាហារជាសមុដ្ឋាន... មានវដ្ដជាសមុដ្ឋាន... រូបជីវិតិន្ទ្រិយ អាស្រ័យនូវពួកមហាភូត របស់ពួកអសញ្ញសត្វ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះឥន្ទ្រិយប្បច្ច័យ គឺពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មហាភូត ១ ... ។

[ ១២ ] នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយបញ្ចវិញ្ញាណ នូវខន្ធ ២ ... ពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មហាភូត ២ អាស្រ័យនូវមហាភូត ២ របស់ពួកអសញ្ញសត្វ ។ ឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺជាខាងក្រៅ... មានអាហារជាសមុដ្ឋាន... មានវដ្ដជាសមុដ្ឋាន... កដត្តារូបជាឧបាទា អាស្រ័យនូវពួកមហាភូតរបស់ពួកអសញ្ញសត្វ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មហាភូត ៣ អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ កដត្តារូបជាឧបាទានិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។

[ ១៣ ] នោឧបាទាធម៌ អាស្រ័យនូវឧបាទាធម៌ ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ មានវារៈ ៥ ។ ... ព្រោះនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ។

[ ១៤ ] នោឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានោឧបាទា ក្នុងអរូប នូវខន្ធ ២ ... ពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មហាភូត ១ របស់ពួកអសញ្ញសត្វ... ។ ឧបាទាធម៌ អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើងព្រោះនវិប្បយុត្តប្បច្ច័យ គឺជាខាងក្រៅ... មានអាហារជាសមុដ្ឋាន... មានរដូវជាសមុដ្ឋាន... កដត្តារូប ជាឧបាទានិងឧបាទារូប អាស្រ័យនូវពួកមហាភូតរបស់ពួកអសញ្ញសត្វ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី អាស្រ័យនូវនោឧបាទាធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺពាហិរៈ... អាហារសមុដ្ឋាន... មហាភូត ៣ ក្តី ឧបាទារូបក្តី អាស្រ័យនូវមហាភូត ១ ដែលមានរដូវជាសមុដ្ឋាន មហាភូត ២ អាស្រ័យនូវមហាភូត ២ មហាភូត ៣ ក្តី កដត្តារូបក្តី ឧបាទារូបក្តី អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ មហាភូត ២ ក្តី កដត្តារូបក្តី ឧបាទារូបក្តី អាស្រ័យនូវមហាភូត ២ ... ព្រោះនោនត្ថិប្បច្ច័យ ព្រោះនោវិគតប្បច្ច័យ ។

[ ១៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហា-

វប្បច្ច័យ មានវារៈ ៣ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ១៨ ] នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនោឧបាទាខន្ធពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។បេ។

នោឧបាទាធម៌ ពឹងផ្អែកនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ។ ក្នុងនោឧបាទាមូលកៈ មានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ផង នឹងនោឧបាទាធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជានោឧបាទាផង នឹងវត្ថុផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។

[ ១៩ ] នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកនោឧបាទាខន្ធ ជាបដិសន្ធិ ពឹងផ្អែកនឹងវត្ថុ ។ នោឧបាទាធម៌ពឹងផ្អែកនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ ១ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ផង នឹងនោឧបាទាធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ដែលប្រកបដោយកាយវិញ្ញាណ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជានោឧបាទាផង នឹងវត្ថុផង នឹងខន្ធ ២ ... ជាបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុង

ឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ២១ ] នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកអហេតុកក្ខន្ធ ជានោឧបាទា ពឹងផ្អែកនឹងវត្ថុ ក្នុងអហេតុកប្បដិសន្ធិក្ខណៈ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ នោឧបាទាធម៌ ពឹងផ្អែកនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជានោឧបាទាក្តី ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ជានោឧបាទា នឹងខន្ធ ២ ... ក្នុងអហេតុកប្បដិសន្ធិក្ខណៈ មហាភូត ១ រហូតដល់ពួកអសញ្ញសត្វ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ឯវារៈមាន ៣ ដូចគ្នានឹងបដិច្ចវារៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ នោឧបាទាធម៌ពឹងផ្អែកនឹងឧបាទាធម៌ផង នឹងនោឧបាទាធម៌ផង ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ដែលប្រកបដោយ កាយវិញ្ញាណ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជានោឧបាទាផង នឹងវត្ថុផង នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយ

វិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ ... ព្រោះនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនអាសេវនប្បច្ច័យ មានវារៈ ៥ ។

[ ២២ ] នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺនោឧបាទាចេតនា ពឹងផ្អែកនឹងវត្ថុ ។ នោឧបាទាធម៌ ពឹងផ្អែកនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា ពឹងផ្អែកនឹងពួកខន្ធជានោឧបាទា ពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មហាភូត ២ ពឹងផ្អែក នឹងមហាភូត ២ ។ ឧបាទាធម៌ ពឹងផ្អែកនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺជាខាងក្រៅ... មានអាហារជាសមុដ្ឋាន... ឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ដែលមានរដូវជាសមុដ្ឋាន ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី ពឹងផ្អែកនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺពាហិរៈ... អាហារសមុដ្ឋាន... មហាភូត ៣ ក្តី ឧបាទារូបក្តី ពឹងផ្អែកនឹងមហាភូត ១ ដែលមានរដូវជាសមុដ្ឋាន នឹងខន្ធ ២ ... ។ នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ផង នឹងនោឧបាទាធម៌ផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺនោឧបាទាចេតនា ពឹងផ្អែកនឹងពួកខន្ធជានោឧបាទាផង នឹងវត្ថុផង ។ ... ព្រោះនវិបាកប្បច្ច័យ មានវារៈ ៥ ព្រោះនអាហារប្បច្ច័យ មានវារៈ ៣ ព្រោះនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ។

[ ២៣ ] នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណពឹងផ្អែកនឹងកាយាយតនៈ ។ នោឧបាទាធម៌ ពឹងផ្អែកនឹងនោឧបាទាធម៌ ទើប

កើតឡើង ព្រោះឈានប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រឡំដោយបញ្ចវិញ្ញាណ នឹងខន្ធ ២ ... ពាហិរ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មហាភូត ២ ពឹងផ្អែកនឹងមហាភូត ២ របស់ពួកអសញ្ញសត្វ ។ ឧបាទាធម៌ ពឹងផ្អែកនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះឈានប្បច្ច័យ ជាខាងក្រៅ... មានអាហារជាសមុដ្ឋាន... មានរដូវជាសមុដ្ឋាន... កដត្តារូបជាឧបាទា ពឹងផ្អែកនឹងពួកមហាភូត របស់ពួកអសញ្ញសត្វ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី ពឹងផ្អែកនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះឈានប្បច្ច័យ គឺពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មហាភូត ៣ ក្តី កដត្តារូប ជាឧបាទាក្តី ពឹងផ្អែកនឹងមហាភូត ១ របស់ពួកអសញ្ញសត្វ នឹងខន្ធ ២ ... ។ នោឧបាទាធម៌ ពឹងផ្អែកនឹងឧបាទាធម៌ផង នឹងនោឧបាទាធម៌ផង ទើបកើតឡើង ព្រោះឈានប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណផង នឹងចក្ខាយតនៈផង នឹងខន្ធ ២ ... ។ ... ព្រោះនមគ្គប្បច្ច័យ មានវារៈ ៥ ព្រោះនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ព្រោះនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ព្រោះនោនត្ថិប្បច្ច័យ មានវារៈ ៣ ព្រោះនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៥ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៥ ក្នុង

នមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្ប-យុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគ-តប្បច្ច័យ មានវារៈ ៣ ។

ការរាប់ ២ យ៉ាង ក្រៅពីនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

[ ២៥ ] នោឧបាទាធម៌ ប្រឡូំនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡូំនឹងខន្ធ ១ ជានោឧបាទា ខន្ធ ២ ប្រឡូំនឹងខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ។បេ។ សេចក្តីបំប្រួញ ។

[ ២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ២៧ ] នោឧបាទាធម៌ ប្រឡូំនឹងនោឧបាទាធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡូំនឹងអហេតុកក្ខន្ធ ១ ជានោឧបាទា នឹងខន្ធ ២ ... ក្នុងអហេតុកប្បដិសន្ធិក្ខណៈ មោហៈដែលប្រឡូំដោយវិចិកិច្ឆា ប្រឡូំដោយឧទ្ធច្ចៈ ប្រឡូំនឹងពួកខន្ធដែលប្រឡូំដោយវិចិកិច្ឆា ប្រឡូំដោយឧទ្ធច្ចៈ ។ សេចក្តីបំប្រួញ ។

[ ២៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ

១ ក្នុងនអាសេវនបច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកបច្ច័យ មានវារៈ ១ ក្នុងនឈានបច្ច័យ មានវារៈ ១ ក្នុងន-មគ្គបច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តបច្ច័យ មានវារៈ ១ ។

ការរាប់ទាំង ២ យ៉ាង ក្រៅពីនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ២៩ ] នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុជានោឧបាទា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តស-មុដ្ឋានរូបជានោឧបាទាផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ជានោឧបាទា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាឧបាទា ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយហេតុប្បច្ច័យ គឺពួកហេតុ ជានោឧបាទា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបជាឧបាទា និងជានោឧបាទាផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ៣០ ] ឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអារម្មណប្បច្ច័យ គឺនូវចក្ខុ... នូវកាយ ពួករូប ពួករស... នូវវត្ថុ ថាមិនទៀង ។បេ។ ទោ-មនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ រសាយតនៈជា

បច្ច័យនៃជិវ្ហាវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកឧបាទាខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលនូវទាន... នូវសីល... ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះប្រារព្ធនូវកុសលនោះ ។បេ។ ទោមនស្សកើតឡើង ក្នុងកាលមុន ។បេ។ អំពីឈាន ។បេ។ ពួកព្រះអរិយៈចេញអំពីមគ្គ ពិចារណានូវមគ្គ នូវផល... នូវនិព្វាន... និព្វានជាបច្ច័យនៃការពិចារណា នូវគោត្រភូវោទានៈ មគ្គនិងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈពិចារណានូវពួកកិលេស ដែលលះបង់ហើយ នូវពួកកិលេសដែលសង្កត់សង្កិនហើយ... ក្នុងកាលមុន ។បេ។ នូវពួកផោដ្ឋព្វៈ... នូវពួកនោឧបាទាខន្ធថាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយនោឧបាទាចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកនោឧបាទាខន្ធ ជាបច្ច័យនៃការពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៣១ ] ឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអធិបតិប្បច្ច័យ

បានដល់ អារម្មណាធិបតិ គឺបុគ្គល នូវចក្ខុ... នូវកាយ ពួករូប ពួករស... ធ្វើនូវវត្ថុ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវវត្ថុនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហ-ជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គល នូវទាន... នូវសីល... ធ្វើនូវឧបោសថកម្ម ធ្វើនូវកុសលនោះឲ្យជាទីគោរព ហើយពិចារណា ត្រេកអររីករាយ រាគៈកើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង នូវពួកកុសលដែលសន្សំហើយ ក្នុងកាលមុន... ចេញអំពីឈាន នូវឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព... នូវផល... នូវនិព្វាន... និព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គនិងផល ដោយអធិបតិប្បច្ច័យ បុគ្គលនូវពួកផោដ្ឋព្វៈ... ធ្វើនូវពួកនោឧបាទាខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវវត្ថុនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺនោឧបាទាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជានោឧបាទាផងដោយអធិបតិប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ ដោយអធិ-បតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺនោឧបាទាធិបតិធម៌ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាឧបាទា ដោយអធិបតិប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺនោឧបាទាធិបតិធម៌ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង

នៃពួកចិត្តសមុដ្ឋានរូបជាឧបាទានិងជានោឧបាទាផង ដោយអធិបតិប្បច្ច័យ ។

[ ៣២ ] នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោឧបាទាខន្ធមុនៗ ជាបច្ច័យនៃពួកនោឧបាទាខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ និងផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យ ដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ ដូចគ្នានឹងនិស្សយប្បច្ច័យ ក្នុងបច្ចយវារៈដែរ ។

[ ៣៣ ] ឧបាទាធម៌ជាបច្ច័យនៃនោឧបាទាធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលនូវចក្ខុសម្បទា... នូវកាយសម្បទា វណ្ណសម្បទា គន្ធសម្បទានិងរសសម្បទា... អាស្រ័យនូវភោជន ហើយឲ្យទាន ។បេ។ បំបែកសង្ឃ ចក្ខុសម្បទា... កាយសម្បទា វណ្ណសម្បទា គន្ធសម្បទា រសសម្បទា... ភោជន ជាបច្ច័យនៃសទ្ធា និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយឲ្យទាន ។បេ។ ញុំាងសមាបត្តិឲ្យកើត ដំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល... នូវសទ្ធា ។បេ។ នូវសេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ និងវដូវ... អាស្រ័យនូវសេនា-

សនៈ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៣៤ ] ឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលនូវចក្ខុ ។បេ។ នូវវត្ថុថាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ រសាយតនៈ ( ជាបច្ច័យ ) នៃជិវ្ហាវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុ ជាបច្ច័យនៃពួកនោឧបាទាខន្ធ ដោយបុរេជាតប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត គឺនូវពួកផោដ្ឋព្វៈ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី ជាបច្ច័យនៃនោឧបាទាធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ ផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកនោឧបាទាខន្ធ ដោយបុរេជាតប្បច្ច័យ ផោដ្ឋព្វាយតនៈក្តី កាយាយតនៈក្តី ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។

[ ៣៥ ] នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃនោឧបាទាកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ បណ្ឌិតគប្បីសួរមូល

ផងចុះ បច្ឆាជាត គឺពួកនោឧបាទាខន្ធជាបច្ច័យ នៃឧបាទាកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ បណ្ឌិតគប្បីសួរមូលផងចុះ បច្ឆាជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃឧបាទាកាយ និងនោឧបាទាកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ ។

[ ៣៦ ] នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺនោឧបាទាចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជានោឧបាទាផង ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។ ឯនានាខណិកៈ គឺនោឧបាទា-ចេតនាជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបជានោឧបាទាផង ដោយកម្មប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺនោឧបាទាចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាឧបាទាដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិ-សន្ធិ... ។ ឯនានាខណិកៈ គឺនោឧបាទាចេតនា ជាបច្ច័យនៃពួកកដត្តារូបជាឧបាទា ដោយកម្មប្បច្ច័យ ។ នោឧបាទាធម៌ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺនោឧបាទាចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាឧបាទានិងជានោឧបាទាផង ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។ ឯនានាខណិកៈ គឺនោឧបាទាចេតនា ជាបច្ច័យនៃពួកវិបា-កក្ខន្ធផង នៃពួកកដត្តារូបជាឧបាទានិងជានោឧបាទាផង ដោយកម្មប្បច្ច័យ ។

[ ៣៧ ] នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ជានោឧបាទា នៃខន្ធ ៣ ... ជាបដិសន្ធិ មានវារៈ ៣ ។

[ ៣៨ ] នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ ដោយអាហារប្បច្ច័យ គឺកពឡិង្ការាហារ ជាបច្ច័យនៃឧបាទាកាយនេះ ដោយអាហារប្បច្ច័យ ។ បណ្ឌិតគប្បីសួរនូវមូលផងចុះ កពឡិង្ការាហារ ជាបច្ច័យនៃនោឧបាទាកាយនេះ ដោយអាហារប្បច្ច័យ ។ បណ្ឌិតគប្បីសួរមូលផងចុះ កពឡិង្ការាហារ ជាបច្ច័យនៃឧបាទាកាយ និងនោឧបាទាកាយនេះ ដោយអាហារប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអាហារប្បច្ច័យ គឺពួកនោ-ឧបាទាអាហារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបជានោឧបាទាផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ វារៈ ៣ ក្នុងនោឧបាទាមូលកៈ ជាបដិសន្ធិ ។

[ ៣៩ ] ឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺរូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ជាឧបាទា ដោយឥន្ទ្រិយប្បច្ច័យ ។ បណ្ឌិតគប្បីសួរមូលផងចុះ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កា-យិន្ទ្រិយ... រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ជានោឧបាទា ដោយឥន្ទ្រិយប្បច្ច័យ ។ បណ្ឌិតគប្បីសួរមូលផងចុះ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូបជាឧបាទា និងជានោឧបាទា ដោយឥន្ទ្រិយប្បច្ច័យ ។ នោឧបា-ទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ជាបដិសន្ធិទៀត ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី ជាបច្ច័យនៃនោឧបាទាធម៌

ដោយឥន្ទ្រិយប្បច្ច័យ គឺចក្ខុន្ទ្រិយក្តី ចក្ខុវិញ្ញាណក្តី ជាបច្ច័យនៃពួកខន្ធដែលប្រទ្បំ ដោយចក្ខុវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ កាយិន្ទ្រិយ... ។

[ ៤០ ] នោឧបាទាធម៌ជាបច្ច័យនៃនោឧបាទាធម៌ ដោយឈានប្បច្ច័យ មានវារៈ ៣ ។ ... ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៣ ជាបដិសន្ធិបណ្ឌិតគប្បីធ្វើចុះ ។ ... ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ១ ។

[ ៤១ ] ឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកនោឧបាទាខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកនោឧបាទាខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃនោឧ-បាទាធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ ស-ហជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជានោឧបាទា ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកនោឧបាទាខន្ធ ជាបច្ច័យនៃពួកកដត្តារូប ជានោឧបាទា ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃនោឧបាទាកាយនេះ ដែលកើតមុន ដោយវិប្ប-យុត្តប្បច្ច័យ ។ នោឧបាទាធម៌ជាបច្ច័យនៃឧបាទាធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺនោឧបាទាខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាឧបាទា ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិ-សន្ធិ... ។ ឯបច្ឆាជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃឧបាទាកាយនេះដែល

កើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាឧបាទានិងជានោឧបាទា ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។ ឯបច្ឆាជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃឧបាទាកាយ និងនោឧបាទាកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤២ ] ឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ ដោយអត្ថិប្បច្ច័យ បានដល់ អាហារនិងឥន្ទ្រិយ ។ កពឡិង្ការាហារ ជាបច្ច័យនៃឧបាទាកាយនេះ ដោយអត្ថិប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូបជាឧបាទា ដោយអត្ថិប្បច្ច័យ ។ ឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃពួកខន្ធជានោឧបាទា ដោយអត្ថិប្បច្ច័យ ។ បុរេជាត គឺនូវចក្ខុជាមិនទៀង ។ សេចក្តីបំប្រួញ ។ ដូចគ្នានឹងបុរេជាតប្បច្ច័យដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ កពឡិង្ការាហារ ជាបច្ច័យនៃនោឧបាទាកាយនេះ ដោយអត្ថិប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូបជានោឧបាទា ដោយអត្ថិប្បច្ច័យ ។ ឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ អាហារនិងឥន្ទ្រិយ ។ កពឡិង្ការាហារ ជាបច្ច័យនៃឧបាទាកាយ និងនោឧបាទាកាយនេះ ដោយអត្ថិប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូបជាឧបាទានិងជានោឧបាទា

ដោយអត្ថិប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺខន្ធ ១ ជានោឧបាទា ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូប ជានោឧបាទាផង ដោយអត្ថិប្បច្ច័យ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ មហាភូត ១ ជាបច្ច័យនៃមហាភូត ៣ ដោយអត្ថិប្បច្ច័យ ។បេ។ មហាភូត ២ ជាបច្ច័យនៃមហាភូត ២ ដោយអត្ថិប្បច្ច័យ រហូតដល់ពួកអសញ្ញសត្វ ។ បុរេជាត គឺនូវពួកផោដ្ឋព្វៈ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃនោឧបាទាកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ជាឧបាទា ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។ ឯបច្ឆាជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃឧបាទាកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆា-ជាត ។ សហជាត គឺខន្ធ ១ ជានោឧបាទា ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូប ជាឧបាទានិងជានោឧបាទាផង ដោយអត្ថិប្បច្ច័យ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ... ។ ឯបច្ឆាជាត គឺពួកនោឧបាទាខន្ធ ជាបច្ច័យនៃឧបាទាកាយ និងនោឧបាទាកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី ជាបច្ច័យនៃឧបាទាធម៌ ដោយអត្ថិប្បច្ច័យ បាន ដល់ បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ បច្ឆាជាត គឺពួកនោឧបាទាខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃឧបាទាកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកនោឧបាទាខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ជាឧបាទា ដោយអត្ថិប្បច្ច័យ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី ជាបច្ច័យនៃនោឧបាទាធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយចក្ខុវិញ្ញាណក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ជានោឧបាទាក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ជានោឧបាទាក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ។ បុរេជាត គឺផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកនោឧបាទាខន្ធ ដោយអត្ថិប្បច្ច័យ ផោដ្ឋព្វាយតនៈក្តី កាយាយតនៈក្តី ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកនោឧបាទាខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃនោឧបាទាកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកនោឧបាទាខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ជានោឧបាទា ដោយអត្ថិប្បច្ច័យ ។ ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ បច្ឆាជាត គឺពួកនោឧបាទាខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃឧបាទាកាយនិងនោឧបាទាកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆា-

ជាត គឺពួកនោឧបាទាខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ជាឧបាទានិងជានោឧបាទា ដោយអត្ថិប្បច្ច័យ ។

[ ៤៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៦ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤៤ ] ឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទាធម៌ ជាបច្ច័យនៃនោឧបាទាធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទាធម៌ជាបច្ច័យនៃឧបាទាធម៌

ផង នៃនោឧបាទាធម៌ផង ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិ-
យប្បច្ច័យ ។ នោឧបាទាធម៌ជាបច្ច័យនៃនោឧបាទាធម៌ ដោយអារម្មណប្បច្ច័យ
ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជា
បច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ
ដោយកម្មប្បច្ច័យ ។ នោឧបាទាធម៌ជាបច្ច័យនៃឧបាទាធម៌ ដោយសហជា-
តប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។
នោឧបាទាធម៌ ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយស-
ហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។
ឧបាទាធម៌ក្តី នោឧបាទាធម៌ក្តី ជាបច្ច័យនៃឧបាទាធម៌ ដោយបច្ឆាជាតប្បច្ច័យ
ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទាធម៌
ក្តី នោឧបាទាធម៌ក្តី ជាបច្ច័យនៃនោឧបាទាធម៌ ដោយសហជាតប្បច្ច័យ ជា
បច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ
ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទាធម៌ក្តី នោ-
ឧបាទាធម៌ក្តី ជាបច្ច័យនៃឧបាទាធម៌ផង នៃនោឧបាទាធម៌ផង ដោយបច្ឆាជា-
តប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៤៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន
វារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ
មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោអត្ថិប្បច្ច័យ មាន
វារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩

ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៤៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៤៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ។ សេចក្តីបំប្រួញ ។ អនុលោមមាតិកា បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

**ចប់ ឧបាទានុកៈ ។**

# ឧបាទិន្នទុកៈ

## បដិច្ចវារៈ

[ ៤៨ ] ឧបាទិន្នធម៌ ( ធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ) អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាឧបាទិន្ន នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ ជាឧបាទិន្ន

នូវខន្ធ ២ ... វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ អនុបាទិន្នធម៌ ( ធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនបានកាន់យកហើយ ) អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទិន្នក្ខន្ធ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាឧបាទិន្ន នូវខន្ធ ២ ... ។ អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាអនុបាទិន្ន នូវខន្ធ ២ ... អាស្រ័យនូវមហាភូត ១ ... ចិត្តសមុដ្ឋានរូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ អនុបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ផង នូវអនុបាទិន្នធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទិន្នក្ខន្ធផង នូវពួកមហាភូតផង ។

[ ៤៩ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាឧបាទិន្ន នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធអាស្រ័យនូវវត្ថុ ។ អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអនុបាទិន្ន នូវខន្ធ ២ ... ។

[ ៥០ ] អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង

ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាអនុបាទិន្ន នូវខន្ធ ២ ... អាស្រ័យនូវមហាភូត ១ ... ចិត្តសមុដ្ឋានរូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ សេចក្តីបំប្រួញ ។

[ ៥១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអាហារប្បច្ច័យ មានវារៈ ៥ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៥ ក្នុងឈានប្បច្ច័យ មានវារៈ ៥ ក្នុងមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ២ ក្នុងវិគតប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៥២ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាឧបាទិន្ន នូវខន្ធ ២ ... ក្នុងអហេតុកប្បដិសន្ធិក្ខណៈ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវខន្ធ ១ ជាឧបាទិន្ន នូវខន្ធ ២ ... វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ អាស្រ័យនូវមហាភូត ១ ... កដត្តារូបនិងឧបាទារូប អាស្រ័យនូវ

ពួកមហាភូត អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ... កដត្តារូប និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ អនុបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកអហេតុកក្ខន្ធ ជាឧបាទិន្ន ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាឧបាទិន្ន នូវខន្ធ ២ ... ។ អនុបាទិន្នធម៌អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអហេតុកក្ខន្ធ ១ ជាអនុបាទិន្ន នូវខន្ធ ២ ... មហាភូត ១ ... ចិត្តសមុដ្ឋានរូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ពាហិរ... អាហារសមុដ្ឋាន... មហាភូត ១ មានរដូវជាសមុដ្ឋាន... ឧបាទារូបអាស្រ័យនូវពួកមហាភូត មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ អនុបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ផង នូវអនុបាទិន្នធម៌ផង ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកអហេតុកក្ខន្ធ ជាឧបាទិន្នផង នូវពួកមហាភូតផង ។

[ ៥៣ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺក្នុងខណៈនៃបដិសន្ធិ កដត្តារូបអាស្រ័យនូវពួក ឧបាទិន្នក្ខន្ធ វត្ថុអាស្រ័យនូវពួកខន្ធ មហាភូត ១ ... កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត មហាភូត ១ របស់ពួកអសញ្ញសត្វ... កដត្តារូប

និងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ អនុបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទិន្នក្ខន្ធ ។ អនុបាទិន្នធម៌អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវអនុបាទិន្នក្ខន្ធ មហាភូត ១ ... ពាហិរ... អាហារសមុដ្ឋាន... មហាភូត ១ មានវដ្ដជាសមុដ្ឋាន... ឧបាទារូប អាស្រ័យនូវពួកមហាភូត ។ អនុបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ផង នូវអនុបាទិន្នធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទិន្នក្ខន្ធផង នូវពួកមហាភូតផង ។

[ ៥៤ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។ ... ព្រោះនអនន្តរប្បច្ច័យ ព្រោះនសមនន្តរប្បច្ច័យ ព្រោះនអញ្ញមញ្ញប្បច្ច័យ ព្រោះនឧបនិស្សយប្បច្ច័យ ។

[ ៥៥ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាឧបាទិន្ន ក្នុងអរូប នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្ដី កដត្តារូបក្ដី អាស្រ័យនូវខន្ធ ១ ជាឧបាទិន្ន រហូតដល់ពួកអសញ្ញសត្វ ។ អនុបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទិន្នក្ខន្ធ ។ អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអនុបាទិន្ន

ក្នុងអរូប នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកអនុបាទិន្នកូន មហាភូត ១ មាននូវជាសមុដ្ឋាន រហូតដល់ពួកអសញ្ញសត្វ ។ អនុបាទិន្ន- ធម៌ អាស្រ័យនូវឧបាទិន្នធម៌ផង នូវអនុបាទិន្នធម៌ផង ទើបកើតឡើង ព្រោះ នបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទិន្នកូនផង នូវពួក មហាភូតផង ។ ... ព្រោះនបច្ឆាជាតប្បច្ច័យ ព្រោះនអាសេវនប្បច្ច័យ ។

[ ៥៦ ] អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើងព្រោះ នកម្មប្បច្ច័យ គឺអនុបាទិន្នចេតនា អាស្រ័យនូវពួកអនុបាទិន្នកូន ពាហិរ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ។បេ។ ឧបាទារូបអាស្រ័យនូវពួក មហា- ភូត ។

[ ៥៧ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះ នវិបាកប្បច្ច័យ គឺមហាភូត ១ របស់ពួកអសញ្ញសត្វ... កដត្តារូបនិងឧបា- ទារូប អាស្រ័យនូវពួកមហាភូត ។ អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវខន្ធ ១ ជាអនុបាទិន្ន នូវខន្ធ ២ ... មហាភូត ១ មាននូវជាសមុដ្ឋាន រហូតតទៅ ។

[ ៥៨ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះ នអាហារប្បច្ច័យ គឺមហាភូត ១ របស់ពួកអសញ្ញសត្វ... ។ អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនអាហារប្បច្ច័យ គឺពាហិរ... ឧតុសមុដ្ឋាន... ។បេ។

[ ៥៩ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនឥន្ទ្រិយប្បច្ច័យ គឺរូបជីវិតិន្ទ្រិយ អាស្រ័យនូវពួកមហាភូត របស់ពួកអសញ្ញសត្វ ។ អនុបាទិន្នធម៌អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនឥន្ទ្រិយប្បច្ច័យ គឺពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ។បេ។

[ ៦០ ] ឧបាទិន្នធម៌អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយបញ្ចវិញ្ញាណ នូវខន្ធ ២ ... របស់ពួកអសញ្ញសត្វ ។បេ។ អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនឈានប្បច្ច័យ គឺពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ។បេ។

[ ៦១ ] ឧបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនមគ្គប្បច្ច័យ គឺដូចគ្នានឹងនហេតុប្បច្ច័យដែរ មោហៈមិនមានទេ ។ ... ព្រោះនសម្បយុត្តប្បច្ច័យ ។

[ ៦២ ] អនុបាទិន្នធម៌ អាស្រ័យនូវឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាឧបាទិន្ន ក្នុងអរូប នូវខន្ធ ២ ... អាស្រ័យនូវមហាភូត ១ របស់ពួកអសញ្ញសត្វ... ។ អនុបាទិន្នធម៌ អាស្រ័យនូវអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាអនុបាទិន្ន ក្នុងអរូប នូវខន្ធ ២ ... ពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ។បេ។ ... ព្រោះនោនត្ថិប្បច្ច័យ ព្រោះនោវិគតប្បច្ច័យ ។

[ ៦៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៤ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនអាហារប្បច្ច័យ មានវារៈ ២ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៦៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៦៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុង

និស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈ ដូចជាបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៦៦ ] ឧបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងខន្ធ ១ ជាឧបាទិន្ន នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី កដត្តារូបក្តី ពឹងផ្អែកនឹងខន្ធ ១ ជាឧបាទិន្ន នឹងខន្ធ ២ ... វត្ថុពឹងផ្អែកនឹងពួកខន្ធ ពួកខន្ធ ពឹងផ្អែកនឹងវត្ថុ មហាភូត ១ ... កដត្តារូបនិងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ពួកឧបាទិន្នក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកឧបាទិន្នក្ខន្ធ ពួកអនុបាទិន្នក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ជាឧបាទិន្ន នឹងខន្ធ ២ ... មហាភូត ១ ... ចិត្តសមុដ្ឋានរូបនិងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ។ អនុបាទិន្នធម៌ ពឹង

ផ្អែក និងអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ជាអនុបាទិន្ន នឹងខន្ធ ២ ... មហាភូត ១ ... ចិត្តសមុដ្ឋានរូបនិងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ផង នឹងអនុបាទិន្នធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបពឹងផ្អែកនឹងពួកឧបាទិន្នក្ខន្ធផង នឹងពួកមហាភូតផង ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាអនុបាទិន្នផង នឹងវត្ថុផង នឹងខន្ធ ២ ... ។

[ ៦៧ ] ឧបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាឧបាទិន្ន នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធពឹងផ្អែកនឹងវត្ថុ ចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកឧបាទិន្នក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកអនុបាទិន្នក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាអនុបាទិន្ន នឹងខន្ធ ២ ... ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ផង នឹងអនុបាទិន្នធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាអនុបាទិន្នផង នឹងវត្ថុផង នឹងខន្ធ ២ ... ។

[ ៦៨ ] អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺពួកអនុបាទិន្នក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ អនុបាទិន្នធម៌ ពឹង

ផ្អែកនឹងអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ជាអនុបាទិន្ន នឹងខន្ធ ២ ... មហាភូត ១ ... ចិត្តសមុដ្ឋានរូប និងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ផង នឹងអនុបាទិន្នធម៌ផង ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាអនុបាទិន្នផង នឹងវត្ថុផង នឹងខន្ធ ២ ... ។ សេចក្តីបំប្រួញ ។

[ ៦៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៤ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៧០ ] ឧបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ជាឧបាទិន្ន នឹងខន្ធ ២ ... ក្នុងអហេតុកប្បដិសន្ធិក្ខណៈ វត្ថុពឹងផ្អែកនឹងពួកខន្ធ ឯពួកខន្ធពឹងផ្អែកនឹងវត្ថុ មហាភូត ១ ... កដត្តារូបនិងឧបាទារូប ពឹងផ្អែកនឹងពួកមហាភូត មហាភូត ១ របស់ពួកអសញ្ញសត្វ... ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែកនឹងកាយាយតនៈ ពួកឧបាទិន្នក្ខន្ធជាអហេតុកៈ ពឹង

ផ្អែកនឹងវត្ថុ ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកអហេតុកក្ខន្ធ ជាឧបាទិន្ន ពួកអហេតុកក្ខន្ធ ជាអនុបាទិន្ន ពឹងផ្អែកនឹងវត្ថុ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ជាឧបាទិន្ន នឹងខន្ធ ២ ... ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ជាអនុបាទិន្ន នឹងខន្ធ ២ ... មហាភូត ១ ... ពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ អនុបាទិន្នធម៌ ពឹងផ្អែកនឹងឧបា-ទិន្នធម៌ផង នឹងអនុបាទិន្នធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងអហេតុកក្ខន្ធជាឧបាទិន្នផង នឹងពួកមហាភូតផង ខន្ធ ៣ ពឹងផ្អែកនឹងអហេតុកក្ខន្ធ ១ ជាអនុបាទិន្នផង នឹងវត្ថុផង នឹងខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សេចក្តីបំប្រួញ ។

[ ៧១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤

ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ២ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៧២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ។បេ។ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៧៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

និស្សយវារៈ ដូចគ្នានឹងបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ៧៤ ] ឧបាទិន្នធម៌ ប្រឡំនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំនឹងខន្ធ ១ ជាឧបាទិន្ន នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ អនុបាទិន្នធម៌ ប្រឡំនឹងអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំនឹងខន្ធ ១ ជាអនុបាទិន្ន នឹងខន្ធ ២ ... ។

[ ៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ៧៦ ] ឧបាទិន្នធម៌ ប្រឡំនឹងឧបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំនឹងអហេតុកក្ខន្ធ ១ ជាឧបាទិន្ន នឹងខន្ធ ២ ... ក្នុងអហេតុកប្បដិសន្ធិក្ខណៈ ។បេ។ អនុបាទិន្នធម៌ ប្រឡំនឹងអនុបាទិន្នធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំនឹងអហេតុកក្ខន្ធ ១ ជា

អនុបាទិន្ន នឹងខន្ធ ២ ... មោហៈដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ច្រឡំ នឹងពួកខន្ធដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ។

[ ៧៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងន-មគ្គប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

ការរាប់ ២ យ៉ាង ក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ៧៨ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយហេតុប្បច្ច័យ គឺពួកឧបាទិន្នហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកឧបាទិន្នហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ដោយហេតុប្បច្ច័យ ។ ឧបាទិន្នធម៌ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយហេតុប្បច្ច័យ គឺពួកឧបាទិន្នហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយហេតុប្បច្ច័យ គឺពួកឧបាទិន្នហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ អនុបាទិន្នធម៌ ជា

បច្ច័យនៃអនុបាទិន្នធម៌ ដោយហេតុប្បច្ច័យ គឺពួកអនុបាទិន្នហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ៧៩ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) នូវចក្ខុ... នូវកាយ ពួករូបជាឧបាទិន្នៈ ពួកគន្ធៈ ពួករសៈ ពួកផោដ្ឋព្វៈនិងវត្ថុ... នូវឧបាទិន្នក្ខន្ធ ថាមិនទៀង ។បេ។ ទោមនស្ស កើតឡើង កាលកុសលាកុសល រលត់ហើយ វិបាក ក៏កើតឡើង ព្រោះមានកុសលាកុសលនោះជាអារម្មណ៍ រូបាយតនៈ ជាឧបាទិន្ន ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ គន្ធាយតនៈ ជាឧបាទិន្ន ( ជាបច្ច័យ ) នៃឃានវិញ្ញាណ ។បេ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) នូវចក្ខុ... នូវកាយ ពួករូបជាឧបាទិន្ន ពួកគន្ធៈ ពួករសៈ ពួកផោដ្ឋព្វៈនិងវត្ថុ... នូវពួកខន្ធ ជាឧបាទិន្ន ថាមិនទៀង ។បេ។ ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូប ជាឧបាទិន្ន ដោយទិព្វចក្ខុ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយឧបាទិន្នចិត្ត ដោយចេតោបរិយញ្ញាណ ពួកឧបាទិន្នក្ខន្ធជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) នូវទាន... នូវសីល... ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ត្រេកអររីករាយ រាគៈ ប្រារព្ធនូវកុសលនោះ ។បេ។ ទោមនស្ស កើតឡើង នូវពួក

កុសលដែលសន្សំហើយ ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈចេញអំពីមគ្គ ហើយពិចារណានូវមគ្គ នូវផល... នូវនិព្វាន... និព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទាន: មគ្គនិងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេស ដែលលះបង់ហើយ... នូវពួកកិលេសដែលសង្កត់សង្កិនហើយ... នូវពួកកិលេស ដែលសន្សំហើយ ក្នុងកាលមុន... នូវពួករូបជាអនុបាទិន្ន... នូវពួកសំឡេង... នូវពួកផោដ្ឋព្វៈ... នូវពួកខន្ធ ជាអនុបាទិន្ន ជាមិនទៀង ។បេ។ ទោមនស្សកើតឡើង ឃើញនូវរូបជាអនុបាទិន្ន ដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយអនុបាទិន្នចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ ពួកអនុបាទិន្នក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ អនុបាទិន្នធម៌ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ... នូវពួករូបជាអនុបាទិន្ន... នូវពួកសំឡេង... នូវពួកផោដ្ឋព្វៈ... នូវពួកអនុបាទិន្នក្ខន្ធ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង កាលកុសលាកុសលរលត់ហើយ វិបាកកើតឡើង ព្រោះមានកុសលាកុសលនោះជាអារម្មណ៍ អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ

ជាអនុបាទិន្ន ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ សទ្ទាយតនៈ... ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៨០ ] ឧបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ ( បុគ្គល ) នូវចក្ខុ... នូវកាយ នូវពួករូប ជាឧបាទិន្ន ពួកគន្ធៈ ពួករសៈ ពួកផោដ្ឋព្វៈនិងវត្ថុ... ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកឧបាទិន្នក្ខន្ធ ឲ្យជាទីគោរព រាគៈកើតឡើង ព្រោះធ្វើនូវហេតុនោះឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) នូវទាន... នូវសីល... ធ្វើនូវឧបោសថកម្ម ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ។បេ។ ទិដ្ឋិ... ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា នូវផល... នូវនិព្វាន... និព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គនិងផល ដោយអធិបតិប្បច្ច័យ នូវពួកអនុបាទិន្នរូប... នូវពួកសំឡេង... នូវពួកផោដ្ឋព្វៈ... រាគៈធ្វើនូវពួកអនុបាទិន្នក្ខន្ធ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ជាអនុបាទិន្ន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៨១ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអនន្តរប្បច្ច័យ គឺ ពួកឧបាទិន្នក្ខន្ធមុនៗ ជាបច្ច័យនៃពួកឧបាទិន្នក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ

បញ្ចវិញ្ញាណ ជាបច្ច័យនៃវិបាកមនោធាតុ ដោយអនន្តរប្បច្ច័យ វិបាកមនោ-ធាតុជាបច្ច័យនៃវិបាកមនោវិញ្ញាណធាតុ ដោយអនន្តរប្បច្ច័យ ។ ឧបាទិន្នធម៌ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអនន្តរប្បច្ច័យ គឺភវង្គ ( ជាបច្ច័យ ) នៃអាវជ្ជនៈ វិបាកមនោវិញ្ញាណធាតុ ជាបច្ច័យនៃកិរិយាមនោវិញ្ញាណធាតុ ដោយអនន្តរប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអនន្តរប្បច្ច័យ គឺពួកអនុបាទិន្នក្ខន្ធមុនៗ ជាបច្ច័យនៃពួកឧបាទិន្នក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកអនុបាទិន្នក្ខន្ធជាបច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ និងផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ អនុបាទិន្នធម៌ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនៈ ( ជាបច្ច័យ ) នៃបញ្ចវិញ្ញាណ ពួកអនុបាទិន្នក្ខន្ធ ជាបច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យ ដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ គឺមានវារៈ ៥ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺមានវារៈ ២ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺមានវារៈ ៥ ដូចគ្នានឹងនិស្សយប្បច្ច័យ ក្នុងបច្ចយវារៈដែរ ។

[ ៨២ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺកាយិកសុខជាបច្ច័យនៃកាយិកសុខនិងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ កាយិកទុក្ខ... រដូវជាឧបាទិន្ន... ភោជនជាបច្ច័យនៃកាយិកសុខនិងកាយិក-

ទុក្ខ ដោយឧបនិស្សយប្បច្ច័យ កាយិកសុខ... កាយិកទុក្ខ... រដូវ... ភោជន ជាបច្ច័យនៃកាយិកសុខនិងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវកាយិកសុខ ហើយឲ្យទាន ។បេ។ បំបែកសង្ឃ នូវកាយិកទុក្ខ... នូវរដូវជាឧបាទិន្ន... អាស្រ័យនូវភោជន ហើយឲ្យទាន ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ។បេ។ បំបែកសង្ឃ កាយិកសុខ... កាយិកទុក្ខ... រដូវ... ភោជនជាបច្ច័យនៃសទ្ធា ។បេ។ នៃសេចក្តីប្រាថ្នា មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយឲ្យទាន ដំឡើងមានះ ប្រកាន់ទិដ្ឋិ សីល ។បេ។ នូវសេចក្តីប្រាថ្នា... នូវរដូវ... នូវភោជន... អាស្រ័យនូវសេនាសនៈហើយឲ្យទាន ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេចក្តីប្រាថ្នា... រដូវ... ភោជន... សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃសេចក្តីប្រាថ្នា មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយញុំាងខ្លួនឲ្យក្តៅ ឲ្យក្តៅសព្វ ការស្វែងរក... សីល ។បេ។ នូវសេចក្តីប្រាថ្នា... នូវរដូវ... នូវ

ភោជន... បុគ្គលអាស្រ័យនូវសេនាសនៈ ហើយញុំាងខ្លួនឲ្យក្តៅ ឲ្យក្តៅសព្វ ការស្វែងរក... សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃកាយិកសុខនិងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ កុសលាកុសលកម្ម ជាបច្ច័យនៃវិបាក ដោយឧបនិស្សយប្បច្ច័យ ។

[ ៨៣ ] ឧប្បាទិន្នធម៌ ជាបច្ច័យនៃឧប្បាទិន្នធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាតគឺ ( បុគ្គល ) នូវចក្ខុ... នូវកាយ នូវពួករូបជាឧប្បាទិន្ន ពួកគន្ធៈ ពួកផោដ្ឋព្វៈ... ។បេ។ នូវវត្ថុ ជាមិនទៀង ។បេ។ ទោមនស្ស... កាលកុសលាកុសល រលត់ហើយ វិបាកកើតឡើង ព្រោះមានកុសលាកុសលនោះជាអារម្មណ៍ រូបាយតនៈ ជាឧប្បាទិន្ន ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ គន្ធាយតនៈ... ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកឧប្បាទិន្នក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ ឧប្បាទិន្នធម៌ ជាបច្ច័យនៃអនុប្បាទិន្នធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ... នូវកាយ នូវពួករូប ជាឧប្បាទិន្ន ពួកគន្ធៈ ពួករសៈ ពួកផោដ្ឋព្វៈ... នូវវត្ថុ ជាមិនទៀង ។បេ។ ទោមនស្សកើតឡើង បុគ្គលឃើញនូវរូបជាឧប្បាទិន្ន ដោយទិព្វចក្ខុ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកអនុប្បាទិន្នក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ អនុប្បាទិន្នធម៌ ជាបច្ច័យនៃអនុប្បាទិន្នធម៌ ដោយបុរេជាតប្បច្ច័យ

បានដល់ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវពួករូប ជាអនុបាទិន្ន... នូវពួកសំឡេង... នូវពួកក្លិន... នូវពួកផោដ្ឋព្វៈ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង ឃើញនូវរូប ជាអនុបាទិន្ន ដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវពួករូប ជាអនុបាទិន្ន... នូវពួកគន្ធៈ... នូវពួកផោដ្ឋព្វៈ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង កាលកុសលាកុសល រលត់ហើយ វិបាកកើតឡើង ព្រោះកុសលាកុសល នោះជាអារម្មណ៍ រូបាយតនៈ ជាអនុបាទិន្ន ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ សទ្ទាយតនៈ... ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ វត្ថុជាបច្ច័យនៃពួកឧបាទិន្នក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃឧបាទិន្នធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ រូបាយតនៈ ជាអនុបាទិន្នក្តី វត្ថុក្តី ផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកឧបាទិន្នក្ខន្ធ ដោយបុរេជាតប្បច្ច័យ រូបាយតនៈជាអនុបាទិន្នក្តី ចក្ខាយតនៈក្តី ជាបច្ច័យនៃចក្ខុវិញ្ញាណ សទ្ទាយតនៈក្តី... ផោដ្ឋព្វាយតនៈក្តី កាយាយតនៈក្តី ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ រូបាយតនៈ ជាអនុបាទិន្នក្តី វត្ថុក្តី ផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកអនុបាទិន្នក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

[ ៨៤ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកឧបាទិន្នក្ខន្ធ ជាបច្ច័យនៃឧបាទិន្នកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកឧបាទិន្នក្ខន្ធ ជាបច្ច័យនៃអនុបាទិន្នកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ អនុបាទិន្នធម៌ជាបច្ច័យនៃឧបាទិន្នធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។

[ ៨៥ ] អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអាសេវនប្បច្ច័យ ។

[ ៨៦ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយកម្មប្បច្ច័យ គឺឧបាទិន្នចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ឧបាទិន្នចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយកម្មប្បច្ច័យ គឺឧបាទិន្នចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយកម្មប្បច្ច័យ គឺឧបាទិន្នចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃ

ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃ អនុបាទិន្នធម៌ ដោយកម្មប្បច្ច័យ គឺអនុបាទិន្នចេតនា ជាបច្ច័យនៃពួកសម្ប- យុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយកម្មប្បច្ច័យ បានដល់ នានាខណិកៈ គឺ អនុបាទិន្នចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយ កម្មប្បច្ច័យ ។

[ ៨៧ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយវិបាកប្បច្ច័យ គឺ ឧបាទិន្នក្ខន្ធ ១ ។ សេចក្តីបំប្រួញ ។ ក្នុងឧបាទិន្នមូលកៈ មានវារៈ ៣ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយវិបាកប្បច្ច័យ គឺអនុបាទិន្នក្ខន្ធ ១ ជាវិបាក ជាបច្ច័យនៃខន្ធ ៣ ផង នៃចិត្តសមុដ្ឋានរូបផង ដោយវិបា- កប្បច្ច័យ ខន្ធ ២ ... ។

[ ៨៨ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអាហារប្បច្ច័យ គឺ ពួកអាហារជាឧបាទិន្ន ជាបច្ច័យ គឺជាបដិសន្ធិនៃពួកសម្បយុត្តកក្ខន្ធ ដោយ អាហារប្បច្ច័យ កពឡិង្ការាហារ ជាឧបាទិន្ន ជាបច្ច័យនៃឧបាទិន្នកាយនេះ ដោយអាហារប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអា- ហារប្បច្ច័យ គឺពួកអាហារជាឧបាទិន្ន ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប កព- ឡិង្ការាហារជាឧបាទិន្ន ជាបច្ច័យនៃអនុបាទិន្នកាយនេះ ដោយអាហារប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយអាហា- រប្បច្ច័យ គឺពួកអាហារ ជាឧបាទិន្ន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃ

ពួកចិត្តសមុដ្ឋានរូបផង កពឡីង្ការាហារជាបច្ច័យនៃកាយនេះ ដែលជាឧបាទិន្ន និងជាអនុបាទិន្ន ដោយអាហារប្បច្ច័យ ។ អនុបាទិន្នធម៌ជាបច្ច័យនៃអនុបា-ទិន្នធម៌ ដោយអាហារប្បច្ច័យ គឺពួកអាហារជាអនុបាទិន្ន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កព-ឡីង្ការាហារ ជាអនុបាទិន្នជាបច្ច័យ នៃអនុបាទិន្នកាយនេះ ដោយអាហា-រប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអាហារប្បច្ច័យ គឺកពឡីង្ការាហារ ជាអនុបាទិន្ន ជាបច្ច័យនៃឧបាទិន្នកាយនេះ ដោយអាហា-រប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយអាហារប្បច្ច័យ គឺកពឡីង្ការាហារ ជាអនុបាទិន្ន ជាបច្ច័យនៃកាយនេះ ជាឧបាទិន្ននិងជាអនុបាទិន្ន ដោយអាហារប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបា-ទិន្នធម៌ក្តី ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអាហារប្បច្ច័យ គឺកពឡីង្ការាហារ ជាឧបាទិន្នក្តី ជាអនុបាទិន្នក្តី ជាបច្ច័យនៃកាយនេះជាឧបាទិន្ន ដោយអាហា-រប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអាហារប្បច្ច័យ គឺកពឡីង្ការាហារ ជាឧបាទិន្នក្តី ជាអនុបាទិន្នក្តី ជាបច្ច័យនៃកាយនេះជាអនុបាទិន្ន ដោយអាហារប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយអាហារប្បច្ច័យ គឺកពឡីង្ការាហារ ជាឧបាទិន្នក្តី ជាអនុបាទិន្នក្តី ជាបច្ច័យនៃកាយនេះ ជាឧបាទិន្ននិងជាអនុបាទិន្ន ដោយអាហារប្បច្ច័យ ។

[ ៨៩ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយឥន្រ្ទិយប្បច្ច័យ គឺ

ពួកឥន្ទ្រិយជាឧបាទិន្ន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ពួកឥន្ទ្រិយជាឧបាទិន្ន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយិន្ទ្រិយ... រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ។បេ។ ក្នុងឧបាទិន្នមូលកៈ មានវារៈ ៣ រូបជីវិតិន្ទ្រិយនៃវារៈទី ១ មិនមានក្នុងពួកវារៈដទៃទេ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ជាអនុបាទិន្ន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ។

[ ៩០ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយឈានប្បច្ច័យ មានវារៈ ៤ ។ ... ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ២ ។

[ ៩១ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺក្នុងខណៈនៃបដិសន្ធិ ពួកឧបាទិន្នក្ខន្ធ ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ពួកខន្ធជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកឧបាទិន្នក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកឧបាទិន្នក្ខន្ធ ជាបច្ច័យនៃឧបាទិន្នកាយ

នេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ ឧបាទិន្នធម៌ជាបច្ច័យនៃអនុបា-
ទិន្នធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។
សហជាត គឺពួកឧបាទិន្នក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្ប-
យុត្តប្បច្ច័យ ។ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកអនុបាទិន្នក្ខន្ធផង នៃពួក
ចិត្តសមុដ្ឋានរូបផង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកឧបាទិន្នក្ខន្ធ
ជាបច្ច័យនៃអនុបាទិន្នកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។
ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយវិប្ប-
យុត្តប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកឧបាទិន្នក្ខន្ធ ជាបច្ច័យនៃកាយនេះ
ជាឧបាទិន្នទិនិងជាអនុបាទិន្ន ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ អនុ-
បាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ ស-
ហជាតនិងបច្ឆាជាត ។ សហជាត គឺពួកអនុបាទិន្នក្ខន្ធ ជាបច្ច័យនៃពួក
ចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកអនុបាទិន្នក្ខន្ធ
ជាបច្ច័យនៃអនុបាទិន្នកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។
អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់
បច្ឆាជាត គឺពួកអនុបាទិន្នក្ខន្ធ ជាបច្ច័យនៃឧបាទិន្នកាយនេះ ដែលកើតមុន
ដោយវិប្បយុត្តប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃ
អនុបាទិន្នធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ បច្ឆាជាត គឺពួកអនុ-
បាទិន្នក្ខន្ធ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នទិនិងជាអនុបាទិន្ន ដែលកើតមុន
ដោយវិប្បយុត្តប្បច្ច័យ ។

[ ៩២ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអត្ថិប្បច្ច័យ បាន ដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ ដូចយ៉ាងបទ ដែលលោកតម្កល់ទុកហើយ បណ្ឌិតគប្បីចែកឲ្យបរិបូណ៌ចុះ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាតនិងអាហារ ។ សេចក្តីបំប្រួញ ។ ដូចយ៉ាងបទដែលលោកតម្កល់ទុកហើយ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាតនិងអាហារ ។ សេចក្តីបំប្រួញ ។ ដូចយ៉ាងបទ ដែលលោកតម្កល់ទុកហើយ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាតនិងអាហារ ។ សេចក្តីបំប្រួញ ។ ដូចយ៉ាងបទ ដែលលោកតម្កល់ទុកហើយ បណ្ឌិតគប្បីចែកចុះ ។ អនុបាទិន្នធម៌ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត បច្ឆាជាតនិងអាហារ ។ បុរេជាត គឺ ( បុគ្គលឃើញ ) នូវពួករូបជាអនុបាទិន្ន ដែលកើតមុន... នូវពួកសំឡេង... នូវពួកផោដ្ឋព្វៈ ជាមិនទៀង ។បេ។ ទោមនស្សកើតឡើង កាលកុសលាកុសលរលត់ហើយ វិបាកកើតឡើង ព្រោះមានកុសលាកុសលនោះ ជាអារម្មណ៍ រូបាយតនៈ ជាអនុបាទិន្ន ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ។ បច្ឆាជាត គឺពួកអនុបាទិន្នក្ខន្ធ ជាបច្ច័យនៃឧបាទិន្នកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ កពឡឹង្ការាហារជាអនុបាទិន្ន ជាបច្ច័យនៃឧបាទិន្នកាយនេះ ដោយ

អត្ថិប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ បច្ឆាជាតនិងអាហារ ។ បច្ឆាជាត គឺពួកអនុបាទិន្នក្ខន្ធ ជាបច្ច័យនៃកាយនេះ ជាឧបាទិន្នទិនិងជាអនុបាទិន្ន ដែលកើតមុន ដោយអត្ថិប្បច្ច័យ កពឡិង្ការាហារជាអនុបាទិន្ន ជាបច្ច័យនៃកាយនេះជាឧបាទិន្នទិនិងជាអនុបាទិន្ន ដោយអត្ថិប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត បច្ឆាជាត អាហារនិងឥន្រ្ទិយ ។ បុរេជាត គឺរូបាយតនៈជាអនុបាទិន្នក្តី វត្ថុក្តី ផោដ្ឋព្វាយតនៈក្តី វត្ថុក្តី ជាបច្ច័យនៃពួកឧបាទិន្នក្ខន្ធ ដោយអត្ថិប្បច្ច័យ រូបាយតនៈ ជាអនុបាទិន្នក្តី ចក្ខាយតនៈក្តី ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាអនុបាទិន្នក្តី កាយាយតនៈក្តី ជាបច្ច័យនៃកាយវិញ្ញាណ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកអនុបាទិន្នក្ខន្ធក្តី កពឡិង្ការាហារ ជាអនុបាទិន្នក្តី ជាបច្ច័យនៃឧបាទិន្នកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកអនុបាទិន្នក្ខន្ធក្តី រូបជីវិតិន្រ្ទិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាតនិងអាហារ ។ សហជាត គឺពួកឧបាទិន្នក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ សហជាត គឺអនុបាទិន្នក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ បុរេជាត គឺរូបាយតនៈជាអនុបាទិន្នក្តី វត្ថុក្តី ជាបច្ច័យនៃពួកអនុបាទិន្នក្ខន្ធ ដោយអត្ថិប្បច្ច័យ ផោដ្ឋព្វាយតនៈ

ក្តី វត្ថុក្តី ជាបច្ច័យនៃពួកអនុបាទិន្នក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកឧបាទិន្នក្ខន្ធក្តី កពឡិង្ការាហារជាអនុបាទិន្នក្តី ជាបច្ច័យនៃអនុបាទិន្នកាយនេះ ដោយអត្ថិប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ អាហារ គឺកពឡិង្ការាហារ ជាឧបាទិន្នក្តី ជាអនុបាទិន្នក្តី ជាបច្ច័យនៃកាយនេះ ជាឧបាទិន្ននិងជាអនុបាទិន្ន ដោយអត្ថិប្បច្ច័យ ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៦ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩៤ ] ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទិន្នធម៌ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ។ ឧបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ។ អនុបាទិន្ន-ធម៌ ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេ-ជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ។ អនុបាទិន្នធម៌ ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយបច្ឆា-ជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃឧបាទិន្នធម៌ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជា-តប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃអនុបាទិន្នធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ។ ឧបាទិន្នធម៌ក្តី អនុបាទិន្នធម៌ក្តី ជាបច្ច័យនៃឧបាទិន្នធម៌ផង នៃអនុបាទិន្នធម៌ផង ដោយអាហារប្បច្ច័យ ។

[ ៩៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ៨ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុង នោវិគតប្បច្ច័យ មានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៩៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ... ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ។បេ។ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៩៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

**ចប់ ឧបាទិន្នទុកៈ ។**

## ឧបាទានទុកៈ
## បដិច្ចវារៈ

[ ៩៨ ] ឧបាទានធម៌ អាស្រ័យនូវឧបាទានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទាន អាស្រ័យនូវទិដ្ឋុបាទាន ទិដ្ឋុបាទាន អាស្រ័យនូវកាមុបាទាន កាមុបាទាន អាស្រ័យនូវសីលព្វតុបាទាន សីលព្វតុបាទាន អាស្រ័យនូវកាមុបាទាន កាមុបាទានអាស្រ័យនូវអត្តវាទុបាទាន អត្តវាទុបាទានអាស្រ័យនូវកាមុបាទាន ។ នោឧបាទានធម៌ ( ធម៌មិនមែនជាឧបាទាន ) អាស្រ័យនូវឧបាទានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកឧបាទាន ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី អាស្រ័យនូវឧបាទានធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺកាមុបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវទិដ្ឋុបាទាន កាមុបាទាន... ។ បណ្ឌិតគប្បីធ្វើជាចក្កៈទាំងអស់ចុះ ។ នោឧបាទានធម៌ អាស្រ័យនូវនោឧបាទានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោឧបាទានក្ខន្ធ ១ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវនោឧបាទានក្ខន្ធ ១ ក្នុងបដិសន្ធិក្ខណៈ នូវខន្ធ ២ ... វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ឧបាទានធម៌អាស្រ័យនូវនោឧបាទានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកឧបាទាន អាស្រ័យនូវពួកនោឧបាទានក្ខន្ធ ។ ឧបាទានធម៌ក្តី នោឧ-

បាទានធម៌ក្តី អាស្រ័យនូវនោឧបាទានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ពួកឧបាទានក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោឧបាទានក្ខន្ធ ១ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ២ ។ ឧបាទានធម៌ អាស្រ័យនូវឧបាទានធម៌ផង នូវនោឧបាទានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទាន អាស្រ័យនូវទិដ្ឋុបាទានផង នូវពួកសម្បយុត្តកក្ខន្ធផង ។ បណ្ឌិតគប្បីធ្វើជាចក្កៈទាំងអស់ចុះ ។ នោឧបាទានធម៌ អាស្រ័យនូវឧបាទានធម៌ផង នូវនោឧបាទានធម៌ផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោឧបាទានក្ខន្ធ ១ ផង នូវឧបាទានផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវឧបាទានផង នូវនោឧបាទានផង នូវពួកមហាភូតផង ពួកនោឧបាទានក្ខន្ធអាស្រ័យនូវឧបាទានផង នូវវត្ថុផង ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី អាស្រ័យនូវឧបាទានធម៌ផង នូវនោឧបាទានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី កាមុបាទានក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោឧបាទានក្ខន្ធ ១ ផង នូវទិដ្ឋុបាទានផង នូវខន្ធ ២ ... ។ បណ្ឌិតគប្បីធ្វើជាចក្កៈចុះ ។

[ ៩៩ ] ឧបាទានធម៌ អាស្រ័យនូវឧបាទានធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺបញ្ហាទាំង ៩ បណ្ឌិតគប្បីធ្វើចុះ ឯរូប បណ្ឌិតគប្បីដកចោលចេញ ។

[ ១០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមាន

វារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០១ ] នោឧបាទានធម៌ អាស្រ័យនូវនោឧបាទានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោឧបាទានក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ ក្នុងអហេតុកបដិសន្ធិក្ខណៈ មហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូបនិងឧបាទារូប អាស្រ័យនូវពួកមហាភូត ពាហិរៈ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ។បេ។ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ របស់ពួកអសញ្ញសត្វ ។

[ ១០២ ] នោឧបាទានធម៌ អាស្រ័យនូវឧបាទានធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទាន ។ នោឧបាទានធម៌ អាស្រ័យនូវនោឧបាទានធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនោឧបាទានក្ខន្ធ កដត្តារូប អាស្រ័យនូវពួកនោឧបាទានក្ខន្ធ ក្នុងបដិសន្ធិក្ខណៈ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ រហូតដល់ពួកអសញ្ញសត្វ ។ នោឧបាទានធម៌ អាស្រ័យនូវឧបាទានធម៌ផង នូវនោឧបាទានធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានក្ខន្ធផង នូវពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានផង នូវពួកមហាភូតផង ។ ... ព្រោះនអធិបតិប្បច្ច័យ ព្រោះនអ-

នន្តរប្បច្ច័យ ។បេ។ ព្រោះឧបនិស្សយប្បច្ច័យ ។

[ ១០៣ ] ឧបាទានធម៌ អាស្រ័យនូវឧបាទានធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប កាមុបាទានអាស្រ័យនូវអត្តវាទុបាទាន អត្តវាទុបាទានអាស្រ័យនូវកាមុបាទាន ។ នោឧបាទានធម៌អាស្រ័យនូវឧបាទានធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវពួកឧបាទាន ក្នុងអរូប ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទាន ។ សេចក្តីបំប្រួញ ។ បញ្ហាទាំង ៩ ឧបាទានទាំង ២ ក្នុងអរូប ។ សេចក្តីបំប្រួញ ។

[ ១០៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១០៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុង

នអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបា-កប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្ប-យុត្តប្បច្ច័យមានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យមានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១០៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ... ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯសហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតកាលចែក គប្បីធ្វើថា កាមុបាទាន កើតជាមួយនឹងទិដ្ឋុបាទានចុះ ។

## បច្ចយវារៈ

[ ១០៧ ] ឧបាទានធម៌ ពឹងផ្អែកនឹងឧបាទានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទាន ពឹងផ្អែកនឹងទិដ្ឋុបាទាន ។ មានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នោឧបាទានធម៌ ពឹងផ្អែកនឹងនោឧបាទានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោឧបាទានក្ខន្ធ ១ នឹងខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ពួកមហាភូតខាងក្នុង ពឹងផ្អែកនឹងពួកខន្ធ របូតដល់ពួកនោឧបាទានក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ ឧបា-ទានធម៌ ពឹងផ្អែកនឹងនោឧបាទានធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកឧបាទាន ពឹងផ្អែកនឹងពួកនោឧបាទានក្ខន្ធ ពួកឧបាទាន ពឹងផ្អែកនឹងវត្ថុ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ពឹងផ្អែកនឹងនោឧបាទានធម៌ ទើបកើត

ឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ពួកឧបាទានក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោឧបាទានក្ខន្ធ ១ នឹងខន្ធ ២ ... ពួកឧបាទានពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ។ ឧបាទានធម៌ ពឹងផ្អែកនឹងឧបាទានធម៌ផង នឹងនោ-ឧបាទានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទាន ពឹងផ្អែកនឹងទិដ្ឋុបាទានផង នឹងពួកសម្បយុត្តកក្ខន្ធផង ទិដ្ឋុបាទាន ពឹងផ្អែកនឹងកា-មុបាទានផង នឹងពួកសម្បយុត្តកក្ខន្ធផង ។ បណ្ឌិតគប្បីធ្វើជាចក្កៈចុះ ។ កាមុបាទាន ពឹងផ្អែកនឹងទិដ្ឋុបាទានផង នឹងវត្ថុផង ។ បណ្ឌិតគប្បីធ្វើជាចក្កៈចុះ ។ នោឧបាទានធម៌ ពឹងផ្អែកនឹងឧបាទានធម៌ផង នឹងនោឧបាទានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោឧបាទានក្ខន្ធ ១ ផង នឹងឧបាទានផង នឹងខន្ធ ២ ... ។ បណ្ឌិតគប្បីធ្វើជាចក្កៈចុះ ។ ចិត្តសមុដ្ឋានរូបពឹងផ្អែកនឹងពួកឧបាទានផង នឹងពួកមហាភូតផង ពួកនោឧបាទានក្ខន្ធ ពឹងផ្អែកនឹងពួកឧបាទានផង នឹងវត្ថុផង ។ ឧបា-ទានធម៌ក្តី នោឧបាទានធម៌ក្តី ពឹងផ្អែកនឹងឧបាទានធម៌ផង នឹងនោឧបាទានធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី កាមុបាទានក្តី ចិត្ត-សមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោឧបាទានក្ខន្ធ ១ ផង នឹងទិដ្ឋុបាទានផង ។ ចក្កៈ ។ កាមុបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងទិដ្ឋុបាទានផង នឹងវត្ថុផង ។ ចក្កៈ ។ ... ព្រោះអារម្មណប្បច្ច័យ គឺអាយតនៈ ៥ ក្តី វត្ថុក្តី បណ្ឌិតគប្បីធ្វើក្នុងអារម្មណប្បច្ច័យ និងក្នុងនោឧបាទានមូលកៈចុះ ។

[ ១០៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០៩ ] នោឧបាទានធម៌ ពឹងផ្អែកនឹងនោឧបាទានធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពឹងផ្អែកនឹងនោឧបាទានក្ខន្ធ ១ ជាអហេតុកៈ ក្នុងអហេតុកប្បដិសន្ធិក្ខណៈ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ រហូតដល់ពួកអសញ្ញសត្វ កាយវិញ្ញាណពឹងផ្អែកនឹងកាយាយតនៈ ពួកនោឧបាទានក្ខន្ធជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផងនឹងវត្ថុផង ។

[ ១១០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំង ២ យ៉ាង ក្រៅនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

[ ១១១ ] ឧបាទានធម៌ ប្រកបនឹងឧបាទានធម៌ ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ គឺកាមុបាទាន ប្រទ្បូំនឹងទិដ្ឋុបាទាន ទិដ្ឋុបាទានប្រទ្បូំនឹងកាមុ-បាទាន ។ ចក្ក: ។ ប្រស្នាទាំង ៩ បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។

[ ១១២ ] ក្នុងហេតុប្បច្ច័យ មានវារ: ៩ ក្នុងអារម្មណប្បច្ច័យ មានវារ: ៩ ក្នុងអធិបតិប្បច្ច័យ មានវារ: ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារ: ៩ ក្នុងវិបាកប្បច្ច័យ មានវារ: ១ ក្នុងវិគតប្បច្ច័យ មានវារ: ៩ ក្នុងអវិគតប្បច្ច័យ មានវារ: ៩ ។

[ ១១៣ ] នោឧបាទានធម៌ ប្រទ្បូំនឹងនោឧបាទានធម៌ ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ប្រទ្បូំនឹងនោឧបាទានក្ខន្ធ ១ ជាអហេតុក: នឹងខន្ធ ២ ... ក្នុងអហេតុកប្បដិសន្ធិក្ខណ: មោហ: ដែលប្រទ្បូំដោយវិចិកិច្ឆា ប្រទ្បូំដោយឧទ្ធច្ច: ប្រទ្បូំនឹងពួកខន្ធដែលប្រទ្បូំដោយវិចិកិច្ឆា ប្រទ្បូំដោយឧទ្ធច្ច: ។

[ ១១៤ ] ក្នុងនហេតុប្បច្ច័យ មានវារ: ១ ក្នុងនអធិបតិប្បច្ច័យ មានវារ: ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារ: ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារ: ៩ ក្នុងនអាសេវនប្បច្ច័យ មានវារ: ៩ ក្នុងនកម្មប្បច្ច័យ មានវារ: ៣ ក្នុងនវិបាកប្បច្ច័យ មានវារ: ៩ ក្នុងនឈានប្បច្ច័យ មានវារ: ១ ក្នុងន-មគ្គប្បច្ច័យ មានវារ: ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារ: ៩ ។

ការរាប់ ២ យ៉ាងក្រៅនេះក្តី សម្បយុត្តវារ:ក្តី បណ្ឌិតគប្បី

ធ្វើយ៉ាងនេះចុះ ។

# បញ្ហាវារៈ

[ ១១៥ ] ឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយហេតុប្បច្ច័យ គឺពួកឧបាទានហេតុជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយហេតុប្បច្ច័យ គឺពួកនោឧបាទានហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងបដិសន្ធិក្ខណៈ ។បេ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយហេតុប្បច្ច័យ គឺពួកនោឧបាទានហេតុ ជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកនោឧបាទានហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃឧបាទានធម៌ ដោយហេតុប្បច្ច័យ គឺពួកឧបាទានហេតុក្តី ពួកនោឧបាទានហេតុក្តី ជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានហេតុក្តី ពួកនោឧបាទានហេតុក្តី ជាបច្ច័យនៃពួក

សម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានហេតុក្តី ពួកនោឧបាទានហេតុក្តី ជាបច្ច័យនៃ ពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយ ហេតុប្បច្ច័យ ។

[ ១១៦ ] ឧបាទានធម៌ជាបច្ច័យនៃឧបាទានធម៌ ដោយអារម្មណប្បច្ច័យ គឺពួកឧបាទាន ប្រារព្ធនូវពួកឧបាទាន ទើបកើតឡើង ។ វារៈ ៣ បណ្ឌិត គប្បីប្រារព្ធធ្វើចុះ ។ នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយ អារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន នូវសីល... ធ្វើនូវឧបោសថកម្ម ពិចា-រណានូវកុសលនោះ ត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវកុសលនោះ... ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ... ទោមនស្សកើតឡើង នូវពួកកុសលដែលសន្សំល្អហើយ ក្នុងកាលមុន... ចេញអំពីឈាន ពិចារណានូវឈាន ពួកព្រះអរិយៈ ចេញ អំពីមគ្គ ពិចារណានូវមគ្គ នូវផល... ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គនិងផល ដោយអា-រម្មណប្បច្ច័យ ពួកព្រះអរិយៈ ( ពិចារណា ) នូវពួកនោឧបាទាន នូវពួក កិលេសដែលលះបង់ហើយ... ពិចារណានូវពួកកិលេស ដែលសង្កត់សង្កិន ហើយ នូវពួកកិលេសដែលសន្សំហើយ ក្នុងកាលមុន... នូវចក្ខុ... នូវវត្ថុ... នូវពួកនោឧបាទានក្ខន្ធ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង ឃើញនូវ រូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយនោឧបាទានចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចា-

យតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ... រូបា-
យតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ពួកនោឧបាទានក្ខន្ធ
ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវា-
សានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្ម-
ណប្បច្ច័យ ។ នោឧបាទានធម៌ជាបច្ច័យនៃឧបាទានធម៌ ដោយអារម្មណប្បច្ច័យ
គឺបុគ្គលនូវទាន... នូវសីល... ធ្វើនូវឧបោសថកម្ម ហើយត្រេកអរ រីករាយ
ចំពោះកុសលនោះ រាគៈប្រារព្ធនូវកុសលនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង
នូវពួកកុសលដែលសន្សំហើយក្នុងកាលមុន... អំពីឈាន... នូវចក្ខុ... នូវ
វត្ថុ... ត្រេកអរ រីករាយចំពោះពួកនោឧបាទានក្ខន្ធ រាគៈប្រារព្ធនូវខន្ធនោះ
ទើបកើតឡើង ទិដ្ឋិ... ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ផង នៃ
នោឧបាទានធម៌ផង ដោយអារម្មណប្បច្ច័យ គឺបុគ្គលនូវទាន... នូវសីល...
នូវឧបោសថកម្ម... នូវពួកកុសល ដែលសន្សំហើយ ក្នុងកាលមុន... អំពី
ឈាន... នូវចក្ខុ... នូវវត្ថុ... ត្រេកអរ រីករាយ ចំពោះពួកនោឧបាទានក្ខន្ធ
ពួកឧបាទានក្ខន្ធក្តី ពួកសម្បយុត្តកក្ខន្ធក្តី ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ។
ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃឧបាទានធម៌ ដោយអារម្ម-
ណប្បច្ច័យ បណ្ឌិតគប្បីប្រារព្ធធ្វើនូវវារៈ ៣ ចុះ ។

[ ១១៧ ] ឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយអធិបតិប្បច្ច័យ
បានដល់ អារម្មណាធិបតិ គឺពួកឧបាទានធ្វើនូវពួកឧបាទាន ឲ្យជាទីគោរព
ទើបកើតឡើង ។ មានវារៈ ៣ បានដល់ អារម្មណាធិបតិហ្នឹងឯង ។

នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យនូវទាន នូវសីល... នូវឧបោសថកម្ម... ក្នុងកាលមុន... ចេញអំពីឈាន ធ្វើនូវឈាន ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ ។បេ។ ពួកព្រះអរិយៈ ចេញអំពី មគ្គ ( ធ្វើ ) នូវមគ្គឲ្យជាទីគោរព... នូវផល... ធ្វើនូវព្រះនិព្វាន ឲ្យជាទី គោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកនោឧបាទានក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ... ។ ឯ សហជាតាធិបតិ គឺអធិបតិធម៌ជានោឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលនូវទាន... នូវសីល... ធ្វើ នូវឧបោសថកម្ម ហើយត្រេកអរ រីករាយ ចំពោះកុសលនោះ រាគៈធ្វើនូវ ពួកខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ... ។ ក្នុងកាលមុន... អំពី ឈាន... នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកនោឧបាទានក្ខន្ធ ឲ្យជាទីគោរព ហើយ ត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ... ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ជានោឧបាទាន ជាបច្ច័យនៃពួកសម្បយុត្ត-កឧបាទាន ដោយអធិបតិប្បច្ច័យ ។ នោឧបាទានធម៌ជាបច្ច័យនៃឧបាទានធម៌ ផង នៃនោឧបាទានធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ

និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលនូវទាន... នូវសីល... នូវឧបោសថកម្ម... ក្នុងកាលមុន... អំពីឈាន... នូវបក្ខ... នូវវគ្គ... ធ្វើនូវពួកនោឧបាទានក្ខន្ធ ឲ្យជាទីគោរព ត្រេកអរ រីករាយ ពួកឧបាទានក្តី សម្បយុត្តកក្ខន្ធក្តី ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ។ សហជាតាធិបតិ គឺអធិបតិធម៌ ជានោឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃឧបាទានធម៌ ដោយអធិបតិប្បច្ច័យ គឺមានវារៈ ៣ ។ ឯអារម្មណាធិបតិ បណ្ឌិតគប្បីប្រាជ្ញធ្វើនូវវារៈ ៣ ឲ្យនៅជាអារម្មណាធិបតិដដែល ។

[ ១១៨ ] ឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយអនន្តរប្បច្ច័យ គឺពួកឧបាទានមុនៗ ជាបច្ច័យនៃពួកឧបាទានក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានមុនៗ ជាបច្ច័យនៃពួកនោឧបាទានក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ឧបាទានធម៌ជាបច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានមុនៗ ជាបច្ច័យនៃពួកឧបាទាននិងពួកសម្បយុត្តកក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោឧបាទានក្ខន្ធមុនៗ ជាបច្ច័យនៃពួកនោឧបាទានក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូនិងផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោ-

ឧបាទានក្ខន្ធមុនៗ ជាបច្ច័យនៃពួកឧបាទានក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃពួកឧបាទាន ដោយអនន្តរប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ផង នៃនោឧបាទានធម៌ផង ដោយអនន្តរប្បច្ច័យ គឺ ពួកនោឧបាទានក្ខន្ធមុនៗ ជាបច្ច័យនៃពួកឧបាទាន និងពួកសម្បយុត្តកក្ខន្ធ ក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃពួកឧបាទានផង នៃពួក សម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ ក្តី ជាបច្ច័យនៃឧបាទានធម៌ ដោយអនន្តរប្បច្ច័យ គឺពួកឧបាទានក្តី ពួកសម្ប-យុត្តកក្ខន្ធក្តីមុនៗ ជាបច្ច័យនៃពួកឧបាទានក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូលបណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានក្តី សម្បយុត្តកក្ខន្ធក្តីមុនៗ ជាបច្ច័យនៃ ពួកនោឧបាទានក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកឧបាទានក្តី សម្ប-យុត្តកក្ខន្ធក្តី ជាបច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បី ធ្វើចុះ ពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តីមុនៗ ជាបច្ច័យនៃពួកឧបាទាន និងពួកសម្បយុត្តកក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យដោយ សមនន្តរប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈ ដែរ ។ ... ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ គឺដូចគ្នានឹងបច្ចយវារៈដែរ ។

[ ១១៩ ] ឧបាទានធម៌ជាបច្ច័យនៃឧបាទានធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកឧបាទាន ជាបច្ច័យនៃពួកឧបាទាន ដោយឧបនិស្ស-

យប្បច្ច័យ មានវារៈ ៣ ។ នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន ។បេ។ ញ៉ាំងសមាបត្តិឲ្យកើតឡើង ជំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ។បេ។ នូវបញ្ញា... នូវរាគៈ ។បេ។ នូវសេចក្ដីប្រាថ្នា... អាស្រ័យនូវសេនាសនៈ ហើយលួចយកនូវទ្រព្យដែលគេមិនបានឲ្យ កុហក... នូវពាក្យញុះញង់... ឲ្យនូវទាន ។បេ។ ញ៉ាំងសមាបត្តិឲ្យកើតឡើង ជំឡើងមានះ ប្រកាន់ទិដ្ឋិ អាស្រ័យនូវសីល... នូវរាគៈ... នូវសេចក្ដីប្រាថ្នា... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ។បេ។ បំបែកសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយឧបនិស្សយប្បច្ច័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ជំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ។បេ។ អាស្រ័យនូវសេនាសនៈ នូវទ្រព្យដែលគេមិនបានឲ្យ... កុហក... នូវពាក្យញុះញង់... នូវពាក្យអាក្រក់... នូវពាក្យរោយរាយ... នូវទឹត... នូវការឆក់យកទ្រព្យគេ... នូវការប្លន់យកទ្រព្យក្នុងផ្ទះមួយ... ត្រង់ផ្លូវជួបគ្នា... នូវប្រពន្ធអ្នកដទៃ... នូវការសម្លាប់អ្នកស្រុក... នូវការសម្លាប់អ្នកនិគម... សទ្ធា ។បេ។ សេនាសនៈជាបច្ច័យនៃពួកឧបាទាន ដោយឧបនិស្សយប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ បុគ្គលអាស្រ័យនូវសទ្ធា ហើយជំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល ។បេ។ អាស្រ័យនូវ

សេនាសនៈ ហើយលួចយកនូវទ្រព្យដែលគេមិនបានឲ្យ កុហក... នូវពាក្យញុះញង់... នូវពាក្យអាក្រក់... នូវពាក្យរោយរាយ... នូវទីត... នូវការឆក់យកទ្រព្យគេ... នូវការប្លន់យកទ្រព្យក្នុងផ្ទះមួយ... ត្រង់ផ្លូវជួបគ្នា... នូវប្រពន្ធអ្នកដទៃ... នូវការសម្លាប់អ្នកស្រុក... នូវការសម្លាប់អ្នកនិគម... សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃពួកឧបាទានផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃឧបាទានធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ មានវារៈ ៣ ។

[ ១២០ ] នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ... នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃនោឧបាទានក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ នោឧបាទានធម៌ជាបច្ច័យនៃឧបាទានធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នឹងចក្ខុ... ត្រេកអរ រីករាយ នឹងវត្ថុ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទិដ្ឋិ... ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកឧបាទាន ដោយ

បុរេជាតប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ផង នៃនោ-ឧបាទានធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និង វត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នឹងចក្ខុ... ត្រេកអរ រីករាយនឹងវត្ថុ ពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ប្រារព្ធនូវវត្ថុនោះ ទើប កើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកឧបាទានផង នៃពួកសម្ប-យុត្តកក្ខន្ធផង ដោយបុរេជាតប្បច្ច័យ ។

[ ១២១ ] ឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយបច្ឆាជា-តប្បច្ច័យ ។ សេចក្តីបំប្រួញ ។ នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃនោឧបាទានធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ ។

[ ១២២ ] នោឧបាទានធម៌ជាបច្ច័យនៃនោឧបាទានធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺនោឧបាទានចេតនា ជា បច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺនោឧបាទានចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួក កដត្តារូបផង ដោយកម្មប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយកម្មប្បច្ច័យ គឺនោឧបាទានចេតនា ជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយកម្មប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ផង នៃនោ-ឧបាទានធម៌ផង ដោយកម្មប្បច្ច័យ គឺនោឧបាទានចេតនា ជាបច្ច័យនៃពួក

សម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ១២៣ ] នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយវិបាកប្បច្ច័យ គឺនោឧបាទានក្ខន្ធ ១ ជាវិបាក ។បេ។ វារៈ ១ ។

[ ១២៤ ] នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយអាហារប្បច្ច័យ គឺមានវារៈ ៣ កពឡិង្ការាហារតែ ១ គត់ ។ ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ គឺមានវារៈ ៣ រូបជីវិតិន្ទ្រិយតែ ១ ។ ... ជាបច្ច័យដោយឈានប្បច្ច័យ គឺមានវារៈ ៣ ។

[ ១២៥ ] ឧបាទានធម៌ជាបច្ច័យនៃឧបាទានធម៌ ដោយមគ្គប្បច្ច័យ គឺពួកអង្គមគ្គជាឧបាទានជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយមគ្គប្បច្ច័យ ។ បញ្ហា ៩ បណ្ឌិត គប្បីធ្វើដោយហេតុនេះចុះ ។ ... ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ១២៦ ] ឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺពួកឧបាទានជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកឧបាទានដែលកើតក្រោយ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់

បុរេជាត គឺវត្ថុជាបច្ច័យនៃពួកឧបាទាន ដោយវិប្បយុត្តប្បច្ច័យ ។ នោឧបា-ទានធម៌ ជាបច្ច័យនៃឧបាទានធម៌ផង នៃនោឧបាទានធម៌ផង ដោយវិប្ប-យុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកឧបាទានផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ ឧបាទានធម៌ក្តី នោឧបាទាន-ធម៌ក្តី ជាបច្ច័យនៃនោឧបាទានធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហ-ជាតនិងបច្ឆាជាត ។ សហជាត គឺពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ១២៧ ] ឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយអត្ថិប្បច្ច័យ គឺទិដ្ឋុបាទានជាបច្ច័យនៃកាមុបាទាន ដោយអត្ថិប្បច្ច័យ ។ ចក្កៈ ។ ឧបាទាន-ធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺពួកឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺពួកឧបាទាន ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ ឧបា-ទានធម៌ជាបច្ច័យនៃឧបាទានធម៌ផង នៃនោឧបាទានធម៌ផង ដោយអត្ថិប្បច្ច័យ ។ សេចក្តីបំប្រួញ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នោឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្តីបំប្រួញ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ នោឧបា-

ទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាតដូចគ្នានឹងសហជាតប្បច្ច័យដែរ ឯបុរេជាត ដូចគ្នានឹងបុរេជាតប្បច្ច័យដែរ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ផង នៃនោឧបាទានធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សេចក្តីបំប្រួញ ។ សហជាតដូចគ្នានឹងសហជាតប្បច្ច័យដែរ បុរេជាតដូចគ្នានឹងបុរេជាតប្បច្ច័យដែរ បណ្ឌិតគប្បីចែកចុះ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃឧបាទានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺទិដ្ឋុបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃកាមុបាទាន ដោយអត្ថិប្បច្ច័យ ។ ចក្ក: ។ សហជាត គឺទិដ្ឋុបាទានក្តី វត្ថុក្តី ជាបច្ច័យនៃកាមុបាទាន ដោយអត្ថិប្បច្ច័យ ។ ចក្ក: ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃនោឧបាទានធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺនោឧបាទានក្ខន្ធ ១ ក្តី ពួកឧបាទានក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហជាត គឺពួកឧបាទានក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ សហជាត គឺពួកឧបាទានក្តី វត្ថុក្តី ជាបច្ច័យនៃពួកនោឧបាទានក្ខន្ធ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយ

អត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកឧបាទានក្ខ័ ពួកសម្បយុត្តកក្ខន្ធក្តី រូបជីវិ-តិន្ទ្រិយក្តី ជាបច្ច័យនៃពួកកជត្តារូប ដោយអត្ថិប្បច្ច័យ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃឧបាទានធម៌ផង នៃនោឧបាទានធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺនោឧបា-ទានក្ខន្ធ ១ ក្តី ទិដ្ឋុបាទានក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃកាមុបាទានផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ ចក្ក: ។ សហជាត គឺទិដ្ឋុបាទានក្តី វត្ថុក្តី ជាបច្ច័យនៃកាមុបាទានផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ។ ចក្ក: ។

[ ១២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ

៩ ។

[ ១២៩ ] ឧបាទានធម៌ជាបច្ច័យនៃឧបាទានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានធម៌ ជាបច្ច័យនៃនោឧបាទានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ផង នៃនោឧបា-ទានធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃនោឧបា-ទានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នោឧបាទានធម៌ ជាបច្ច័យនៃឧបាទានធម៌ផង នៃនោឧបាទានធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃឧបាទានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានធម៌

ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃនោឧបាទានធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទានធម៌ក្តី នោឧបាទានធម៌ក្តី ជាបច្ច័យនៃឧបាទានធម៌ផង នៃនោឧបាទានធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១៣០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៣១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៣២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

**ចប់ ឧបាទានទុកៈ ។**

## ឧបាទានិយទុកៈ

## បដិច្ចវារៈ

[ ១៣៣ ] ឧបាទានិយធម៌ ( ធម៌ជាប្រយោជន៍ដល់ឧបាទាន ) អាស្រ័យនូវឧបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវឧបាទានិយក្ខន្ធ ១ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ក្នុងបដិសន្ធិក្ខណៈ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... ។

លោកិយទុកៈ យ៉ាងណា បណ្ឌិតគប្បីធ្វើ ( ឧបាទានិយទុកៈ ) យ៉ាងនោះដែរ មិនមានការធ្វើឲ្យប្លែកៗគ្នាទេ ។

## ឧបាទានសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ១៣៤ ] ឧបាទានសម្បយុត្តធម៌ ( ធម៌ប្រកបដោយឧបាទាន ) អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវឧបាទានសម្បយុត្តក្ខន្ធ ១ នូវខន្ធ ២ ... ។ ឧបាទានវិប្បយុត្តធម៌ ( ធម៌ដែលប្រាសចាកឧបាទាន ) អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានសម្បយុត្តក្ខន្ធ លោភៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង

ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវឧបាទានសម្បយុត្តក្ខន្ធ ១ នូវខន្ធ ២ ... ខន្ធ ៣ ក្តី លោកៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រទូ្បំដោយលោកៈ តែប្រាសចាកទិដ្ឋិ នូវខន្ធ ២ ... ។ ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវឧបាទានវិប្បយុត្តក្ខន្ធ ១ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវលោកៈ ដែលប្រាសចាកទិដ្ឋិ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវឧបាទានវិប្បយុត្តក្ខន្ធ ១ ក្នុងបដិសន្ធិក្ខណៈ នូវខន្ធ ២ ... វត្ថុអាស្រ័យនូវពួកខន្ធ ឯពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... ។ ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវលោកៈ ដែលប្រាសចាកទិដ្ឋិ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវលោកៈ ដែលប្រាសចាកទិដ្ឋិ ។ ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ផង នូវឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រទូ្បំដោយលោកៈ តែប្រាសចាកទិដ្ឋិផង នូវលោកៈផង នូវខន្ធ ២ ... ។ ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ផង នូវឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង

ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាក ទិដ្ឋិផង នូវលោភៈផង ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី អាស្រ័យនូវឧបាទានសម្បយុត្តធម៌ផង នូវឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នូវលោភៈផង នូវខន្ធ ២ ... ។

[ ១៣៥ ] ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវឧបាទានសម្បយុត្តកខន្ធ ១ នូវខន្ធ ២ ... ។ ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺលោភៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិ ។ ឧបាទាន-សម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី លោភៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយលោភៈតែប្រាសចាកទិដ្ឋិ នូវខន្ធ ២ ... ។ ឧបា-ទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យនូវពួកឧបាទានវិប្បយុត្តកខន្ធ វត្ថុអាស្រ័យនូវពួកខន្ធ ក្នុងបដិសន្ធិក្ខណៈ ពួកខន្ធអាស្រ័យនូវវត្ថុ ។ ឧបា-ទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកខន្ធ អាស្រ័យនូវលោភៈ ដែលប្រាស

បាកទិដ្ឋិ ។ ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ផង នូវឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយលោភៈតែប្រាសចាកទិដ្ឋិផង នូវលោភៈផង នូវខន្ធ ២ ... ។ សេចក្ដីបំប្រួញ ។

[ ១៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងវិគតប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៣៧ ] ឧបាទានវិប្បយុត្តធម៌អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្ដី ចិត្តសមុដ្ឋានរូបក្ដី អាស្រ័យនូវឧបាទានវិប្បយុត្តក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... អហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយ

ឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ១៣៨ ] ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានសម្បយុត្តក្ខន្ធ ។ ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានវិប្បយុត្តក្ខន្ធ ចិត្តសមុដ្ឋានរូប អាស្រ័យនូវលោកៈដែលប្រាសចាកទិដ្ឋិ ក្នុងបដិសន្ធិក្ខណៈ រហូតដល់ពួកអសញ្ញសត្វ ។ ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ផង នូវឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានសម្បយុត្តក្ខន្ធផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នូវលោភៈផង ។ ... ព្រោះនអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ ។

[ ១៣៩ ] ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ អាស្រ័យនូវឧបាទានសម្បយុត្តក្ខន្ធ ១ នូវខន្ធ ២ ... ។ ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប លោភៈអាស្រ័យនូវពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិ ចិត្តសមុដ្ឋានរូបអាស្រ័យនូវពួកឧបាទានសម្បយុត្តក្ខន្ធ ។ ឧបាទានសម្បយុត្តធម៌

ក្តី ឧបាទានវិប្បយុត្តធម៌ក្តី អាស្រ័យនូវឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ ក្តី លោភៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិ នូវខន្ធ ២ ... ។ ឧបាទានវិប្បយុត្តធម៌អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ អាស្រ័យនូវឧបាទានវិប្បយុត្តខន្ធ ១ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានវិប្បយុត្តខន្ធ ចិត្តសមុដ្ឋានរូប អាស្រ័យនូវលោភៈ ដែលប្រាសចាកទិដ្ឋិ ក្នុងបដិសន្ធិក្ខណៈ រហូតដល់ពួកអសញ្ញសត្វ ។ ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវលោភៈដែលប្រាសចាកទិដ្ឋិ ។ ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ផង នូវឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នូវលោភៈផង នូវខន្ធ ២ ... ។ ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ផង នូវឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានវិប្បយុត្តខន្ធផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នូវលោភៈផង ។ ... ព្រោះនបច្ឆាជាតប្បច្ច័យនិងនអាសេវនប្បច្ច័យ ។

[ ១៤០ ] ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌

ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកឧបាទានសម្បយុត្តក្ខន្ធ ។ ឧបាទានវិប្បយុត្តធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើងព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកឧបាទានវិប្បយុត្តក្ខន្ធ ពាហិរ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ។ ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវលោភៈ ដែលប្រាសចាកទិដ្ឋិ ។ ឧបាទានសម្បយុត្តធម៌ អាស្រ័យនូវឧបាទានសម្បយុត្តធម៌ផង នូវឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិផង នូវលោភៈផង ។ សេចក្តីបំប្រួញ ។

[ ១៤១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ

៣ ។

ការរាប់ទាំងពីរយ៉ាងក្រៅនេះ បណ្ឌិតគប្បីធ្វើចុះ ឯសហជាតវារៈ ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ១៤២ ] ឧបាទានសម្បយុត្តធម៌ ពឹងផ្អែកនឹងឧបាទានសម្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ឧបាទានវិប្បយុត្តធម៌ ពឹងផ្អែកនឹងឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពឹងផ្អែកនឹងឧបាទានវិប្បយុត្តក្ខន្ធ ១ ... រហូតដល់ពួកមហាភូតខាងក្នុង ពួកឧបាទានវិប្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ លោភៈ ដែលប្រាសចាកទិដ្ឋិ ពឹងផ្អែកនឹងវត្ថុ ។ ឧបាទានសម្បយុត្តធម៌ ពឹងផ្អែកនឹងឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកឧបាទានសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងលោភៈ ដែលប្រាសចាកទិដ្ឋិ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកឧបាទានសម្បយុត្តក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងលោភៈ ដែលប្រាសចាកទិដ្ឋិ ពួកខន្ធដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ពឹងផ្អែកនឹងវត្ថុ ។ ឧបាទានសម្បយុត្តធម៌ ពឹងផ្អែកនឹងឧបាទានសម្បយុត្តធម៌ផង នឹងឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹង

ផ្អែកនឹងឧបាទានសម្បយុត្តក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រឡំដោយលោកៈតែប្រាសចាកទិដ្ឋិផង នឹងលោកៈផង នឹងខន្ធ ២ ... ។ ឧបាទានវិប្បយុត្តធម៌ ពឹងផ្អែកនឹងឧបាទានសម្បយុត្តធម៌ផង នឹងឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកឧបាទានសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធដែលប្រឡំដោយលោកៈ តែប្រាសចាកទិដ្ឋិផង នឹងលោកៈផង លោកៈពឹងផ្អែកនឹងពួកខន្ធ ដែលប្រឡំដោយលោកៈ តែប្រាសចាកទិដ្ឋិផង នឹងវត្ថុផង ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ពឹងផ្អែកនឹងឧបាទានសម្បយុត្តធម៌ផង នឹងឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែក នឹងឧបាទានសម្បយុត្តក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកឧបាទានសម្បយុត្តក្ខន្ធផង នឹងពួកមហាភូតផង ខន្ធ ៣ ក្តី លោកៈក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រឡំដោយលោកៈ តែប្រាសចាកទិដ្ឋិផង នឹងវត្ថុផង នឹងខន្ធ ២ ... ។ សេចក្តីបំប្រួញ ។ វិញ្ញាណទាំង ៥ ក្នុងអារម្មណប្បច្ច័យ បណ្ឌិតគប្បីធ្វើចុះ ។

[ ១៤៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៤៤ ] ឧបាទានវិប្បយុត្តធម៌ ពឹងផ្អែកនឹងឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពឹងផ្អែកនឹងឧបាទានវិប្បយុត្តក្ខន្ធ ១ ជាអហេតុកៈ... រហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ... ពួកឧបាទានវិប្បយុត្តក្ខន្ធ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ សេចក្តីបំប្រួញ ។

[ ១៤៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យមានវារៈ ៩ ក្នុងនអាហារប្បច្ច័យមានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំង ២ យ៉ាងក្រៅនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

[ ១៤៦ ] ឧបាទានសម្បយុត្តធម៌ ប្រកបនឹងឧបាទានសម្បយុត្តធម៌ ទើប

កើតឡើង ព្រោះហេតុប្បច្ច័យ គឺប្រឡំនឹងឧបាទានសម្បយុត្តក្ខន្ធ ១ ... មានវារៈ ៣ ។ ឧបាទានវិប្បយុត្តធម៌ ប្រឡំនឹងឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអរូបដូចគ្នានឹងបដិច្ចវារៈដែរ ។ ឧបាទានសម្បយុត្តធម៌ ប្រឡំនឹងឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអរូប ដូចគ្នានឹងបដិច្ចវារៈដែរ ។ ឧបាទានសម្បយុត្តធម៌ ប្រឡំនឹងឧបាទានសម្បយុត្តធម៌ផង នឹងឧបាទានវិប្បយុត្តធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអរូបដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ១៤៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៦ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។

[ ១៤៨ ] ឧបាទានវិប្បយុត្តធម៌ ប្រឡំនឹងឧបាទានវិប្បយុត្តធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ១៤៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ។ ការរាប់

ទាំង ២ យ៉ាងក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ១៥០ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកឧបាទានសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកឧបាទានសម្បយុត្តហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ពួកហេតុដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃលោភៈដែលប្រាសចាកទិដ្ឋិផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានសម្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ពួកហេតុដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺពួកឧបាទានវិប្បយុត្តហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ លោភៈ ដែលប្រាសចាកទិដ្ឋិ ជាបច្ច័យ គឺជាបដិសន្ធិនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ លោភៈដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើ

ចុះ លោភៈដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយហេតុប្បច្ច័យ គឺមោហៈក្តី លោភៈក្តី ដែលច្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ មោហៈក្តី លោភៈក្តី ដែលច្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយហេតុប្បច្ច័យ គឺមោហៈក្តី លោភៈក្តី ដែលច្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ១៥១ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺពួកឧបាទានសម្បយុត្តក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកឧបាទានសម្បយុត្តក្ខន្ធ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានវិប្បយុត្តក្ខន្ធក្តី លោភៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកឧបាទានសម្បយុត្តក្ខន្ធ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលច្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី កើតឡើងព្រោះប្រារព្ធនូវពួកឧបាទានសម្បយុត្តក្ខន្ធ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យនូវទាន... នូវសីល... នូវឧបោសថកម្ម ។បេ។ នូវពួក

កុសលដែលសន្សំល្អហើយ ក្នុងកាលមុន... ចេញអំពីឈានហើយពិចារណា នូវឈាន ត្រេកអរ រីករាយ រាគៈដែលប្រាសចាកទិដ្ឋិ ប្រារព្ធនូវកុសល នោះ... វិចិកិច្ឆា... ឧទ្ធច្ចៈ... ទោមនស្សរបស់បុគ្គល អ្នកមានសេចក្តីក្តៅ ក្រហាយ ព្រោះតែលះបង់ឈាន កើតឡើង ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ នូវផល... ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជា បច្ច័យនៃការពិចារណានូវគោត្រភូ វោទានៈ មគ្គនិងផល ដោយអារម្ម- ណប្បច្ច័យ ពួកព្រះអរិយៈ ( ពិចារណា ) នូវពួកឧបាទានវិប្បយុត្តកិលេស ដែលលះបង់ហើយ... នូវពួកកិលេសដែលសង្កត់សង្កិនហើយ... ក្នុងកាល មុន... នូវចក្ខុ... នូវវត្ថុ... ឃើញច្បាស់នូវពួកឧបាទានវិប្បយុត្តក្ខន្ធផង នូវ លោកៈផង ថាមិនទៀង... ហើយត្រេកអរ រីករាយ រាគៈ ដែលប្រាសចាក ទិដ្ឋិ ប្រារព្ធនូវខន្ធនោះ... វិចិកិច្ឆា... ឧទ្ធច្ចៈ... ទោមនស្ស... ដំណើរទាំង អស់ មានបរិបូណ៌ ( តាំងអំពីឃើញរូប ) ដោយទិព្វចក្ខុ រហូតដល់កាយ- វិញ្ញាណ ពួកឧបាទានវិប្បយុត្តក្ខន្ធ ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និង អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជា បច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យ នូវទាន... ។បេ។ នូវឈាន... នូវចក្ខុ... នូវវត្ថុ... ត្រេកអរ រីករាយនឹងពួក ឧបាទានវិប្បយុត្តក្ខន្ធផង នឹងលោកៈផង រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើត ឡើង ទិដ្ឋិ ។បេ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្ត-

ធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវចក្ខុ... នូវវត្ថុ... ពួកខន្ធដែលប្រឡាំដោយលោកៈ តែប្រាសចាកទិដ្ឋិក្តី លោកៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកឧបាទានវិប្បយុត្តក្ខន្ធផង នូវលោកៈផង ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ គឺពួកឧបាទានសម្បយុត្តក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធដែលប្រឡាំដោយលោកៈ តែប្រាសចាកទិដ្ឋិផង នូវលោកៈផង ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានវិប្បយុត្តក្ខន្ធក្តី លោកៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រឡាំដោយលោកៈតែប្រាសចាកទិដ្ឋិផង នូវលោកៈផង ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលប្រឡាំដោយលោកៈ តែប្រាសចាកទិដ្ឋិក្តី លោកៈក្តី កើតឡើងព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រឡាំដោយលោកៈតែប្រាសចាកទិដ្ឋិផង នូវលោកៈផង ។

[ ១៥២ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកឧបាទានសម្បយុត្តក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកឧបាទានសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺឧបាទានសម្បយុត្តាធិបតិជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ មូល គឺ អារម្មណាធិបតិ និងសហជាតាធិបតិ បណ្ឌិតគប្បីធ្វើចុះ ។ អារម្មណាធិបតិ គឺលោកៈដែលប្រាសចាកទិដ្ឋិ កើតឡើងព្រោះធ្វើនូវពួកឧបាទានសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺឧបាទានសម្បយុត្តាធិបតិ ជាបច្ច័យ

នៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ អធិបតិដែលប្រទូរ្យំដោយលោកៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃលោកៈ ដោយអធិបតិប្បច្ច័យ ។ មូល គឺ អារម្មណាធិបតិនិងសហជាតាធិបតិ បណ្ឌិតគប្បីធ្វើចុះ ។ អារម្មណាធិបតិ គឺពួកខន្ធ ដែលប្រទូរ្យំដោយលោកៈតែប្រាសចាកទិដ្ឋិក្តី លោកៈក្តី កើតឡើង ព្រោះធ្វើនូវពួកឧបាទានសម្បយុត្តក្ខន្ធ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺឧបាទានសម្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ អធិបតិដែលប្រទូរ្យំដោយលោកៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃលោកៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិគឺ ( បុគ្គល ) នូវទាន... នូវសីល ។បេ។ ចេញអំពីឈាន ហើយធ្វើនូវឈានឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈដែលប្រាសចាកទិដ្ឋិ ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទើបកើតឡើង ។បេ។ ពួកព្រះអរិយៈ ចេញអំពីមគ្គ ។បេ។ ជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកឧបាទានវិប្បយុត្តក្ខន្ធផង នូវលោកៈផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈដែលប្រាសចាកទិដ្ឋិ ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ។បេ។ ឯសហជាតា-ធិបតិ គឺឧបាទានវិប្បយុត្តាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ជាបច្ច័យ

នៃឧបាទានសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ ( បុគ្គល ) ឲ្យនូវទាន ។បេ។ អំពីឈាន... នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកឧបាទានវិប្បយុត្តក្ខន្ធផង នូវលោកៈផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្ប-យុត្តធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺនូវចក្ខុ... នូវវត្ថុ... ពួកខន្ធដែលប្រឡំដោយលោកៈ តែប្រាសចាកទិដ្ឋិក្តី លោកៈក្តី កើតឡើង ព្រោះធ្វើនូវពួកឧបាទានវិប្បយុត្តក្ខន្ធផង នូវលោកៈផង ឲ្យជាទីគោរព ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧ-បាទានសម្បយុត្តធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកឧបាទានសម្បយុត្តក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកខន្ធ ដែលប្រឡំដោយលោកៈតែប្រាសចាកទិដ្ឋិផង នូវលោកៈផង ឲ្យជាទីគោរព ។ មូល បណ្ឌិតគប្បីធ្វើចុះ លោកៈដែលប្រាសចាកទិដ្ឋិ កើតឡើងព្រោះធ្វើនូវពួកខន្ធ ដែលប្រឡំដោយលោកៈ តែប្រាសចាកទិដ្ឋិផង នូវលោកៈផង ឲ្យជាទីគោរព ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលប្រឡំដោយលោកៈតែប្រាសចាកទិដ្ឋិក្តី លោកៈក្តី កើតឡើងព្រោះធ្វើនូវពួកខន្ធ ដែលប្រឡំដោយលោកៈ តែប្រាសចាកទិដ្ឋិផង នូវលោកៈផង ឲ្យជាទីគោរព ។

[ ១៥៣ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកឧបាទានសម្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកឧបា-

ទានសម្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធមុនៗដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃលោភៈក្រោយៗដែលប្រាសចាកទិដ្ឋិ ដោយអនន្តរប្បច្ច័យ ពួកឧបាទានសម្បយុត្តក្ខន្ធ ជាបច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធមុនៗ ដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិផង នៃលោភៈផង ដោយអនន្តរប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺលោភៈមុនៗ ដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃលោភៈក្រោយៗ ដែលប្រាសចាកទិដ្ឋិ ដោយអនន្តរប្បច្ច័យ លោភៈដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ពួកឧបាទានវិប្បយុត្តក្ខន្ធមុនៗ ជាបច្ច័យនៃពួកឧបាទានវិប្បយុត្តក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យនៃគោត្រភូ និងផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ លោភៈមុនៗ ដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិ ដោយអនន្តរប្បច្ច័យ អាវជ្ជនា ( ការពិចារណា ) ជាបច្ច័យនៃពួកឧបាទានសម្បយុត្តក្ខន្ធ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ លោភៈមុនៗ ដែលប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិផង នៃលោភៈផង ដោយអនន្តរប្បច្ច័យ អាវជ្ជនាជាបច្ច័យនៃពួកខន្ធដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិផង នៃលោភៈផង ដោយអនន្តរប្បច្ច័យ ។

ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិ ដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធមុនៗ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃលោភៈក្រោយៗ ដែលប្រាសចាកទិដ្ឋិ ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃវុដ្ឋានដោយអនន្តរប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធមុនៗ ដែលប្រកបដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយលោភៈតែប្រាសចាកទិដ្ឋិផង នៃលោភៈផង ដោយអនន្តរប្បច្ច័យ ។

[ ១៥៤ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយសមនន្តរប្បច្ច័យ ។ ... ជាបច្ច័យដោយសហជាតប្បច្ច័យ មានវារៈ ៩ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ... ជាបច្ច័យដោយនិស្សយប្បច្ច័យ មានវារៈ ៩ ដូចគ្នានឹងបច្ចយវារៈដែរ ។

[ ១៥៥ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកឧបាទានសម្បយុត្តក្ខន្ធ

ជាបច្ច័យនៃពួកឧបាទានសម្បយុត្តក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានសម្បយុត្តក្ខន្ធ ជាបច្ច័យនៃពួកឧបាទានវិប្ប-យុត្តក្ខន្ធផង នៃលោភៈផង ដោយឧបនិស្សយប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកឧបាទានសម្បយុត្តក្ខន្ធ ជាបច្ច័យនៃពួកខន្ធដែលប្រទូស្តដោយលោភៈតែប្រាសចាកទិដ្ឋិផង នៃលោភៈផង ដោយឧបនិស្សយប្បច្ច័យ ។ ឧបាទាន-វិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធាហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងមានះ នូវសីល ។បេ។ នូវបញ្ញា... នូវឧបាទានវិប្បយុត្តរាគៈ នូវមានះ នូវសេចក្តីប្រាថ្នា... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃបញ្ញា នៃឧបាទានវិប្បយុត្តរាគៈ មានះ សេចក្តីប្រាថ្នា កាយិកសុខនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ឧបា-ទានវិប្បយុត្តធម៌ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ បុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងមានះ ប្រកាន់ទិដ្ឋិនូវសីល ។បេ។ នូវបញ្ញា... នូវឧបាទានវិប្បយុត្តរាគៈ នូវមានះ នូវសេចក្តីប្រាថ្នា... អាស្រ័យនូវសេនាសនៈ នូវទ្រព្យដែលគេមិនបានឲ្យ... កុហក... នូវពាក្យញុះញង់... នូវពាក្យឥតប្រយោជន៍... នូវទីត... នូវការលបធក់យកទ្រព្យគេ... នូវការប្លន់យកទ្រព្យក្នុងផ្ទះមួយ... ( ចាំស្កាត់ ) ក្នុងផ្លូវជួប

គ្នា... នូវប្រពន្ធនៃបុគ្គលដទៃ... នូវការសម្លាប់អ្នកស្រុក... នូវការសម្លាប់អ្នកនិគម... សទ្ធា... សេនាសនៈជាបច្ច័យនៃឧបាទានសម្បយុត្តកគៈ មោហៈ មានៈ ទិដ្ឋិនិងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយដំឡើងមានះ នូវសីល... នូវបញ្ញា... នូវឧបាទានវិប្បយុត្តកគៈ ។បេ។ អាស្រ័យនូវសេនាសនៈ ហើយធ្វើនូវការសម្លាប់អ្នកស្រុក ធ្វើនូវការសម្លាប់អ្នកនិគម សទ្ធា... សេនាសនៈ ជាបច្ច័យនៃពួកខន្ធដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិផង នៃលោភៈផង ដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយឧបនិស្សយប្បច្ច័យ ពួកខន្ធដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃពួកឧបាទានសម្បយុត្តកខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃពួកឧបាទានវិប្បយុត្តកខន្ធផង នៃលោភៈផង ដោយឧបនិស្សយប្បច្ច័យ ។ មូល បណ្ឌិតគប្បីធ្វើចុះ ពួកខន្ធដែលប្រឡំដោយ លោភៈតែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃពួកខន្ធដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិផង នៃលោភៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៥៦ ] ឧបាទានវិប្បយុត្តធម៌ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណ-បុរេជាត គឺ ( បុគ្គល ) នូវចក្ខុ... នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្ស កើតឡើង ឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ។ ឯវត្ថុបុរេ-ជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកឧបាទានវិប្បយុត្តក្ខន្ធផង នៃលោភៈផង ដោយបុរេជាតប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) នូវចក្ខុ... ត្រេកអរ រីករាយចំពោះវត្ថុ រាគៈប្រារព្ធ នូវវត្ថុនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកឧបាទានសម្បយុត្តក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយបុរេ-ជាតប្បច្ច័យ បានដល់អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... ពួកខន្ធដែលច្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុ ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកខន្ធដែលច្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិផង នៃលោភៈផង ដោយបុរេ-ជាតប្បច្ច័យ ។

[ ១៥៧ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌

ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ ។

[ ១៥៨ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយកម្មប្បច្ច័យ គឺឧបាទានសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺឧបាទានសម្បយុត្តចេតនាជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ចេតនាដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺឧបាទានសម្បយុត្តចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយកម្មប្បច្ច័យ គឺឧបាទានសម្បយុត្តចេតនា ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនាដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិ ជាបច្ច័យនៃពួកសម្បយុត្តក្ខន្ធផង នៃលោភៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌

ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺឧបាទានវិប្បយុត្ត ចេតនាជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺឧបាទានវិប្បយុត្តចេតនាជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ១៥៩ ] ឧបាទានវិប្បយុត្តធម៌ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយវិបាកប្បច្ច័យ គឺឧបាទានវិប្បយុត្តក្ខន្ធ ១ ជាវិបាក ។បេ។ វារៈ ១ ។

[ ១៦០ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអាហារប្បច្ច័យ ។ ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ។ ឯលោកៈដែលប្រាសចាកទិដ្ឋិ លោកបានសម្តែងហើយក្នុងកម្មប្បច្ច័យយ៉ាងណា ( លោកៈនេះ ) បណ្ឌិតគប្បីសម្តែងក្នុងបច្ច័យទាំង ៤ នេះ យ៉ាងនោះដែរ មានបញ្ហាបួនៗ ។ ... ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៦ ។

[ ១៦១ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ឧបាទានវិប្បយុត្តធម៌ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកឧបាទានសម្បយុត្តកក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង

នៃឧបាទានវិប្បយុត្តធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត គឺ វត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រទូរ្យំដោយលោកៈតែប្រាស ចាកទិដ្ឋិផង នៃលោកៈផង ដោយវិប្បយុត្តប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលប្រទូរ្យំដោយលោកៈតែប្រាសចាកទិដ្ឋិក្តី លោកៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺ ។បេ។

[ ១៦២ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ គឺមានវារៈ ១ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ គឺដូចគ្នានឹងបដិច្ចវារៈដែរ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សេចក្តីបំប្រួញ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ បណ្តាសហជាតនិងបុរេជាតទាំងនេះ សហ-

ជាតដូចគ្នានឹងសហជាតប្បច្ច័យ ឯបុរេជាតដូចគ្នានឹងបុរេជាតប្បច្ច័យដែរ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត ។ សហជាត គឺ ឧបាទានសម្បយុត្តក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺពួកឧបាទានសម្បយុត្តក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ សហជាត គឺពួកខន្ធដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ សហជាត គឺពួកខន្ធដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី វត្ថុក្តី ជាបច្ច័យនៃលោភៈ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលប្រឡំដោយលោភៈតែប្រាសចាក ទិដ្ឋិក្តី លោភៈក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកខន្ធដែលប្រឡំដោយលោភៈ តែប្រាសចាកទិដ្ឋិក្តី លោភៈក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យ

នៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិគ្គី លោភៈក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហជាត គឺខន្ធ ១ ដែលប្រឡំដោយលោភៈតែប្រាសចាកទិដ្ឋិគ្គី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃលោភៈផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ១៦៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៦៤ ] ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្ប-យុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហ-ជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេ-ជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ឧបាទានវិប្បយុត្តធម៌ ជាបច្ច័យនៃឧបាទានសម្ប-យុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយ

សហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។ ឧបាទានសម្ប-យុត្តធម៌ក្តី ឧបាទានវិប្បយុត្តធម៌ក្តី ជាបច្ច័យនៃឧបាទានវិប្បយុត្តធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្ស-យប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ ឧបាទានសម្បយុត្តធម៌ក្តី ឧបាទានវិប្ប-យុត្តធម៌ ជាបច្ច័យនៃឧបាទានសម្បយុត្តធម៌ផង នៃឧបាទានវិប្បយុត្តធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១៦៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៦៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៦៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ អនុលោមមាតិកា ។ ... ក្នុងអវិគ-

តប្បច្ច័យ មានវារៈ ៩ ។

ចប់ ឧបាទានសម្បយុត្តទុកៈ ។

## ឧបាទានឧបាទានិយទុកៈ

## បដិច្ចវារៈ

[ ១៦៨ ] ធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទាន អាស្រ័យនូវធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទាន អាស្រ័យនូវទិដ្ឋុបាទាន ទិដ្ឋុបាទាន អាស្រ័យនូវកាមុបាទាន ។ ចក្កៈ ។ ធម៌ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន អាស្រ័យនូវធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកឧបាទាន ។ ធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានក្តី ធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទានក្តី អាស្រ័យនូវធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវទិដ្ឋុបាទាន ។ ចក្កៈ ។ ធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន អាស្រ័យនូវធម៌ជាឧបាទានតែមិនមែនជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជា

ប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន បដិសន្ធិដរាបដល់មហាភូតខាងក្នុង ។ ធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន អាស្រ័យនូវធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកឧបាទានអាស្រ័យនូវពួកខន្ធ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ។ ធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានក្តី ធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទានក្តី អាស្រ័យនូវធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ខន្ធ ៣ ក្តី ពួកឧបាទានក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន នូវវត្ថុ ២ ... ។ ធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទាន អាស្រ័យនូវធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានផង នូវធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទាន អាស្រ័យនូវទិដ្ឋុបាទានផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ចក្កៈ ។ ធម៌ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន អាស្រ័យនូវធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទានផង នូវធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទានផង នូវពួកឧបាទានផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានផង នូវពួកមហាភូតផង ។ ធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទានក្តី ធម៌

ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទានក្តី អាស្រ័យនូវធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានផង នូវធម៌ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី កាមុបាទានក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទានផង នូវទិដ្ឋុបាទានផង នូវខន្ធ ២ ... ។ ចក្កៈ ។

ឧបាទានទុកៈ យ៉ាងណា ( ឧបាទានឧបាទានិយទុកៈ ) ក៏យ៉ាងនោះដែរ បដិច្ចវារៈក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ អាមសនៈ គឺបរាមាសទុកៈ ទើបមានការធ្វើឲ្យផ្សេងៗគ្នា ។

## បញ្ហាវារៈ

[ ១៦៩ ] ធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន ដោយហេតុប្បច្ច័យ គឺពួកហេតុជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ ធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ដោយហេតុប្បច្ច័យ គឺពួកហេតុ ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេ-

តុប្បច្ច័យ ។ បញ្ហាទាំង ៩ មិនប្លែកគ្នាទេ ដូចឧបាទានទុកៈដែរ ។

[ ១៧០ ] ធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ គឺពួកឧបាទាន ប្រារព្ធហើយនូវពួកឧបាទាន ទើបកើតឡើង ។ មានវារៈ ៣ ។ ធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ជាបច្ច័យនៃធម៌ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) នូវទាន ។បេ។ ចេញអំពីឈាន ហើយពិចារណានូវឈាន ត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវកុសលនោះ... ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ... ទោមនស្ស កើតឡើង ពួកព្រះអរិយៈពិចារណានូវគោត្រភូ ពិចារណានូវវោទាន នូវពួកកិលេសដែលលះបង់ហើយ... នូវពួកកិលេស ដែលសង្កត់សង្កិនហើយ... នូវពួកកិលេសដែលសន្សំហើយក្នុងកាលមុន... នូវចក្ខុ... នូវវត្ថុ... ។ សេចក្តីបំប្រួញ ។ ជាបច្ច័យនៃការពិចារណានូវអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧ-បាទាន ជាបច្ច័យនៃធម៌ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ ។ សេចក្តីបំប្រួញ ។ វារៈទាំង ២ ក្រៅនេះ ដូចគ្នានឹងឧបាទានទុកៈដែរ ។ ធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទានក្តី ធម៌ជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទានក្តី ជាបច្ច័យនៃធម៌ជាឧបាទានទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អ-ធិបតិធម៌ខាងក្រោម មានវារៈ ៣ ដូចឧបាទានទុកៈដែរ ។

[ ១៧១ ] ធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ជាបច្ច័យនៃធម៌ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) នូវទាន ។បេ។ ចេញអំពីឈានធ្វើនូវឈាន ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈធ្វើនូវកុសលនោះឲ្យជាទីគោរព... ទិដ្ឋិកើតឡើង ។បេ។ ពួកសេក្ខបុគ្គលធ្វើនូវគោត្រភូឲ្យជាទីគោរព... នូវវោទាន... នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកខន្ធជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទានឲ្យជាទីគោរព ត្រេកអរ រីករាយ រាគៈធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិ ។បេ។ ពួកខន្ធជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន កើតឡើង ។ ឯសហជាតាធិបតិ គឺអធិបតិធម៌ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ បច្ច័យទាំង ២ ដ៏សេសក្តី អារម្មណាធិបតិក្តី សហជាតាធិបតិក្តី ដូចឧបាទានទុកៈដែរ ។ ឯការ**តេ** និងអធិបតិ មានវារៈ ៣ ដូចឧបាទានទុកៈដែរ បច្ច័យទាំងអស់ ដូចឧបាទានទុកៈដែរ ឯលោកុត្តរក្នុងឧបាទានិយៈ មិនមានទេ បច្ចនីយៈក្តី ការរាប់ ទាំង ២ យ៉ាង ក្រៅនេះក្តី ដូចឧបាទានទុកៈដែរ ។

**ចប់ ឧបាទានឧបាទានិយទុកៈ ។**

# ឧបាទានឧបាទានសម្បយុត្តទុកៈ

## បដិច្ចវារៈ

[ ១៧២ ] ធម៌ជាឧបាទាន ទាំងប្រកបដោយឧបាទាន អាស្រ័យនូវធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទាន អាស្រ័យនូវទិដ្ឋុបាទាន ។ បណ្ឌិត គប្បីធ្វើជាចក្កៈចុះ ។ ធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន អាស្រ័យនូវធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្ត-កក្ខន្ធ អាស្រ័យនូវពួកឧបាទាន ។ ធម៌ជាឧបាទាន ទាំងប្រកបដោយឧបាទានក្តី ធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី អាស្រ័យនូវធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺកាមុបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវទិដ្ឋុបាទាន ។ ចក្កៈ ។ នូវធម៌ប្រកបដោយឧបាទាន ។ សេចក្តីបំប្រួញ ។ មានការប៉ះពាល់ មានការធ្វើឲ្យផ្សេងៗគ្នា ដូចគ្នានឹងឧបាទានទុកៈដែរ មានបញ្ហា ៩ រូបមិនមានទេ វារៈទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ អរូបនៅដដែល ។

## បញ្ហាវារៈ

[ ១៧៣ ] ធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយហេតុប្បច្ច័យ គឺពួកហេតុជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយហេ-តុប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកហេតុ ជាឧបាទានទាំងប្រកប

ដោយឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិត គប្បីសួរផងចុះ ពួកហេតុជាឧបាទាន ទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង ដោយហេតុប្បច្ច័យ ។ ធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យនៃធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយហេតុប្បច្ច័យ គឺពួកហេតុប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកហេតុប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកហេតុប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង ដោយហេតុប្បច្ច័យ ។ ធម៌ជាឧបាទាន ទាំងប្រកបដោយឧបាទានក្តី ធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី ជាបច្ច័យនៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយហេតុប្បច្ច័យ គឺពួកហេតុជាឧបាទាន ទាំងប្រកបដោយឧបាទានក្តី ពួកហេតុប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី ជាបច្ច័យនៃពួកសម្បយុត្តកឧបាទាន ដោយហេតុប្បច្ច័យ ។ មូលបណ្ឌិតគប្បីសួរផងចុះ ពួកហេតុ ជាឧបាទានទាំងប្រកបដោយឧបាទានក្តី ពួកហេតុប្រកបដោយឧបាទានតែមិនមែនជាឧបាទានក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកហេតុ ជាឧបាទានទាំងប្រកបដោយឧបាទានក្តី ពួកហេតុប្រកបដោយឧបាទាន តែមិនមែនជា

ឧបាទានក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកឧបាទានផង ដោយហេតុប្បច្ច័យ ។

[ ១៧៤ ] ធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយអារម្មណប្បច្ច័យ គឺពួកឧបាទានកើតឡើង ព្រោះប្រារព្ធនូវពួកឧបាទាន ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកខន្ធប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន កើតឡើង ព្រោះប្រារព្ធនូវពួកឧបាទាន ។ បណ្ឌិត គប្បីសួរនូវមូលចុះ ពួកឧបាទានក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកឧបាទាន ។ ធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យនៃធម៌ប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ដោយអារម្មណប្បច្ច័យ គឺពួកខន្ធប្រកបដោយឧបាទានតែមិនមែនជាឧបាទាន កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ។ បណ្ឌិត គប្បីធ្វើវារៈ ៣ យ៉ាងចុះ ។ ក្នុងតំណដែលតគ្នា បណ្ឌិតគប្បីធ្វើវារៈ ៣ យ៉ាងទៀតចុះ ។

[ ១៧៥ ] ធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយអធិបតិប្បច្ច័យ គឺមានវារៈ ៣ ។ ធម៌ប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ជាបច្ច័យនៃធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ សហជាតាធិបតិ មានវារៈ ៣ ដែរ ។ អធិបតិទាំង ២ យ៉ាង បណ្ឌិតគប្បីធ្វើ ក្នុងវារៈទាំង ៣ ចុះ ។ ឯឆន្ទាធិបតិ មានវារៈ ៣ ។

[ ១៧៦ ] ធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយអនន្តរប្បច្ច័យ គឺពួកខន្ធ ជាឧបាទានទាំងប្រកបដោយឧបាទានមុនៗ ជាបច្ច័យនៃពួកឧបាទានក្រោយៗ ដោយអនន្តរប្បច្ច័យ ។ បញ្ហា ៩ យ៉ាង បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ អាវជ្ជនាក្តី វុដ្ឋានក្តី មិនមានទេ ។

[ ១៧៧ ] ធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយសមនន្តរប្បច្ច័យ គឺមានវារៈ ៩ ។ ... ជាបច្ច័យ ដោយសហជាតប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយនិស្សយប្បច្ច័យ មានវារៈ ៩ ។

[ ១៧៨ ] ធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ដោយឧបនិស្សយប្បច្ច័យ ។បេ។ មានវារៈ ៣ ។ ធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យនៃធម៌ដែលប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ ឯក្នុងឃដនូបនិស្ស័យ មានវារៈ ៣ ដែរ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ មានវារៈ ៩ ។

[ ១៧៩ ] ធម៌ប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ជាបច្ច័យនៃ

ធម៌ប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ដោយកម្មប្បច្ច័យ មានវារៈ ៣ ។ ... ជាបច្ច័យដោយអាហារប្បច្ច័យ មានវារៈ ៣ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៣ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអត្ថិប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយនត្ថិប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយវិគតប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៨១ ] ធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ជាឧបាទាន ទាំងប្រកបដោយឧបាទាន ដោយអារម្មណប្បច្ច័យ ជាបច្ច័យ

ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាឧបាទាន ទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ ដែលប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ជាឧបាទានទាំងប្រកបដោយឧបាទាន ជាបច្ច័យនៃធម៌ជាឧបាទាន ទាំងប្រកបដោយឧបាទានផង នៃធម៌ដែលប្រកបដោយឧបាទាន តែមិនមែនជាឧបាទានផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

វារៈ ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ក្នុងមូលនៃបច្ច័យមួយៗ មានបញ្ហាបីៗ ។

[ ១៨២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៨៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៨៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើផង ចុះ ។

**ចប់ ឧបាទានឧបាទានសម្បយុត្តទុកៈ ។**

# ឧបាទានវិប្បយុត្តឧបាទានិយទុកៈ
# បដិច្ចវារៈ

[ ១៨៥ ] ឧបាទានវិប្បយុត្តឧបាទានិយធម៌ ( ធម៌ដែលប្រាសចាក ឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ) អាស្រ័យនូវឧបាទានវិប្បយុត្តឧបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវឧបាទានវិប្បយុត្តឧបាទានិយក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ ។បេ។ មហាភូត ១ ... ចិត្តសមុដ្ឋានរូប កដត្តារូបនិង ឧបាទារូប អាស្រ័យនូវពួកមហាភូត ។ ឧបាទានវិប្បយុត្តអនុបាទានិយធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តអនុបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវឧបាទានវិប្បយុត្តអនុបាទានិយក្ខន្ធ ១ នូវខន្ធ ២ ... ។ ឧបាទានវិប្បយុត្តឧបាទានិយធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តអនុបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបាទានវិប្បយុត្តអនុបាទានិយក្ខន្ធ ។ ឧបាទានវិប្បយុត្តឧបា-

ទានិយធម៌ក្តី ឧបាទានវិប្បយុត្តអនុបាទានិយធម៌ក្តី អាស្រ័យនូវឧបាទាន-វិប្បយុត្តអនុបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវឧបាទានវិប្បយុត្តអនុបាទានិយក្ខន្ធ ១ ។ ឧបាទានវិប្បយុត្តឧបាទានិយធម៌ អាស្រ័យនូវឧបាទានវិប្បយុត្តឧបាទានិយធម៌ផង នូវឧបាទានវិប្បយុត្តអនុបាទានិយធម៌ផង ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ គឺចិត្តសមុដ្ឋានរូបអាស្រ័យនូវពួកឧបាទានវិប្បយុត្តអនុបាទានិយក្ខន្ធផង នូវពួកមហាភូតផង ។

[ ១៨៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។ ទុកៈនេះ ដូចគ្នានឹងលោកិយទុកៈ ក្នុងចូឡន្តរទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

**ចប់ ឧបាទានវិប្បយុត្តឧបាទានិយទុកៈ ។**

# កិលេសទុកៈ

## បដិច្ចវារៈ

[ ១៨៧ ] កិលេសធម៌អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ទិដ្ឋិ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ មានះ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវ

លោភៈ មោហៈ មានះ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យ នូវលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវទោសៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវទោសៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវវិចិកិច្ឆា មោហៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវឧទ្ធច្ចៈ ។ នោកិលេសធម៌អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវកិលេស ។ កិ-លេសធម៌ក្តី នោកិលេសធម៌ក្តី អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវលោភៈ ។ ចងជាចក្កៈ ផងចុះ ។ នោកិលេសធម៌ អាស្រ័យនូវនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោកិ-លេសក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងបដិសន្ធិក្ខណៈ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ មហាភូត ១ ... ។ កិលេសធម៌ អាស្រ័យនូវនោ-កិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកកិលេស អាស្រ័យនូវពួកនោកិលេសក្ខន្ធ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី អាស្រ័យនូវនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ពួកកិលេសក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោកិលេសក្ខន្ធ ១ នូវខន្ធ ២ ... ។

កិលេសធម៌ អាស្រ័យនូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវលោភៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។ ចងជាចក្កៈផងចុះ ។ នោកិលេសធម៌អាស្រ័យនូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោកិលេសក្ខន្ធ ១ ផង នូវពួកកិលេសផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកកិលេសផង នូវពួកមហាភូតផង ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី អាស្រ័យនូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈនិងចិត្តសមុដ្ឋានរូប អាស្រ័យនូវនោកិលេសក្ខន្ធ ១ ផង នូវលោភៈផង នូវ ខន្ធ ២ ... ។ ចងជាចក្កៈផងចុះ ។ សេចក្តីបំប្រួញ ។

[ ១៨៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៨៩ ] កិលេសធម៌ អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ អាស្រ័យនូវវិចិកិច្ឆា មោហៈ អាស្រ័យនូវឧទ្ធច្ចៈ ។ នោកិលេសធម៌ អាស្រ័យនូវនោកិលេសធម៌ ទើបកើតឡើង

ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនោ-កិលេសក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... មានអហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ ។ កិលេសធម៌ អាស្រ័យនូវនោកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។ កិលេសធម៌ អាស្រ័យនូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រឡំដោយវិចិកិច្ឆា អាស្រ័យនូវពួកខន្ធដែលប្រឡំដោយវិចិកិច្ឆាផង នូវវិចិកិច្ឆាផង មោហៈដែលប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រឡំដោយឧទ្ធច្ចៈផង នូវឧទ្ធច្ចៈផង ។

[ ១៩០ ] នោកិលេសធម៌ អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកកិលេស ។ នោកិលេសធម៌ អាស្រ័យនូវនោកិលេសធម៌ ទើបកើតឡើង ព្រោះនអា-រម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនោកិលេសក្ខន្ធ ក្នុងបដិ-សន្ធិក្ខណៈ វត្ថុអាស្រ័យនូវពួកខន្ធ មានរហូតដល់ពួកអសញ្ញសត្វ ។ នោ-កិលេសធម៌ អាស្រ័យនូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកកិលេសផង នូវពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកកិលេសផង នូវពួកមហាភូតផង ។ ... ព្រោះនអធិបតិប្បច្ច័យ ព្រោះនអនន្តរប្បច្ច័យ ព្រោះនសមនន្តរប្បច្ច័យ ព្រោះនអញ្ញមញ្ញប្បច្ច័យ ព្រោះនឧបនិស្ស-

យប្បច្ច័យ ។

[ ១៩១ ] កិលេសធម៌ អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ទិដ្ឋិ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ មានះ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ មានះ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវលោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវវិចិកិច្ឆា មោហៈ អហិរិកៈនិងអនោត្តប្បៈ អាស្រ័យនូវឧទ្ធច្ចៈ ។ ក្នុងអរូបមិនមានទោសមូលទេ ។ នោកិលេសធម៌ អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺក្នុងអរូប ពួកសម្បយុត្តកក្ខន្ធអាស្រ័យនូវពួកកិលេស ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកកិលេស ។ បញ្ហាទាំង ៩ យ៉ាង បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។ ... ព្រោះនបច្ឆាជាតប្បច្ច័យ ព្រោះនអាសេវនប្បច្ច័យ ។

[ ១៩២ ] នោកិលេសធម៌ អាស្រ័យនូវកិលេសធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺពួកសម្បយុត្តកចេតនា អាស្រ័យនូវពួកកិលេស នោកិលេសធម៌ អាស្រ័យនូវនោកិលេសធម៌ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺពួកសម្បយុត្តកចេតនា អាស្រ័យនូវពួកនោកិលេសក្ខន្ធ ពាហិរៈ... អា-

ហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ។បេ។ នោកិលេសធម៌ អាស្រ័យនូវកិលេសធម៌ផង នូវនោកិលេសធម៌ផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺសម្បយុត្តកចេតនា អាស្រ័យនូវពួកកិលេសផង នូវពួកសម្បយុត្តកក្ខន្ធផង ។ បច្ច័យទាំងអស់ បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

[ ១៩៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ ២ យ៉ាង ក្រៅនេះក្តី សហជាតវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បច្ចយវារៈ

[ ១៩៤ ] កិលេសធម៌ ពឹងផ្អែកនឹងកិលេសធម៌ ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ គឺមានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នោកិលេសធម៌ពឹងផ្អែកនឹងនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងនោកិលេសក្ខន្ធ ១ រហូតដល់ពួកមហាភូតខាងក្នុង ពួកនោ-កិលេសក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ កិលេសធម៌ ពឹងផ្អែកនឹងនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកកិលេសពឹងផ្អែក នឹងពួកនោ-កិលេសក្ខន្ធ ពួកកិលេសពឹងផ្អែកនឹងវត្ថុ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ពឹងផ្អែកនឹងនោកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ពួកកិលេសក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោកិលេសក្ខន្ធ ១ នឹងខន្ធ ២ ... ពួកកិលេសពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី ពឹងផ្អែកនឹងវត្ថុ ។ កិលេសធម៌ ពឹងផ្អែកនឹងកិលេសធម៌ផង នឹងនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ពឹងផ្អែកនឹងលោភៈផង នឹងពួកសម្បយុត្តកក្ខន្ធផង ។ ចងជាចក្កៈចុះ ។ ពួកកិលេសពឹងផ្អែកនឹងលោភៈផង នឹងវត្ថុផង ។ នោកិលេសធម៌ ពឹងផ្អែកនឹងកិលេស-ធម៌ផង នឹងនោកិលេសធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោកិលេសក្ខន្ធ ១ ផង នឹងកិលេសផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកកិលេសផង នឹងពួកមហាភូតផង ពួកនោកិលេសក្ខន្ធពឹងផ្អែកនឹងពួកកិលេសផង នឹងវត្ថុផង ។ កិលេស-ធម៌ក្តី នោកិលេសធម៌ក្តី ពឹងផ្អែកនឹងកិលេសធម៌ផង នឹងនោកិលេសធម៌

ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនោកិលេសក្ខន្ធ ១ ផង នឹងលោភៈផង នឹងខន្ធ ២ ... ។ ចងជាចក្កៈចុះ ។ មោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងលោភៈផង នឹងវត្ថុផង ។ ចងជាចក្កៈចុះ ។

បញ្ចវិញ្ញាណ ក្នុងនោកិលេសមូល បណ្ឌិត គប្បីធ្វើក្នុងអារម្មណប្បច្ច័យចុះ ។

[ ១៩៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៩៦ ] កិលេសធម៌ ពឹងផ្អែកនឹងកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ពឹងផ្អែកនឹងវិចិកិច្ឆា មោហៈដែលប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងឧទ្ធច្ចៈ ។ នោកិលេសធម៌ ពឹងផ្អែកនឹងនោកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺរហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ កាយាយតនៈ ពឹងផ្អែកនឹងចក្ខាយតនៈ... ពួកនោកិលេសក្ខន្ធ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ ។ កិលេសធម៌ ពឹងផ្អែកនឹងនោកិលេសធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ កិលេសធម៌ ពឹងផ្អែកនឹង

កិលេសធម៌ផង និងនោកិលេសធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រទូ្បំដោយវិចិកិច្ឆា ពឹងផ្អែកនឹងវិចិកិច្ឆាផង នឹងពួកសម្ប-យុត្តកក្ខន្ធផង នឹងវត្ថុផង មោហៈដែលប្រទូ្បំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងឧទ្ធច្ចៈផង នឹងពួកសម្បយុត្តកក្ខន្ធផង នឹងវត្ថុផង ។ សេចក្ដីបំប្រួញ ។

[ ១៩៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ឯការរាប់ ២ យ៉ាង ក្រៅពីនេះក្ដី និស្សយវារៈក្ដី បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

[ ១៩៨ ] កិលេសធម៌ ប្រទូ្បំនឹងកិលេសធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ប្រទូ្បំនឹងលោភៈ ។ ចងជាចក្កៈចុះ ។ បញ្ហាទាំង ៩ បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។

[ ១៩៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២០០ ] កិលេសធម៌ ប្រទូ្បំនឹងកិលេសធម៌ ទើបកើតឡើង ព្រោះ

នហេតុប្បច្ច័យ គឺនហេតុប្បញ្ហា ៤ យ៉ាង បណ្ឌិត គប្បីធ្វើយ៉ាងនេះចុះ ។

[ ២០១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

ការរាប់ពីរយ៉ាងក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ២០២ ] កិលេសធម៌ ជាបច្ច័យនៃកិលេសធម៌ ដោយហេតុប្បច្ច័យ គឺពួកកិលេសហេតុ ជាបច្ច័យនៃពួកសម្បយុត្តកកិលេស ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកកិលេសហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកកិលេសហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកិលេសផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នោកិលេសធម៌ ជាបច្ច័យនៃនោកិលេសធម៌ ដោយហេតុប្បច្ច័យ គឺពួកនោកិលេសហេតុ ជាបច្ច័យ គឺជាបដិសន្ធិនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ២០៣ ] កិលេសធម៌ជាបច្ច័យនៃកិលេសធម៌ ដោយអារម្មណប្បច្ច័យ

គឺពួកកិលេស កើតឡើង ព្រោះប្រារព្ធនូវពួកកិលេស ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកនោកិលេស កើតឡើង ព្រោះប្រារព្ធនូវពួកកិលេស ។ មូល បណ្ឌិតគប្បីសួរផងចុះ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវពួកកិលេស ។ នោកិលេសធម៌ ជាបច្ច័យនៃនោកិលេសធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គល ( ឲ្យ ) នូវទាន... នូវសីល... នូវឧបោសថកម្ម... ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន... ចេញអំពីឈាន ពិចារណានូវឈាន ត្រេកអរ រីករាយ រាគៈ... ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ... ទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវកុសលនោះ ពួកព្រះអរិយៈ ចេញអំពីមគ្គ ។បេ។ ជាបច្ច័យនៃការពិចារណានូវផល ដោយអារម្មណប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... នូវពួកនោកិលេសក្ខន្ធ ជាមិនទៀង ។បេ។ ទោមនស្ស កើតឡើង បុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ដោយទិព្វសោតធាតុ ។បេ។ ជាបច្ច័យនៃការពិចារណានូវអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ នោកិលេសធម៌ជាបច្ច័យនៃកិលេសធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គល ( ឲ្យ ) នូវទាន ។បេ។ ចេញអំពីឈាន ត្រេកអរ រីករាយនឹងឈាន រាគៈ... ទិដ្ឋិ... វិចិកិច្ឆា... ឧទ្ធច្ចៈ ព្រោះប្រារព្ធនូវកុសលនោះ ។បេ។ ទោមនស្សរបស់បុគ្គលអ្នកមានសេចក្តីស្តាយក្រោយ ព្រោះសាបសូន្យឈាន កើតឡើង នឹងចក្ខុ... នឹងវត្ថុ... បុគ្គល ត្រេកអរ រីករាយនឹងពួកនោកិលេសក្ខន្ធ រាគៈ ប្រារព្ធនូវធម៌នោះ ។បេ។ ទោមនស្ស... ។ នោកិលេសធម៌ ជាបច្ច័យនៃកិលេសធម៌ផង នៃនោកិលេសធម៌ផង ដោយអារម្មណប្បច្ច័យ គឺបុគ្គល

( ឲ្យ ) នូវទាន ។បេ។ ចេញអំពីឈាន ។បេ។ នឹងចក្ខុ... នឹងវត្ថុ... បុគ្គល ត្រេកអរ រីករាយនឹងពួកនោកិលេសក្ខន្ធ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវខន្ធនោះ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ជាបច្ច័យនៃកិលេសធម៌ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ២០៤ ] កិលេសធម៌ ជាបច្ច័យនៃកិលេសធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកកិលេស កើតឡើង ព្រោះធ្វើនូវពួកកិលេសឲ្យជាទីគោរព ។ មានវារៈ ៣ នៅជាអារម្មណាធិបតិដដែល ។ នោកិលេសធម៌ ជាបច្ច័យនៃនោកិលេសធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល ( ឲ្យ ) នូវទាន... នូវសីល... ធ្វើនូវឧបោសថកម្ម ធ្វើនូវកុសលកម្មនោះ ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយធ្វើនូវមគ្គឲ្យជាទីគោរព ។បេ។ ជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... បុគ្គលធ្វើនូវពួកនោកិលេសក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទិដ្ឋិ... ។ ឯសហជាតាធិបតិ គឺនោកិលេសាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នោកិលេសធម៌ ជាបច្ច័យនៃកិលេសធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្ម-

ណាធិបតិ គឺបុគ្គល ( ឲ្យ ) នូវទាន ។បេ។ នូវឈាន... នូវចក្ខុ... នូវវត្ថុ... បុគ្គលធ្វើនូវពួកនោកិលេសក្ខន្ធ ឲ្យជាទីគោរពហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវខន្ធនោះឲ្យជាទីគោរព ទិដ្ឋិ... ។ ឯសហជាតាធិបតិ គឺនោកិលេសាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្កិលេស ដោយអធិបតិប្បច្ច័យ ។ នោកិលេសធម៌ជាបច្ច័យនៃកិលេសធម៌ផង នៃនោកិលេសធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គល ( ឲ្យ ) នូវទាន ។បេ។ នូវឈាន... នូវចក្ខុ... នូវវត្ថុ... បុគ្គលធ្វើនូវពួកនោកិលេសក្ខន្ធ ឲ្យជាទីគោរព ត្រេកអរ រីករាយ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះធ្វើនូវធម៌នោះឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺនោកិលេសាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកិលេសផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ជាបច្ច័យនៃកិលេសធម៌ ដោយអធិបតិប្បច្ច័យ គឺមានវារៈ ៣ នៅជាអារម្មណាធិបតិដដែល ។

[ ២០៥ ] កិលេសធម៌ ជាបច្ច័យនៃកិលេសធម៌ ដោយអនន្តរប្បច្ច័យ គឺពួកកិលេសមុនៗ ជាបច្ច័យនៃពួកកិលេសក្រោយៗ ដោយអនន្តរប្បច្ច័យ ។ គប្បីសួរនូវមូលផងចុះ ពួកកិលេសមុនៗជាបច្ច័យនៃពួកកិលេសក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកកិលេសជាបច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ គប្បីសួរនូវមូលផងចុះ ពួកកិលេសមុនៗ ជាបច្ច័យនៃពួកកិលេសផង នៃពួកសម្បយុត្តកក្ខន្ធផង ក្រោយៗ ដោយអនន្តរប្បច្ច័យ ។ នោកិលេសធម៌

ជាបច្ច័យនៃនោកិលេសធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនោកិលេសក្ខន្ធមុនៗ ជាបច្ច័យនៃពួកនោកិលេសក្រោយៗ ដោយអនន្តរប្បច្ច័យ ។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ គប្បីសួរនូវមូលផងចុះ ពួកនោកិលេសក្ខន្ធមុនៗ ជាបច្ច័យនៃពួកកិលេសក្រោយៗ ដោយអនន្តរប្បច្ច័យ ការពិចារណា ជាបច្ច័យនៃពួកកិលេស ដោយអនន្តរប្បច្ច័យ ។ គប្បីសួរនូវមូលផងចុះ ពួកនោកិលេសក្ខន្ធមុនៗ ជាបច្ច័យនៃពួកកិលេសផង នៃពួកសម្បយុត្តកក្ខន្ធផង ក្រោយៗ ដោយអនន្តរប្បច្ច័យ ការពិចារណាជាបច្ច័យនៃពួកកិលេសផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអនន្តរប្បច្ច័យ ។ កិលេសធម៌ក្តី នោកិលេសធម៌ក្តី ជាបច្ច័យនៃពួកកិលេសធម៌ ដោយអនន្តរប្បច្ច័យ គឺពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី មុនៗ ជាបច្ច័យនៃពួកកិលេសក្រោយៗ ដោយអនន្តរប្បច្ច័យ ។ គប្បីសួរនូវមូលផងចុះ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី មុនៗ ជាបច្ច័យនៃពួកនោកិលេសក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី ជាបច្ច័យនៃវុដ្ឋាន ដោយអនន្តរប្បច្ច័យ ។ គប្បីសួរនូវមូលផងចុះ ពួកកិលេសក្តី ពួកសម្បយុត្តកក្ខន្ធក្តី មុនៗ ជាបច្ច័យនៃពួកកិលេសផង នៃពួកសម្បយុត្តកក្ខន្ធផង ក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ ។

[ ២០៦ ] កិលេសធម៌ ជាបច្ច័យនៃកិលេសធម៌ ដោយឧបនិស្ស-

[ ២៧២ ] ទស្សនេនបហាតព្វធម៌ អាស្រ័យនូវទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ។ នទស្សនេនបហាតព្វធម៌ អាស្រ័យនូវនទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រកបដោយឧទ្ធច្ចៈ រហូតដល់ពួកអសញ្ញសត្វ ។

[ ២៧៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុង

នអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំងពីរយ៉ាងក្រៅនេះក្តី សហជាតវារៈក្តី បណ្ឌិតគប្បីធ្វើចុះ ។

## បច្ចយវារៈ

[ ២៧៤ ] ទស្សនេនបហាតព្វធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នទស្សនេនបហាតព្វធម៌ ពឹងផ្អែកនឹងនទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនទស្សនេនបហាតព្វក្ខន្ធ ១ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ រហូតដល់ពួកមហាភូតខាងក្នុង ពួកនទស្សនេនបហាតព្វក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ ទស្សនេនបហាតព្វធម៌ ពឹងផ្អែកនឹងនទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកទស្សនេនបហាតព្វក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ ទស្សនេនបហាតព្វធម៌ក្តី នទស្សនេនបហាតព្វធម៌ក្តី ពឹងផ្អែកនឹងនទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកទស្សនេនបហាតព្វក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត ។ ទស្សនេនបហា-

តព្វធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វធម៌ផង នឹងនទស្សនេនបហាតព្វធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងទស្សនេនបហាតព្វក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ។ នទស្សនេនបហាតព្វធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វធម៌ផង នឹងនទស្សនេនបហាតព្វធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកទស្សនេនបហាតព្វក្ខន្ធផង នឹងពួកមហាភូតផង ។ ទស្សនេនបហាតព្វធម៌ក្តី នទស្សនេនបហាតព្វធម៌ក្តី ពឹងផ្អែកនឹងទស្សនេនបហាតព្វធម៌ផង នឹងនទស្សនេនបហាតព្វធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងទស្សនេនបហាតព្វក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកទស្សនេនបហាតព្វក្ខន្ធផង នឹងពួកមហាភូតផង ។

[ ២៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ២៧៦ ] ទស្សនេនបហាតព្វធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលច្រឡំដោយវិចិកិច្ឆា ពឹងផ្អែកនឹងពួកខន្ធ ដែលច្រឡំដោយវិចិកិច្ឆា ។ នទស្សនេនបហាតព្វធម៌ ពឹងផ្អែកនឹងនទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនទស្សនេនបហាតព្វក្ខន្ធ ១ ជាអហេតុកៈ រហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ

នឹងកាយាយតនៈ... ពួកនទស្សនេទបហាតព្វក្ខន្ធ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រឡំដោយឧទ្ធច្ចៈ មោហៈដែលប្រឡំដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងវត្ថុ ។ ទស្សនេទបហាតព្វធម៌ ពឹងផ្អែកនឹងនទស្សនេទបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ មោហៈដែលប្រឡំដោយវិចិកិច្ឆា ពឹងផ្អែកនឹងវត្ថុ ។ ទស្សនេទបហាតព្វធម៌ ពឹងផ្អែកនឹងទស្សនេទបហាតព្វធម៌ផង នឹងនទស្សនេទបហាតព្វធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រឡំដោយវិចិកិច្ឆា ពឹងផ្អែកនឹងពួកខន្ធដែលប្រឡំដោយវិចិកិច្ឆាផង នឹងវត្ថុផង ។

[ ២៧៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ ២ យ៉ាង ក្រៅពីនេះក្តី និស្សយវារៈក្តី

បណ្ឌិតគប្បីធ្វើផងចុះ ។

# សំសដ្ឋវារៈ

[ ២៧៨ ] ទស្សនេនបហាតព្វធម៌ ប្រឡូកនឹងទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សេចក្ដីបំប្រួញ ។ នទស្សនេនបហាតព្វធម៌ ប្រឡូកនឹងនទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សេចក្ដីបំប្រួញ ។

[ ២៧៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ២៨០ ] ទស្សនេនបហាតព្វធម៌ប្រឡូកនឹងទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រឡូកដោយវិចិកិច្ឆា ប្រឡូកនឹងពួកខន្ធ ដែលប្រឡូកដោយវិចិកិច្ឆា ។ នទស្សនេនបហាតព្វធម៌ ប្រឡូកនឹងនទស្សនេនបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ សេចក្ដីបំប្រួញ ។

[ ២៨១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

ការរាប់ពីរយ៉ាងក្រៅពីនេះក្តី សម្បយុត្តវារៈក្តី
បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

# បញ្ហាវារៈ

[ ២៨២ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយហេតុប្បច្ច័យ គឺពួកនទស្សនេនបហាតព្វហេតុ ( ហេតុដែលមិនត្រូវលះដោយសោតាបត្តិមគ្គ ) ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ២៨៣ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលត្រេកអរ រីករាយ ចំពោះទស្សនេនបហាតព្វរាគៈ ទស្សនេនបហាតព្វរាគៈ កើតឡើង ព្រោះប្រារព្ធនូវទស្សនេនបហាតព្វរាគៈនោះ ទិដ្ឋិ... វិចិកិច្ឆា... ទស្សនេនបហាតព្វទោមនស្ស កើតឡើង បុគ្គលត្រេកអរ រីករាយចំពោះទស្សនេនបហាតព្វទិដ្ឋិ ទស្សនេនបហាតព្វរាគៈ កើតឡើង ព្រោះប្រារព្ធនូវទស្សនេនបហាតព្វទិដ្ឋិនោះ ទិដ្ឋិ... វិចិកិច្ឆា... ទស្សនេនបហាតព្វទោមនស្ស កើតឡើង វិចិកិច្ឆា កើតឡើង ព្រោះប្រារព្ធនូវវិចិកិច្ឆា ទិដ្ឋិ... ទោមនស្សកើតឡើង ទស្សនេនបហាតព្វទោមនស្ស កើតឡើង ព្រោះប្រារព្ធនូវទស្សនេនបហាតព្វទោមនស្ស ទិដ្ឋិ

កើតឡើង វិចិកិច្ឆាកើតឡើង ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទ-
ទស្សនេនបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ពិចារណា
នូវពួកទស្សនេនបហាតព្វកិលេស ដែលលះបង់ហើយ ដែលធ្លាប់សន្សំ
ហើយ ក្នុងកាលមុន... ឃើញនូវពួកទស្សនេនបហាតព្វក្ខន្ធ ថាមិនទៀង...
ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយទស្សនេនបហាតព្វចិត្ត ដោយចេតោ-
បរិយញ្ញាណ ពួកទស្សនេនបហាតព្វក្ខន្ធ ជាបច្ច័យនៃការពិចារណានូវចេ-
តោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និង
អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជា
បច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គល ( ឲ្យ )
នូវទាន... នូវសីល... ធ្វើនូវឧបោសថកម្ម ពិចារណា ត្រេកអរ រីករាយ
ចំពោះកុសលនោះ នទស្សនេនបហាតព្វរាគៈ កើតឡើង ព្រោះប្រារព្ធនូវ
កុសលនោះ នទស្សនេនបហាតព្វទោមនស្ស កើតឡើង ដែលធ្លាប់សន្សំ
ហើយ ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈចេញអំពីមគ្គ ពិចារណា
នូវមគ្គ ។បេ។ ជាបច្ច័យនៃការពិចារណានូវផល ដោយអារម្មណប្បច្ច័យ
ពួកព្រះអរិយៈ ពិចារណានូវពួកនទស្សនេនបហាតព្វកិលេស ដែលលះបង់
ហើយ ពិចារណានូវពួកកិលេសដែលសង្កត់សង្កិនហើយក្នុងកាលមុន ។បេ។
នូវចក្ខុ... នូវវត្ថុ... ឃើញនូវពួកនទស្សនេនបហាតព្វក្ខន្ធ ថាមិនទៀង...
ត្រេកអរ រីករាយ នទស្សនេនបហាតព្វរាគៈ កើតឡើង ព្រោះប្រារព្ធនូវ
នទស្សនេនបហាតព្វក្ខន្ធនោះ ឧទ្ធច្ចៈ... នទស្សនេនបហាតព្វទោមនស្ស កើត

ឡើង ដោយទិព្វចក្ខុ ។បេ។ ជាបច្ច័យនៃការពិចារណានូវអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេន-បហាតព្វធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន... នូវសីល... នូវឧបោសថកម្ម... ក្នុងកាលមុន... អំពីឈាន ។បេ។ នូវចក្ខុ... នូវវត្ថុ... ត្រេកអរ រីករាយចំពោះពួកនទស្សនេនបហាតព្វក្ខន្ធ ទស្សនេនបហាតព្វរាគៈកើតឡើង ព្រោះប្រារព្ធនូវនទស្សនេនបហាតព្វក្ខន្ធនោះ ទិដ្ឋិ... វិចិកិច្ឆា... ទស្សនេនបហាតព្វទោមនស្ស កើតឡើង ។

[ ២៨៤ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អា-រម្មណាធិបតិ គឺបុគ្គលធ្វើនូវទស្សនេនបហាតព្វរាគៈ ឲ្យជាទីគោរព ត្រេកអររីករាយចំពោះទស្សនេនបហាតព្វរាគៈ ធ្វើនូវទស្សនេនបហាតព្វរាគៈនោះ ឲ្យជាទីគោរព... ទិដ្ឋិកើតឡើង ធ្វើនូវទិដ្ឋិឲ្យជាទីគោរព ។បេ។ ឯសហជា-តាធិបតិ គឺទស្សនេនបហាតព្វាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វ-ធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺទស្សនេនបហា-តព្វាធិបតិ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ផង នៃនទស្ស-នេនបហាតព្វធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺទស្សនេនបហាតព្វាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្ត-

សមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យនូវទាន... នូវសីល... នូវឧបោសថកម្ម... ដែលសន្សំហើយ ក្នុងកាលមុន... ចេញអំពីឈានត្រេកអរ រីករាយនឹងឈាន នទស្សនេនបហាតព្វរាគៈ កើតឡើងព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ។បេ។ ពួកព្រះអរិយៈចេញអំពីមគ្គ ធ្វើនូវមគ្គ ឲ្យជាទីគោរព ។បេ។ ជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ ។ សហជាតាធិបតិ គឺនទស្សនេនបហាតព្វាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺឲ្យនូវទាន ។បេ។ នូវឈាន... នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកនទស្សនេនបហាតព្វក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយទស្សនេនបហាតព្វរាគៈ កើតឡើង ព្រោះធ្វើនូវនទស្សនេនបហាតព្វក្ខន្ធនោះឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។

[ ២៨៥ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអនន្តរប្បច្ច័យ គឺពួកទស្សនេនបហាតព្វក្ខន្ធមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយអនន្តរប្បច្ច័យ គឺពួកទស្សនេនបហាតព្វក្ខន្ធជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ ( មូលគប្បីធ្វើចុះ ) ពួក

នទស្សនេនបហាតព្វក្ខន្ធមុនៗ ។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ មូល ( គប្បីធ្វើផងចុះ ) ការពិចារណា ជាបច្ច័យនៃពួកទស្សនេនបហាតព្វក្ខន្ធ ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ជាបច្ច័យដោយនិស្សយប្បច្ច័យ ។

[ ២៨៦ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវទស្សនេនបហាតព្វរាគៈ ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ នូវទស្សនេនបហាតព្វទោមនស្ស... នូវមោហៈ... នូវទិដ្ឋិ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ ទស្សនេនបហាតព្វរាគៈ ។បេ។ សេចក្តីប្រាថ្នា ជាបច្ច័យនៃទស្សនេនបហាតព្វរាគៈ ។បេ។ នៃសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវទស្សនេនបហាតព្វរាគៈ ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង នូវទស្សនេនបហាតព្វទោមនស្ស... នូវមោហៈ... នូវទិដ្ឋិ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ទស្សនេនបហាតព្វរាគៈ ។បេ។ សេចក្តីប្រាថ្នាជាបច្ច័យនៃសទ្ធា ។បេ។ នៃ

បញ្ញា នទស្សនេនបហាតព្វរាគៈ ទោសៈ មោហៈ មានះ សេចក្ដីប្រាថ្នា កាយិកសុខនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងនូវមានះ នូវសីល... នូវបញ្ញា នូវនទស្សនេនបហាតព្វរាគៈ ទោសៈ មោហៈ មានះ សេចក្ដីប្រាថ្នា និងកាយិកសុខ... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានះ សទ្ធា ។បេ។ បញ្ញា... នទស្សនេនបហាតព្វរាគៈ ។បេ។ សេចក្ដីប្រាថ្នា... កាយិកសុខ... សេនាសនៈ ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ ជាបច្ច័យនៃបញ្ញា នៃនទស្សនេនបហាតព្វរាគៈ ។បេ។ នៃសេចក្ដីប្រាថ្នា កាយិកសុខ មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា... ប្រកាន់នូវទិដ្ឋិ នូវសីល ។បេ។ អាស្រ័យនូវបញ្ញា... នូវនទស្សនេនបហាតព្វរាគៈ... នូវទោសៈ មោហៈ មានះ សេចក្ដីប្រាថ្នា និងកាយិកសុខ... អាស្រ័យនូវសេនាសនៈ ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ... សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃទស្សនេនបហា-

តព្វរាគៈ ទោសៈ មោហៈ ទិដ្ឋិនិងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៧ ] នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវចក្ខុ... នូវវត្ថុ ថាមិនទៀង... ត្រេកអរ រីករាយ នទស្សនេនបហាតព្វរាគៈ ប្រារព្ធនូវវត្ថុនោះ... ឧទ្ធច្ចៈ... នទស្សនេនបហាតព្វទោមនស្ស កើតឡើង ដោយទិព្វចក្ខុ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកនទស្សនេនបហាតព្វក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនឹងចក្ខុ... ត្រេកអរ រីករាយនឹងវត្ថុ ទស្សនេនបហាតព្វរាគៈ ប្រារព្ធនូវវត្ថុនោះ... ទិដ្ឋិ... វិចិកិច្ឆា... ទស្សនេនបហាតព្វទោមនស្ស កើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកទស្សនេនបហាតព្វក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។

[ ២៨៨ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយបច្ឆាជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ មានវារៈ ២ ។

[ ២៨៩ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌

ដោយកម្មប្បច្ច័យ ។ ទស្សនេនបហាតព្វចេតនា ជាបច្ច័យនៃពួកសម្បយុត្ត-កក្ខន្ធ ដោយកម្មប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្ស-នេនបហាតព្វធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺទស្សនេនបហាតព្វចេតនាជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ នានាខណិកៈ គឺទស្សនេនបហាតព្វចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ទស្សនេនបហា-តព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ផង នៃនទស្សនេនបហាតព្វធម៌ផង ដោយកម្មប្បច្ច័យ ទស្សនេនបហាតព្វចេតនា ជាបច្ច័យនៃពួកសម្ប-យុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ នទស្សនេន-បហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺនទស្សនេនបហាតព្វ-ចេតនាជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ នានាខណិកៈ គឺនទស្សនេនបហាតព្វចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ២៩០ ] នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វ-ធម៌ ដោយវិបាកប្បច្ច័យ ។ ... ជាបច្ច័យដោយអាហារប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៤ ជាបច្ច័យ ដោយសម្បយុត្តប្បច្ច័យ មានវារៈ ២ ។

[ ២៩១ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត បុរេជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃពួកទស្សនេនបហាតព្វក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។

[ ២៩២ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអត្ថិប្បច្ច័យ ដូចគ្នានឹងបដិច្ចវារៈដែរ ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ផង នៃនទស្សនេនបហាតព្វធម៌ផង ដោយអត្ថិប្បច្ច័យ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នទស្សនេនបហាតព្វធម៌ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺនូវចក្ខុ... ។ សេចក្តីបំប្រួញ ។ ដូចគ្នានឹងបុរេជាតប្បច្ច័យដែរ ។ ទស្សនេនបហាតព្វធម៌ក្តី នទស្សនេនបហាតព្វធម៌ក្តី ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺទស្សនេនបហាតព្វក្ខន្ធ ១ ក្តី

វុត្តិ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ ទស្សនេន-បហាតព្វធម៌ក្តី នទស្សនេនបហាតព្វធម៌ក្តី ជាបច្ច័យនៃនទស្សនេនបហាតព្វ-ធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺពួកទស្សនេនបហាតព្វក្ខន្ធក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកទស្សនេនបហា-តព្វក្ខន្ធក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកទស្សនេនបហាតព្វក្ខន្ធក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ២៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ

មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ២៩៤ ] ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ផង នៃនទស្សនេនបហាតព្វធម៌ផង ដោយសហជាតប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ នទស្សនេនបហាតព្វធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ក្តី នទស្សនេនបហាតព្វធម៌ក្តី ជាបច្ច័យនៃទស្សនេនបហាតព្វធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ទស្សនេនបហាតព្វធម៌ក្តី នទស្សនេនបហាតព្វធម៌ក្តី ជាបច្ច័យនៃនទស្សនេនបហាតព្វធម៌ ដោយសហជាតប្បច្ច័យ ជា

បច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ២៩៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ។បេ។ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ២៩៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ២៩៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើផង

ចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ចប់ ទស្សនទុកៈ ។

## ភាវនាទុកៈ

## បដិច្ចវារៈ

[ ២៩៨ ] ភាវនាយបហាតព្វធម៌ ( ធម៌ដែលត្រូវលះដោយភាវនា ) អាស្រ័យនូវភាវនាយបហាតព្វធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ទស្សនទុកៈយ៉ាងណា ភាវនាទុកៈ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះចុះ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

[ ២៩៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៣០០ ] ភាវនាយបហាតព្វធម៌ អាស្រ័យនូវភាវនាយបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រឡំដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធដែលប្រឡំដោយឧទ្ធច្ចៈ ។ នភាវនាយបហាតព្វធម៌ ( ធម៌ដែលមិនត្រូវលះដោយភាវនា ) អាស្រ័យនូវនភាវនាយបហាតព្វធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រឡំដោយវិចិកិច្ឆា អាស្រ័យនូវនភាវនាយបហាតព្វខន្ធ ១ ជាអហេតុកៈផង នូវពួកខន្ធដែលប្រឡំដោយវិចិកិច្ឆាផង រហូតដល់ពួកអសញ្ញសត្វ ។ សេចក្តីបំប្រួញ ។

[ ៣០១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។ ( ត្រង់ពួកខន្ធ ) ដែលប្រឡំដោយឧទ្ធច្ចៈ ក្នុងនហេតុប្បច្ច័យជាបច្ចនីយៈ ក្នុងបច្ចយវារៈ មានវារៈ ៣ មោហៈ បណ្ឌិតគប្បីរើឡើងសំម្ដែងចុះ វារៈទាំងអស់ ដូចគ្នានឹងទស្សនទុកៈដែរ ឯឧទ្ធច្ចបច្ចនីយៈ ទើបផ្សេងគ្នា ។

## បញ្ហាវារៈ

[ ៣០២ ] ការនាយបហាតព្វធម៌ ជាបច្ច័យនៃការនាយបហាតព្វធម៌ ដោយហេតុប្បច្ច័យ គឺពួកការនាយបហាតព្វហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ នការនាយបហាតព្វធម៌ ជាបច្ច័យនៃនការនាយបហាតព្វធម៌ ដោយហេតុប្បច្ច័យ ។ សេចក្ដីបំប្រួញ ។

[ ៣០៣ ] ការនាយបហាតព្វធម៌ ជាបច្ច័យនៃការនាយបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលត្រេកអរ រីករាយនឹងការនាយបហាតព្វរាគៈ ការនាយបហាតព្វរាគៈ ព្រោះប្រារព្ធនូវការនាយបហាតព្វរាគៈនោះ... ឧទ្ធច្ចៈ... ការនាយបហាតព្វទោមនស្ស... ឧទ្ធច្ចៈកើតឡើងព្រោះប្រារព្ធនូវឧទ្ធច្ចៈ ការនាយបហាតព្វទោមនស្សកើតឡើង ការនាយបហាតព្វទោមនស្ស ប្រារព្ធនូវការនាយបហាតព្វទោមនស្ស... ឧទ្ធច្ចៈកើតឡើង ។ ការនាយបហាតព្វធម៌ ជាបច្ច័យនៃនការនាយបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ( ឃើញ ) នូវពួកការនាយបហាតព្វក្កិលេស ដែលលះបង់ហើយ... នូវ

ពួកកិលេស ដែលសង្កត់សង្កិនហើយ... ដែលសន្សំហើយ ក្នុងកាលមុន... ឃើញច្បាស់នូវពួកការនាយបហាតពុក្ខន្ធ ថាមិនទៀង... ត្រេកអរ រីករាយ នការនាយបហាតពុរាគៈ កើតឡើងព្រោះប្រារព្ធនូវការនាយបហាតពុក្ខន្ធនោះ ទិដ្ឋិ... វិចិកិច្ឆា... នការនាយបហាតពុទោមនស្ស កើតឡើង ពួកព្រះអរិយៈ ដឹងនូវចិត្តរបស់បុគ្គលអ្នកប្រកបដោយការនាយបហាតពុចិត្ត ដោយចេតោ-បរិយញ្ញាណ ពួកការនាយបហាតពុក្ខន្ធ ជាបច្ច័យនៃការពិចារណានូវចេ-តោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ ។បេ។ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នការនាយបហាតពុធម៌ ជាបច្ច័យនៃនការនា-យបហាតពុធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន... នូវសីល... ធ្វើនូវឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ត្រេកអរ រីករាយ នការនាយបហាតពុរាគៈ កើតឡើង ព្រោះប្រារព្ធនូវកុសលនោះ ទិដ្ឋិ... វិចិកិច្ឆា... នការនាយបហាតពុទោមនស្ស កើតឡើង ក្នុងកាលមុន ។បេ។ អំពីឈាន ។បេ។ ពួកព្រះអរិយៈចេញអំពីមគ្គ ។បេ។ ជាបច្ច័យនៃការពិចា-រណានូវផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ( ឃើញ ) នូវពួក នការនាយបហាតពុក្កិលេស ដែលលះបង់ហើយ ។បេ។ នូវចក្ខុ... នូវវត្ថុ... ឃើញច្បាស់នូវពួកនការនាយបហាតពុក្ខន្ធ ថាមិនទៀង... ត្រេកអរ រីករាយ នការនាយបហាតពុរាគៈ កើតឡើង ព្រោះប្រារព្ធនូវនការនាយបហាតពុក្ខន្ធ នោះ ទិដ្ឋិ... វិចិកិច្ឆា... នការនាយបហាតពុទោមនស្ស កើតឡើង ដោយ ទិព្វចក្ខុ ។បេ។ ជាបច្ច័យនៃការពិចារណានូវយថាកម្មុបគញ្ញាណ និងអនា-

គតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នការនៃាយបហាតព្វធម៌ ជាបច្ច័យនៃការនៃាយបហាតព្វធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន... នូវសីល... ។បេ។ នូវឈាន... នូវចក្ខុ... នូវវត្ថុ... ត្រេកអរ រីករាយ នឹងពួកនការនៃាយបហាតព្វក្ខន្ធ ការនៃាយបហាតព្វរាគៈ កើតឡើង ព្រោះប្រារព្ធនូវនការនៃាយបហាតព្វក្ខន្ធនោះ... ឧទ្ធច្ចៈ... ការនៃាយបហាតព្វទោមនស្ស កើតឡើង ។

[ ៣០៤ ] ការនៃាយបហាតព្វធម៌ ជាបច្ច័យនៃការនៃាយបហាតព្វធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវការនៃាយបហាតព្វរាគៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ការនៃាយបហាតព្វរាគៈ កើតឡើង ព្រោះធ្វើនូវការនៃាយបហាតព្វរាគៈនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺការនៃាយបហាតព្វាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ការនៃាយបហាតព្វធម៌ ជាបច្ច័យនៃនការនៃាយបហាតព្វធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវការនៃាយបហាតព្វរាគៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ នការនៃាយបហាតព្វរាគៈ កើតឡើង ព្រោះធ្វើនូវការនៃាយបហាតព្វរាគៈនោះ ឲ្យជាទីគោរព ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺការនៃាយបហាតព្វាធិបតិជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ ការនៃាយបហាតព្វធម៌ ជាបច្ច័យនៃការនៃាយបហាតព្វធម៌ផង នៃនការនៃាយបហាតព្វធម៌

ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺការនាយបបហា-តព្វាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នការនាយបបហាតព្វធម៌ ជាបច្ច័យនៃនការនា-យបបហាតព្វធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និង សហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យនូវទាន នូវសីល... ធ្វើនូវឧបោសថកម្ម នការនាយបបហាតព្វរាគៈ កើតឡើង ព្រោះធ្វើនូវកុសលនោះ ឲ្យជាទីគោរព ។ សហជាតាធិបតិ គឺនការនាយបបហាតព្វាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នការនាយបបហាតព្វធម៌ ជាបច្ច័យនៃការនាយបបហាតព្វធម៌ ដោយអធិប-តិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺនូវទាន ។បេ។ នូវឈាន... នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកនការនាយបបហាតព្វក្ខន្ធ ឲ្យជាទីគោរព ត្រេកអរ រីករាយ ការនាយបបហាតព្វរាគៈ កើតឡើង ព្រោះធ្វើនូវនការនាយបបហាតព្វក្ខន្ធនោះ ឲ្យជាទីគោរព ។

[ ៣០៥ ] ការនាយបបហាតព្វធម៌ ជាបច្ច័យនៃការនាយបបហាតព្វធម៌ ដោយអនន្តរប្បច្ច័យ មានវារៈ ៤ ។ ការនាទុកៈដូចគ្នានឹងទស្សនេទុកៈដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។ ... ជាបច្ច័យដោយសហជាតប្បច្ច័យ មាន វារៈ ៥ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ជាបច្ច័យដោយ និស្សយប្បច្ច័យ មានវារៈ ៧ ។

[ ៣០៦ ] ការនាយបបហាតព្វធម៌ ជាបច្ច័យនៃការនាយបបហាតព្វធម៌

ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺការនាយបហាតព្វរាគៈ... ទោសៈ មោហៈ មានះ... សេចក្តីប្រាថ្នាជាបច្ច័យនៃការនាយបហាតព្វរាគៈ ទោសៈ មោហៈ មានះនិងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។ ការនា-យបហាតព្វធម៌ជាបច្ច័យនៃនការនាយបហាតព្វធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវការនាយបហាតព្វរាគៈ ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ នូវការនាយបហាតព្វទោសៈ... នូវមោហៈ... នូវមានះ... បុគ្គលអាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ ការនាយបហាតព្វរាគៈ ។បេ។ សេចក្តីប្រាថ្នា ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ បញ្ញា ជាបច្ច័យនៃនការនាយបហាតព្វរាគៈ ទោសៈ មោហៈ ទិដ្ឋិ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ ផល និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នការនាយបហាតព្វធម៌ ជាបច្ច័យនៃនការនាយបហាតព្វធម៌ ដោយឧប-និស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យនូវទាន ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ប្រកាន់នូវទិដ្ឋិ នូវសីល... បុគ្គលអាស្រ័យនូវបញ្ញា នការនាយបហាតព្វរាគៈ ទោសៈ មោហៈ មានះ

ទិដ្ឋិ សេចក្តីប្រាថ្នា កាយិកសុខនិងកាយិកទុក្ខ... នូវសេនាសនៈ ហើយសម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ។បេ។ នៃបញ្ញា នការនាយបហាតព្វរាគៈ ទោសៈ មោហៈ ទិដ្ឋិ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នការនាយបហាតព្វធម៌ជាបច្ច័យនៃការនាយបហាតព្វធម៌ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងនូវមានះ នូវសីល ។បេ។ នូវបញ្ញា នូវរាគៈ ។បេ។ នូវសេចក្តីប្រាថ្នា កាយិកសុខនិងកាយិកទុក្ខ ។បេ។ អាស្រ័យនូវសេនាសនៈ ហើយដំឡើងនូវមានះ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃការនាយបហាតព្វរាគៈ ទោសៈ មោហៈ មានះនិងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ៣០៧ ] នការនាយបហាតព្វធម៌ ជាបច្ច័យនៃនការនាយបហាតព្វធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវចក្ខុ... នូវវត្ថុ ថាមិនទៀង... ត្រេកអរ រីករាយ នការនាយបហាតព្វរាគៈ កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ ទិដ្ឋិ កើតឡើង វិចិកិច្ឆាកើតឡើង នការនាយបហាតព្វទោមនស្ស កើតឡើង ដោយទិព្វចក្ខុ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ

( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកនការនោយបហាតព្វក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ នការនោយបហាតព្វធម៌ ជាបច្ច័យនៃការនោយ-បហាតព្វធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុ-បុរេជាត ។ អារម្មណបុរេជាត គឺបុគ្គល ត្រេកអរ រីករាយនឹងចក្ខុ... នឹងវត្ថុ ការនោយបហាតព្វរាគៈ កើតឡើង ព្រោះប្រារព្ធនូវវត្ថុនោះ ឧទ្ធច្ចៈកើតឡើង ការនោយបហាតព្វទោមនស្ស កើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកការនោយបហាតព្វក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ មានវារៈ ២ ជាបច្ច័យដោយអាសេវនប្បច្ច័យ មានវារៈ ២ ។

[ ៣០៨ ] ... ជាបច្ច័យដោយកម្មប្បច្ច័យ គឺការនោយបហាតព្វចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ការនោយបហាតព្វចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ មូល បណ្ឌិតគប្បីសួរផងចុះ ការនោយបហាតព្វចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ នការនោយបហាតព្វធម៌ ជាបច្ច័យនៃនការនោយបហាតព្វធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺនការនោយបហាតព្វ-ចេតនាជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺនការនោយបហាតព្វចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ... ជាបច្ច័យ

ដោយវិបាកប្បច្ច័យ មានវារៈ ១ ។ សេចក្តីបំប្រួញ ។ ... ជាបច្ច័យដោយអវិគតប្បច្ច័យ ។ ការនាទុកៈដូចគ្នានឹងទស្សនទុកៈ គ្រប់បច្ច័យទាំងអស់ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

[ ៣០៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ការចែកនូវបច្ចនីយៈ ដូចគ្នានឹងទស្សនទុកៈដែរ បណ្ឌិតគប្បីចែកផងចុះ ឯការរាប់ទាំង ៣ យ៉ាង បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

**ចប់ ភាវនាទុកៈ ។**

# អភិធម្មបិដក

## បដ្ឋាន ឯកាទសមភាគ

## ទស្សនេនបហាតព្វហេតុកទុកៈ

## បដិច្ចវារៈ

[ ១ ] ទស្សនេនបហាតព្វហេតុកធម៌ ( ធម៌មានហេតុដែលត្រូវលះដោយទស្សនៈ ) អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ ( ធម៌មានហេតុដែលត្រូវលះដោយទស្សនៈ ) ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាទស្សនេនបហាតព្វហេតុកៈ នូវខន្ធ ២ ... ។ នទស្សនេនបហាតព្វហេតុកធម៌ ( ធម៌មានហេតុ ដែលមិនត្រូវលះដោយទស្សនៈ ) អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកខន្ធជាទស្សនេនបហាតព្វ-ហេតុកៈ ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជាទស្ស-នេនបហាតព្វហេតុកៈ នូវខន្ធ ២ ... ។ នទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជានទស្ស-នេនបហាតព្វហេតុកៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ក្នុងខណៈនៃបដិសន្ធិ រហូតដល់ពួកមហាភូត ជា

ខាងក្នុង ។ ទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវនទស្សនេនបហា-
តព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ពួកសម្បយុត្តកក្ខន្ធ
អាស្រ័យនូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ។ ទស្សនេនបហាតព្វហេតុ-
កធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី អាស្រ័យនូវនទស្សនេនបហា-
តព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្តី
ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ។ ទស្ស-
នេនបហាតព្វហេតុកធម៌ អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ផង នូវ
នទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ
ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង នូវមោហៈផង
នូវខន្ធ ២ ... ។ នទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវទស្សនេន-
បហាតព្វហេតុកធម៌ផង នូវនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើត
ឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកទស្សនេន-
បហាតព្វហេតុកក្ខន្ធផង នូវពួកមហាភូតផង ចិត្តសមុដ្ឋានរូប អាស្រ័យ
នូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆាផង នូវមោហៈផង ។ ទស្សនេនបហា-
តព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី អាស្រ័យនូវទស្សនេន-
បហាតព្វហេតុកធម៌ផង នូវនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង
ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១
ដែលប្រកបដោយវិចិកិច្ឆាផង នូវមោហៈផង អាស្រ័យនូវខន្ធ ២ ... ។

[ ២ ] ទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវទស្សនេនបហាតព្វ-

ហេតុកធម៌ក្តី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាទស្សនេនបហាតព្វហេតុកៈ នូវខន្ធ ២ ... ។ នទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា អាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា នូវខន្ធ ២ ... ។ នទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ ទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធអាស្រ័យនូវមោហៈដែលប្រកបដោយវិចិកិច្ឆា ។ ទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ផង នូវនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង នូវមោហៈផង នូវខន្ធ ២ ... ។ សេចក្តីបំប្រួញ ។

[ ៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុង

សមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងវិគតប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤ ] នទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ។ នទស្សនេនបហាតព្វហេតុកធម៌ អាស្រ័យនូវនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវខន្ធ ១ ជានទស្សនេនបហាតព្វហេតុក ជាអហេតុកៈ រហូតដល់ពួកអសញ្ញសត្វ មោហៈដែលប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយឧទ្ធច្ចៈ ។

[ ៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣

ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យមានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ។បេ។ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៨ ] ទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺមានវារៈ ៣ ។ នទស្ស-

នៃទបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងនទស្សនេទបហាតព្វហេតុកធម៌ ទើប
កើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹង
ខន្ធ ១ ជានទស្សនេទបហាតព្វហេតុកៈ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ
រហូតដល់ពួកមហាភូតជាខាងក្នុង ពួកនទស្សនេទបហាតព្វហេតុកក្ខន្ធ ពឹង
ផ្អែកនឹងវត្ថុ ។ ទស្សនេទបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងនទស្សនេទបហា-
តព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកទស្សនេទបហា-
តព្វហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈ
ដែលប្រកបដោយវិចិកិច្ឆា ។ ទស្សនេទបហាតព្វហេតុកធម៌ក្តី នទស្សនេទ-
បហាតព្វហេតុកធម៌ក្តី ពឹងផ្អែកនឹងនទស្សនេទបហាតព្វហេតុកធម៌ ទើបកើត
ឡើង ព្រោះហេតុប្បច្ច័យ គឺពួកទស្សនេទបហាតព្វហេតុកក្ខន្ធ ពឹងផ្អែកនឹង
វត្ថុ ចិត្តសមុដ្ឋានរូបពឹងផ្អែកនឹងពួកមហាភូត ពួកសម្បយុត្តកក្ខន្ធក្តី ចិត្ត-
សមុដ្ឋានរូបក្តី ពឹងផ្អែកនឹងមោហៈ ដែលប្រកបដោយវិចិកិច្ឆា ។ ទស្ស-
នេទបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងទស្សនេទបហាតព្វហេតុកធម៌ផង នឹង
នទស្សនេទបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ
ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាទស្សនេទបហាតព្វហេតុកផង នឹងវត្ថុផង
នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹង ខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង
នឹងវត្ថុផង នឹងខន្ធ ២ ... ។ នទស្សនេទបហាតព្វហេតុកធម៌ ពឹងផ្អែកនឹង
ទស្សនេទបហាតព្វហេតុកធម៌ផង នឹងនទស្សនេទបហាតព្វហេតុកធម៌ផង ទើប
កើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកទស្សនេទ-

បហាតព្វហេតុកក្ខន្ធផង និងពួកមហាភូតផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆាផង នឹងមោហៈផង ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ពឹងផ្អែកនឹងទស្សនេនបហាតព្វហេតុកធម៌ផង នឹងនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹង ខន្ធ ១ ជាទស្សនេនបហាតព្វហេតុកៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកខន្ធជាទស្សនេនបហាតព្វហេតុកៈផង នឹងពួកមហាភូតផង ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង នឹងមោហៈផង នឹងខន្ធ ២ ... ។

[ ៩ ] ទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈ ៣ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ នទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ពឹងផ្អែកនឹងវត្ថុ... មានវារៈ ៣ ខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជានទស្សនេនបហាតព្វហេតុក នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ចក្ខុវិញ្ញាណពឹងផ្អែកនឹងចក្ខាយតនៈ ពួកនទស្សនេនបហាតព្វហេតុកក្ខន្ធ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ពឹងផ្អែកនឹងវត្ថុ ។ ទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកទស្សនេនបហាតព្វហេតុកក្ខន្ធ ពឹង

ផ្អែកនឹងវត្ថុ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងមោហៈ ដែលប្រកបដោយវិចិកិច្ឆា ។ ពួកទស្សនេនបហាតព្វហេតុកធម៌ក្តី ពួកនទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ពឹងផ្អែកនឹងវត្ថុ ។ ទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វហេតុកធម៌ផង នឹងនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាទស្សនេនបហាតព្វហេតុកៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង នឹងមោហៈផង នឹងខន្ធ ២ ផង ... ។ នទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វហេតុកធម៌ផង នឹងនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆាផង នឹងវត្ថុផង ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ពឹងផ្អែកនឹងទស្សនេនបហាតព្វហេតុកធម៌ផង នឹងនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាទស្សនេនបហាតព្វហេតុកធម៌ផង នឹងវត្ថុផង នឹងខន្ធ ២ ផង... ខន្ធ ៣ ក្តី មោហៈក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង នឹងវត្ថុផង នឹងខន្ធ ២ ផង... ។

[ ១០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមាន វារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១ ] នទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ។ នទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺជានទស្សនេនបហាតព្វហេតុកៈ ជាអហេតុកៈ រហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ មោហៈ ដែលប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ នទស្សនេនបហាតព្វហេតុកធម៌ ពឹងផ្អែកនឹង ទស្សនេនបហាតព្វហេតុកធម៌ផង នឹងនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា ពឹងផ្អែកនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆាផង នឹងវត្ថុផង ។ សេចក្តីបំប្រួញ ។

[ ១២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហា-

វប្បច្ច័យ មានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងឈានប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ពីរយ៉ាងដទៃក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

# សំសដ្ឋវារៈ

[ ១៣ ] នទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងខន្ធ ១ ជាទស្សនេនបហាតព្វហេតុកៈ នឹងខន្ធ ២ ... ។ នទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងខន្ធ ១ ជានទស្សនេនបហាតព្វហេតុកៈ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ ទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ លាយឡំនឹងមោហៈ ដែលប្រកបដោយវិចិកិច្ឆា ។ ទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងទស្សនេនបហាតព្វហេតុកធម៌ផង នឹងនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង នឹងមោហៈផង នឹងខន្ធ ២ ... ។

[ ១៤ ] ទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺមានវារៈប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ នទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងខន្ធ ១ ជានទស្សនេនបហាតព្វហេតុកៈ នឹងខន្ធ ២ ... ។ ទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ ទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងទស្សនេនបហាតព្វហេតុកធម៌ផង នឹងនទស្សនេនបហាតព្វហេតុកធម៌ផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ សេចក្តីបំប្រួញ ។

[ ១៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៦ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។

[ ១៦ ] នទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆា លាយឡំនឹងពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ។ នទស្សនេនបហាតព្វហេតុកធម៌ លាយឡំនឹងនទស្សនេនបហាតព្វហេតុកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងខន្ធ ១ ជា

នទស្សនេនបហាតព្វហេតុកៈ ជាអហេតុកៈ នឹងខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលប្រកបដោយឧទ្ធច្ចៈ លាយឡំនឹងពួកខន្ធដែលប្រកបដោយឧទ្ធច្ចៈ ។

[ ១៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ។

[ ១៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ... ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ។បេ។ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ។

[ ១៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សម្បយុត្តវារៈ ដូចគ្នានឹងសំសដ្ឋវារៈដែរ ។

## បញ្ហាវារៈ

[ ២០ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយហេតុប្បច្ច័យ គឺពួកទស្សនេនបហាតព្វហេតុកហេតុ ជា

បច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល គឺពួកទស្សនេនបហាតព្វហេតុកហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។ មូល គឺពួកទស្សនេនបហាតព្វហេតុកហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយហេតុប្បច្ច័យ គឺពួកនទស្សនេនបហាតព្វហេតុកហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ មូល គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។ មូល គឺមោហៈដែលប្រកបដោយវិចិកិច្ឆាជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ២១ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកទស្សនេនបហាតព្វហេតុកក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកទស្សនេនបហាតព្វហេតុកក្ខន្ធ ។ មូល គឺពួកនទស្សនេនបហាតព្វហេតុកក្ខន្ធផង មោហៈផង កើតឡើង ព្រោះប្រារព្ធនូវពួកទស្សនេនបហាតព្វហេតុកក្ខន្ធ ។ មូលគឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង កើតឡើងព្រោះប្រារព្ធនូវពួកទស្សនេនបហាតព្វហេតុកក្ខន្ធ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌

ដោយអារម្មណប្បច្ច័យ គឺនូវទាន... នូវសីល... បុគ្គលធ្វើនូវឧបោសថកម្ម ហើយពិចារណានូវអំពើនោះក៏ត្រេកអរ រីករាយ រាគៈជានេទស្សនេនបហាតព្វហេតុកៈ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ឧទ្ធច្ច.... ទោមនស្សជានេទស្សនេនបហាតព្វហេតុកៈ កើតឡើងដែលសន្សំហើយក្នុងកាលមុន... ។ ចេញអំពីឈាន ។បេ។ ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ។បេ។ ជាបច្ច័យនៃអាវជ្ជនៈ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈពិចារណានូវកងកិលេស ជានេទស្សនេនបហាតព្វហេតុកៈ ដែលលះហើយនូវកងកិលេស ដែលសង្កត់សង្កិនហើយ... ដឹងនូវកងកិលេសដែលសន្សំហើយក្នុងកាលមុន នូវចក្ខុ... នូវវត្ថុ... នូវពួកខន្ធជានេទស្សនេនបហាតព្វហេតុកៈផង នូវមោហៈផង ថាមិនទៀង... ឃើញច្បាស់ក៏ត្រេកអរ រីករាយរាគៈជានេទស្សនេនបហាតព្វហេតុកៈ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះឧទ្ធច្ចៈ... ទោមនស្ស ជានេទស្សនេនបហាតព្វហេតុកៈ កើតឡើង នូវរូបដោយទិព្វចក្ខុ ។បេ។ ជាបច្ច័យនៃការពិចារណានូវអនាគតំសញ្ញាណផង នៃមោហៈផង ដោយអារម្មណប្បច្ច័យ ។ នេទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ដោយអារម្មណប្បច្ច័យ គឺនូវទាន ។បេ។ នូវឈាន... នូវចក្ខុ... នូវវត្ថុ... ត្រេកអរ រីករាយនឹងពួកខន្ធ ជានេទស្សនេនបហាតព្វហេតុកៈផង នឹងមោហៈផង រាគៈជាទស្សនេនបហាតព្វហេតុកៈកើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ទិដ្ឋិ... វិចិកិច្ឆា... ទោមនស្ស ជាទស្សនេនបហាតព្វហេតុកៈ កើតឡើង ។ នេទស្សនេនបហាតព្វហេតុកធម៌

ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃនទស្សនេនបហាតព្វហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវចក្ខុ... នូវវត្ថុ... ពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធជាទស្សនេនបហាតព្វហេតុកៈផង នូវមោហៈផង ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកខន្ធជាទស្សនេនបហាតព្វហេតុកៈ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆាផង នូវមោហៈផង ។ មូល គឺពួកខន្ធជានទស្សនេនបហាតព្វហេតុកៈក្តី មោហៈក្តី កើតឡើងព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆាផង នូវមោហៈផង ។ មូល គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆាផង នូវមោហៈផង ។

[ ២២ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកទស្សនេនបហាតព្វហេតុកក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកទស្សនេនបហាតព្វហេតុកក្ខន្ធ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិ ជាទស្សនេនបហាតព្វហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺអធិបតិ ជាទស្សនេនបហាតព្វហេតុកៈ ជាបច្ច័យនៃពួក

ចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃទស្សនេនបហាតព្វហេតុកធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិ ជាទស្សនេនបហាតព្វហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន... នូវសីល... បុគ្គលធ្វើនូវឧបោសថកម្ម ធ្វើនូវកុសលនោះ ឲ្យជាទីគោរពហើយ ពិចារណា ត្រេកអរ រីករាយ រាគៈជានទស្សនេនបហាតព្វហេតុកៈ កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ។បេ។ ( នូវអំពើ ) ដែលសន្សំហើយ ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយធ្វើនូវមគ្គឲ្យជាទីគោរព ។បេ។ ជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធជានទស្សនេនបហា-តព្វហេតុកៈ ឲ្យជាទីគោរព រាគៈជានទស្សនេនបហាតព្វហេតុកៈ កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិ ជានទស្សនេនបហាតព្វហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺនូវទាន... នូវសីល... បុគ្គលធ្វើនូវឧបោសថកម្ម ។បេ។

អំពីឈាន... នូវចក្ខុ... នូវវត្ថុ បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធជាទស្សនេនបហាតព្វហេតុកៈ ឲ្យជាទីគោរព រាគៈជាទស្សនេនបហាតព្វហេតុកៈ កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ទិដ្ឋិ... ។

[ ២៣ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធ ជាទស្សនេនបហាតព្វហេតុកៈមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាមុនៗ ជាបច្ច័យនៃមោហៈដែលប្រកបដោយវិចិកិច្ឆាក្រោយដោយអនន្តរប្បច្ច័យ ពួកទស្សនេនបហាតព្វហេតុកក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ មូល គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាមុនៗ ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្រោយៗផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺមោហៈ ដែលប្រកបដោយវិចិកិច្ឆាមុនៗ ជាបច្ច័យនៃមោហៈ ដែលប្រកបដោយវិចិកិច្ឆាក្រោយៗដោយអនន្តរប្បច្ច័យ ជានទស្សនេនបហាតព្វហេតុកៈមុនៗ ។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ មូល គឺមោហៈដែលប្រកបដោយវិចិកិច្ឆាមុនៗ ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្រោយៗ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃពួកទស្សនេនបហាតព្វហេតុកក្ខន្ធ ដោយអនន្តរប្បច្ច័យ ។ មូល គឺមោហៈដែលប្រកបដោយវិចិកិច្ឆាមុនៗ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆាក្រោយៗផង នៃមោហៈផង ដោយ

អនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាមុនៗក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាមុនៗក្តី មោហៈក្តី ជាបច្ច័យនៃមោហៈ ដែលប្រកបដោយវិចិកិច្ឆាក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ មូល គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាមុនៗក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្រោយៗផង នៃមោហៈផង ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយសហជាតប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ជាបច្ច័យដោយនិស្សយប្បច្ច័យ មានវារៈ ៩ ។

[ ២៤ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធជាទស្សនេនបហាតព្វហេតុកៈ ជាបច្ច័យនៃពួកខន្ធ ជាទស្សនេនបហាតព្វហេតុកៈ ដោយឧបនិស្សយប្បច្ច័យ អនន្តរូបនិស្ស័យក្តី បកតូបនិស្ស័យក្តី ( បណ្ឌិតគប្បីដឹង ) ក្នុងបទទាំងពីរដ៏សេស ។ មូល គឺពួកខន្ធ ជាទស្ស-

នៃនបហាតព្វហេតុកៈ ជាបច្ច័យនៃពួកខន្ធ ជានទស្សនេនបហាតព្វហេតុកៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកខន្ធជាទស្សនេនបហាតព្វហេតុកៈ ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលឲ្យនូវទាន ព្រោះអាស្រ័យនូវសទ្ធា ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានះ នូវសីល ។បេ។ នូវបញ្ញា រាគៈ ទោសៈ មោហៈ មានះ សេចក្តីប្រាថ្នា កាយិកសុខនិងកាយិកទុក្ខ ជានទស្សនេនបហាតព្វហេតុកៈ ។បេ។ ឲ្យនូវទាន ព្រោះអាស្រ័យនូវសេនាសនៈ ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សទ្ធា ។បេ។ សេនាសនៈ ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ នៃបញ្ញា នៃរាគៈ ជាទស្សនេនបហាតព្វហេតុកៈ ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា... ប្រកាន់នូវទិដ្ឋិ នូវសីល ។បេ។ នូវបញ្ញា រាគៈ ទោសៈ មោហៈ មានះ សេចក្តីប្រាថ្នា កាយិកសុខ និងកាយិកទុក្ខ ជានទស្សនេនបហាតព្វហេតុកៈ ។បេ។ សម្លាប់នូវសត្វ ព្រោះអាស្រ័យនូវសេនាសនៈ ។បេ។ បំបែក

នូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ ទិដ្ឋិ និងសេចក្តីប្រាថ្នា ជាទស្សនេនបហាតព្វហេតុកៈ ដោយឧបនិស្សយប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃនទស្សនេនបហាតព្វហេតុកធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យគឺសទ្ធា ។បេ។ បញ្ញា រាគៈ ទោសៈ មោហៈ មានះ សេចក្តីប្រាថ្នា កាយិកសុខ ( កាយិកទុក្ខ ) ជានទស្សនេនបហាតព្វហេតុកៈ ។បេ។ សេនាសនៈ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ជាបច្ច័យនៃពួកខន្ធ ជាទស្សនេនបហាតព្វហេតុកៈ ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធ ជានទស្សនេនបហាតព្វហេតុកៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៥ ] នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និង

វត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង... ឃើញច្បាស់ ត្រេកអរ រីករាយ រាគៈជានទស្សនេនបហាតព្វហេតុកៈ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ឧទ្ធច្ចៈ... ទោមនស្ស ជានទស្សនេនបហាតព្វហេតុកៈ កើតឡើង ដោយទិព្វចក្ខុ... សេចក្តីបំប្រួញ ។ ឯវត្ថុបុរេជាត គឺសេចក្តីបំប្រួញ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ត្រេកអរ រីករាយ រាគៈ ជាទស្សនេនបហាតព្វហេតុកៈ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ទិដ្ឋិ... វិចិកិច្ឆា... ទោមនស្ស ជាទស្សនេនបហាតព្វហេតុកៈ កើតឡើង ។ ឯវត្ថុបុរេជាត គឺសេចក្តីបំប្រួញ ។ នទស្សនេនបហាតព្វហេតុកធម៌ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃនទស្សនេនបហាតព្វហេតុកធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... ពួកខន្ធដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវវត្ថុ ។ ឯវត្ថុបុរេជាត គឺសេចក្តីបំប្រួញ ។

[ ២៦ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយបច្ឆាជាតប្បច្ច័យ ។បេ។ នទស្សនេនបហាតព្វហេតុកធម៌ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយបច្ឆាជាតប្បច្ច័យ ។បេ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយបច្ឆាជាតប្បច្ច័យ ។បេ។ ... ដោយ

អាសេវនប្បច្ច័យ ។

[ ២៧ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយកម្មប្បច្ច័យ ទស្សនេនបហាតព្វហេតុកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ មូល គឺសហជាតនិងនានាខណិកៈ ។ សហជាត គឺទស្សនេនបហាតព្វហេតុកចេតនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺទស្សនេនបហាតព្វហេតុកចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃទស្សនេនបហាតព្វហេតុកធម៌ផង ដោយកម្មប្បច្ច័យ គឺទស្សនេនបហាតព្វហេតុកចេតនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាតនិងនានាខណិកៈ ។ សហជាត គឺនទស្សនេនបហាតព្វហេតុកចេតនាជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺនទស្សនេនបហាតព្វហេតុកចេតនា ជាបច្ច័យនៃពួកវិបាកក្ខន្ធផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។ ... ជាបច្ច័យដោយវិបាកប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៦ ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យ

មានវារៈ ៥ ។

[ ២៨ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអត្ថិប្បច្ច័យ មានវារៈ ៣ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតនិងបុរេជាត ។ សេចក្តីបំប្រួញ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃនទស្សនេនបហាតព្វហេតុកធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សេចក្តីបំប្រួញ ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាតនិងបុរេជាត ។ សហជាត គឺខន្ធ ១ ជាទស្សនេនបហាតព្វហេតុកៈផង វត្ថុផង ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃ

ទស្សនេនបហាតព្វហេតុកធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិង បុរេជាត ។ សេចក្តីបំប្រួញ ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ២៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៣០ ] ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយ

សហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆា-
ជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌
ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃនទស្សនេនបហាតព្វហេតុ-
កធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជា
បច្ច័យដោយឧបនិស្សយប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជា
បច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ
ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយ
បុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ
ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយ នទស្សនេនបហាតព្វ-
ហេតុកធម៌ ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ
ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជា
បច្ច័យដោយបុរេជាតប្បច្ច័យ ។ នទស្សនេនបហាតព្វហេតុកធម៌ ជាបច្ច័យ
នៃទស្សនេនបហាតព្វហេតុកធម៌ផង នៃនទស្សនេនបហាតព្វហេតុកធម៌ផង
ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយ
ឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ ទស្សនេនបហាតព្វ-
ហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃទស្សនេនបហា-
តព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ
ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី ន-
ទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃនទស្សនេនបហាតព្វហេតុកធម៌

ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ ទស្សនេនបហាតព្វហេតុកធម៌ក្តី នទស្សនេនបហាតព្វហេតុកធម៌ក្តី ជាបច្ច័យនៃទស្សនេនបហាតព្វហេតុកធម៌ផង នៃនទស្សនេនបហាតព្វហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៣១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៣២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៦ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៦ ។បេ។ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៦ ។

[ ៣៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ អនុលោមមាតិកា បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ចប់ ទស្សនេនបហាតព្វហេតុកៈ ។

## ការឆាយបហាតព្វហេតុកទុកៈ

## បដិច្ចវារៈ

[ ៣៤ ] ការនាយបហាតព្វហេតុកធម៌ ( ធម៌មានហេតុដែលត្រូវលះដោយការនា ) អាស្រ័យនូវការនាយបហាតព្វហេតុកធម៌ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ជាការនាយបហាតព្វហេតុកៈ នូវខន្ធ ២ ... ។

បដិច្ចវារៈក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងទស្សនេនបហាតព្វហេតុកទុកៈដែរ មោហៈ ដែលប្រកបដោយឧទ្ធច្ចៈ បណ្ឌិតគប្បីតម្កល់ទុកក្នុងទីនៃមោហៈ ដែលប្រកបដោយវិចិកិច្ឆា ចុះ ។

## បញ្ហាវារៈ

[ ៣៥ ] ការនាយបហាតព្វហេតុកធម៌ ជាបច្ច័យនៃការនាយបហាតព្វហេតុកធម៌ ដោយហេតុប្បច្ច័យ ។ វារៈទាំង ៦ ប្រហែលគ្នានឹងទស្សនេនបហាតព្វហេតុកៈដែរ ។

[ ៣៦ ] ការនាយបហាតព្វហេតុកធម៌ ជាបច្ច័យនៃការនាយបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ ។ បណ្ឌិតប្រាវព្ធនូវវារៈទាំង ៣ ឲ្យប្រហែលគ្នានឹងទស្សនេនបហាតព្វហេតុកទុកៈ ។ នការនាយបហាតព្វហេតុកធម៌ ជាបច្ច័យនៃនការនាយបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ

គឺនូវទាន... នូវសីល... បុគ្គលធ្វើនូវឧបោសថកម្ម ហើយពិចារណានូវអំពើនោះ ត្រេកអរ រីករាយ រាគៈជានភាវនាយបហាតព្វហេតុកៈ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ទិដ្ឋិ... វិចិកិច្ឆា... ទោមនស្សជានភាវនាយបហា-តព្វហេតុកៈ កើតឡើង ដែលខ្លួនសន្សំហើយ ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈចេញអំពីមគ្គ ។បេ។ ជាបច្ច័យនៃការពិចារណានូវផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈឃើញច្បាស់នូវកិលេសជានភាវនាយបហា-តព្វហេតុកៈ ដែលលះបង់ហើយ... ក្នុងកាលមុន... នូវចក្ខុ... នូវវត្ថុ... នូវពួកខន្ធ ជានភាវនាយបហាតព្វហេតុកៈផង នូវមោហៈផង ថាមិនទៀង... ឃើញច្បាស់ ត្រេកអរ រីករាយ រាគៈ ជានភាវនាយបហាតព្វហេតុកៈ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ទិដ្ឋិ... វិចិកិច្ឆា... ទោមនស្ស ជានភាវនា-យបហាតព្វហេតុកៈ កើតឡើង ដោយទិព្វចក្ខុ ។បេ។ ជាបច្ច័យនៃការពិចារណានូវអនាគតំសញ្ញាណផង នូវមោហៈផង ដោយអារម្មណប្បច្ច័យ ។

នភាវនាយបហាតព្វហេតុកធម៌ជាបច្ច័យនៃភាវនាយបហាតព្វហេតុកធម៌ ដោយអារម្មណប្បច្ច័យ គឺនូវទាន... នូវសីល... ។បេ។ នូវឈាន... នូវចក្ខុ... នូវវត្ថុ... ត្រេកអរ រីករាយនឹងពួកខន្ធ ជានភាវនាយបហាតព្វហេតុកៈផង នឹងមោហៈផង រាគៈជាភាវនាយបហាតព្វហេតុកៈ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ឧទ្ធច្ចៈ... ទោមនស្សជាភាវនាយបហាតព្វហេតុកៈ កើតឡើង ។

នភាវនាយបហាតព្វហេតុកធម៌ ជាបច្ច័យនៃភាវនាយបហាតព្វហេតុកធម៌ផង នៃនភាវនាយបហាតព្វហេតុកធម៌ផង ដោយអារម្មណប្បច្ច័យ គឺនូវចក្ខុ...

នូវវត្ថុ... ពួកខន្ធដែលប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ ជានការនោយបហាតព្វហេតុកៈផង នូវមោហៈផង ។ វារៈទាំង ៣ ដែលមានឃដនៈជាអារម្មណ៍ បណ្ឌិតគប្បីធ្វើផងចុះ ។

[ ៣៧ ] ការនោយបហាតព្វហេតុកធម៌ ជាបច្ច័យនៃការនោយបហាតព្វហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវរាគៈ ជាការនោយបហាតព្វហេតុកៈ ឲ្យជាទីគោរពហើយត្រេកអរ រីករាយ រាគៈជាការនោយបហាតព្វហេតុកៈ កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ។បេ។ ឯសហជាតាធិបតិ គឺអធិបតិជាការនោយបហាតព្វហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ ការនោយបហាតព្វហេតុកធម៌ ជាបច្ច័យនៃនការនោយបហាតព្វហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវរាគៈជាការនោយបហាតព្វហេតុកៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈជានការនោយបហាតព្វហេតុកៈ កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ទិដ្ឋិ... ។ ឯសហជាតាធិបតិ គឺអធិបតិជាការនោយបហាតព្វហេតុកៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ ការនោយបហាតព្វហេតុកធម៌ ជាបច្ច័យនៃការនោយបហាតព្វហេតុកធម៌ផង នៃនការនោយបហាតព្វហេតុធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺអធិបតិជាការនោយបហាតព្វហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃ

ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នការនៅយបហាតព្វហេតុ-កធម៌ ជាបច្ច័យនៃនការនៅយបហាតព្វហេតុធម៌ ដោយអធិបតិប្បច្ច័យ បាន ដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន... នូវសីល... បុគ្គលធ្វើនូវឧបោសថកម្ម ធ្វើនូវអំពើនោះឲ្យជាទីគោរព ហើយ ពិចារណា រាគៈជានការនៅយបហាតព្វហេតកុះ កើតឡើង ព្រោះធ្វើនូវអំពើ នោះ ឲ្យជាទីគោរព ទិដ្ឋិ... ក្នុងកាលមុន... អំពីឈាន... ពួកព្រះអរិយៈ ចេញអំពីមគ្គ ។បេ។ ជាបច្ច័យនៃផល ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... បុគ្គលត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធជានការនៅយបហាតព្វ-ហេតុកៈឲ្យជាទីគោរព រាគៈជានការនៅយបហាតព្វហេតុកៈ កើតឡើង ព្រោះ ធ្វើនូវអំពើនោះ ឲ្យជាទីគោរព ទិដ្ឋិ... ។ ឯសហជាតាធិបតិ គឺអធិបតិ ជា នការនៅយបហាតព្វហេតុកៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្ត-សមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នការនៅយបហាតព្វហេតុកធម៌ ជាបច្ច័យនៃការនៅយបហាតព្វហេតុកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺនូវទាន... ។បេ។ អំពីឈាន... នូវចក្ខុ... នូវវត្ថុ... បុគ្គល ត្រេកអរ រីករាយ ព្រោះធ្វើនូវពួកខន្ធ ជានការនៅយបហាតព្វហេតុកៈ ឲ្យជា ទីគោរព រាគៈជាការនៅយបហាតព្វហេតុកៈ កើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ។

[ ៣៨ ] ... ក្នុងនអនន្តរប្បច្ច័យ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ព្រោះហេតុនៃនការនៅយបហាតព្វហេតុកៈ បណ្ឌិត មិនគប្បីធ្វើទេ មោហៈ

ដែលប្រកបដោយឧទ្ធច្ចៈ បណ្ឌិតគប្បីធ្វើចុះ ។ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ជាបច្ច័យដោយនិស្សយប្បច្ច័យ មានវារៈ ៩ ។

[ ៣៩ ] ភាវនាយបហាតព្វហេតុកធម៌ ជាបច្ច័យនៃភាវនាយបហាតព្វហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ បកតូបនិស្ស័យ គឺពួកភាវនាយបហាតព្វហេតុកក្ខន្ធ ជាបច្ច័យនៃពួកភាវនាយបហាតព្វហេតុកក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកភាវនាយបហាតព្វហេតុកក្ខន្ធ ជាបច្ច័យនៃពួកភាវនាយបហាតព្វហេតុកក្ខន្ធផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ឆន្ទរាគៈក្នុងកណ្ឌៈរបស់ខ្លួន ជាបច្ច័យនៃឆន្ទរាគៈក្នុងកណ្ឌៈរបស់បុគ្គលដទៃ ដោយឧបនិស្សយប្បច្ច័យ ឆន្ទរាគៈក្នុងទ្រព្យរបស់ខ្លួន ជាបច្ច័យនៃឆន្ទរាគៈ ក្នុងទ្រព្យរបស់បុគ្គលដទៃ ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកភាវនាយបហាតព្វហេតុកក្ខន្ធ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។ នភាវនាយបហាតព្វហេតុកធម៌ ជាបច្ច័យនៃនភាវនាយបហាតព្វហេតុកធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលឲ្យនូវទាន ព្រោះអាស្រ័យនូវសទ្ធា ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ប្រកាន់នូវទិដ្ឋិ នូវសីល ។បេ។

នូវបញ្ញា រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ បត្ថនៈ កាយិកសុខ និង កាយិកទុក្ខ ជានការនៅយបហាតព្វហេតុកៈ ។បេ។ ឲ្យនូវទានព្រោះអាស្រ័យ នូវសេនាសនៈ ។បេ។ សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ។បេ។ សេនាសនៈ ( ជាបច្ច័យ ) នៃសទ្ធា ។បេ។ ( ជាបច្ច័យ ) នៃបញ្ញា រាគៈ ទោសៈ មោហៈ ទិដ្ឋិ បត្ថនៈនិងកាយិកសុខ ជានការនៅយបហាតព្វហេ-តុកៈ ។បេ។ ជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ ន-ការនៅយបហាតព្វហេតុកធម៌ជាបច្ច័យនៃការនៅយបហាតព្វហេតុកធម៌ ដោយ ឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និង បកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលដំឡើងនូវមានះ ព្រោះ អាស្រ័យនូវ សទ្ធា ។បេ។ សេនាសនៈ ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះនិងបត្ថនៈ ជាការនៅយបហាតព្វហេតុកៈ ដោយឧបនិស្សយប្បច្ច័យ ។ នការនៅយបហាតព្វហេតុកធម៌ ជាបច្ច័យនៃការនៅយបហាតព្វហេតុកធម៌ផង នៃនការនៅយបហាតព្វហេតុកធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូ-បនិស្ស័យ គឺសទ្ធា... បញ្ញា... កាយិកសុខ ។បេ។ សេនាសនៈ ជាបច្ច័យ នៃពួកខន្ធ ដែលប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្ស-យប្បច្ច័យ ។ យដនូបនិស្ស័យ មានវារៈ ៣ បណ្ឌិតគប្បីធ្វើចុះ ។

[ ៤០ ] នការនៅយបហាតព្វហេតុកធម៌ ជាបច្ច័យនៃនការនៅយបហា-តព្វហេតុកធម៌ ដោយបុរេជាតប្បច្ច័យ មានវារៈ ៣ ។ ... ជាបច្ច័យដោយ

បច្ឆាជាតប្បច្ច័យ មានវារៈ ៣ ជាបច្ច័យដោយអាសេវនប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយកម្មប្បច្ច័យ ឯនានាខណិកៈ បណ្ឌិតបានក្នុងហេតុនៃកិរិយា ចែកនូវនការនាយបហាតព្វធម៌ ។ ... ជាបច្ច័យដោយនោវិគតប្បច្ច័យ ។ សេចក្ដីបំប្រួញ ។ ទស្សនេនបហាតព្វហេតុកៈយ៉ាងណា ការនាយបហាតព្វ-ហេតុកប្បច្ច័យក្ដី បច្ចនីយៈក្ដី វិភាគៈក្ដី គណនាក្ដី ក៏យ៉ាងនោះដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាឡើយ ។ នទស្សនេនបហាតព្វធម៌ ( ជាបច្ច័យ ) នៃនទស្សនេនបហាតព្វធម៌... ធនុភាគៈ ក្នុងកណ្ឌៈរបស់ខ្លួន បណ្ឌិតគប្បីធ្វើដោយវត្ថុរបស់បុគ្គលដទៃ ។ ការនាយបហាតព្វធម៌ ( ជាបច្ច័យ ) នៃនការនាយបហាតព្វធម៌... ធនុភាគៈ ក្នុងកណ្ឌៈរបស់ខ្លួន បណ្ឌិតគប្បីធ្វើដោយវត្ថុរបស់បុគ្គលដទៃ ។

**ចប់ ការនាយបហាតព្វហេតុកទុកៈ ។**

# សវិតក្កទុកៈ

## បដិច្ចវារៈ

[ ៤១ ] សវិតក្កធម៌ ( ធម៌ដែលប្រកបដោយសេចក្ដីត្រិះរិះ ) អាស្រ័យនូវសវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិតក្កៈ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ អវិតក្កៈធម៌ ( ធម៌ដែលមិនមានសេចក្ដីត្រិះរិះ ) អាស្រ័យនូវសវិតក្កធម៌

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិតក្កៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ ។បេ។ សវិតក្កធម៌ក្តី អវិតក្កធម៌ក្តី អាស្រ័យនូវសវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង វិតក្កៈផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ ។បេ។ អវិតក្កៈធម៌ អាស្រ័យនូវអវិតក្កៈធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវខន្ធ ១ ដែលមិនមានវិតក្កៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវអវិតក្កក្ខន្ធ ១ នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវវិតក្កៈ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ វត្ថុអាស្រ័យនូវវិតក្កៈ វិតក្កៈអាស្រ័យនូវវត្ថុ នូវមហាភូត ១ ... ។ សវិតក្កធម៌ អាស្រ័យនូវអវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវវិតក្កៈ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ ពួកសវិតក្កក្ខន្ធ អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី អាស្រ័យនូវអវិតក្កៈធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវវិតក្កៈ ពួកសវិតក្កក្ខន្ធ អាស្រ័យនូវវិតក្កៈ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកមហាភូត ពួកសម្បយុត្តកក្ខន្ធក្តី កដត្តារូបក្តី អាស្រ័យនូវវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ ពួកសវិតក្កក្ខន្ធ អាស្រ័យនូវវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ

កដត្តារូប អាស្រ័យនូវពួកមហាភូត ពួកសវិតក្កក្ខន្ធ អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូបអាស្រ័យនូវពួកមហាភូត វិតក្កៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ សវិតក្កធម៌ អាស្រ័យនូវសវិតក្កធម៌ផង នូវអវិតក្កធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវិតក្កៈផង អាស្រ័យនូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវិតក្កៈផង ក្នុងខណៈនៃបដិសន្ធិ អាស្រ័យនូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិនូវខន្ធ ២ ... ។ អវិតក្កៈធម៌ អាស្រ័យនូវសវិតក្កធម៌ផង នូវអវិតក្កធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង នូវពួកមហាភូតផង កដត្តារូបអាស្រ័យនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង នូវពួកមហាភូតផង ក្នុងខណៈបដិសន្ធិ វិតក្កៈអាស្រ័យនូវពួកសវិតក្កក្ខន្ធផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។ សវិតក្កធម៌ក្តី អវិតក្កធម៌ក្តី អាស្រ័យនូវសវិតក្កធម៌ផង នូវអវិតក្កធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវិតក្កៈផង នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវិតក្កៈផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង នូវពួកមហាភូតផង ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវិតក្កៈផង នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវិតក្កៈផង

ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវពួកសវិតក្កក្ខន្ធ ផង នូវវិតក្កៈផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី វិតក្កៈក្តី អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... សេចក្តីបំប្រួញ ។

[ ៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤៣ ] សវិតក្កធម៌អាស្រ័យនូវសវិតក្កធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសវិតក្កក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។បេ។ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ បញ្ហាទាំង ២ ដ៏សេសសល់ ដែលមានសវិតក្កៈជាមូល បណ្ឌិតគប្បីធ្វើចុះ ឯអហេតុកៈ មិនមានផ្សេងគ្នាឡើយ ។ អវិតក្កធម៌ អាស្រ័យនូវអវិតក្កធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវអវិតក្កក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវវិតក្កៈ ជាអហេតុកៈ កដត្តារូបអាស្រ័យនូវវិតក្កៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ វត្ថុអាស្រ័យនូវវិតក្កៈ វិតក្កៈអាស្រ័យនូវវត្ថុ ។ សវិតក្ក-

ធម៌ អាស្រ័យនូវអវិតក្កធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវវិតក្កៈ ជាអហេតុកៈ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវវិតក្កៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវវិតក្កៈ ។ សវិតក្កធម៌ក្តី អវិតក្កៈ-ធម៌ក្តី អាស្រ័យនូវអវិតក្កធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ សេចក្តីបំប្រួញ ប្រហែលគ្នានឹងហេតុកប្បច្ច័យដែរ បណ្ឌិតគប្បីកំណត់ថា ជាអហេតុកៈផងចុះ ។ សវិតក្កធម៌ អាស្រ័យនូវសវិតក្កធម៌ផង នូវអវិតក្កធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសវិតក្កក្ខន្ធ ១ ជាអហេតុកៈផង នូវវិតក្កៈផង នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវអវិតក្កក្ខន្ធ ១ ផង នូវវិតក្កៈផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវសវិតក្កក្ខន្ធ ១ ផង នូវវត្ថុផង នូវវិតក្កៈផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវវិតក្កៈផង ។ បញ្ហាទាំងពីរដ៏សេស ប្រហែលគ្នានឹងហេតុកប្បច្ច័យដែរ មិនប្លែកគ្នាទេ បណ្ឌិតគប្បីកំណត់ថា ជាអហេតុកៈផងចុះ ។

[ ៤៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ

មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៤៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៤៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ។បេ។ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ។

សហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៤៧ ] សវិតក្កធម៌ ពឹងផ្អែកនឹងសវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ អវិតក្កធម៌ពឹងផ្អែកនឹងអវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្ដី ចិត្តសមុដ្ឋានរូបក្ដី ពឹងផ្អែកនឹងអវិតក្កក្ខន្ធ ១ នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិតក្កៈ ខន្ធ ៣ ក្ដី កដត្តារូបក្ដី ពឹងផ្អែកនឹងអវិតក្កក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ នឹងខន្ធ ២ ... កដត្តារូប ពឹងផ្អែកនឹងវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ វត្ថុពឹងផ្អែកនឹងពួកខន្ធ ពួកខន្ធពឹងផ្អែកនឹងវត្ថុ វត្ថុពឹងផ្អែកនឹងវិតក្កៈ វិតក្កៈពឹងផ្អែកនឹងវត្ថុ មហាភូត ៣ ពឹងផ្អែកនឹងមហាភូត ១ ។បេ។ ពួកអវិតក្កក្ខន្ធ ពឹងផ្អែកនឹងវត្ថុ វិតក្កៈពឹងផ្អែកនឹងវត្ថុ ។ សវិតក្កៈ ពឹងផ្អែកនឹងអវិតក្កៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងវិតក្កៈ ពួកសវិតក្កក្ខន្ធពឹងផ្អែកនឹងវត្ថុ ក្នុងបដិសន្ធិកាល មានវារៈ ២ ។ សវិតក្កធម៌ក្ដី អវិតក្កធម៌ក្ដី ពឹងផ្អែកនឹងអវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធក្ដី ចិត្តសមុដ្ឋានរូបក្ដី ពឹងផ្អែកនឹងវិតក្កៈ ពួកសម្បយុត្តកក្ខន្ធ ពឹងផ្អែកនឹងវិតក្កៈ ចិត្តសមុដ្ឋានរូបពឹងផ្អែកនឹងពួកមហាភូត ពួកសវិតក្កក្ខន្ធ ពឹងផ្អែកនឹងវត្ថុចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត វិតក្កៈក្ដី ពួកសម្បយុត្តកក្ខន្ធក្ដី ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ... ( ខន្ធទាំងឡាយ ) ក្នុងបដិសន្ធិកាល ប្រហែលគ្នានឹងក្នុងបវត្តិកាលដែរ ។ សវិតក្កធម៌ ពឹងផ្អែកនឹងសវិតក្កធម៌ផង នឹងអវិតក្កធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងសវិតក្កក្ខន្ធ ១ ផង នឹងវិតក្កៈផង

នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹងសវិតក្កខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ( បញ្ហា ) ២ បណ្ឌិត គប្បីធ្វើក្នុងខណៈនៃបដិសន្ធិ ។ អវិតក្កធម៌ ពឹងផ្អែកនឹងសវិតក្កធម៌ផង នឹងអវិតក្កធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកសវិតក្កខន្ធផង នឹងវិតក្កៈផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកសវិតក្កខន្ធផង នឹងវិតក្កធម៌ផង នឹងពួកមហាភូតផង វិតក្កៈពឹងផ្អែកនឹងពួកសវិតក្កខន្ធផង នឹងវត្ថុផង ក្នុងខណៈនៃបដិសន្ធិ... មានវារៈ ៣ ក្នុងបដិសន្ធិកាល ។ សវិតក្កធម៌ក្តី អវិតក្កធម៌ក្តី ពឹងផ្អែកនឹងសវិតក្កធម៌ផង នឹងអវិតក្កធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងសវិតក្កខន្ធ ១ ផង នឹងវិតក្កៈផង នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹងសវិតក្កខន្ធ ១ ផង នឹងវិតក្កៈផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកសវិតកក្ខន្ធផង នឹងវិតក្កៈផង នឹងពួកមហាភូតផង ខន្ធ ៣ ក្តី វិតក្កៈក្តី ពឹងផ្អែកនឹងសវិតក្កខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ៤៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤៩ ] សវិតក្កធម៌ ពឹងផ្អែកនឹងសវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បញ្ហា ៩ បណ្ឌិតគប្បីធ្វើ វារៈ ៣ បណ្ឌិតគប្បីកំណត់ថា

ជាអហេតុកៈផងចុះ ឯមោហៈ បណ្ឌិតគប្បីលើកឡើង បញ្ហាទាំងឡាយប្រហែល គ្មានឹងហេតុប្បច្ច័យក្នុងបដិច្ចវារៈដែរ វិញ្ញាណ ៥ ជារបស់លើសមានមោហៈ និងវិតក្កៈ ។

[ ៥០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំងពីរយ៉ាង ក្រៅនេះក្តី និស្សយវារៈក្តី
បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

[ ៥១ ] សវិតក្កធម៌ លាយឡំនឹងសវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងសវិតក្កខន្ធ ១ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ... ។ អវិតក្កធម៌លាយឡំនឹងសវិតក្កធម៌ ទើបកើតឡើង

ព្រោះហេតុប្បច្ច័យ គឺវិតក្កៈ លាយឡំនឹងពួកសវិតក្កក្ខន្ធ ។ សវិតក្កធម៌ក្តី អវិតក្កធម៌ក្តី លាយឡំនឹងសវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កៈក្តី លាយឡំនឹងសវិតក្កក្ខន្ធ ១ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ អវិតក្កធម៌លាយឡំនឹងអវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងអវិតក្កក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ ។បេ។ សវិតក្កធម៌ លាយឡំនឹងអវិតក្កធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ លាយឡំនឹងវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ... ។ សវិតក្កធម៌ លាយឡំនឹងសវិតក្កធម៌ផង នឹងអវិតក្កធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងសវិតក្កក្ខន្ធ ១ ផង នឹងវិតក្កៈផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ៥២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៦ ក្នុងនអវិគតប្បច្ច័យ មានវារៈ ៦ ។

[ ៥៣ ] សវិតក្កធម៌លាយឡំនឹងសវិតក្កធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ បញ្ហាទាំង ៦ ប្រហែលគ្នានឹងអនុលោម បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ វារៈ ៣ បណ្ឌិតគប្បីកំណត់ថា ជាអហេតុកៈផងចុះ ឯមោហៈ បណ្ឌិតគប្បីរើឡើង ។

[ ៥៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៦ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ

៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៦ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ។

ការរាប់ទាំងពីរយ៉ាង ក្រៅនេះក្តី សម្បយុត្តវារៈក្តី

បណ្ឌិត គប្បីធ្វើយ៉ាងនេះ ។

## បញ្ហាវារៈ

[ ៥៥ ] សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយវិតក្កៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ សវិតក្កធម៌ជាបច្ច័យនៃអវិតក្កធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយវិតក្កៈ ជាបច្ច័យនៃវិតក្កៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ មូល គឺពួកហេតុ ដែលប្រកបដោយវិតក្កៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃវិតក្កៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ អវិតក្កៈធម៌ ជាបច្ច័យនៃអវិតក្កធម៌ ដោយហេតុប្បច្ច័យ ពួកហេតុដែលមិនមានវិតក្កៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ៥៦ ] សវិតក្កធម៌ជាបច្ច័យនៃសវិតក្កធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសវិតក្កក្ខន្ធ ប្រារព្ធនូវពួកសវិតក្កក្ខន្ធ ទើបកើតឡើង ។ មូល គឺពួក

អវិតក្កក្ខន្ធក្តី វិតក្កៈក្តី ប្រារព្ធនូវពួកសវិតក្កក្ខន្ធទើបកើតឡើង ។ មូល គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី ប្រារព្ធនូវពួកសវិតក្កក្ខន្ធ ទើបកើតឡើង ។ អវិតក្កៈ-ធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈចេញអំពីឈាន ដែលមិនមានវិតក្កៈ ហើយពិចារណានូវឈាន ដែលមិនមានវិតក្កៈ ចេញអំពីមគ្គហើយពិចារណានូវមគ្គ ចេញអំពីផល ហើយពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វានជាបច្ច័យនៃមគ្គនិងផល ដែលមិនមានវិតក្កៈផង នៃវិតក្កៈផង ដោយអារម្មណប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... ឃើញច្បាស់នូវពួក អវិតក្កក្ខន្ធ និងវិតក្កៈ ថាមិនទៀង... ត្រេកអរ រីករាយ វិតក្កៈ កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់អវិតក្កចិត្តសមង្គីបុគ្គល ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ... អាកិញ្ចញ្ញាយតនៈ... រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ពួកអវិតក្កក្ខន្ធជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ និងវិតក្កៈ ដោយអារម្មណប្បច្ច័យ ពួកអវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើងព្រោះប្រារព្ធនូវពួកអវិតក្កក្ខន្ធនិងវិតក្កៈ ។ អវិតក្កៈធម៌ជាបច្ច័យនៃសវិតក្កធម៌ ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈចេញអំពីឈានដែលមិនមានវិតក្កៈ... ចេញអំពីមគ្គនូវមគ្គ... ចេញអំពីផល ហើយពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃកិរិយាពិចារណានូវគោត្រភូ វោទានៈ មគ្គនិងផល ដែលប្រកបដោយវិតក្កៈ

ដោយអារម្មណប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... ឃើញច្បាស់នូវពួកអវិតក្កក្ខន្ធ និងវិតក្កៈថាមិនទៀង... ត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។បេ។ ទោមនស្សកើតឡើង ព្រោះសវិតក្កក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវពួកអវិតក្កក្ខន្ធផង នូវវិតក្កៈផង ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយអារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ចេញអំពីឈានដែលមិនមានវិតក្កៈ... ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ចេញអំពីផល ហើយពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ សវិតក្កមគ្គ ផលនិងកិរិយារំពឹងផង នៃវិតក្កៈផង ដោយអារម្មណប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... ឃើញច្បាស់នូវពួកអវិតក្កក្ខន្ធផង នូវវិតក្កៈផង ថាមិនទៀង... ត្រេកអររីករាយ ពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើងព្រោះប្រារព្ធនូវហេតុនោះ ពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកអវិតក្កក្ខន្ធផង នូវវិតក្កៈផង ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី ជាបច្ច័យនៃសវិតក្កធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសវិតក្កក្ខន្ធកើតឡើង ព្រោះប្រារព្ធនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង ។ មូល គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើង ព្រោះប្រារព្ធនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង ។ មូល គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើងព្រោះប្រារព្ធនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង ។

[ ៥៧ ] សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួក

សវិតក្កក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកសវិតក្កក្ខន្ធ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិប្រកបដោយវិតក្កៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ សវិតក្កធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺវិតក្កៈកើតឡើង ព្រោះធ្វើនូវពួកសវិតក្កក្ខន្ធឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិប្រកបដោយវិតក្កៈ ជាបច្ច័យនៃវិតក្កៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើង ព្រោះធ្វើនូវពួកសវិតក្កក្ខន្ធឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិ ប្រកបដោយវិតក្កៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃវិតក្កៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកព្រះអរិយៈចេញអំពីឈានដែលមិនមានវិតក្កៈ... ចេញអំពីមគ្គ នូវមគ្គ... ចេញអំពីផល ធ្វើនូវផលឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវព្រះនិព្វានឲ្យជាទីគោរព ហើយពិចារណា ឯព្រះនិព្វាន ជាបច្ច័យនៃអវិតក្កមគ្គនិងផលផង នៃវិតក្កៈផង ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកអវិតក្កក្ខន្ធផង នូវវិតក្កៈផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ វិតក្កៈកើតឡើង ព្រោះធ្វើនូវអំពើនោះឲ្យ

ជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិមិនមានវិតក្កៈ ជាបច្ច័យនៃពួក
សម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ វិតក្កៈ
កើតឡើង ព្រោះធ្វើនូវពួកអវិតក្កក្ខន្ធផង នូវវិតក្កៈផង ឲ្យជាទីគោរព ។
អវិតក្កៈធម៌ជាបច្ច័យនៃសវិតក្កធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្ម-
ណាធិបតិ គឺពួកព្រះអរិយៈចេញអំពីឈាន ដែលមិនមានវិតក្កៈ នូវឈាន...
ចេញអំពីមគ្គ នូវមគ្គ... ចេញអំពីផល ធ្វើនូវផលឲ្យជាទីគោរព ហើយ
ពិចារណា ធ្វើនូវព្រះនិព្វានឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វាន ជា
បច្ច័យនៃគោត្រភូ វោទានៈ សវិតក្កមគ្គនិងផល ដោយអធិបតិប្បច្ច័យ នូវ
ចក្ខុ... នូវវត្ថុ... ធ្វើនូវពួកអវិតក្កក្ខន្ធផង នូវវិតក្កៈផង ឲ្យជាទីគោរព ហើយ
ត្រេកអរ រីករាយ រាគៈ កើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះ
ឲ្យជាទីគោរព ពួកសវិតក្កក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកអវិតក្កក្ខន្ធផង នូវ
វិតក្កៈផង ឲ្យជាទីគោរព ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ផង នៃ
អវិតក្កៈធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួក
ព្រះអរិយៈ ចេញអំពីឈាន ដែលមិនមានវិតក្កៈ... ចេញអំពីផល ហើយ
ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ
វោទានៈ សវិតក្កមគ្គ និងផលផង នៃវិតក្កៈផង ដោយអធិបតិប្បច្ច័យ នូវ
ចក្ខុ... នូវវត្ថុ... ធ្វើនូវពួកអវិតក្កក្ខន្ធផង នូវវិតក្កៈផង ឲ្យជាទីគោរព ហើយ
ត្រេកអរ រីករាយ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យ
ជាទីគោរព ពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើងព្រោះធ្វើនូវពួកអវិតក្កក្ខន្ធ

ផង នូវវិតក្កៈផង ឲ្យជាទីគោរព ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី ជាបច្ច័យនៃសវិតក្កធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺពួកសវិតក្កក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង ឲ្យជាទីគោរព ។ មូល គឺវិតក្កៈកើតឡើងព្រោះធ្វើនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង ឲ្យជាទីគោរព ។ មូល គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើង ព្រោះធ្វើនូវពួកសវិតក្កក្ខន្ធផង នូវវិតក្កៈផង ឲ្យជាទីគោរព ។

[ ៥៨ ] សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសវិតក្កក្ខន្ធមុនៗ ជាបច្ច័យនៃពួកសវិតក្កក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ សវិតក្កធម៌ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសវិតក្កក្ខន្ធមុនៗ ជាបច្ច័យនៃវិតក្កៈក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលប្រកបដោយវិតក្កៈ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមានវិតក្កៈ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃវិញ្ញាណ ៥ ដោយអនន្តរប្បច្ច័យ ពួកសវិតក្កក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ ( ការចេញអំពីឈាន ) ដែលមិនមានវិតក្កៈ ដោយអនន្តរប្បច្ច័យ ការបរិកម្មនូវទុតិយជ្ឈានជាបច្ច័យនៃទុតិយជ្ឈាន ដោយអនន្តរប្បច្ច័យ ការបរិកម្មនូវតតិយជ្ឈាន ។បេ។ ការបរិកម្មនូវនេវសញ្ញានាសញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ការបរិកម្មនូវទិព្វចក្ខុ... ការបរិកម្មនូវទិព្វសោតធាតុ... ការបរិកម្មនូវឥទ្ធិវិធញ្ញាណ... នូវចេតោបរិយញ្ញាណ... នូវបុព្វេនិវាសានុស្សតិញ្ញាណ... ការបរិកម្មនូវយថាកម្មុបគញ្ញាណ ជាបច្ច័យនៃយថាកម្មុបគញ្ញាណ ការបរិកម្មនូវអនាគតំ-

សញ្ញាណ ជាបច្ច័យនៃអនាគតំសញ្ញាណ ដោយអនន្តរប្បច្ច័យ គោត្រភូ ( ជាបច្ច័យ ) នៃអវិតក្កមគ្គ វោទានៈ ( ជាបច្ច័យ ) នៃអវិតក្កមគ្គ អនុលោម ជាបច្ច័យនៃផលសមាបត្តិដែលមិនមានវិតក្កៈ ដោយអនន្តរប្បច្ច័យ ។ សវិតក្កធម៌ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកសវិតក្កក្ខន្ធមុនៗ ជាបច្ច័យនៃសវិតក្កក្ខន្ធក្រោយៗផង នៃវិតក្កៈផង ដោយអនន្តរប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអនន្តរប្បច្ច័យ គឺវិតក្កៈមុនៗជាបច្ច័យនៃវិតក្កៈក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកអវិតក្កក្ខន្ធមុនៗ ជាបច្ច័យនៃពួកអវិតក្កក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អវិតក្កមគ្គ ( ជាបច្ច័យ ) នៃអវិតក្កផល អវិតក្កផល ( ជាបច្ច័យ ) នៃអវិតក្កផល នេវសញ្ញានាសញ្ញាយតនៈរបស់ព្រះយោគីដែលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិដែលមិនមានវិតក្កៈ ដោយអនន្តរប្បច្ច័យ ។ អវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយអនន្តរប្បច្ច័យ គឺពួកអវិតក្កក្ខន្ធមុនៗ ជាបច្ច័យនៃពួកសវិតក្កក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលមិនមានវិតក្កៈ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលប្រកបដោយវិតក្កៈ ភវង្គដែលមិនមានវិតក្កៈ ( ជាបច្ច័យ ) នៃអាវជ្ជនៈ ពួកអវិតក្កក្ខន្ធ ជាបច្ច័យនៃវុដ្ឋានៈ ដែលប្រកបដោយវិតក្កៈ ដោយអនន្តរប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយអនន្តរប្បច្ច័យ គឺវិតក្កៈមុនៗ ជាបច្ច័យនៃពួកសវិតក្កក្ខន្ធក្រោយៗផង នៃវិតក្កៈផង ដោយអនន្តរប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កធម៌ក្តី ជាបច្ច័យនៃសវិតក្កៈ ដោយអនន្តរប្បច្ច័យ គឺពួក

សវិតក្កក្ខន្ធមុនៗក្តី វិតក្កៈក្តី ជាបច្ច័យនៃពួកសវិតក្កក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសវិតក្កក្ខន្ធមុនៗក្តី វិតក្កៈក្តី ជាបច្ច័យនៃវិតក្កៈក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តប្រកបដោយវិតក្កៈក្តី វិតក្កៈក្តី ( ជាបច្ច័យ ) នៃឧបបត្តិចិត្តដែលមិនមានវិតក្កៈ អាវជ្ជនៈក្តី វិតក្កៈក្តី ( ជាបច្ច័យ ) នៃបញ្ចវិញ្ញាណ ពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី ជាបច្ច័យនៃវុដ្ឋានៈ ដែលមិនមានវិតក្កៈ ដោយអនន្តរប្បច្ច័យ ការបរិកម្មនូវទុតិយជ្ឈានក្តី វិតក្កៈក្តី ។បេ។ អក្ខរៈដែលសរសេរហើយខាងក្រោម បណ្ឌិតគប្បីឃើញតាមហេតុនេះចុះ ។ អនុលោមក្តី វិតក្កៈក្តី ជាបច្ច័យនៃផលសមាបត្តិ ដែលមិនមានវិតក្កៈ ដោយអនន្តរប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កធម៌ក្តី ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកសវិតក្កក្ខន្ធមុនៗក្តី វិតក្កៈក្តី ជាបច្ច័យនៃពួកសវិតក្កក្ខន្ធក្រោយៗផង នៃវិតក្កៈផង ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយនិស្សយប្បច្ច័យ មានវារៈ ៩ ។

[ ៥៩ ] សវិតក្កធម៌ជាបច្ច័យនៃសវិតក្កធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកសវិតក្កក្ខន្ធ ជាបច្ច័យនៃពួកសវិតក្កក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកសវិតក្កក្ខន្ធ ជាបច្ច័យនៃពួកអវិតក្កក្ខន្ធផង

នៃវិតក្កៈផង ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកសវិតក្កក្ខន្ធ ជាបច្ច័យនៃសវិតក្កក្ខន្ធផង នៃវិតក្កៈផង ដោយឧបនិស្សយប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយឧបនិស្សយប្បច្ច័យ គឺអារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធាដែលមិនមានវិតក្កៈ ហើយញុំាងឈាន ដែលមិនមានវិតក្កៈឲ្យកើតឡើង ញុំាងមគ្គឲ្យកើតឡើង ញុំាងអភិញ្ញាឲ្យកើតឡើង ញុំាងសមាបត្តិឲ្យកើតឡើង ញុំាងសីលដែលមិនមានវិតក្កៈ ( ឲ្យកើតឡើង ) ។បេ។ នូវបញ្ញា... នូវកាយិកសុខ កាយិកទុក្ខ រដូវ នូវភោជន... អាស្រ័យនូវសេនាសនៈ និងវិតក្កៈ ហើយញុំាងឈានដែលមិនមានវិតក្កៈ... ញុំាងមគ្គ... ញុំាងអភិញ្ញា... ញុំាងសមាបត្តិឲ្យកើតឡើង សទ្ធាដែលមិនមានវិតក្កៈ ។បេ។ សេនាសនៈក្តី វិតក្កៈក្តី ( ជាបច្ច័យ ) នៃសទ្ធាដែលមិនមានវិតក្កៈ ។បេ។ ជាបច្ច័យនៃបញ្ញា កាយិកសុខ កាយិកទុក្ខ មគ្គ ដែលមិនមានវិតក្កៈ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អវិតក្កៈធម៌ជាបច្ច័យនៃសវិតក្កធម៌ ដោយឧបនិស្សយប្បច្ច័យ ។ សូម្បីឧបនិស្សយប្បច្ច័យ ទាំង ៣ បណ្ឌិតគប្បីធ្វើក្នុងបច្ច័យទាំងពួង ។ បុគ្គលអាស្រ័យនូវសទ្ធា មិនមានវិតក្កៈ ហើយឲ្យនូវទាន សមាទាននូវសីល ធ្វើនូវឧបោសថកម្ម ញុំាងឈានដែលប្រកបដោយវិតក្កៈ... ញុំាងវិបស្សនា ញុំាងមគ្គ ញុំាងអភិញ្ញា... ញុំាងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីលដែលមិនមានវិតក្កៈ ។បេ។ អាស្រ័យនូវសេនាសនៈនិងវិតក្កៈហើយឲ្យនូវទាន ។បេ។

ញុំាំងសមាបត្តិឲ្យកើតឡើង សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ដែលមិនមានវិតក្កៈ ។បេ។ សេនាសនៈក្តី វិតក្កៈក្តី ( ជាបច្ច័យ ) នៃសទ្ធា ដែលប្រកបដោយវិតក្កៈ ។បេ។ ជាបច្ច័យនៃបញ្ញា រាគៈ សេចក្តីប្រាថ្នា មគ្គ ដែលប្រកបដោយវិតក្កៈ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយឧប-និស្សយប្បច្ច័យ គឺបុគ្គលអាស្រ័យនូវសទ្ធាដែលមិនមានវិតក្កៈ ហើយឲ្យនូវទាន ។បេ។ បទដែលសរសេរទាំងអស់ បណ្ឌិតគប្បីធ្វើក្នុងវារៈទី ២ ផងចុះ ។ បុគ្គលញុំាំងសមាបត្តិ ឲ្យកើតឡើង ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល... នូវបញ្ញា... អាស្រ័យនូវសេនាសនៈ និងវិតក្កៈ ហើយឲ្យនូវទាន ។បេ។ សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ដែលមិនមានវិតក្កៈ ។បេ។ សេនាសនៈក្តី វិតក្កៈក្តី ( ជាបច្ច័យ ) នៃសទ្ធាដែលប្រកបដោយវិតក្កៈ ។បេ។ ជាបច្ច័យនៃបញ្ញា រាគៈ សេចក្តីប្រាថ្នា មគ្គដែលប្រកបដោយវិតក្កៈ ផលសមាបត្តិនិងវិតក្កៈ ដោយឧបនិស្សយប្បច្ច័យ ។ សវិតក្ក-ធម៌ក្តី អវិតក្កៈធម៌ក្តី ជាបច្ច័យនៃសវិតក្កធម៌ ដោយឧបនិស្សយប្បច្ច័យ គឺពួកសវិតកក្ខន្ធក្តី វិតក្កៈក្តី ជាបច្ច័យនៃពួកសវិតក្កក្ខន្ធ ដោយឧបនិស្ស-យប្បច្ច័យ ។ មូល គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី ជាបច្ច័យនៃពួកអវិតក្កក្ខន្ធផង នៃវិតក្កៈផង ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី ជាបច្ច័យនៃពួកសវិតក្កក្ខន្ធផង នៃវិតក្កៈផង ដោយឧបនិស្ស-យប្បច្ច័យ ។

[ ៦០ ] អវិតក្កៈធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ជាមិនទៀង... បុគ្គលពិចារណាឃើញច្បាស់ ត្រេកអរ រីករាយ វិតក្កៈ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ដោយទិព្វចក្ខុ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខ្វាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុ ជាបច្ច័យនៃពួកអវិតក្កក្ខន្ធផង នៃវិតក្កៈផង ដោយបុរេជាតប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ជាមិនទៀង... បុគ្គលពិចារណាឃើញច្បាស់ ត្រេកអរ រីករាយ ពួកសវិតក្កក្ខន្ធ កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកសវិតក្កក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ នៃអវិតក្កៈ-ធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ជាមិនទៀង... បុគ្គលពិចារណាឃើញច្បាស់ ត្រេកអរ រីករាយ ពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កើតឡើង ព្រោះប្រារព្ធនូវអំពើនោះ ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកសវិតក្កក្ខន្ធផង នៃវិតក្កៈផង ដោយបុរេជាតប្បច្ច័យ ។

[ ៦១ ] សវិតក្កធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយបច្ឆាជាតប្បច្ច័យ មានវារៈ ៣ បានដល់ បច្ឆាជាត ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ

មានវារៈ ៩ ។

[ ៦២ ] សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយវិតក្កៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលប្រកបដោយវិតក្កៈ ជាបច្ច័យនៃវិបាកក្ខន្ធ ដែលប្រកបដោយវិតក្កៈ ដោយកម្មប្បច្ច័យ ។ វារៈ ៤ ក្តី សហជាតក្តី នានាខណិកៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះ ។ ... ជាបច្ច័យដោយវិបាកប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអាហារប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយមគ្គប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៦ ។

[ ៦៣ ] សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ អវិតក្កៈធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាតនិងបុរេជាត ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺវត្ថុ ជាបច្ច័យនៃវិតក្កៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។ ឯបុរេជាត គឺវត្ថុជាបច្ច័យនៃវិតក្កៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយវិប្បយុត្តប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី ជា

បច្ច័យនៃអវិតក្កៈធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សេចក្តីបំប្រួញ ។

[ ៦៤ ] សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយអត្ថិប្បច្ច័យ មានវារៈ ១ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ សវិតក្កធម៌ ជាបច្ច័យនៃអវិតក្កធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ សវិតក្កធម៌ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយអត្ថិប្បច្ច័យ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ អវិតក្កៈធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្តីបំប្រួញ ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សេចក្តីបំប្រួញ ។ អវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺវិតក្កៈជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ វិតក្កៈជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ វត្ថុជាបច្ច័យនៃវិតក្កៈផង នៃពួកសម្បយុត្តកក្ខន្ធផង ក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺនូវចក្ខុ... នូវវត្ថុថាមិនទៀង... ពិចារណាឃើញច្បាស់ ត្រេកអរ រីករាយ វិតក្កៈក្តី ពួកសម្បយុត្តកក្ខន្ធក្តី កើតឡើងព្រោះប្រារព្ធនូវអំពើនោះ ។ វត្ថុជាបច្ច័យនៃវិតក្កៈផង នៃពួកសម្បយុត្តកក្ខន្ធផង ដោយអត្ថិប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី ជាបច្ច័យនៃសវិតក្ក-

ធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺ សវិតក្កក្ខន្ធ ១ ក្តី វិតក្កៈក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហជាត គឺសវិតក្កក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយ អត្ថិប្បច្ច័យ ខន្ធ ២ ... សូម្បីសហជាតប្បច្ច័យ ក៏មានវារៈ ២ បណ្ឌិតគប្បី ធ្វើក្នុងខណៈនៃបដិសន្ធិ ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី ជាបច្ច័យនៃអវិ-តក្កៈធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ សហជាត គឺពួកសវិតក្កក្ខន្ធក្តី វត្ថុក្តី ជាបច្ច័យនៃវិតក្កៈ ដោយអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងខណៈនៃ បដិសន្ធិ ។ បច្ឆាជាត គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺ ពួកសវិតក្កក្ខន្ធក្តី វិតក្កៈក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយ អត្ថិប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កធម៌ក្តី ជាបច្ច័យនៃសវិតក្កធម៌ផង នៃ អវិតក្កៈធម៌ផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺសវិតក្កក្ខន្ធ ១ ក្តី វិតក្កៈក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃពួក ចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។ សហជាតគឺ សវិ-តក្កក្ខន្ធ ១ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃវិតក្កៈផង ដោយ អត្ថិប្បច្ច័យ ខន្ធ ២ ... បដិសន្ធិកាល មានវារៈ ២ ។ ... ជាបច្ច័យដោយ

នត្ថិប្បច្ច័យ ខន្ធ ២ ... បដិសន្ធិកាល មានវារៈ ២ ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ៦៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៦ ] សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ សវិតក្កធម៌ ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

សវិតក្កធម៌ ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ អវិតក្កៈធម៌ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ អវិតក្កៈធម៌ ជាបច្ច័យនៃសវិតក្កៈធម៌ផង អវិតក្កៈធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កធម៌ក្តី ជាបច្ច័យនៃសវិតក្កធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី ជាបច្ច័យនៃអវិតក្កៈធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ សវិតក្កធម៌ក្តី អវិតក្កៈធម៌ក្តី ជាបច្ច័យនៃសវិតក្កធម៌ផង នៃអវិតក្កៈធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យនៃដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៦៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៨ ] ក្នុងនអារម្មណប្បច្ច័យមានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។បេ។ ... ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ៦៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។ អនុលោមមាតិកា បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

**ចប់ សវិតក្កទុកៈ ។**

# សវិចារណាទុកៈ

# បដិច្ចវារៈ

[ ៧០ ] សវិចារធម៌អាស្រ័យនូវសវិចារធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសវិចារក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ សវិតក្កទុកៈយ៉ាងណា បណ្ឌិតគប្បីធ្វើយ៉ាងនោះចុះ មិន

មានការធ្វើផ្សេងៗគ្នាទេ វារៈ ៤ ក្នុងមគ្គប្បច្ច័យក្នុងទីនេះ បណ្ឌិតគប្បីធ្វើចុះ នេះជាការធ្វើឲ្យផ្សេងៗគ្នាក្នុងសវិចារទុកៈ ។

ចប់ សវិចារទុកៈ ។

## សប្បីតិកទុកៈ

## បដិច្ចវារៈ

[ ៧១ ] សប្បីតិកធម៌ ( ធម៌ប្រកបដោយបីតិ ) អាស្រ័យនូវសប្បីតិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយបីតិ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ អប្បីតិកធម៌ ( ធម៌មិនមានបីតិ ) អាស្រ័យនូវសប្បីតិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺបីតិផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវពួកខន្ធប្រកបដោយបីតិ ក្នុងខណៈនៃបដិសន្ធិ ។បេ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី អាស្រ័យនូវសប្បីតិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី បីតិក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសប្បីតិកក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ អប្បីតិកធម៌ អាស្រ័យនូវអប្បីតិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអប្បីតិកក្ខន្ធ ១ ចិត្តសមុដ្ឋានរូប អាស្រ័យនូវបីតិ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវអប្បីតិកក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប

អាស្រ័យនូវបីតិ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ វត្ថុអាស្រ័យនូវបីតិ បីតិអាស្រ័យនូវវត្ថុ អាស្រ័យនូវមហាភូត ១ ។

សវិតក្កទុក: ក្នុងវារៈទាំងពួងយ៉ាងណា សប្បីតិកទុក: បណ្ឌិតគប្បីធ្វើយ៉ាងនោះ មានបវត្តិបដិសន្ធិ ក្នុងវារៈទាំងពួង មានបញ្ហា ៩ ។

[ ៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៣ ] សប្បីតិកធម៌អាស្រ័យនូវសប្បីតិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសប្បីតិកក្ខន្ធ ១ ជាអហេតុក: នូវខន្ធ ២ ... ។ អប្បីតិកធម៌ អាស្រ័យនូវសប្បីតិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺបីតិក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកសប្បីតិកក្ខន្ធ ជាអហេតុក: ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី អាស្រ័យនូវសប្បីតិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី បីតិក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសប្បីតិកក្ខន្ធ ១ ជាអហេតុក: នូវខន្ធ ២ ... ។ សប្បីតិកធម៌ អាស្រ័យនូវអប្បីតិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវអប្បីតិកក្ខន្ធ ១ ជាអហេតុក: នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវបីតិ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវអប្បីតិកក្ខន្ធ ១ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អា-

ស្រ័យនូវខន្ធ ២ វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ទាំងដរាបដល់ពួកអសញ្ញសត្វ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ សប្បីតិកធម៌ អាស្រ័យនូវអប្បីតិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសប្បីតិកក្ខន្ធ អាស្រ័យនូវបីតិ ជាអហេតុកៈ ។ មូល គឺពួកសប្បីតិកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវបីតិ ។ សប្បីតិកធម៌ អាស្រ័យនូវសប្បីតិកធម៌ផង នូវអប្បីតិកធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវសប្បីតិកក្ខន្ធ ១ ជាអហេតុកផង នូវបីតិផង នូវខន្ធ ២ ... ។ សប្បីតិកធម៌ អាស្រ័យនូវសប្បីតិកធម៌ផង នូវអប្បីតិកធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសប្បីតិកក្ខន្ធ ជាអហេតុកៈផង នូវបីតិផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសប្បីតិកក្ខន្ធជាអហេតុកៈផង នូវពួកមហាភូតផង ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី អាស្រ័យនូវសប្បីតិកធម៌ផង នូវអប្បីតិកធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវសប្បីតិកក្ខន្ធ ១ ជាអហេតុកៈផង នូវបីតិផង នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យនូវសប្បីតិកក្ខន្ធ ១ ជាអហេតុកៈផង នូវបីតិផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកសប្បីតិកក្ខន្ធ ជាអហេតុកៈផង នូវបីតិផង នូវពួកមហាភូតផង ។

[ ៧៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំងពីរយ៉ាង ក្រៅនេះក្តី សហជាតវារៈក្តី
បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បច្ចយវារៈ

[ ៧៥ ] សប្បីតិកធម៌ ពឹងផ្អែកនឹងសប្បីតិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សេចក្តីបំប្រួញ ។ អនុលោមប្បច្ចយវារៈ ក្នុងសវិតក្កទុកៈ យ៉ាងណា បវត្តិបដិសន្ធិ បញ្ហាទាំង ៩ បីតិបរិបូណ៌យ៉ាងនោះដែរ មិនមានការធ្វើឲ្យផ្សេងៗគ្នាទេ ។

[ ៧៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងអវិគតប្បច្ច័យ មាន

វារៈ ៩ ។

[ ៧៧ ] សប្បីតិកធម៌ ពឹងផ្អែកនឹងសប្បីតិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ មានវារៈ ៣ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ អប្បីតិកធម៌ ពឹងផ្អែកនឹងអប្បីតិកធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ បវត្តិ-បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ប្រហែលគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីធ្វើចុះ ។ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ... ពួកអប្បីតិកក្ខន្ធ ជាអហេតុកៈក្តី បីតិក្តី ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ បញ្ហា ៩ ប្រហែលគ្នានឹងអនុលោម មានតែបវត្តិ មិនមានបដិសន្ធិទេ តែមានមោហៈ ១ ប៉ុណ្ណោះ ។

[ ៧៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៩ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហា-រប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំងពីរយ៉ាងក្រៅនេះក្តី និស្សយវារៈក្តី
បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## សំសដ្ឋវារៈ

[ ៧៩ ] សប្បីតិកធម៌លាយឡំនឹងសប្បីតិកធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។

[ ៨១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៦ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៦ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ។

ការរាប់ទាំង ២ យ៉ាង ក្រៅនេះក្តី សម្បយុត្តវារៈក្តី
បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ៨២ ] សប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុប្រកបដោយបីតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ

ក្នុងខណៈនៃបដិសន្ធិ ។បេ។ សប្បីតិកធម៌ ជាបច្ច័យនៃអប្បីតិកធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុប្រកបដោយបីតិ ជាបច្ច័យនៃបីតិផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ មូល គឺពួកហេតុប្រកបដោយបីតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបីតិផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។ សប្បីតិកធម៌ ជាបច្ច័យនៃអប្បីតិកធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុមិនមានបីតិជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ៨៣ ] សប្បីតិកធម៌ជាបច្ច័យនៃសប្បីតិកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសប្បីតិកក្ខន្ធ ប្រារព្ធនូវពួកសប្បីតិកក្ខន្ធ ទើបកើតឡើង ។ មូល គឺអប្បីតិកក្ខន្ធក្តី បីតិក្តី ប្រារព្ធនូវពួកសប្បីតិកក្ខន្ធ ទើបកើតឡើង ។ មូល គឺពួកសប្បីតិកក្ខន្ធក្តី បីតិក្តី ប្រារព្ធនូវពួកសប្បីតិកក្ខន្ធ ទើបកើតឡើង ។ អប្បីតិកធម៌ ជាបច្ច័យនៃអប្បីតិកធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន ដោយចិត្តមិនមានបីតិ នូវសីល... ធ្វើនូវឧបោសថកម្ម ហើយពិចារណា ដោយចិត្តមិនមានបីតិ ត្រេកអរ រីករាយ រាគៈ មិនមានបីតិកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ចេញអំពីឈានមិនមានបីតិ... ចេញអំពីមគ្គ... ចេញអំពីផល ហើយពិចារណាដោយចិត្តមិនមានបីតិ ពួកព្រះអរិយៈពិចារណានូវព្រះនិព្វាន ដោយចិត្តមិនមានបីតិ ឯព្រះនិព្វានជាបច្ច័យនៃគោ-

ត្រភូ វោទាន: មគ្គ ផល កិរិយារំពឹងដែលមិនមានបីតិ និងបីតិ ដោយ អារម្មណប្បច្ច័យ ពួកព្រះអរិយៈពិចារណានូវកងកិលេសមិនមានបីតិ ដែល លះបង់ហើយ ដោយចិត្តប្រកបដោយបីតិ... នូវកងកិលេស ដែលសង្កត់ សង្កិនហើយ... ក្នុងកាលមុន ។បេ។ នូវចក្ខុ... នូវវត្ថុ... នូវពួកខន្ធ មិនមាន បីតិផង នូវបីតិផង ជាមិនទៀង ដោយចិត្តមិនមានបីតិ... ពិចារណាឃើញ ត្រេកអរ រីករាយ រាគៈមិនមានបីតិ កើតឡើងទោមនស្ស កើតឡើង ព្រោះ ប្រារព្ធនូវហេតុនោះ ដោយទិព្វចក្ខុ ។បេ។ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃ កាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកខន្ធមិនមានបីតិ ជាបច្ច័យនៃ កិរិយារំពឹងនូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ និងបីតិ ដោយអារម្មណប្បច្ច័យ ពួកខន្ធមិនមានបីតិក្តី បីតិក្តី កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ មិនមាន បីតិផង នូវបីតិផង ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ ដោយអារម្ម- ណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន ដោយចិត្តមិនមានបីតិ នូវសីល... នូវ ឧបោសថកម្ម... ហើយពិចារណា ដោយចិត្តប្រកបដោយបីតិ ត្រេកអរ រីករាយ រាគៈប្រកបដោយបីតិកើតឡើង ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវហេតុ នោះ ចេញអំពីឈានមិនមានបីតិ... ចេញអំពីមគ្គ... ចេញអំពីផល ហើយ ពិចារណាដោយចិត្តប្រកបដោយបីតិ ពួកព្រះអរិយៈពិចារណានូវព្រះនិព្វាន ដោយចិត្តប្រកបដោយបីតិ ឯព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផលប្រកបដោយបីតិ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណា

នូវកងកិលេសមិនមានបីតិ ដែលលះបង់ហើយដោយចិត្តប្រកបដោយបីតិ... នូវកងកិលេសដែលសង្កត់សង្កិនហើយ... ក្នុងកាលមុន ។បេ។ នូវចក្ខុ... នូវវត្ថុ... នូវពួកខន្ធមិនមានបីតិផង នូវបីតិផង ជាមិនទៀង ដោយចិត្តប្រកបដោយបីតិ ពិចារណាឃើញ ត្រេកអរ រីករាយ រាគៈ ប្រកបដោយបីតិកើតឡើង ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ពួកខន្ធប្រកបដោយបីតិ កើតឡើង ព្រោះប្រារព្ធនូវពួកខន្ធ មិនមានបីតិផង នូវបីតិផង ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយអារម្មណប្បច្ច័យ គឺ បុគ្គលឲ្យនូវទាន ដោយចិត្តមិនមានបីតិ នូវសីល... នូវឧបោសថកម្ម... ពិ-ចារណា ត្រេកអរ រីករាយ ដោយចិត្តប្រកបដោយបីតិ ពួកខន្ធប្រកបដោយបីតិផង បីតិផង កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ អំពីឈានមិនមានបីតិ... អំពីមគ្គ... ចេញអំពីផល ហើយពិចារណាដោយចិត្តប្រកបដោយបីតិ ពួកព្រះអរិយៈ ពិចារណានូវព្រះនិព្វាន ដោយចិត្តប្រកបដោយបីតិ ឯព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផលប្រកបដោយបីតិ និងបីតិ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវកងកិលេសមិនមានបីតិ ដែលលះបង់ហើយ ដោយចិត្តប្រកបដោយបីតិ នូវកងកិលេសដែលសង្កត់សង្កិនហើយ... ក្នុងកាលមុន ។បេ។ នូវចក្ខុ... នូវវត្ថុ... នូវពួកខន្ធមិនមានបីតិផង នូវបីតិផង ជាមិនទៀង ដោយចិត្តប្រកបដោយបីតិ... ពិចារណាឃើញ ត្រេកអរ រីករាយ រាគៈប្រកបដោយបីតិកើតឡើង ទិដ្ឋិកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ពួកខន្ធប្រកបដោយបីតិក្តី បីតិក្តី កើតឡើង ព្រោះ

ប្រារព្ធនូវពួកខន្ធមិនមានបីតិផង នូវបីតិផង ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី ជាបច្ច័យនៃសប្បីតិកធម៌ ដោយអារម្មណប្បច្ច័យ គឺពួកសប្បីតិកក្ខន្ធកើតឡើង ព្រោះប្រារព្ធនូវពួកសប្បីតិកក្ខន្ធផង នូវបីតិផង ។ មូល គឺពួកសប្បីតិកក្ខន្ធក្តី បីតិក្តី កើតឡើង ព្រោះប្រារព្ធនូវពួកសប្បីតិកក្ខន្ធផង នូវបីតិផង ។ មូល គឺពួកសប្បីតិកក្ខន្ធក្តី បីតិក្តី កើតឡើង ព្រោះប្រារព្ធនូវពួកសប្បីតិកក្ខន្ធផង នូវបីតិផង ។

[ ៨៤ ] សប្បីតិកធម៌ជាបច្ច័យនៃសប្បីតិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកខន្ធប្រកបដោយបីតិ កើតឡើង ព្រោះធ្វើនូវពួកខន្ធប្រកបដោយបីតិ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិប្រកបដោយបីតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ សប្បីតិកធម៌ជាបច្ច័យនៃអប្បីតិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ អារម្មណាធិបតិ គឺពួកអប្បីតិកក្ខន្ធផង បីតិផង កើតឡើង ព្រោះធ្វើនូវពួកខន្ធ ប្រកបដោយបីតិឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិប្រកបដោយបីតិ ជាបច្ច័យនៃបីតិផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ សប្បីតិកធម៌ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺពួកអប្បីតិកក្ខន្ធផង បីតិផង កើតឡើង ព្រោះធ្វើពួកសប្បីតិកក្ខន្ធ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិប្រកបដោយបីតិ ជា

បច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃបីតិផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ អប្បីតិកធម៌ជាបច្ច័យនៃអប្បីតិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ អារម្មណាធិបតិ គឺបុគ្គលនូវទាន... នូវសីល... នូវឧបោសថកម្ម... ដោយចិត្តមិនមានបីតិ ធ្វើនូវអំពើនោះ ឲ្យជាទីគោរព ដោយចិត្តមិនមានបីតិ ហើយពិចារណា ត្រេកអររីករាយ រាគៈមិនមានបីតិ កើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះឲ្យជាទីគោរព ចេញអំពីឈាន មិនមានបីតិ... អំពីមគ្គ... អំពីផល ធ្វើនូវផលឲ្យជាទីគោរព ហើយពិចារណា ពួកព្រះអរិយៈធ្វើនូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ដោយចិត្តមិនមានបីតិ ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផលសមាបត្តិជាអប្បីតិកៈ និងបីតិ ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... បុគ្គលធ្វើនូវពួកអប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ដោយចិត្តមិនមានបីតិ ហើយត្រេកអរ រីករាយ រាគៈមិនមានបីតិ កើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព ទិដ្ឋិ... ពួកអប្បីតិកក្ខន្ធផង បីតិផង កើតឡើង ព្រោះធ្វើនូវពួកអប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺអធិបតិមិនមានបីតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺនូវទានដោយចិត្តមិនមានបីតិ... នូវសីល... នូវឧបោសថកម្ម... ។ សេចក្តីបំប្រួញ ។ អធិបតិ... និព្វានជាបច្ច័យនៃគោត្រភូ

វោទាន: មគ្គនិងផល ប្រកបដោយបីតិ ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... បុគ្គលធ្វើនូវពួកអប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ដោយចិត្តប្រកបដោយបីតិ ហើយត្រេកអរ រីករាយ រាគៈ ប្រកបដោយបីតិ កើតឡើង ព្រោះធ្វើនូវអំពើនោះឲ្យជាទីគោរព ទិដ្ឋិ... ពួកសប្បីតិកក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកអប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺនូវទាន... ។ សេចក្តីបំប្រួញ ។ អធិបតិ... និព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ ផលប្រកបដោយបីតិ និងបីតិ ដោយអធិបតិប្បច្ច័យ នូវចក្ខុ... នូវវត្ថុ... បុគ្គលធ្វើនូវពួកអប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ដោយចិត្តប្រកបដោយបីតិ ហើយត្រេកអរ រីករាយ រាគៈប្រកបដោយបីតិ ធ្វើនូវអំពើនោះឲ្យជាទីគោរព... ទិដ្ឋិកើតឡើង ពួកសប្បីតិកក្ខន្ធក្តី បីតិក្តី កើតឡើងព្រោះធ្វើនូវពួកអប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី ជាបច្ច័យនៃសប្បីតិកធម៌ ដោយអធិបតិប្បច្ច័យ គឺពួកសប្បីតិកក្ខន្ធ កើតឡើង ព្រោះធ្វើនូវពួកសប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ។ មូល គឺពួកអប្បីតិកក្ខន្ធផង បីតិផង កើតឡើង ព្រោះធ្វើពួកសប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ។ មូលគឺពួកសប្បីតិកក្ខន្ធផង បីតិផង កើតឡើង ព្រោះធ្វើនូវពួកសប្បីតិកក្ខន្ធផង នូវបីតិផង ឲ្យជាទីគោរព ។

[ ៨៥ ] សប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ ដោយអនន្តរប្បច្ច័យ

គឺពួកសប្បីតិកក្ខន្ធមុនៗ ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធក្រោយៗ ដោយអនន្តរបច្ច័យ ។ មូល គឺពួកសប្បីតិកក្ខន្ធមុនៗ ជាបច្ច័យនៃអប្បីតិកធម៌ និងបីតិក្រោយៗ ដោយអនន្តរបច្ច័យ ចុតិចិត្តប្រកបដោយបីតិ ( ជាបច្ច័យ ) នៃឧបបត្តិចិត្ត មិនមានបីតិ ភវង្គៈ ប្រកបដោយបីតិ ( ជាបច្ច័យ ) នៃអាវជ្ជនៈ ពួកសប្បីតិកក្ខន្ធ ( ជាបច្ច័យ ) នៃវុដ្ឋានៈ មិនមានបីតិ វិបាកមនោវិញ្ញាណធាតុ ប្រព្រឹត្តទៅជាមួយនឹងបីតិ ( ជាបច្ច័យ ) នៃកិរិយាមនោវិញ្ញាណធាតុ ភវង្គៈប្រកបដោយបីតិ ( ជាបច្ច័យ ) នៃភវង្គមិនមានបីតិ កុសលាកុសលប្រកបដោយបីតិ ( ជាបច្ច័យ ) នៃវុដ្ឋានៈ មិនមានបីតិ កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផល ( ជាបច្ច័យ ) នៃវុដ្ឋានៈ ដោយអនន្តរបច្ច័យ ។ មូលគឺពួកសប្បីតិកក្ខន្ធមុនៗ ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធនិងបីតិក្រោយៗ ដោយអនន្តរបច្ច័យ ។ អប្បីតិកធម៌ជាបច្ច័យនៃអប្បីតិកធម៌ ដោយអនន្តរបច្ច័យ គឺពួកអប្បីតិកក្ខន្ធនិងបីតិមុនៗ ជាបច្ច័យនៃបីតិក្រោយៗ ដោយអនន្តរបច្ច័យ ពួកអប្បីតិកក្ខន្ធមុនៗ ជាបច្ច័យនៃពួកអប្បីតិកក្ខន្ធក្រោយៗ ដោយអនន្តរបច្ច័យ អនុលោមជាបច្ច័យនៃគោត្រភូ និងផលសមាបត្តិ មិនមានបីតិ ដោយអនន្តរបច្ច័យ ។ មូល គឺបីតិមុនៗ ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធក្រោយៗ ដោយអនន្តរបច្ច័យ ចុតិចិត្ត មិនមានបីតិ ( ជាបច្ច័យ ) នៃឧបបត្តិចិត្តប្រកបដោយបីតិ អាវជ្ជនៈ ( ជាបច្ច័យ ) នៃពួកសប្បីតិកក្ខន្ធ ពួកអប្បីតិកក្ខន្ធ ( ជាបច្ច័យ ) នៃវុដ្ឋានៈ ប្រកបដោយបីតិ វិបាកមនោធាតុ ( ជាបច្ច័យ ) នៃមនោវិញ្ញាណធាតុ ប្រកបដោយបីតិ

ភវង្គមិនមានបីតិ ( ជាបច្ច័យ ) នៃភវង្គប្រកបដោយបីតិ កុសលាកុសល មិនមានបីតិ ( ជាបច្ច័យ ) នៃវុដ្ឋានៈប្រកបដោយបីតិ កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផល ( ជាបច្ច័យ ) នៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ នេវសញ្ញា-នាសញ្ញាយតនៈនៃបុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃសមាបត្តិប្រកបដោយបីតិ ដោយអនន្តរប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយអនន្តរប្បច្ច័យ គឺបីតិមុនៗ ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធក្រោយៗផង នៃបីតិផង ដោយអនន្តរប្បច្ច័យ ។ សប្បីតិកធម៌ផង អប្បីតិកធម៌ផង ជាបច្ច័យនៃសប្បីតិកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសប្បីតិកក្ខន្ធ និងបីតិមុនៗ ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី ជាបច្ច័យនៃអប្បីតិកធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសប្បីតិកក្ខន្ធមុនៗផង បីតិផង ជាបច្ច័យនៃបីតិក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តប្រកបដោយបីតិក្តី បីតិក្តី ( ជាបច្ច័យ ) នៃឧបបត្តិចិត្ត មិនមានបីតិ ភវង្គប្រកបដោយបីតិក្តី បីតិក្តី ( ជាបច្ច័យ ) នៃអាវជ្ជនៈ ពួកសប្បីតិកក្ខន្ធក្តី បីតិក្តី ( ជាបច្ច័យ ) នៃវុដ្ឋានៈ មិនមានបីតិ វិបាកមនោវិញ្ញាណធាតុប្រកបដោយបីតិក្តី បីតិក្តី ( ជាបច្ច័យ ) នៃកិរិយាមនោវិញ្ញាណធាតុ ភវង្គប្រកបដោយបីតិក្តី បីតិក្តី ( ជាបច្ច័យ ) នៃភវង្គៈមិនមានបីតិ កុសលាកុសលប្រកបដោយបីតិក្តី បីតិក្តី ( ជាបច្ច័យ ) នៃវុដ្ឋានៈមិនមានបីតិ កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផល ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី ជាបច្ច័យនៃ

សប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកសប្បីតិ-កក្ខន្ធមុនៗផង បីតិផង ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធក្រោយៗផង នៃបីតិផង ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយសហជាតប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយអញ្ញ-មញ្ញប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយនិស្សយប្បច្ច័យ មានវារៈ ៩ ។

[ ៨៦ ] សប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ ដោយឧបនិស្ស-យប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូប-និស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺពួកសប្បីតិកក្ខន្ធ ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកសប្បីតិកក្ខន្ធ ជាបច្ច័យនៃពួកអប្បីតិកក្ខន្ធផង នៃបីតិផង ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកសប្បីតិកក្ខន្ធ ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធផង នៃបីតិផង ដោយឧបនិស្សយប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃអប្បីតិកធម៌ ដោយឧប-និស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូ-បនិស្ស័យ ។បេ។ ឯ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា មិនមានបីតិ ហើយឲ្យនូវទាន ដោយចិត្តមិនមានបីតិ នូវសីល... នូវឧបោសថកម្ម ញុំាងឈាន វិបស្សនា មគ្គនិងអភិញ្ញា មិនមានបីតិ... ញុំាងសមាបត្តិ ឲ្យកើតឡើង ជំឡើងនូវមានៈ ប្រកាន់នូវទិដ្ឋិ នូវសីល មិនមានបីតិ ។បេ។ អាស្រ័យនូវបញ្ញា... នូវអភិជ្ឈា រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ រដូវ នូវភោជន... នូវសេនាសនៈ និងបីតិ

នូវទានដោយចិត្តមិនមានបីតិ ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា មិនមានបីតិ ។បេ។ សេនាសនៈក្តី បីតិក្តី ជាបច្ច័យនៃសទ្ធា មិនមានបីតិ ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ ផលសមាបត្តិ និងបីតិ ដោយឧបនិស្សយប្បច្ច័យ ។ អប្បីតិកធម៌ជាបច្ច័យនៃសប្បីតិកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺឧបនិស្ស័យ ៣ យ៉ាង បុគ្គលអាស្រ័យនូវសទ្ធាមិនមានបីតិ ហើយឲ្យនូវទាន ដោយចិត្តប្រកបដោយបីតិ ។បេ។ អំពីឈាន មិនមានបីតិ ។បេ។ ជំឡើងនូវមានៈ ប្រកាន់នូវទិដ្ឋិ នូវសីល មិនមានបីតិ ។បេ។ អាស្រ័យនូវសេនាសនៈ បីតិ ហើយឲ្យនូវទាន ដោយចិត្តប្រកបដោយបីតិ ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង នូវទ្រព្យដែលគេពុំបានឲ្យ... មិនពិត... ញុះញង់... រោយរាយឥតប្រយោជន៍... នូវទឹត... នូវការប្លន់... នូវការប្លន់ក្នុងផ្ទះមួយ... ក្នុងផ្លូវ... នូវប្រពន្ធអ្នកដទៃ... នូវការសម្លាប់អ្នកស្រុក... នូវការសម្លាប់អ្នកនិគម ដោយចិត្តប្រកបដោយបីតិ... សទ្ធាមិនមានបីតិ ។បេ។ សេនាសនៈក្តី បីតិក្តី ជាបច្ច័យនៃសទ្ធាប្រកបដោយបីតិ ។បេ។ ជាបច្ច័យនៃបញ្ញា រាគៈ មោហៈ មានៈ ទិដ្ឋិ សេចក្តីប្រាថ្នា មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយឧបនិស្សយប្បច្ច័យ គឺឧបនិស្ស័យ ៣ យ៉ាង បុគ្គលអាស្រ័យនូវសទ្ធាមិនមានបីតិ ហើយឲ្យនូវទានដោយចិត្តប្រកបដោយបីតិ ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង ជំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ ។បេ។ នូវសីលមិន

មានបីតិ ។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ និងបីតិ ហើយឲ្យនូវទាន ដោយចិត្តប្រកបដោយបីតិ ។បេ។ ញុំាងសមាបត្តិឲ្យកើតឡើង កាន់យកនូវទ្រព្យដែលគេមិនបានឲ្យដោយចិត្តប្រកបដោយបីតិ ។បេ។ ( ពាក្យដ៏សេស ) ប្រហែលគ្នានឹងទុតិយវារៈដែរ ។ បុគ្គលធ្វើនូវការសម្លាប់អ្នកនិគម សទ្ធាមិនមានបីតិ ។បេ។ សេនាសនៈក្តី បីតិក្តី ( ជាបច្ច័យ ) នៃសទ្ធាប្រកបដោយបីតិ ។បេ។ ជាបច្ច័យនៃបញ្ញា រាគៈ មោហៈ មានៈ ទិដ្ឋិ សេចក្តីប្រាថ្នា មគ្គផលសមាបត្តិ និងបីតិ ដោយឧបនិស្សយប្បច្ច័យ ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី ជាបច្ច័យនៃសប្បីតិកធម៌ ដោយឧបនិស្សយប្បច្ច័យ គឺឧបនិស្ស័យ ៣ យ៉ាង ពួកសប្បីតិកក្ខន្ធក្តី បីតិក្តី ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធ ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកសប្បីតិកក្ខន្ធក្តី បីតិក្តី ជាបច្ច័យនៃពួកអប្បីតិកក្ខន្ធផង នៃបីតិផង ដោយឧបនិស្សយប្បច្ច័យ ។ មូល គឺពួកសប្បីតិកក្ខន្ធក្តី បីតិក្តី ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធផង នៃបីតិផង ដោយឧបនិស្សយប្បច្ច័យ ។

[ ៨៧ ] អប្បីតិកធម៌ ជាបច្ច័យនៃអប្បីតិកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង ដោយចិត្តមិនមានបីតិ... ពិចារណា ត្រេកអរ រីករាយ រាគៈមិនមានបីតិ កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។បេ។ ទោមនស្ស បីតិ កើតឡើង ដោយទិព្វចក្ខុ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុ-

វិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃពួកសប្បីតិកក្ខន្ធផង នៃបីតិផង ដោយបុរេជាតប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ជាមិនទៀង ដោយចិត្តមិនមានបីតិ... ពិចារណា ត្រេកអរ រីករាយ រាគៈ ប្រកបដោយបីតិកើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ទិដ្ឋិ... ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកសប្បីតិកក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុជាមិនទៀង ដោយចិត្តមិនមានបីតិ... ពិចារណា ត្រេកអរ រីករាយ បីតិក្តីពួកសម្បយុត្តកក្ខន្ធក្តី កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។ វត្ថុបុរេជាតគឺវត្ថុជាបច្ច័យនៃពួកសប្បីតិកក្ខន្ធផង នៃបីតិផង ដោយបុរេជាតប្បច្ច័យ ។

[ ៨៨ ] សប្បីតិកធម៌ ជាបច្ច័យនៃអប្បីតិកធម៌ ដោយបច្ឆាជាតប្បច្ច័យមានវារៈ ៣ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយកម្មប្បច្ច័យ មានវារៈ ៦ សហជាតក្តី នានាខណិកៈក្តី បណ្ឌិតគប្បីធ្វើចុះ មាននានាខណិកៈ ២ ។ ... ជាបច្ច័យដោយវិបាកប្បច្ច័យ មានវារៈ ៩ ជាបច្ច័យ ដោយអាហារប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ

មានវារៈ ៦ ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ជាបច្ច័យដោយអត្ថិប្បច្ច័យ មានវារៈ ៩ ។ សេចក្តីបំប្រួញ ។ បណ្ឌិតគប្បីធ្វើឲ្យដូចគ្នានឹងសវិតក្កទុកៈផងចុះ ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៦ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្រ្ទិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩០ ] សប្បីតិកធម៌ជាបច្ច័យនៃសប្បីតិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ សប្បីតិកធម៌ ជាបច្ច័យនៃអប្បីតិកធម៌ ដោយ

អារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ សប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃអប្បីតិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ អប្បីតិកធម៌ ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី ជាបច្ច័យនៃសប្បីតិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី ជាបច្ច័យនៃអប្បីតិកធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។ សប្បីតិកធម៌ក្តី អប្បីតិកធម៌ក្តី ជាបច្ច័យនៃសប្បីតិកធម៌ផង នៃអប្បីតិកធម៌ផង

ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

ការរាប់នូវបច្ចនីយវិភង្គ ប្រហែលគ្នានឹងសវិតក្កទុកៈ ប្រសិនបើមិនសមទេ បណ្ឌិតគប្បីពិចារណា ចំពោះអនុលោមនេះហើយរាប់ចុះ ការរាប់ទាំងពីរយ៉ាងក្រៅនេះ បណ្ឌិតគប្បីរាប់ផងចុះ ។

**ចប់ សប្បីតិកទុកៈ ។**

## បីតិសហគតទុកៈ

## បដិច្ចវារៈ

[ ៩១ ] ធម៌ដែលប្រកបដោយបីតិ អាស្រ័យនូវធម៌ដែលប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវខន្ធ ១ ដែលប្រកបដោយបីតិ នូវខន្ធ ២ ... ។ បីតិសហគតទុកៈ ប្រហែលគ្នានឹងសប្បីតិកទុកៈ បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ មិនមានការធ្វើផ្សេងៗគ្នាទេ អាមសនៈក៏មិនមានផ្សេងគ្នាដែរ ។

**ចប់ បីតិសហគតទុកៈ ។**

# សុខសហគតទុកៈ

## បដិច្ចវារៈ

[ ៩២ ] សុខសហគតធម៌ ( ធម៌ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ) អាស្រ័យនូវសុខសហគតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវសុខសហគតក្ខន្ធ ១ ( ខន្ធ ១ ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ) ខន្ធ ១ អាស្រ័យនូវខន្ធ ២ មានបដិសន្ធិ ។ នសុខសហគតធម៌ ( ធម៌ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ) អាស្រ័យនូវសុខសហគតធម៌ ( ធម៌ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ) ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺសុខក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកសុខសហគតក្ខន្ធ ។ អនុលោមប្បដិច្ចវារៈនៃសប្បីតិកទុកៈយ៉ាងណា សុខសហគតទុកៈ បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩៤ ] សុខសហគតធម៌អាស្រ័យនូវសុខសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវសុខសហគតក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ។ មូល គឺសុខក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវពួកសុខសហគតក្ខន្ធ ជាអហេតុកៈ ។ សុខសហគតធម៌ក្តី នសុខសហគតធម៌ក្តី អាស្រ័យនូវសុខសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ

គឺខន្ធ ២ សុខផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវសុខសហគតក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ។ នសុខសហគតធម៌ អាស្រ័យនូវនសុខ-សហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តស-មុដ្ឋានរូបផង អាស្រ័យនូវនសុខសហគតក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវសុខ ជាអហេតុកៈ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវនសុខសហគតក្ខន្ធ ១ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២... វត្ថុអាស្រ័យនូវពួកខន្ធ ឯពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ដរាប ដល់ពួកអសញ្ញសត្វ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ដូច ជាក្នុងសប្បីតិកៈដែរ ប្រហែលគ្នានឹងនហេតុប្បច្ច័យ មិនមានផ្សេងគ្នាទេ ក្នុង បច្ច័យទាំងអស់ សុទ្ធតែមានបញ្ហា ៩ ។

[ ៩៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន វារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មាន វារៈ ៩ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុង នអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុង នឈានប្បច្ច័យ មានវារៈ ៦ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្ប-យុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោ-នត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំងពីរយ៉ាងក្រៅនេះយ៉ាងនេះឯង ។ ឯសហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ បវត្តិក្ដី បដិសន្ធិក្ដី ក្នុងបច្ចយវារៈ បណ្ឌិត គប្បីឲ្យពិស្ដារ ដូចជាក្នុងសប្បីតិកទុ-កប្បច្ចយវារប្បច្ចនិយៈ ឯវត្ថុក្នុងបវត្តិកាល បណ្ឌិតគប្បីឲ្យពិស្ដារ ដូចជាក្នុងសប្បីតិកទុកៈ មានមោហៈតែមួយគត់ ។ និស្សយវារៈក្ដី សំសដ្ឋវារៈក្ដី សម្បយុត្តវារៈក្ដី បណ្ឌិតគប្បីធ្វើឲ្យដូចជាសប្បីតិកទុកៈចុះ ។

## បញ្ហាវារៈ

[ ៩៦ ] សុខសហគតធម៌ ជាបច្ច័យនៃសុខសហគតធម៌ ដោយហេ-តុប្បច្ច័យ មានវារៈ ៤ ។ ក្នុងអារម្មណប្បច្ច័យក្ដី ក្នុងអធិបតិប្បច្ច័យក្ដី ប្រហែលគ្នានឹងសប្បីតិកទុកៈដែរ មានការធ្វើឲ្យផ្សេងៗគ្នា តែត្រង់ពាក្យថា សុខៈ ។

[ ៩៧ ] សុខសហគតធម៌ ជាបច្ច័យនៃសុខសហគតធម៌ ដោយអនន្ត-រប្បច្ច័យ គឺពួកសុខសហគតក្ខន្ធមុនៗ ជាបច្ច័យនៃពួកសុខសហគតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល គឺពួកសុខសហគតក្ខន្ធមុនៗ ជាបច្ច័យនៃនសុខសហគតធម៌ក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ជាបច្ច័យនៃឧបបត្តិចិត្តដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ភវង្គដែលប្រព្រឹត្តទៅជាមួយនឹងសុខ ( ជាបច្ច័យ ) នៃអាវជ្ជនៈ

កាយវិញ្ញាណដែលប្រព្រឹត្តទៅជាមួយនឹងសុខ ( ជាបច្ច័យ ) នៃវិបាកមនោ-ធាតុ វិបាកមនោវិញ្ញាណធាតុដែលប្រព្រឹត្តទៅជាមួយនឹងសុខ ( ជាបច្ច័យ ) នៃកិរិយាមនោវិញ្ញាណធាតុ ភវង្គ ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ( ជាបច្ច័យ ) នៃភវង្គ ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ កុសលាកុសល ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ( ជាបច្ច័យ ) នៃវុដ្ឋានៈ ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផល ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ មូលគឺពួកសុខសហគតក្ខន្ធមុនៗ ជាបច្ច័យនៃពួកសុខសហគតក្ខន្ធក្រោយៗផង នៃសុខផង ដោយអនន្តរប្បច្ច័យ ។ នសុខសហគតធម៌ជាបច្ច័យនៃនសុខសហគតធម៌ ដោយអនន្តរប្បច្ច័យ គឺពួកនសុខសហគតក្ខន្ធមុនៗ... ។ មូលគឺមានវារៈ ៣ ប្រហែលគ្នានឹងសប្បីតិកទុកៈ ។ សុខសហគតធម៌ក្តី នសុខសហគតធម៌ក្តី ជាបច្ច័យនៃសុខ-សហគតធម៌ ដោយអនន្តរប្បច្ច័យ គឺពួកសុខសហគតក្ខន្ធមុនៗផង សុខផង ជាបច្ច័យនៃពួកសុខសហគតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូលគឺពួកសុខសហគតក្ខន្ធមុនៗក្តី សុខក្តី ជាបច្ច័យនៃសុខក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងសុខក្តី សុខក្តី ( ជាបច្ច័យ ) នៃឧបបត្តិចិត្ត ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ភវង្គៈ ដែលប្រព្រឹត្តទៅជាមួយនឹងសុខក្តី សុខក្តី ( ជាបច្ច័យ ) នៃអាវជ្ជនៈ កាយ-វិញ្ញាណ ដែលប្រព្រឹត្តទៅជាមួយនឹងសុខក្តី សុខក្តី ( ជាបច្ច័យ ) នៃវិបាកមនោធាតុ វិបាកមនោវិញ្ញាណ ប្រព្រឹត្តទៅជាមួយនឹងសុខក្តី សុខក្តី

( ជាបច្ច័យ ) នៃកិរិយាមនោវិញ្ញាណធាតុ កវន្គដែលប្រព្រឹត្តទៅជាមួយនឹងសុខក្តី សុខក្តី ( ជាបច្ច័យ ) នៃកវន្គៈ ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ កុសលាកុសល ដែលប្រព្រឹត្តទៅជាមួយនឹងសុខក្តី សុខក្តី ជា ( បច្ច័យ ) នៃវុដ្ឋានៈ ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផលជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ មូល គឺពួកសុខសហគតក្ខន្ធមុនៗក្តី សុខក្តី ជាបច្ច័យនៃពួកសុខសហគតក្ខន្ធក្រោយៗផង នៃសុខផង ដោយអនន្តរប្បច្ច័យ ។ ... ជាបច្ច័យដោយសមនន្តរប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ ។

[ ៩៨ ] សុខសហគតធម៌ ជាបច្ច័យនៃសុខសហគតធម៌ ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ នសុខសហគតធម៌ ជាបច្ច័យនៃនសុខ-សហគតធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ហើយឲ្យនូវទានដោយចិត្តដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ សីល ។បេ។ ញ៉ាំងសមាបត្តិឲ្យកើតឡើង ដំឡើងនូវមានៈ ប្រកាន់នូវទិដ្ឋិ នូវសីលដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ នូវបញ្ញា... នូវរាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ រដូវនិងភោជន... បុគ្គលអាស្រ័យនូវសេនាសនៈ នូវសុខហើយឲ្យនូវទាន ដោយចិត្តដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ ញ៉ាំង

សមាបត្តិឲ្យកើតឡើង ។បេ។ សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ សេនាសនៈក្តី សុខក្តី ជាបច្ច័យ នៃសទ្ធា ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ ជាបច្ច័យនៃបញ្ញា រាគៈ ទោសៈ សេចក្តីប្រាថ្នា កាយិកសុខ មគ្គ ផលសមាបត្តិ និងសុខ ដោយ ឧបនិស្សយប្បច្ច័យ ។ នសុខសហគតធម៌ ជាបច្ច័យនៃសុខសហគតធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ហើយឲ្យនូវទាន ដោយចិត្តដែលប្រព្រឹត្ត ទៅជាមួយនឹងសុខ ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ នូវ បញ្ញា... នូវរាគៈ សេចក្តីប្រាថ្នានិងកាយិកសុខ... បុគ្គលអាស្រ័យនូវសេនា- សនៈ និងសុខ ហើយឲ្យនូវទានដោយចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹង សុខ ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង កាន់យកនូវរបស់ដែលគេមិន បានឲ្យដោយចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងសុខ មិនពិត... ញុះញង់... រោយរាយឥតប្រយោជន៍... នូវទីត... នូវការប្លន់... នូវការប្លន់ក្នុងផ្ទះមួយ... ក្នុងផ្លូវ... នូវប្រពន្ធរបស់អ្នកដទៃ... នូវការសម្លាប់អ្នកស្រុក... នូវការ សម្លាប់អ្នកនិគម... សទ្ធាដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ សេនា- សនៈ ជាបច្ច័យនៃសទ្ធា ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ ជាបច្ច័យ នៃបញ្ញា រាគៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា កាយិកសុខ មគ្គនិង

ផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នសុខសហគតធម៌ ជាបច្ច័យនៃសុខសហគតធម៌ផង នៃនសុខសហគតធម៌ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គល អាស្រ័យនូវសទ្ធា ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ហើយឲ្យនូវទានដោយចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ។ ប្រហែលគ្នានឹងជំណើរទី ២ ដែរ ។ ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីលដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ បុគ្គលអាស្រ័យនូវសេនាសនៈ សុខ ហើយឲ្យនូវទាន ។បេ។ ញុំាំងសមាបត្តិឲ្យកើតឡើង កាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ដោយចិត្តដែលប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ សទ្ធា ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ សេនាសនៈក្តី សុខក្តី ជាបច្ច័យនៃសទ្ធា ដែលប្រព្រឹត្តទៅជាមួយនឹងសុខ ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា កាយិកសុខ មគ្គ ផលសមាបត្តិនិងសុខ ដោយឧបនិស្សយប្បច្ច័យ ។ សុខសហគតធម៌ក្តី នសុខសហគតធម៌ក្តី ជាបច្ច័យនៃសុខសហគតធម៌ ដោយឧបនិស្សយប្បច្ច័យ មានវារៈ ។

[ ៩៩ ] នសុខសហគតធម៌ ជាបច្ច័យនៃនសុខសហគតធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ដោយចិត្តដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ជាមិនទៀង... ពិចារណា ត្រេកអរ រីករាយ រាគៈ ដែលមិនប្រព្រឹត្តទៅជាមួយនឹងសុខ ប្រារព្ធនូវហេតុនោះ ។បេ។ ទោមនស្សកើតឡើង ឃើញនូវ

រូបដោយទិព្វចក្ខុ ។បេ។ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកនសុខសហគតក្ខន្ធផង នៃសុខផង ដោយបុរេជាតប្បច្ច័យ ។ នសុខសហគតធម៌ជាបច្ច័យនៃសុខសហគតធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ដោយចិត្តដែលប្រព្រឹត្តទៅជាមួយនឹងសុខ ថាមិនទៀង... ពិចារណា ត្រេកអរ រីករាយ រាគៈ ដែលប្រព្រឹត្តទៅជាមួយនឹងសុខ កើតឡើង ទិដ្ឋិ កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃសុខសហគតក្ខន្ធ ដោយបុរេជាតប្បច្ច័យ នសុខសហគតធម៌ ជាបច្ច័យនៃសុខសហគតធម៌ផង នៃនសុខសហគតធម៌ផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ដោយចិត្តដែលប្រព្រឹត្តទៅជាមួយនឹងសុខ ថាមិនទៀង... ពិចារណា ត្រេកអរ រីករាយ រាគៈដែលប្រព្រឹត្តទៅជាមួយនឹងសុខ កើតឡើង ព្រោះប្រារព្ធនូវហេតុនោះ ទិដ្ឋិ... ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃពួកសុខ-សហគតក្ខន្ធផង នៃសុខផង ដោយបុរេជាតប្បច្ច័យ ។ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ជាបច្ច័យដោយអាសេវនប្បច្ច័យ មានវារៈ ៩ ។

[ ១០០ ] សុខសហគតធម៌ ជាបច្ច័យនៃសុខសហគតធម៌ ដោយកម្មប្បច្ច័យ បានដល់ កម្ម ៦ ជាសហជាត និងជានានាខណិកៈ គឺកម្ម ៤

ជាសហគត:ខ្វះ ជានានាខណិក:ខ្វះ ឯកម្ម ២ ជានានាខណិក: បណ្ឌិត គប្បីធ្វើចុះ ។ ... ជាបច្ច័យដោយវិបាកប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអាហារប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៦ ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ជាបច្ច័យដោយអត្ថិប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយនត្ថិប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយវិគតប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៦ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ

៩ ។

បច្ចនីយវិភង្គក្តី ការរាប់ក្តី ប្រហែលគ្នានឹងសប្បីតិកទុកៈ
បណ្ឌិត គប្បីធ្វើយ៉ាងនោះចុះ ប្រសិនបើមានសេចក្តីសង្ស័យ
បណ្ឌិតគប្បីមើលអនុលោម ហើយរាប់ផងចុះ ។

**ចប់ សុខសហគតទុកៈ ។**

# ឧបេក្ខាសហគតទុកៈ

## បដិច្ចវារៈ

[ ១០២ ] ឧបេក្ខាសហគតធម៌ ( ធម៌ដែលប្រព្រឹត្តទៅជាមួយនឹងឧបេក្ខា ) អាស្រ័យនូវឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ នឧបេក្ខាសហគតធម៌អាស្រ័យនូវឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺឧបេក្ខាផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវពួកឧបេក្ខាសហគតក្ខន្ធ មានបដិសន្ធិ ។ ឧបេក្ខាសហគតធម៌ក្តី នឧបេក្ខាសហគតធម៌ក្តី អាស្រ័យនូវឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ផង ឧបេក្ខាផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ នូវខន្ធ ២ ... មានបដិសន្ធិ ។ នឧបេក្ខាសហគតធម៌ អាស្រ័យនូវនឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះហេ-

តុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ នូវខន្ធ ២ .... ចិត្តសមុដ្ឋានរូប អាស្រ័យនូវឧបេក្ខា ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យនូវនឧបេក្ខាសហគតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូបអាស្រ័យនូវឧបេក្ខា វត្ថុអាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ វត្ថុអាស្រ័យនូវឧបេក្ខា ឧបេក្ខាអាស្រ័យនូវវត្ថុ អាស្រ័យនូវមហាភូត ១ ក្នុងខណៈនៃបដិសន្ធិ។

មានបញ្ហា ៩ ក្នុងអនុលោម ដូចគ្នានឹងសប្បីតិកទុកៈដែរ ។

[ ១០៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងពួងសុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០៤ ] ឧបេក្ខាសហគតធម៌ អាស្រ័យនូឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកបដិសន្ធិ ។ ឧបេក្ខាសហគតធម៌ អាស្រ័យនូវឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺឧបេក្ខាក្តី ចិត្ត-សមុដ្ឋានរូបក្តី អាស្រ័យនូវពួកឧបេក្ខាសហគតក្ខន្ធ ជាអហេតុកៈ ក្នុងខណៈនៃអហេតកបដិសន្ធិ ។បេ។ ឧបេក្ខាសហគតធម៌ក្តី នឧបេក្ខាសហគតធម៌ក្តី

អាស្រ័យនូវឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ក្តី ឧបេក្ខាក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។បេ។ នឧបេក្ខាសហគតធម៌ អាស្រ័យនូវនឧបេក្ខាសហគតធម៌ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវឧបេក្ខា ជាអហេតុកៈ វត្ថុអាស្រ័យនូវឧបេក្ខា ឯឧបេក្ខាអាស្រ័យនូវវត្ថុ មហាភូត ១ ដរាបដល់ពួកអសញ្ញសត្វ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ ឧបេក្ខាសហគតធម៌ អាស្រ័យនូវនឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវឧបេក្ខា ជាអហេតុកៈ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវឧបេក្ខា ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ វត្ថុអាស្រ័យនូវឧបេក្ខា ពួកឧបេក្ខាសហគតក្ខន្ធ អាស្រ័យនូវវត្ថុ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវឧបេក្ខា ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ឧបេក្ខាសហគតធម៌ផង នឧបេក្ខាសហគតធម៌ផង អាស្រ័យនូវនឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវឧបេក្ខា ជាអហេតុកៈ ពួកឧបេក្ខាសហគតក្ខន្ធ អាស្រ័យនូវឧបេក្ខាជាអហេតុកៈ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកមហាភូត ពួកសម្បយុត្តកក្ខន្ធផង កដត្តារូបផង អាស្រ័យនូវឧបេក្ខា ក្នុងខណៈនៃ

អហេតុកប្បដិសន្ធិ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យនូវឧបេក្ខា កដត្តារូប អាស្រ័យ នូវពួកមហាភូត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ពួកឧបេក្ខា-សហគតក្ខន្ធ អាស្រ័យនូវវត្ថុ កដត្តារូបអាស្រ័យនូវពួកមហាភូត ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ឧបេក្ខាផង ពួកសម្បយុត្តកក្ខន្ធផង អាស្រ័យនូវវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ ឧបេក្ខាសហគតធម៌ អាស្រ័យនូវឧបេក្ខា-សហគតធម៌ផង នូវនឧបេក្ខាសហគតធម៌ផង ទើបកើតឡើង ព្រោះនហេ-តុប្បច្ច័យ គឺខន្ធ ២ អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈផង នូវឧបេក្ខាផង នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ផង នូវឧបេក្ខាផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈផង នូវវត្ថុផង នូវខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នូវឧបេក្ខាផង ។ នឧបេក្ខាសហ-គតធម៌ អាស្រ័យនូវឧបេក្ខាសហគតធម៌ផង នូវនឧបេក្ខាសហគតធម៌ផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបេក្ខាសហគតក្ខន្ធ ជាអហេតុកៈផង នូវឧបេក្ខាផង ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបេក្ខាសហគតក្ខន្ធ ជាអហេតុកៈផង នូវពួកមហាភូតផង កដត្តារូបអាស្រ័យនូវពួកឧបេក្ខាសហគតក្ខន្ធផង នូវឧបេក្ខាផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យនូវពួកឧបេក្ខាសហគតក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ឧបេក្ខាអាស្រ័យនូវពួក

ឧបេក្ខាសហគតក្ខន្ធផង នូវវត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ ឧបេក្ខាសហគតធម៌ផង នឧបេក្ខាសហគតធម៌ផង អាស្រ័យនូវឧបេក្ខាសហគតធម៌ផង នូវនឧបេក្ខាសហគតធម៌ផងទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈផង នូវឧបេក្ខាផង នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈផង នូវឧបេក្ខាផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកឧបេក្ខាសហគតក្ខន្ធ ជាអហេតុកៈផង នូវឧបេក្ខាផង នូវពួកមហាភូតផង ខន្ធ ២ ផង កដត្តារូបផង អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ផង នូវឧបេក្ខាផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ផង នូវឧបេក្ខាផង នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួក ឧបេក្ខាសហគតក្ខន្ធ ជាអហេតុកកៈផង នូវឧបេក្ខាផង នូវពួកមហាភូតផង ខន្ធ ២ ផង កដត្តារូបផង អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ផង នូវឧបេក្ខាផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ នូវខន្ធ ២ ... ខន្ធ ២ អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ផង នូវឧបេក្ខាផង នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវពួកឧបេក្ខាសហគតក្ខន្ធផង នូវឧបេក្ខាផង នូវពួកមហាភូតផង ខន្ធ ២ ផង ឧបេក្ខាផង អាស្រ័យនូវឧបេក្ខាសហគតក្ខន្ធ ១ ផង នូវឧបេក្ខាផង នូវវត្ថុផង នូវខន្ធ ២ ... ។ សេចក្តីបំព្រួញ ។

[ ១០៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ

មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំងពីរក្រៅនេះក្តី សហជាតវារៈក្តី
បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បច្ចយវារៈ

[ ១០៦ ] ឧបេក្ខាសហគតធម៌ ពឹងផ្អែកនឹងឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងឧបេក្ខាសហគតក្ខន្ធ ១ នឹងខន្ធ ២ ... មានបដិសន្ធិ ។

ឧបេក្ខាសហគតទុកៈនេះ ដូចជាសវិតក្កទុកៈដែរ ។ ក្នុងបច្ចយវារៈ មានតែការធ្វើឲ្យផ្សេងៗគ្នាថា ឧបេក្ខាប៉ុណ្ណោះ ។ បណ្ឌិតគប្បីធ្វើជាបញ្ហា ៩ មានបដិសន្ធិផង បវត្តិផង វត្ថុ

ផង ។

[ ១០៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០៨ ] ឧបេក្ខាសហគតធម៌ ពឹងផ្អែកនឹងឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ ពឹងផ្អែកនឹងឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈ នឹងខន្ធ ២ ... មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ បញ្ហា ៩ នៃសវិតក្កទុកៈ បណ្ឌិតគប្បីធ្វើឲ្យជាបវត្តិបដិសន្ធិយ៉ាងនេះ មោហៈ ទាំង ៣ បណ្ឌិតគប្បីធ្វើទាំងវត្ថុ បណ្ឌិតគប្បីធ្វើក្នុងបវត្តិកាលយ៉ាងនេះ ។

[ ១០៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៩ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុង

នវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោ-វិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ទាំងពីរក្រៅនេះក្តី និស្សយវារៈក្តី
បណ្ឌិតគប្បីធ្វើយ៉ាងនេះ ។

# សំសដ្ឋវារៈ

[ ១១០ ] ឧបេក្ខាសហគតធម៌ លាយឡំនឹងឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ២ លាយឡំនឹងឧបេក្ខាសហគតក្ខន្ធ ១ នឹងខន្ធ ២ ... មានបដិសន្ធិ ( ឧបេក្ខាសហគតទុកៈនេះ ) បណ្ឌិតគប្បីធ្វើឲ្យដូចជាសវិតក្កទុកៈផងចុះ ។

[ ១១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។

[ ១១២ ] ឧបេក្ខាសហគតធម៌ លាយឡំនឹងឧបេក្ខាសហគតធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ២ លាយឡំនឹងឧបេក្ខាសហគតក្ខន្ធ ១ ជាអហេតុកៈ នឹងខន្ធ ២ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ លាយឡំនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ បញ្ហា ៥ បណ្ឌិតគប្បីធ្វើឲ្យដូចជាក្នុងសវិតក្កទុកៈផងចុះ ។

[ ១១៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៦ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៦ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ។

ការរាប់ពីរយ៉ាង ក្រៅនេះក្តី សម្បយុត្តវារៈក្តី

បណ្ឌិតគប្បីធ្វើយ៉ាងនេះចុះ ។

## បញ្ហាវារៈ

[ ១១៤ ] ឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខាសហគតធម៌ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រកបដោយឧបេក្ខា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ មានបដិសន្ធិ ។ បញ្ហា ៤ ដូចជា ( បញ្ហា ) នៃសវិតក្កទុកៈ យ៉ាងនេះឯង ។

[ ១១៥ ] ឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខាសហគតធម៌ ដោយអារម្មណប្បច្ច័យ ។ ... ជាបច្ច័យដោយអធិបតិប្បច្ច័យ ។ សប្បីតិកទុកៈ យ៉ាងណា អារម្មណ៍ក្តី អធិបតិក្តី បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ មានសេចក្តីផ្សេងគ្នាតែពាក្យថា ឧបេក្ខាប៉ុណ្ណោះ ។

[ ១១៦ ] ឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខាសហគតធម៌ ដោយអនន្តរប្បច្ច័យ គឺពួកឧបេក្ខាសហគតក្ខន្ធមុនៗ ជាបច្ច័យនៃពួកឧបេក្ខាសហគតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ ឧបេក្ខាសហគតធម៌ ជាបច្ច័យនៃ

ឧបេក្ខាសហគតធម៌ ដោយអនន្តរប្បច្ច័យ គឺពួកឧបេក្ខាសហគតក្ខន្ធមុនៗ ជាបច្ច័យនៃឧបេក្ខាក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលប្រកបដោយឧបេក្ខា ជា ( បច្ច័យ ) នៃឧបបត្តិចិត្តដែលមិនប្រកបដោយឧបេក្ខា អាវជ្ជនៈ ( ជាបច្ច័យ ) នៃពួកខន្ធ ដែលមិនប្រកបដោយឧបេក្ខា វិបាកមនោធាតុ ( ជាបច្ច័យ ) នៃវិបាកមនោវិញ្ញាណធាតុ ដែលមិនប្រកបដោយឧបេក្ខា ភវង្គៈដែលប្រកបដោយឧបេក្ខា ( ជាបច្ច័យ ) នៃភវង្គៈ ដែលមិនប្រកបដោយឧបេក្ខា កុសលាកុសលដែលប្រកបដោយឧបេក្ខា ( ជាបច្ច័យ ) នៃវុដ្ឋានដែលមិនប្រកបដោយឧបេក្ខា កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផល ( ជាបច្ច័យ ) នៃវុដ្ឋានៈ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដែលមិនប្រកបដោយឧបេក្ខា ដោយអនន្តរប្បច្ច័យ ។ ឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខាសហគតធម៌ផង នៃនឧបេក្ខាសហគតធម៌ផង ដោយអនន្តរប្បច្ច័យ គឺពួកឧបេក្ខាសហគតក្ខន្ធមុនៗ ជាបច្ច័យនៃពួកឧបេក្ខាសហគតក្ខន្ធក្រោយៗផង នៃឧបេក្ខាផង ដោយអនន្តរប្បច្ច័យ ។ នឧបេក្ខាសហគតធម៌ ជាបច្ច័យនៃនឧបេក្ខាសហគតធម៌ ដោយអនន្តរប្បច្ច័យ គឺឧបេក្ខាមុនៗ ជាបច្ច័យនៃឧបេក្ខាក្រោយៗ ដោយអនន្តរប្បច្ច័យ ពួកនឧបេក្ខាសហគតក្ខន្ធមុនៗ ជាបច្ច័យនៃពួកនឧបេក្ខាសហគតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលមិនប្រកបដោយឧបេក្ខា ( ជាបច្ច័យ ) នៃឧបបត្តិចិត្ត ដែលមិនប្រកបដោយឧបេក្ខា អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោមជាបច្ច័យនៃផលសមាបត្តិ

ដោយអនន្តរប្បច្ច័យ ។ មូលគឺឧបេក្ខាមុនៗ ជាបច្ច័យនៃពួកឧបេក្ខាសហ-គតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលមិនប្រកបដោយឧបេក្ខា ( ជាបច្ច័យ ) នៃឧបបត្តិចិត្តដែលប្រកបដោយឧបេក្ខា ភវង្គៈ ដែលមិនប្រកបដោយឧបេក្ខា ( ជាបច្ច័យ ) នៃអាវជ្ជនៈ កាយវិញ្ញាណធាតុ ( ជាបច្ច័យ ) នៃវិបាកមនោធាតុ វិបាកមនោវិញ្ញាណធាតុ ដែលមិនប្រកបដោយឧបេក្ខា ( ជាបច្ច័យ ) នៃកិរិយាមនោវិញ្ញាណធាតុ ភវង្គៈ ដែលមិនប្រកបដោយឧបេក្ខា ( ជាបច្ច័យ ) នៃភវង្គៈ ដែលប្រកបដោយឧបេក្ខា កុសលាកុសល ដែលមិនប្រកបដោយឧបេក្ខា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ដែលប្រកបដោយឧបេក្ខា កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផលជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។ នឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខា-សហគតធម៌ផង នៃនឧបេក្ខាសហគតធម៌ផង ដោយអនន្តរប្បច្ច័យ គឺឧបេក្ខាមុនៗ ជាបច្ច័យនៃពួកឧបេក្ខាសហគតក្ខន្ធក្រោយៗផង នៃឧបេក្ខាផង ដោយអនន្តរប្បច្ច័យ ។ ឧបេក្ខាសហគតធម៌ក្តី នឧបេក្ខាសហគតធម៌ក្តី ជាបច្ច័យនៃឧបេក្ខាសហគតធម៌ ដោយអនន្តរប្បច្ច័យ គឺពួកឧបេក្ខាសហគតក្ខន្ធមុនៗផង ឧបេក្ខាផង ជាបច្ច័យនៃពួកឧបេក្ខាសហគតក្ខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ ។ មូល គឺពួកឧបេក្ខាសហគតក្ខន្ធមុនៗផង ឧបេក្ខាផង ជាបច្ច័យនៃឧបេក្ខាក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលប្រកបដោយឧបេក្ខាផង ឧបេក្ខាផង ( ជាបច្ច័យ ) នៃឧបបត្តិចិត្ត ដែលមិនប្រកបដោយឧបេក្ខា អាវជ្ជនៈផង ឧបេក្ខាផង ( ជាបច្ច័យ ) នៃពួកនឧបេក្ខាសហគតក្ខន្ធ វិបា-

កមនោធាតុផង ឧបេក្ខាផង ( ជាបច្ច័យ ) នៃវិបាកមនោវិញ្ញាណធាតុ ដែលមិនប្រកបដោយឧបេក្ខា វកន្ធៈដែលមិនប្រកបដោយឧបេក្ខាផង ឧបេក្ខាផង ( ជាបច្ច័យ ) នៃកវន្ធៈដែលមិនប្រកបដោយឧបេក្ខា កុសលាកុសល ដែលប្រកបដោយឧបេក្ខាផង ឧបេក្ខាផង ( ជាបច្ច័យ ) នៃវុដ្ឋានៈ ដែលមិនប្រកបដោយឧបេក្ខា កិរិយា ( ជាបច្ច័យ ) នៃវុដ្ឋានៈ ផល ( ជាបច្ច័យ ) នៃវុដ្ឋានៈ នេវសញ្ញានាសញ្ញាយតនៈរបស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិដែលមិនប្រកបដោយឧបេក្ខា ដោយអនន្តរបច្ច័យ ។ មូលគឺពួកឧបេក្ខាសហគតក្ខន្ធមុនៗផង ឧបេក្ខាផង ជាបច្ច័យនៃពួកឧបេក្ខា-សហគតក្ខន្ធក្រោយៗផង នៃឧបេក្ខាផង ដោយអនន្តរបច្ច័យ ។ ... ជាបច្ច័យដោយសមនន្តរបច្ច័យ ជាបច្ច័យដោយសហជាតបច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអញ្ញមញ្ញបច្ច័យមានវារៈ ៩ ជាបច្ច័យដោយនិស្សយបច្ច័យ មានវារៈ ៩ ។

[ ១១៧ ] ឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខាសហគតធម៌ ដោយឧបនិស្សយបច្ច័យ មានវារៈ ៣ ។ នឧបេក្ខាសហគតធម៌ ជាបច្ច័យនៃនឧបេក្ខាសហគតធម៌ ដោយឧបនិស្សយបច្ច័យ បានដល់ អារម្មណូប-និស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺ បុគ្គលអាស្រ័យនូវសទ្ធាដែលមិនប្រកបដោយឧបេក្ខា ហើយឲ្យនូវទានដោយចិត្តដែលមិនប្រកបដោយឧបេក្ខា នូវសីល... នូវឧបោសថកម្ម... ញុំាងឈាន មិនប្រកបដោយឧបេក្ខា... ញុំាងវិបស្សនា... ញុំាងមគ្គ... ញុំាងសមាបត្តិ ឲ្យ

កើតឡើង ជំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ដែលមិនប្រកបដោយ ឧបេក្ខា ។បេ។ នូវបញ្ញា... នូវរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ រដូវនិងភោជន... អាស្រ័យនូវសេនាសនៈ នូវឧបេក្ខា ហើយឲ្យនូវទាន ដោយចិត្តដែលមិនប្រកបដោយឧបេក្ខា ។បេ។ ញុាំងសមាបត្តិឲ្យកើតឡើង សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធា ដែលមិនប្រកបដោយឧបេក្ខា ។បេ។ សេនាសនៈផង ឧបេក្ខាផង ( ជាបច្ច័យ ) នៃសទ្ធា ដែលមិនប្រកបដោយឧបេក្ខា ។បេ។ នៃបញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ ផលសមាបត្តិ និងឧបេក្ខា ដោយឧបនិស្សយប្បច្ច័យ ។ នឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខា-សហគតធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ ឧបនិស្ស័យ ៣ គឺបុគ្គល អាស្រ័យនូវសទ្ធា ដែលមិនប្រកបដោយឧបេក្ខា ហើយឲ្យនូវទានដោយចិត្ត ដែលប្រកបដោយឧបេក្ខា ។បេ។ ញុាំងសមាបត្តិ ឲ្យកើតឡើង ជំឡើងនូវ មានះ ប្រកាន់នូវទិដ្ឋិ នូវសីល ដែលមិនប្រកបដោយឧបេក្ខា ។បេ។ អាស្រ័យនូវសេនាសនៈ នូវឧបេក្ខា ហើយឲ្យនូវទាន ដោយចិត្តដែលប្រកប ដោយឧបេក្ខា ។បេ។ ញុាំងសមាបត្តិឲ្យកើតឡើង កាន់យកនូវទ្រព្យដែល គេមិនបានឲ្យ ដោយចិត្តដែលប្រកបដោយឧបេក្ខា ពោលនូវពាក្យកុហក នូវ ពាក្យញុះញង់... នូវពាក្យអាក្រក់... នូវពាក្យរោយរាយ... នូវទីត... នូវការ ប្លន់... នូវការប្លន់ក្នុងផ្ទះតែមួយ... ក្នុងផ្លូវស្ងាត់... នូវប្រពន្ធរបស់អ្នកដទៃ... នូវការសម្លាប់អ្នកស្រុក... នូវការសម្លាប់អ្នកនិគម... សទ្ធាដែលមិនប្រកប

ដោយឧបេក្ខា ។បេ។ សេនាសនៈ ( ជាបច្ច័យ ) នៃសទ្ធា ដែលប្រកប ដោយឧបេក្ខា ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខាសហគត-ធម៌ផង នៃនឧបេក្ខាសហគតធម៌ផង ដោយឧបនិស្សយប្បច្ច័យ ។ ឧប-និស្ស័យ ៣ ដូចគ្នានឹងដំណើរនៃវារៈទី ២ ។ ឧបេក្ខាសហគតធម៌ក្តី ន-ឧបេក្ខាសហគតធម៌ក្តី ជាបច្ច័យនៃឧបេក្ខាសហគតធម៌ ដោយឧបនិស្ស-យប្បច្ច័យ មានវារៈ ៣ ។

[ ១១៨ ] នឧបេក្ខាសហគតធម៌ ជាបច្ច័យនៃនឧបេក្ខាសហគតធម៌ ដោយបុរេជាតប្បច្ច័យ មានវារៈ ៣ ដូចគ្នានឹងសប្បីតិកទុកៈដែរ ។

[ ១១៩ ] ឧបេក្ខាសហគតធម៌ ជាបច្ច័យនៃឧបេក្ខាសហគតធម៌ ដោយបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ។ ... ជាបច្ច័យដោយអាសេវនប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយកម្មប្បច្ច័យ មានវារៈ ៦ និងវារៈ ៤ ជាសហជាតនិងជានានាខណិកៈ ចំណែកវារៈ ២ ជានានាខណិកៈ បណ្ឌិតគប្បីធ្វើចុះ ។ ... ជាបច្ច័យដោយវិបាកប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយអាហា-រប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ មានវារៈ ៦ ជាបច្ច័យដោយវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ជាបច្ច័យដោយអត្ថិប្បច្ច័យ មានវារៈ ៩ ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិ-

គតប្បច្ច័យ ។

បច្ច័យទាំងនេះ បណ្ឌិតគប្បីចែកដោយការធ្វើដូចសប្បីតិកៈដែរ ។

[ ១២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៦ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

បច្ចនីយវិភង្គក្តី ការរាប់ទាំង ៣ ក្រៅនេះក្តី បណ្ឌិតគប្បីធ្វើឲ្យដូចជាសប្បីតិកទុកៈ យ៉ាងនេះចុះ ។

**ចប់ ឧបេក្ខាសហគតទុកៈ ។**

# កាមាវចរទុកៈ

# បដិច្ចវារៈ

[ ១២១ ] កាមាវចរធម៌ អាស្រ័យនូវកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវកាមាវចរក្ខន្ធ ១ គឺបដិសន្ធិ... នូវមហាភូត ១ ... ។ សេចក្តីបំប្រួញ ។ នកាមាវចរធម៌ អាស្រ័យនូវកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនកាមាវចរក្ខន្ធ អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ កាមាវចរធម៌ក្តី នកាមាវចរធម៌ក្តី អាស្រ័យនូវកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនកាមាវចរក្ខន្ធ អាស្រ័យនូវវត្ថុ កដត្តារូប អាស្រ័យនូវពួកមហាភូត ក្នុងខណៈនៃបដិសន្ធិ ។ នកាមាវចរធម៌អាស្រ័យនូវនកាមាវចរធម៌ ទើប កើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវនកាមាវចរក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ... ។ កាមាវចរធម៌ អាស្រ័យនូវនកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនកាមាវចរក្ខន្ធ កដត្តារូបអាស្រ័យនូវពួកនកាមាវចរក្ខន្ធ ក្នុងខណៈនៃ បដិសន្ធិ ។ កាមាវចរធម៌ក្តី នកាមាវចរធម៌ក្តី អាស្រ័យនូវនកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនកាមាវចរក្ខន្ធ ១ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ... ។ កាមាវចរធម៌អាស្រ័យនូវកាមាវចរធម៌ផង នូវនកាមាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួក

នកាមាវចរក្ខន្ធផង នូវពួកមហាភូតផង កដត្តារូប អាស្រ័យនូវពួកនកាមា-វចរក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ។ នកាមាវចរធម៌ អាស្រ័យនូវកាមាវចរធម៌ផង នូវនកាមាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវនកាមាវចរក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃសន្ធិ នូវខន្ធ ២ ... ។ កាមាវចរធម៌ក្តី នកាមាវចរធម៌ក្តី អាស្រ័យនូវកាមាវចរធម៌ផង នូវនកាមាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវនកាមាវចរក្ខន្ធ ១ ផង នូវវត្ថុផង កដត្តារូប អាស្រ័យនូវខន្ធ ២ ផង នូវពួកនកាមាវចរក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ១២២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបា-កប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ

មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១២៣ ] កាមាវចរធម៌ អាស្រ័យនូវកាមាវចរធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវកាមាវចរក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... អហេតុកប្បដិសន្ធិ រហូតដល់ពួកអសញ្ញសត្វ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈអាស្រ័យនូវពួកខន្ធដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ... ព្រោះនអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ១២៤ ] កាមាវចរធម៌ អាស្រ័យនូវកាមាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ មានវារៈ ៣ ។ នកាមាវចរធម៌ អាស្រ័យនូវនកាមាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺនកាមាវចរាធិបតិ អាស្រ័យនូវពួកកាមាវចរក្ខន្ធ ខន្ធ ៣ អាស្រ័យនូវនកាមាវចរក្ខន្ធ ១ ជាវិបាកនូវខន្ធ ២ ... គឺបដិសន្ធិ ។ កាមាវចរធម៌អាស្រ័យនូវនកាមាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនកាមាវចរក្ខន្ធ ជាវិបាកក្នុងខណៈនៃបដិសន្ធិ ។បេ។ កាមាវចរធម៌ក្តី នកាមាវចរធម៌ក្តី អាស្រ័យនូវនកាមាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនកាមាវចរក្ខន្ធ ១ ជាវិបាក នូវខន្ធ ២ ... គឺបដិសន្ធិ ។ កាមាវចរធម៌ អាស្រ័យនូវកាមាវចរធម៌ផង នូវនកាមាវចរធម៌ផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនកាមាវចរក្ខន្ធ ជាវិបាកផង នូវពួកមហា-

កុតផង ក្នុងខណៈនៃបដិសន្ធិ ។បេ។ ខន្ធ ២ ក្រៅនេះជាខន្ធដ៏ប្រាកដ ។ ... ជាបច្ច័យព្រោះនអនន្តរប្បច្ច័យ ។បេ។ ព្រោះនបុរេជាតប្បច្ច័យ ព្រោះនបច្ឆាជាតប្បច្ច័យ ។

[ ១២៥ ] កាមាវចរធម៌ អាស្រ័យនូវកាមាវចរធម៌ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ មានវារៈ ៣ ។ នកាមាវចរធម៌ អាស្រ័យនូវនកាមាវចរធម៌ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវនកាមាវចរក្ខន្ធ ១ ជាវិបាក នូវខន្ធ ២ ... គឺបដិសន្ធិ ។ កាមាវចរធម៌ អាស្រ័យនូវនកាមាវចរធម៌ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនកាមាវចរក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ។បេ។ មូល គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យនូវនកាមាវចរក្ខន្ធ ១ ជាវិបាក នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ ខន្ធ ៣ ដ៏សេស ជាខន្ធដ៏ប្រាកដ ។ សេចក្តីបំប្រួញ ។

[ ១២៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុង

នមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យមានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់ដ៏សេសក្តី សហជាតវារៈក្តី បណ្ឌិតគប្បីធ្វើផងចុះ ។

## បច្ចយវារៈ

[ ១២៧ ] កាមាវចរធម៌ ពឹងផ្អែកនឹងកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងកាមាវចរក្ខន្ធ ១ នឹងខន្ធ ២ ... គឺបដិសន្ធិ ពួកកាមាវចរក្ខន្ធ រាប់តាំងពីពួកមហាភូតខាងក្នុងមក សុទ្ធតែពឹងផ្អែកនឹងវត្ថុ ។ នកាមាវចរធម៌ ពឹងផ្អែកនឹងកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនកាមាវចរក្ខន្ធ ពឹងផ្អែកនឹងវត្ថុ បដិសន្ធិ ។ កាមាវចរធម៌ក្តី នកាមាវចរធម៌ក្តី ពឹងផ្អែកនឹងកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកនកាមាវចរក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត បដិសន្ធិ ។ នកាមាវចរធម៌ ពឹងផ្អែកនឹងនកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ កាមាវចរធម៌ ពឹងផ្អែកនឹងកាមាវចរធម៌ផង នឹងនកាមាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ដូចគ្នានឹងបដិច្ចវារៈដែរ ។ នកាមាវចរធម៌ ពឹងផ្អែកនឹងកាមាវចរធម៌ផង នឹងនកាមាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹង

នកាមាវចរក្ខន្ធ ១ ផង និងវត្ថុផង នឹងខន្ធ ២ ... គឺបដិសន្ធិ ។ កាមាវចរធម៌ក្តី នកាមាវចរធម៌ក្តី ពឹងផ្អែកនឹងកាមាវចរធម៌ផង នឹងនកាមាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងនកាមាវចរក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ១ ពឹងផ្អែកនឹងពួកនកាមាវចរក្ខន្ធផង នឹងពួកមហាភូតផង គឺបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ១២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៤ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១២៩ ] កាមាវចរធម៌ ពឹងផ្អែកនឹងកាមាវចរធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ពឹងផ្អែកនឹងកាមាវចរក្ខន្ធ ១ ជាអហេតុកៈ... អហេតុកប្បដិសន្ធិ ចក្ខុវិញ្ញាណ រាប់តាំងពីពួកអសញ្ញសត្វ សុទ្ធតែពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ... ពួកកាមាវចរក្ខន្ធ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។ ... ព្រោះនអារម្មណប្បច្ច័យ ។

[ ១៣០ ] កាមាវចរធម៌ ពឹងផ្អែកនឹងកាមាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ មានវារៈ ១ ដរាបដល់ពួកអសញ្ញសត្វ ។ នកាមាវចរធម៌ ពឹងផ្អែកនឹងកាមាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺនកាមាវចរាធិបតិ ពឹងផ្អែកនឹងវត្ថុ ពួកនកាមាវចរក្ខន្ធជាវិបាក ពឹងផ្អែកនឹងវត្ថុ បដិសន្ធិ ។ កាមាវចរធម៌ក្តី នកាមាវចរធម៌ក្តី ពឹងផ្អែកនឹងកាមាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺពួកនកាមាវចរក្ខន្ធ ជាវិបាក ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត គឺបដិសន្ធិ ។ នកាមាវចរធម៌ ពឹងផ្អែកនឹងនកាមាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ មានវារៈ ៣ ដូចគ្នានឹងបដិច្ចវារៈដែរ ។ កាមាវចរធម៌ ពឹងផ្អែកនឹងកាមាវចរធម៌ផង នឹងនកាមាវចរធម៌ផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ដូចគ្នានឹងបដិច្ចវារៈដែរ ។ មូល គឺនកាមាវចរាធិបតិ ពឹងផ្អែកនឹងពួកនកាមាវចរក្ខន្ធផង នឹងវត្ថុផង ខន្ធ ៣ ពឹងផ្អែកនឹងនកាមាវចរក្ខន្ធ ១ ជាវិបាកផង នឹងវត្ថុផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។ មូល គឺខន្ធ ៣ ពឹងផ្អែកនឹងកាមាវចរក្ខន្ធ ១ ជាវិបាកផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកនកាមាវចរក្ខន្ធ ជាវិបាកផង នឹងពួកមហាភូតផង គឺបដិសន្ធិ ។ ... ព្រោះនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ព្រោះនអាសេវនប្បច្ច័យ ( បានដល់វារៈ ) ដែលបណ្ឌិតគប្បីកំណត់ថា ជាវិបាក ក្នុងសុទ្ធកៈផង ក្នុងអរូបមិស្សកៈផង ( ឯវារៈ ) ក្នុងរូបមិស្សកៈមិនមានទេ ។

[ ១៣១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់វារៈ ២ ក្រៅនេះក្តី និស្សយវារៈក្តី

បណ្ឌិតគប្បីធ្វើយ៉ាងនេះផងចុះ ។

## សំសដ្ឋវារៈ

[ ១៣២ ] កាមាវចរធម៌លាយឡំនឹងកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងកាមាវចរក្ខន្ធ ១ នឹងខន្ធ ២ ... បដិសន្ធិ ។ នកាមាវចរធម៌ លាយឡំនឹងនកាមាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងនកាមាវចរក្ខន្ធ ១ នឹងខន្ធ ២ ... បដិសន្ធិ ។

[ ១៣៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៣៤ ] កាមាវចរធម៌ លាយឡំនឹងកាមាវចរធម៌ ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងកាមាវចរក្ខន្ធ ១ ជាអហេតុកៈនឹងខន្ធ ២ ... ក្នុងខណៈអហេតុកប្បដិសន្ធិ ។បេ។ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ លាយឡំនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។

[ ១៣៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

ការរាប់វារៈ ២ ក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើយ៉ាងនេះផងចុះ ។

## បញ្ហាវារៈ

[ ១៣៦ ] កាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយហេតុប្បច្ច័យ គឺពួកកាមាវចរហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺបដិសន្ធិ ។ នកាមាវចរធម៌ ជាបច្ច័យ

នៃនកាមាវចរធម៌ ដោយហេតុប្បច្ច័យ គឺពួកនកាមាវចរហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ គឺបដិសន្ធិ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយហេតុប្បច្ច័យ គឺពួកនកាមាវចរហេតុ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ គឺបដិសន្ធិ ។ មូល គឺពួកនកាមាវចរហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺបដិសន្ធិ ។

[ ១៣៧ ] កាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន នូវសីល... នូវឧបោសថកម្ម... ពិចារណានូវពួកអំពើដែលសន្សំហើយក្នុងកាលមុន ត្រេកអរ រីករាយ រាគៈប្រារព្ធនូវហេតុនោះ ។បេ។ ទោមនស្ស កើតឡើង ពួកព្រះអរិយៈ ពិចារណានូវគោត្រភូ ពិចារណានូវវោទានៈ នូវពួកកិលេសដែលលះបង់ហើយ... នូវពួកកិលេស ដែលសង្កត់សង្កិនហើយ... នូវពួកអំពើដែលខ្លួនសន្សំហើយក្នុងកាលមុន... អំពីឈាន... នូវចក្ខុ... នូវវត្ថុ... នូវពួកកាមាវចរក្ខន្ធ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ។ កាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយកាមាវចរចិត្ត ដោយចេតោបរិយញ្ញាណ ពួកកាមាវចរក្ខន្ធ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអ-

នាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃ នកាមាវចរធម៌ ដោយអារម្មណប្បច្ច័យ គឺនិព្វាន ជាបច្ច័យនៃមគ្គនិងផល ដោយអារម្មណប្បច្ច័យ បុគ្គលដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយ នកាមាវចរចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ( ជា បច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃ នេវសញ្ញានាសញ្ញាយតនៈ ពួកនកាមាវចរក្ខន្ធ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និង អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃ កាមាវចរធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលចេញអំពីឈាន ពិចារណានូវ ឈាន ត្រេកអរ រីករាយ រាគៈ កើតឡើង ទិដ្ឋិកើតឡើង ព្រោះប្រារព្ធ នូវហេតុនោះ ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណានូវមគ្គ នូវផល... ពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈនិងកិរិយា- ពិចារណា ដោយអារម្មណប្បច្ច័យ ពិចារណានូវអាកាសានញ្ចាយតនៈ ពិចារណានូវវិញ្ញាណញ្ចាយតនៈ ពិចារណានូវអាកិញ្ចញ្ញាយតនៈ ពិចារណា នូវនេវសញ្ញានាសញ្ញាយតនៈ ពិចារណានូវទិព្វចក្ខុ ពិចារណានូវទិព្វសោត- ធាតុ ពិចារណានូវឥទ្ធិវិធញ្ញាណ នូវចេតោបរិយញ្ញាណ... ។បេ។ នូវ បុព្វេនិវាសានុស្សតិញ្ញាណ... យថាកម្មុបគញ្ញាណ... ពិចារណានូវអនាគតំ- សញ្ញាណ នូវពួកនកាមាវចរក្ខន្ធជាមិនទៀង ។បេ។ ទោមនស្សកើតឡើង ។

[ ១៣៨ ] កាមាវចរធម៌ជាបច្ច័យនៃកាមាវចរធម៌ ដោយអធិបតិប្បច្ច័យ

បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺនូវទាន... នូវសីល... នូវឧបោសថកម្ម... នូវពួកអំពើដែលខ្លួនសន្សំល្អហើយក្នុងកាលមុន ធ្វើនូវអំពើនោះឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈកើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ពួកសេក្ខបុគ្គល ធ្វើនូវគោត្រភូ ឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវអំពើនោះ ឲ្យជាទីគោរព ហើយពិចារណា នូវចក្ខុ... នូវវត្ថុ... ធ្វើនូវពួកកាមាវចរក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ទិដ្ឋិកើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ។ ឯសហជាតាធិបតិ គឺកាមាវចរាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ អារម្មណាធិបតិ គឺព្រះនិព្វាន ជាបច្ច័យនៃមគ្គនិងផល ដោយអធិបតិប្បច្ច័យ ។ ឯសហជាធិបតិ គឺនកាមាវចរាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលចេញអំពីឈាន ធ្វើនូវឈានឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះនូវអំពើនោះ ឲ្យជាទីគោរព ទិដ្ឋិ... ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណានូវផល... ធ្វើនូវនិព្វានឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃ

គោត្រភូនិងវោទានៈ ដោយអធិបតិប្បច្ច័យ ធ្វើនូវអាកាសានញ្ចាយតនៈឲ្យជាទីគោរពហើយពិចារណា វិញ្ញាណញ្ចាយតនៈ... នូវអាកិញ្ចញ្ញាយតនៈ នេវសញ្ញានាសញ្ញាយតនៈ ទិព្វចក្ខុ ទិព្វសោតធាតុ និងឥទ្ធិវិធញ្ញាណ... ។បេ។ ធ្វើនូវអនាគតំសញ្ញាណឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវពួកនកាមាវចរក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈកើតឡើង ព្រោះធ្វើនូវអំពើនោះ ឲ្យជាទីគោរព ទិដ្ឋិ... ។ ឯសហជាតាធិបតិ គឺនកាមាវចរាធិបតិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ផង នៃនកាមាវចរធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺនកាមាវចរាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ១៣៩ ] កាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយអនន្តរប្បច្ច័យ គឺពួកកាមាវចរក្ខន្ធមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ អាវជ្ជនៈ ជាបច្ច័យនៃពួកកាមាវចរក្ខន្ធ ដោយអនន្តរប្បច្ច័យ ។ កាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយអនន្តរប្បច្ច័យ កាមាវចរចុតិចិត្ត ( ជាបច្ច័យ ) នៃនកាមាវចរឧបបត្តិចិត្ត អាវជ្ជនៈ ជាបច្ច័យនៃពួកនកាមាវចរក្ខន្ធ ដោយអនន្តរប្បច្ច័យ ពួកកាមាវចរក្ខន្ធ ជាបច្ច័យនៃនកាមាវចរវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ បរិកម្មនៃបឋមជ្ឈាន ជាបច្ច័យនៃបឋមជ្ឈាន ដោយអនន្តរប្បច្ច័យ ។បេ។ នៃចតុត្ថជ្ឈាន... ។បេ។ បរិកម្មនៃ

នេវសញ្ញានាសញ្ញាយតនៈ... ។បេ។ នៃទិព្វចក្ខុ ទិព្វសោតធាតុ ឥទ្ធិវិ-
ធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងយថាកម្មុប-
គញ្ញាណ... បរិកម្មនៃអនាគតំសញ្ញាណជាបច្ច័យនៃអនាគតំសញ្ញាណ ដោយ
អនន្តរបច្ច័យ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ( ជាបច្ច័យ )
នៃមគ្គ ទអនុលោម ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរបច្ច័យ ។
នកាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយអនន្តរបច្ច័យ គឺពួក
នកាមាវចរក្ខន្ធមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដោយអនន្តរបច្ច័យ មគ្គ
( ជាបច្ច័យ ) នៃផល ផល ( ជាបច្ច័យ ) នៃផល នេវសញ្ញានា-
សញ្ញាយតនៈរបស់បុគ្គលកាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ
ដោយអនន្តរបច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយ
អនន្តរបច្ច័យ គឺនកាមាវចរចុតិចិត្ត ( ជាបច្ច័យ ) នៃកាមាវចរឧបបត្តិចិត្ត
នកាមាវចរភវង្គ ( ជាបច្ច័យ ) នៃអាវជ្ជនៈ ពួកនកាមាវចរក្ខន្ធ ជាបច្ច័យ
នៃកាមាវចរវុដ្ឋានៈ ដោយអនន្តរបច្ច័យ ។ ... ជាបច្ច័យដោយសមនន្ត-
របច្ច័យ ជាបច្ច័យដោយសហជាតបច្ច័យ មានវារៈ ៧ ជាបច្ច័យដោយ
អញ្ញមញ្ញបច្ច័យ មានវារៈ ៦ ជាបច្ច័យដោយនិស្សយបច្ច័យ មានវារៈ
៧ ។

[ ១៤០ ] កាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយឧបនិស្ស-
យបច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូប-
និស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ជាកាមាវចរ:

ហើយឲ្យនូវទាន នូវសីល... នូវឧបោសថកម្ម... នូវវិបស្សនា... ។បេ។ ជំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល ជាកាមាវចរៈ ។បេ។ នូវបញ្ញា... នូវរាគៈ... សេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ រដូវនិងភោជន... អាស្រ័យនូវសេនាសនៈ ហើយឲ្យនូវទាន នូវវិបស្សនា... ។បេ។ សម្លាប់នូវសត្វ ។បេ។ បំបែកនូវសង្ឃ សទ្ធាជាកាមាវចរៈ ។បេ។ សេនាសនៈ ជាបច្ច័យនៃសទ្ធា ជាកាមាវចរៈ ។បេ។ ជាបច្ច័យនៃសេចក្តីប្រាថ្នា កាយិកសុខនិងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ។ កាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ជាកាមាវចរៈ ញ៉ាំងនកាមាវចរជ្ឈាន ឲ្យកើតឡើង ញ៉ាំងមគ្គ... ញ៉ាំងអភិញ្ញា... ញ៉ាំងសមាបត្តិ ឲ្យកើតឡើង នូវសីល ជាកាមាវចរៈ... ។បេ។ អាស្រ័យនូវសេនាសនៈ ញ៉ាំងនកាមាវចរជ្ឈាន ឲ្យកើតឡើង ញ៉ាំងមគ្គ... ញ៉ាំងអភិញ្ញា... ញ៉ាំអសមាបត្តិឲ្យកើតឡើង សទ្ធាជាកាមាវចរៈ... ។បេ។ សេនាសនៈ ជាបច្ច័យនៃនកាមាវចរសទ្ធា ។បេ។ ជាបច្ច័យនៃបញ្ញា មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ បរិកម្មនៃបឋមជ្ឈាន ជាបច្ច័យនៃបឋមជ្ឈាន ។បេ។ នៃចតុត្ថជ្ឈាន... នៃអាកាសានញ្ចាយតនៈ... នៃបឋមមគ្គ... បរិកម្មនៃចតុត្ថមគ្គ... ។បេ។ នកាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យ

នូវសទ្ធា មិនមែនជាកាមាវចរៈ ញុំាងឈានមិនមែនជាកាមាវចរៈ ឲ្យកើតឡើង ញុំាងមគ្គ... ញុំាងអភិញ្ញា... ញុំាងសមាបត្តិ ឲ្យកើតឡើង នូវសីលមិនមែនជាកាមាវចរៈ... ។បេ។ អាស្រ័យនូវបញ្ញា ញុំាងឈានមិនមែនជាកាមាវចរៈ ឲ្យកើតឡើង ញុំាងមគ្គ... ញុំាងអភិញ្ញា... ញុំាងសមាបត្តិ ឲ្យកើតឡើង សទ្ធា មិនមែនជាកាមាវចរៈ... ។បេ។ បញ្ញាជាបច្ច័យនៃសទ្ធាមិនមែនជាកាមាវចរៈ មគ្គនិងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ បឋមជ្ឈាន ជាបច្ច័យនៃទុតិយជ្ឈាន ដោយឧបនិស្សយប្បច្ច័យ ។បេ។ តតិយជ្ឈាន... ចតុត្ថជ្ឈាន... អាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយឧបនិស្សយប្បច្ច័យ បឋមមគ្គ ( ជាបច្ច័យ ) នៃទុតិយមគ្គ ទុតិយមគ្គ ( ជាបច្ច័យ ) នៃតតិយមគ្គ តតិយមគ្គ ជាបច្ច័យនៃចតុត្ថមគ្គ ដោយឧបនិស្សយប្បច្ច័យ មគ្គជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។បេ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា មិនមែនជាកាមាវចរៈ ហើយឲ្យនូវទាន នូវសីល... នូវឧបោសថកម្ម... ញុំាងវិបស្សនា ឲ្យកើតឡើង ដំឡើងនូវមានះ ប្រកាន់នូវទិដ្ឋិ នូវសីល មិនមែនកាមាវចរៈ... ។បេ។ អាស្រ័យនូវបញ្ញា ហើយឲ្យនូវទាន នូវសីល... នូវឧបោសថកម្ម... ញុំាងវិបស្សនា ឲ្យកើតឡើង ដំឡើងនូវមានះ ប្រកាន់នូវ

ទិដ្ឋិ សទ្ធាមិនមែនជាកាមាវចរៈ... ។បេ។ បញ្ញា ជាបច្ច័យនៃសទ្ធា ជាកាមាវចរៈនៃបញ្ញា រាគៈ សេចក្តីប្រាថ្នា កាយិកសុខនិងកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ពួកព្រះអរិយៈអាស្រ័យនូវមគ្គ ពិចារណាឃើញនូវពួកសង្ខារ ថាមិនទៀង មគ្គ ជាបច្ច័យនៃអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា និងឋានាឋានកោសល្លៈ របស់ពួកព្រះអរិយៈ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យនៃផលសមាបត្តិនិងកាយិកសុខ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៤១ ] កាមាវចរធម៌ជាបច្ច័យនៃកាមាវចរធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺនូវចក្ខុ... នូវវត្ថុ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ... វត្ថុជាបច្ច័យនៃពួកកាមាវចរក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ កាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាតនិងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញនូវរូប ដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកនកាមាវចរក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ ... ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ មានវារៈ ២ ជាបច្ច័យ ដោយអាសេវនប្បច្ច័យ មានវារៈ ៣ ។

[ ១៤២ ] កាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយកម្មប្បច្ច័យ

បានដល់ សហជាត និងនានាខណិកៈ ។ សេចក្តីបំប្រួញ ។ នកាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និង នានាខណិកៈ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សេចក្តីបំប្រួញ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ផង នៃនកាមាវចរធម៌ផង ដោយកម្មប្បច្ច័យ បាន ដល់ សហជាត និងនានាខណិកៈ ។ សេចក្តីបំប្រួញ ។ ... ជាបច្ច័យដោយ វិបាកប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយអាហារប្បច្ច័យ មានវារៈ ៤ ជា បច្ច័យដោយ ឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយឈានប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយមគ្គប្បច្ច័យ មានវារៈ ៤ ជាបច្ច័យដោយសម្ប- យុត្តប្បច្ច័យ មានវារៈ ២ ។

[ ១៤៣ ] កាមាវចរធម៌ជាបច្ច័យនៃកាមាវចរធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សេចក្តីបំប្រួញ ។ កាមាវ- ចរធម៌ជាបច្ច័យនៃនកាមាវចរធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់សហជាត និងបុរេជាត ។ សហជាត គឺសេចក្តីបំប្រួញ ។ វត្ថុជាបច្ច័យនៃពួកនកា- មាវចរក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។ ឯបុរេជាត គឺវត្ថុ ជាបច្ច័យនៃពួកនកាមាវចរក្ខន្ធ ដោយវិប្បយុត្តប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និង បច្ឆាជាត ។ សហជាត គឺពួកនកាមាវចរក្ខន្ធ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ គឺបដិសន្ធិ ។ ឯបច្ឆាជាត គឺពួកនកាមាវចរក្ខន្ធ ជា

បច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ១៨៤ ] កាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សេចក្ដីបំប្រួញ ។ កាមាវចរធម៌ជាបច្ច័យនៃនកាមាវចរធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។ សហជាត គឺវត្ថុជាបច្ច័យនៃពួកនកាមាវចរក្ខន្ធ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។ ឯបុរេជាត គឺដោយទិព្វចក្ខុ... ដូចគ្នានឹងបុរេជាតប្បច្ច័យដែរ ។ នកាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយអត្ថិប្បច្ច័យ បានដល់សហជាត ។ សេចក្ដីបំប្រួញ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត ដូចគ្នានឹងវិប្បយុត្តប្បច្ច័យដែរ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ផង នៃនកាមាវចរធម៌ផង ដោយអត្ថិប្បច្ច័យ ដូចគ្នានឹងបដិច្ចវារៈដែរ ។ កាមាវចរធម៌ក្ដី នកាមាវចរធម៌ក្ដី ជាបច្ច័យនៃកាមាវចរធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាតគឺពួកនកាមាវចរក្ខន្ធផង ពួកមហាភូតផង ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ គឺបដិសន្ធិ ។ បច្ឆាជាត គឺពួកនកាមាវចរក្ខន្ធផង កពឡិង្ការាហារផង ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺពួកនកាមាវចរក្ខន្ធផង រូបជីវិតិន្ទ្រិយផង ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ កាមាវចរធម៌ក្ដី នកាមាវចរធម៌ក្ដី ជាបច្ច័យនៃនកាមាវចរធម៌ ដោយអត្ថិប្បច្ច័យ បានដល់ សហជាតនិងបុរេជាត ។

សហជាត គឺនកាមាវចរក្ខន្ធ ១ ផង វត្ថុផង ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... បដិសន្ធិ ។ ... ជាបច្ច័យដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ១៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១៨៦ ] កាមាវចរធម៌ជាបច្ច័យនៃកាមាវចរធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

កាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃនកាមាវចរធម៌ ដោយអា-រម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្ស-យប្បច្ច័យ ។ នកាមាវចរធម៌ជាបច្ច័យនៃកាមាវចរធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ នកាមាវចរធម៌ ជាបច្ច័យនៃកាមាវចរធម៌ផង នៃនកាមាវចរធម៌ផង ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។ កាមាវចរធម៌ក្តី នកាមាវចរធម៌ក្តី ជាបច្ច័យនៃកាមាវចរធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។ កាមាវចរ-ធម៌ក្តី នកាមាវចរធម៌ក្តី ជាបច្ច័យនៃនកាមាវចរធម៌ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ១៤៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ។បេ។ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនវិប្បយុត្តប្បច្ច័យ

មានវារៈ ៥ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ១៤៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ។

[ ១៤៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ។ អនុលោមមាតិកា បណ្ឌិតគប្បីធ្វើ ។ ... ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

**ចប់ កាមាវចរទុកៈ ។**

# រូបាវចរទុកៈ

## បដិច្ចវារៈ

[ ១៥០ ] រូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវរូបាវចរខន្ធ ១ នូវខន្ធ ២ ... គឺបដិសន្ធិ ។ នរូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួករូបាវចរខន្ធ គឺបដិសន្ធិ ។

រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវរូបាវចរក្ខន្ធ ១ នូវខន្ធ ២ ... គឺបដិសន្ធិ ។ នរូបាវចរធម៌ អាស្រ័យនូវនរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនរូបាវចរក្ខន្ធ ១ នូវខន្ធ ២ ... គឺបដិសន្ធិ ។ រូបាវចរធម៌ អាស្រ័យនូវនរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួករូបាវចរក្ខន្ធ អាស្រ័យនូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី អាស្រ័យនូវនរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួករូបាវចរក្ខន្ធ អាស្រ័យនូវវត្ថុ កដត្តារូប អាស្រ័យនូវពួកមហាភូត ក្នុងខណៈនៃបដិសន្ធិ ។ រូបាវចរធម៌អាស្រ័យនូវរូបាវចរធម៌ផង នូវនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវរូបាវចរក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ នរូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ផង នូវនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួករូបាវចរក្ខន្ធផង នូវពួកមហាភូតផង កដត្តារូប អាស្រ័យនូវពួករូបាវចរក្ខន្ធផង នូវពួកមហាភូតផង ក្នុងខណៈនៃបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី អាស្រ័យនូវរូបាវចរធម៌ផង នូវនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវរូបាវចរក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវពួករូបាវចរក្ខន្ធផង នូវពួកមហាភូតផង ។

សេចក្ដីបំប្រួញ ។

[ ១៥១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៥២ ] នរូបាវចរធម៌ អាស្រ័យនូវនរូបាវចរធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនរូបាវចរក្ខន្ធ ១ ជាអហេតុកៈ នូវខន្ធ ២ ... វត្ថុ អាស្រ័យនូវពួកខន្ធ ពួកខន្ធអាស្រ័យនូវវត្ថុ នូវមហាភូត ១ ដរាបដល់ពួកអសញ្ញសត្វ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ ... ព្រោះនអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ១៥៣ ] រូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះ

នអធិបតិប្បច្ច័យ គឺរូបាវចរាធិបតិ អាស្រ័យនូវពួករូបាវចរក្ខន្ធ ៣ អាស្រ័យនូវរូបាវចរក្ខន្ធ ១ ជាវិបាក នូវខន្ធ ២ ... គឺបដិសន្ធិ ។ នរូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួករូបាវចរក្ខន្ធ ជាវិបាក គឺបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវរូបាវចរក្ខន្ធ ១ ជាវិបាក នូវខន្ធ ២ ... គឺបដិសន្ធិ ។ នរូបាវចរធម៌ អាស្រ័យនូវនរូបាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យនូវនរូបាវចរក្ខន្ធ ១ ។ នកាមាវចរៈ ៣ ប្រហែលគ្នានឹងបដិច្ចវារៈ មិនមានផ្សេងគ្នាទេ ពួកមហាភូតទាំងអស់ បណ្ឌិតគប្បីធ្វើក្នុងបទនេះ ។ រូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ផង នូវនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវរូបាវចរក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។ នរូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ផង នូវនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួករូបាវចរក្ខន្ធ ជាវិបាកផង នូវពួកមហាភូតផង គឺបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី អាស្រ័យនូវរូបាវចរធម៌ផង នូវនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវរូបាវចរក្ខន្ធ ១ ផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប អាស្រ័យនូវពួករូបាវចរក្ខន្ធផង នូវពួកមហាភូតផង ។ ...

ព្រោះនអនន្តរប្បច្ច័យ ព្រោះនឧបនិស្សយប្បច្ច័យ ។

[ ១៥៤ ] រូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវរូបាវចរក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ នរូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួករូបាវចរក្ខន្ធ គឺបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ ផង កដត្តារូបផង អាស្រ័យនូវរូបាវចរក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ នរូបាវចរធម៌ អាស្រ័យនូវនរូបាវចរធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវនរូបាវចរក្ខន្ធ ១ ក្នុងអរូប នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូប អាស្រ័យនូវពួកនរូបាវចរក្ខន្ធ គឺបដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ។ បញ្ហាទាំង ៥ ក្រៅនេះ បណ្ឌិតគប្បីធ្វើជាអនុលោម ។ ... ព្រោះនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ។

[ ១៥៥ ] រូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវរូបាវចរក្ខន្ធ ១ ជាវិបាក គឺបដិសន្ធិ ។ នរូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យនូវពួករូបាវចរក្ខន្ធ គឺបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី អាស្រ័យនូវរូបាវចរធម៌ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ

នូវរូបាវចរក្ខន្ធ ១ ជាវិបាក នូវខន្ធ ២ ... គឺបដិសន្ធិ ។ នរូបាវចរធម៌ អាស្រ័យនូវនរូបាវចរធម៌ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ មានវារៈ ៣ ។ រូបាវចរធម៌ អាស្រ័យនូវរូបាវចរធម៌ផង នូវនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ ។ សេចក្ដីបំប្រួញ ។ មូល គឺបញ្ហាក្រៅនេះ បណ្ឌិតគប្បីធ្វើ ។ ... ព្រោះនកម្មប្បច្ច័យ មានវារៈ ២ ។ សេចក្ដីបំប្រួញ ។ ... ព្រោះនសម្បយុត្តប្បច្ច័យ ។

[ ១៥៦ ] នរូបាវចរធម៌ អាស្រ័យនូវនរូបាវចរធម៌ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យនូវនរូបាវចរក្ខន្ធ ១ ក្នុងអរូប នូវខន្ធ ២ ... ខាងក្រៅ... អាហារសមុដ្ឋាន... ឧតុសមុដ្ឋាន... ពួកអសញ្ញសត្វ ។ សេចក្ដីបំប្រួញ ។

[ ១៥៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគ-

តប្បច្ច័យ មានវារៈ ៣ ។

ការរាប់វារៈពីរយ៉ាងក្រៅនេះក្តី សហជាតវារៈក្តី បណ្ឌិតគប្បីធ្វើផងចុះ ។

## បច្ចយវារៈ

[ ១៥៨ ] រូបាវចរធម៌ ពឹងផ្អែកនឹងរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ នរូបាវចរធម៌ ពឹងផ្អែកនឹងនរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនរូបាវចរក្ខន្ធ ១ ដរាបដល់ពួកអជ្ឈត្តិកមហាភូត ពួកនរូបាវចរក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ។ រូបាវចរធម៌ ពឹងផ្អែកនឹងនរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួករូបាវចរក្ខន្ធ ពឹងផ្អែកនឹងវត្ថុ គឺបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី ពឹងផ្អែកនឹងនរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺរូបាវចរក្ខន្ធ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត គឺបដិសន្ធិ ។ រូបាវចរធម៌ ពឹងផ្អែកនឹងរូបាវចរធម៌ផង នឹងនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងរូបាវចរក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... គឺបដិសន្ធិ ។ នរូបាវចរធម៌ ពឹងផ្អែកនឹងរូបាវចរធម៌ផង នឹងនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួករូបាវចរក្ខន្ធផង នឹងពួកមហាភូតផង គឺបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី ពឹងផ្អែកនឹងរូបាវចរធម៌ផង នរូបាវចរធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ

៣ ពឹងផ្អែកនឹង រូបាវចរក្ខន្ធ ១ ផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្ត-សមុដ្ឋានរូប ពឹងផ្អែកនឹងពួករូបាវចរក្ខន្ធផង នឹងពួកមហាភូតផង គឺបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ១៥៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៤ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៦០ ] នរូបាវចរធម៌ពឹងផ្អែកនឹងនរូបាវចរធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងនរូបាវចរក្ខន្ធ ១ ជាអហេតុកៈ នឹងខន្ធ ២ ជាអហេតុកប្បដិសន្ធិ ដរាបដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ... ពួកនរូបាវចរក្ខន្ធជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង នឹងវត្ថុផង ។

[ ១៦១ ] រូបាវចរធម៌ ពឹងផ្អែកនឹងរូបាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ មានវារៈ ៣ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។ នរូបាវចរ-

ធម៌ ពឹងផ្អែកនឹងនរូបាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ប្រហែល គ្មានទីឯបដិច្ចវារៈដែរ ។ រូបាវចរធម៌ពឹងផ្អែកនឹងនរូបាវចរធម៌ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺរូបាវចរាធិបតិ ពឹងផ្អែកនឹងវត្ថុ ពួករូបាវចរក្ខន្ធជាវិបាក ពឹងផ្អែកនឹងវត្ថុ គឺបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី ពឹងផ្អែកនឹងនរូបាវចរធម៌ ទើបកើតឡើងព្រោះនអធិបតិប្បច្ច័យ គឺពួករូបាវចរក្ខន្ធជាវិបាក ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួកមហាភូត គឺបដិសន្ធិ ។ រូបាវចរធម៌ ពឹងផ្អែកនឹងរូបាវចរធម៌ផង នឹងនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺរូបាវចរាធិបតិ ពឹងផ្អែកនឹងពួករូបាវចរក្ខន្ធផង នឹងវត្ថុផង ខន្ធ ៣ ពឹងផ្អែកនឹងរូបាវចរក្ខន្ធ ១ ជាវិបាកផង នឹងវត្ថុផង នឹងខន្ធ ២ ... ខន្ធ ៣ ពឹងផ្អែកនឹងរូបាវចរក្ខន្ធ ១ ផង នឹងវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នឹងខន្ធ ២ ... ។ នរូបាវចរធម៌ ពឹងផ្អែកនឹងរូបាវចរធម៌ផង នឹងនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួករូបាវចរក្ខន្ធជាវិបាកផង នឹងពួកមហាភូតផង គឺបដិសន្ធិ ។ រូបាវចរធម៌ក្តី នរូបាវចរធម៌ក្តី ពឹងផ្អែកនូវរូបាវចរធម៌ផង នឹងនរូបាវចរធម៌ផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងរូបាវចរក្ខន្ធ ១ ជាវិបាកផង នឹងវត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងពួករូបាវចរក្ខន្ធ ជាវិបាកផង នឹងពួកមហាភូតផង គឺបដិសន្ធិ ។ សេចក្តីបំប្រួញ ។

[ ១៦២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ បណ្ឌិតគប្បីកំណត់ក្នុងអរូប ដែលសុទ្ធផង ដែលលាយឡំផង ជាវិបាក ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ការរាប់វារៈ ២ ក្រៅនេះក្តី និស្សយវារៈក្តី បណ្ឌិតគប្បីធ្វើ ។

## សំសដ្ឋវារៈ

[ ១៦៣ ] រូបាវចរធម៌ លាយឡំនឹងរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងរូបាវចរក្ខន្ធ ១ នឹងខន្ធ ២ ... គឺបដិសន្ធិ ។ នរូបាវចរធម៌ លាយឡំនឹងនរូបាវចរធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ លាយឡំនឹងនរូបាវចរក្ខន្ធ ១ នឹងខន្ធ ២ ... គឺបដិសន្ធិ។

[ ១៦៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៦៥ ] នរូបាវចរធម៌លាយឡំនឹងនរូបាវចរធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ១៦៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។

ការរាប់វារៈ ២ ក្រៅនេះក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីធ្វើ ។

## បញ្ហាវារៈ

[ ១៦៧ ] រូបាវចរធម៌ ជាបច្ច័យនៃរូបាវចរធម៌ ដោយហេតុប្បច្ច័យ គឺពួករូបាវចរហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ គឺបដិសន្ធិ ។ មូល គឺពួករូបាវចរហេតុ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ គឺបដិសន្ធិ ។ មូល គឺពួករូបាវចរហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺបដិសន្ធិ ។ នរូបាវចរធម៌ ជាបច្ច័យនៃនរូបាវចរធម៌ ដោយហេតុប្បច្ច័យ គឺពួករូបាវចរហេតុ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ គឺបដិសន្ធិ ។

[ ១៦៨ ] រូបាវចរធម៌ ជាបច្ច័យនៃរូបាវចរធម៌ ដោយអារម្មណប្បច្ច័យ

គឺបុគ្គលដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយរូបាវចរចិត្ត ដោយចេតោ-បរិយញ្ញាណ ពួករូបាវចរក្ខន្ធ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ រូបាវចរធម៌ ជាបច្ច័យនៃនរូបាវចរធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលពិចារណានូវបឋមជ្ឈាន ពិចារណានូវចតុត្ថជ្ឈាន ពិចារណានូវទិព្វចក្ខុ នូវទិព្វសោតធាតុ... នូវឥទ្ធិវិធញ្ញាណ ចេតោបរិ-យញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងយថាកម្មុបគញ្ញាណ... ពិចារណានូវអនាគតំសញ្ញាណ នូវពួករូបាវចរក្ខន្ធ ថាមិនទៀង ។បេ។ ទោមនស្សកើតឡើង ។ នរូបាវចរធម៌ ជាបច្ច័យនៃនរូបាវចរធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យនូវទាន នូវសីល... នូវឧបោសថកម្ម... ពិចារណានូវពួកកុសល-កម្ម ដែលបានសន្សំហើយ ក្នុងកាលមុន ត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវហេតុនោះ ។បេ។ ទោមនស្ស កើតឡើង ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណានូវមគ្គ ពិចារណានូវផល ពិចារណានូវព្រះនិព្វាន ឯព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ មគ្គ ផលនិងកិរិយារំពឹង ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណានូវពួកកិលេស ដែលលះបង់ហើយ... នូវពួកកិលេស ដែលសង្កត់សង្កិនហើយ... ក្នុងកាលមុន ។បេ។ នូវចក្ខុ... នូវវត្ថុ... នូវពួកនរូបាវចរក្ខន្ធ ថាមិនទៀង ។បេ។ ទោមនស្ស កើតឡើង អា-កាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញា-យតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ ( ជា

បច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ... ។ នរូបាវចរធម៌ ជាបច្ច័យនៃរូបាវចរធម៌ ដោយអារម្មណប្បច្ច័យ គឺបុគ្គលឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្តរបស់បុគ្គល អ្នកប្រកបដោយនរូបាវចរចិត្ត ដោយចេតោបរិយញ្ញាណ ពួកនរូបាវចរក្ខន្ធ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ១៦៩ ] រូបាវចរធម៌ ជាបច្ច័យនៃរូបាវចរធម៌ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺរូបាវចរាធិបតិ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។ រូបាវចរធម៌ ជាបច្ច័យនៃនរូបាវចរធម៌ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវបឋមជ្ឈានឲ្យជាទីគោរពហើយពិចារណា ត្រេកអរ រីករាយ រាគៈ កើតឡើងព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព ទិដ្ឋិ... ។បេ។ នូវចតុត្ថជ្ឈាន... នូវទិព្វចក្ខុ នូវទិព្វសោតធាតុ ឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងយថាកម្មុបគញ្ញាណ... ធ្វើនូវអនាគតំសញ្ញាណ ឲ្យជាទីគោរព ហើយពិចារណា ត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើនូវហេតុនោះឲ្យជាទីគោរព ទិដ្ឋិ... ធ្វើនូវពួករូបាវចរក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើនូវហេតុនោះ ឲ្យជាទីគោរព ទិដ្ឋិ... ។ ឯសហជាតាធិបតិ គឺរូបាវចរាធិបតិ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអធិបតិប្បច្ច័យ ។ រូបាវចរធម៌ ជាបច្ច័យនៃ

